UNESCO

អង្គការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌ នៃសហប្រជាជាតិ

សារមន្ទីរអន្តរជាតិ

២១៣
២១៤

អង្គរ
សារមន្ទីរមានជីវិត

រំលែកដោយស៊ីណោភា ទៅ ឃុនសំរិនអំពីការណាខ្មែរ
ដើម្បីទុកដាក់ក្នុង eLibrary of Cambodia
កក្កដា 2016

សារមន្ទីរអន្តរជាតិ

២១៣_២១៤

ខែឧសភា ឆ្នាំ ២០០២

អង្គរ សារមន្ទីរមានជីវិត

៣/វិចារណកថា

ម៉ូនារ ប៊ូសេណាគី / ៣

៥/អារម្ភកថា

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ / ៥

សេចក្តីផ្តើមរបស់អគ្គនាយកអង្គការយូណេស្កូ កូអ៊ិឈីរ៉ុ ម៉ាត់ស៊ុអ៊ុរ៉ា /៧

៩/បុព្វកថា

សម្តេច ហ៊ុន សែន / ៩

ឯកឧត្តម សុខ អាន / ១១

១៣/ប្រវត្តិ និងសង្គម

ប្រវត្តិនៃតំបន់អង្គរ

ប៊្រុយណូ ដាហ្សង់/១៣

២៥ ការអភិវឌ្ឍន៍ធនធានមនុស្ស និងវប្បធម៌ :
ករណីសិក្សានៃប្រាសាទទាំងឡាយនៅអង្គរ

យ៉ូស៊ីអាគិ អ៊ិស៊ីហ្សាវ៉ា /២៥

សិល្បះ និងសិប្បកម្មបុរាណសម្រាប់អនាគតកាល

គីរី ស្គុលហ្ស៍/៣១

ការអភិវឌ្ឍន៍វប្បធម៌សង្គមតាមរយៈទំនាក់ទំនងអន្តរជំនាន់

ណូបូ អិនដូ/៣៩

អង្គការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌ នៃសហប្រជាជាតិ

ក្រមុខ

ព្រះវិស្ណុ ប្រាសាទអង្គរវត្ត ខ្លោងទ្វារចូលខាងលិច ឬគោពុរៈខាងលិច ទោះបីជាត្រូវបានគេចាត់ទុកថា ជាអាទិទេពក្នុងសាសនាព្រាហ្មណ៍ក៏ដោយ ក៏វត្តមានរបស់ព្រះវិស្ណុនៅមានចំនួនតិចជាងព្រះសិវៈដែរនៅក្នុងប្រទេសកម្ពុជា ។ ប្រាសាទទាំងឡាយដែលគេកសាងឡើង ដើម្បីឧទ្ទិសចំពោះអាទិទេពផ្សេងៗក្នុងសាសនាព្រាហ្មណ៍ ជាសាសនាដែលមានអ្នកគោរពច្រើនជាងគេរហូតដល់សតវត្សទី១២ និងឧទ្ទិសចំពោះព្រះពុទ្ធសាសនាកើតមានព្រមគ្នា នៅប្រាសាទអង្គរ © UNESCO/Georges Malempré) ។

ចាងហ្វាង
ម៉ូនារ ប៊ូសេណាគី
និពន្ធនាយក
អ៊ីសាបិល វិនសុន
ជំនួយការនិពន្ធ
គ្រិសស៊ីន វិលគីនសុន
គណៈទីប្រឹក្សា
អាម៉ារេសា ហ្កាតា **ប្រទេសអូស្ត្រាលី**
ហ្កាអែល ជី ហ៊ុលឆីន **ប្រទេសអ៊ីស្រ្កែម**
យ៉ានី ហ៊ើរម៉ាន **ប្រទេសម៉ិចស៊ិកូ**
ណាន់ស៊ី ហាត់សុន **ប្រទេសកាណាដា**
ជីន ព្យែរ ម៉ូហង់ **ប្រទេសបារាំង**
ស្តិលីអូ ប៉ាប៉ាដូពូឡូ **ប្រទេសក្រិច**
ម៉ានុស ប្រ៊ិងខ័រម៉ែន **អគ្គលេខាធិការ** ICOM, *ex officio*
មីកាអែល ប៉ិតហ្សិត ប្រធាន ICOMOS, *ex officio*
តូមិស្លាយ សូឡា **សាធារណរដ្ឋក្រូអាត**
រចនា និងរូបភាព
ផីរុស ឱសាញ (Taurus Design, 93800 Epinay)

រក្សាសិទ្ធិដោយយូណេស្កូឆ្នាំ២០០២
បោះពុម្ពផ្សាយសម្រាប់អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ ដោយក្រុមហ៊ុនបោះពុម្ពផ្សាយ Blackwell ។

អ្នកនិពន្ធមានភារៈកិច្ចទទួលខុសត្រូវក្នុងការជ្រើសរើស និងបង្ហាញពីការពិពណ៌នា និងគំនិតទាំងឡាយដែលមានក្នុងអត្ថបទនេះ មិនមែនធ្វើឡើងដោយអង្គការ UNESCO ឡើយ ដែលស្តីពីឋានៈ ច្បាប់របស់ប្រទេសមួយ, ទឹកដី, ទីក្រុង តំបន់ ឬអាជ្ញាធរ មូលដ្ឋាន ឬក៏ភាពគ្មានព្រំដែនរបស់វាឡើយ ។

អត្រាជាវសម្រាប់ឆ្នាំ២០០២

អឺរ៉ុប	ROW	អាមេរិក
ស្ថាប័ន ៩៣.០០ផោន	៩៣.០០ផោន	១៤៦.០០ដុល្លា
ឯកជន ៣៧.០០ផោន	៣៧.០០ផោន	៥៣.០០ដុល្លា
ស្ថាប័នក្នុងប្រទេសកំពុងអភិវឌ្ឍ		៤០.០០ផោន
ឯកជនក្នុងប្រទេសកំពុងអភិវឌ្ឍ		១៩.០០ផោន

ពត៌មានសម្រាប់អ្នកជាវ

បញ្ជាទិញថ្មី និងលិខិតស្នើសុំគំរូត្រូវផ្ញើជូនអ្នកចាត់ចែងខាងទីផ្សារ នៃកាសែត The Journals តាមអាស័យដ្ឋានរបស់ក្រុមហ៊ុនបោះពុម្ពផ្សាយខាងលើ ឬតាមអ៊ីមែល : jnlsamples@blackwellpublishers.co.uk បញ្ជាទិញថ្មី និងលិខិតស្នើសុំគំរូត្រូវផ្ញើជូនអ្នកចាត់ចែងខាងទីផ្សារ នៃកាសែត The Journals តាមអាស័យដ្ឋានរបស់ក្រុមហ៊ុនបោះពុម្ពផ្សាយ ខាងលើ ឬតាមអ៊ីមែល : jnlsamples@blackwellpublishers.co.uk ដោយដកស្រង់ឈ្មោះរបស់ The Journals ។ ការបន្តការជាវ ការទាមទារ និងការឆ្លើយឆ្លងគ្នាផ្សេងៗ ពាក់ព័ន្ធនឹងការជាវត្រូវផ្ញើទៅអាស័យដ្ឋានរបស់ Blackwell Publishers Journals តាមប្រអប់សំបុត្រ P.O Box 805, 108 Cowley Road, Oxford 0x4 1FH, UK (ទូរស័ព្ទលេខ : ៤៤០) ១៨៦៥ ២៤៤០៨៣ (ទូរសារ : ៤៤០) ១៨៦៥ ៣៨១ ៣៨១ ឬអ៊ីមែល : jnlinfo@blackwellpublishers.co.uk) មូលប្បទានប័ត្រទាំងអស់ត្រូវបង់ទៅក្រុមហ៊ុនបោះពុម្ពផ្សាយ Blackwell Publishers Ltd ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

សារមន្ទីរមួយនៃអារ្យធម៌អង្គរ ៖ ក្តីសង្ឃឹម និងសំណើ

ឯកឧត្តម សឺន ស៊ូប៊ែរ្ត៍/៤៥

ពិធីបុណ្យក្នុងរឿងរាមកេរ្តិ៍ ៖ មរតកអង្គរដែលគ្មានរូបរាង

សម្តេចរាជបុត្រី ព្រះរៀមនរោត្តម បុប្ផាទេវី/៥១

ការបកវណ្ណវង់ ៖ ជំងឺខូចទ្រង់ទ្រាយនៃចម្លាក់ប្រាសាទអង្គរវត្ត

ហានស៍ លីសឺន/៥៥

ការរក្សាការពារតួប៉មប្រាសាទបាយ័ន និងប្រាសាទសួព្រ័ត្រ

តាកេស៊ិ ណាកាហ្គាវ៉ា/៦៣

៦៩/គោលនយោបាយសម្រាប់បេតិកភណ្ឌ និងទស្សនៈអន្តរជាតិ

វិធានការណ៍ពិសេសៗសំរាប់តំបន់មួយដែលមានតម្លៃដ៏វិសេសវិសាល

អាហ្សេឌីន បែសឆាអ៊ូច/៦៩

គ្រប់គ្រងរមណីយដ្ឋានអង្គរដែលជានិមិត្តរូបជាតិ

និងតំបន់បេតិកភណ្ឌពិភពលោក

ឯកឧត្តម វណ្ណ មូលីវណ្ណ/៧៥

ទេសចរណ៍វប្បធម៌ និងការអភិវឌ្ឍន៍និរន្តរភាព

ហឹរវេ បារេ/៨១

អំពើលួចប្លន់នៅតំបន់អង្គរ ៖ នៅតែជាសម្ពាធដ៏ធ្ងន់មួយ

អេដែន ក្លេម៉ង់/៨៧

៩៣/ការអានបន្ថែម

វិចារណកថា

តាមការផ្លាស់ប្ដូររូបរាងថ្មីរបស់ខ្លួន ទស្សនាវដ្ដីចេញរាល់បីខែម្ដង របស់យូណេស្កូ ឈ្មោះសារមន្ទីរអន្តរជាតិ (Museum International) ផ្ដល់នូវវេទិកាមួយសម្រាប់ការពិភាក្សាដ៏ហ្មត់ចត់ ដ៏មាននិរន្តរភាពផ្អែកពុទ្ធិ និងដែលតំកល់ជាឯកសារបីខែម្ដង អំពីក្រមសីលធម៌ និងការអនុវត្តន៍របស់សារមន្ទីរ និងបេតិកភណ្ឌនៅក្នុងទស្សនៈអន្តរជាតិមួយ ។ គោលបំណងរបស់ទស្សនាវដ្ដីនេះ គឺសំដៅផ្ដល់ចំណើគំនិតតាមរយៈពត៌មាន នៃលក្ខណៈវិទ្យាសាស្ត្រមួយដែលបានមកពីវិភាគទានរបស់ផ្នែកសិក្សាផ្សេងៗ ដើម្បីជំរុញការពិភាក្សាចំគោលដៅមួយទៅលើបញ្ហាចំពោះមុខ និងជាចុងក្រោយដើម្បីផ្ដល់អនុសាសន៍លើគោលនយោបាយវប្បធម៌ជាតិ និងអន្តរជាតិនានា និងលើបញ្ហាទាំងឡាយដែលពាក់ព័ន្ធជាមួយសារមន្ទីរ និងបេតិកភណ្ឌ ។ ទិសដៅនៃការសង្កត់ធ្ងន់ពិសេសដែលផ្អែកលើការយល់ទូលំទូលាយអំពីការងារសារមន្ទីរនេះ គួរធានានូវទំនាក់ទំនងជិតដិតរវាងការស្រាវជ្រាវក្នុងវិស័យវិទ្យាសាស្ត្រ និងការឆ្លើយតបផ្នែកនយោបាយចំពោះការផ្លាស់ប្ដូរបរិស្ថានវប្បធម៌ ដើម្បីបានជាប្រយោជន៍ផ្ទាល់ដល់អ្នកអនុវត្ត អ្នកស្រាវជ្រាវ និងអ្នកធ្វើសេចក្ដីសម្រេចចិត្ត ។

Museum International ចេញផ្សាយបីដងក្នុងមួយឆ្នាំ ក្នុងលក្ខណៈពីរច្បាប់ជាប់គ្នាមួយលេខ និងច្បាប់ធម្មតាពីរលេខ ។ ប្រធានបទសំខាន់មួយត្រូវបានពិភាក្សា និងពិនិត្យលំអិតដោយអ្នកឯកទេសនានាមកពីគ្រប់វិស័យ ។ វិភាគទានចំពោះប្រធានបទនេះ ត្រូវបានបញ្ចូលជាមួយកិច្ចពិភាក្សាមួយរវាងឥស្សរជនពីររូបដែលល្បីល្បាញលើឆាកអន្តរជាតិចំពោះលក្ខណៈជាក់លាក់មួយពាក់ព័ន្ធនឹងប្រធានបទនោះ ។ ក្នុងកំឡុងពេលពិភាក្សា អ្នកឯកទេសទាំងពីររូបនេះអាចរួមចំណែក និងយកការវិភាគបញ្ហានោះមកពិភាក្សាគ្នា ខណៈដែលដាក់វានៅក្នុងបរិបទចំណេះដឹងដ៏ទូលំទូលាយមួយ ។ តាមលក្ខណៈពិសេសនេះហើយដែលគោលគំនិតថ្មី និងវិធីសាស្ត្រវិភាគថ្មីៗទាំងឡាយដែលគេបានបង្កើតឡើង និងពិភាក្សាគ្នានៅក្នុងសហគមន៍អន្តរជាតិចំពោះវិស័យនៃសារមន្ទីរ និងបេតិកភណ្ឌនោះ ត្រូវបានលើកយកមកបកស្រាយជូនមិត្តអ្នកអានរបស់ Museum International ទាំងឡាយ ។

លេខចេញផ្សាយដំបូងសម្រាប់ឆ្នាំ២០០២ (ពីរលេខជាប់គ្នា) គឺឧទ្ទិសចំពោះតំបន់អង្គរដែលបានលេចឡើងដោយច្រើនប្រការ ជាសារមន្ទីរមានជីវិត ។ ប្រវត្តិនៃតំបន់វប្បធម៌នេះ ពីដំបូងបានវិវត្តតាមរយៈការអនុវត្តន៍បុរាណវត្ថុវិទ្យា បដិសំខារកម្ម ស្ថាបត្យកម្ម និងការវិភាគសិលាចារឹក ។ ភារកិច្ចដ៏យូរអង្វែង និងយ៉ាងប្រិតប្រៀនទាំងនេះបានអភិវឌ្ឍអង្គរអោយទៅជាសារមន្ទីរក្នុងលំហដ៏ពិតប្រាកដមួយជាមួយនឹងប្រធានបទពាក់ព័ន្ធ និងគ្រោះថ្នាក់ទាំងឡាយជាពិសេស គឺការលួចប្លន់ ។ ម្យ៉ាងវិញទៀត អង្គរក៏ជាទីអភិរក្សមួយផងដែរ ដែលក្នុងនោះ តាមន័យសារមន្ទីរបុរាណ សិល្បៈទាំងអស់ត្រូវបានបង្ហាញ និងដែលតាមរយៈទំនាក់ទំនងនៃការបំពេញបន្ថែមដែលបង្កើតឡើងរវាងពួកគេនោះ បង្កើតបានជាការរួបរួម និងខ្លឹមសារនៃភាពច្នៃប្រឌិតជាសកល ។

ក្រោយពីមានកិច្ចប្រឹងប្រែងជាអន្តរជាតិនៅអង្គររយៈពេល១០ឆ្នាំមក បច្ចុប្បន្ននេះយើងអាចគូសបញ្ជាក់នូវការវិភាគផែនការដ៏សំខាន់បំផុតមួយសម្រាប់ការថែទាំបេតិកភណ្ឌវប្បធម៌ ដោយមានការសម្របសម្រួលពីអង្គការយូណេស្កូក្នុងកំឡុងទសវត្សចុងក្រោយនៃសតវត្សទី២០នេះ ។ ដោយសម្គោធនៅក្នុងឆ្នាំ១៩៩២ នៅពេលដែលតំបន់នេះត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកស្ថិតក្នុងគ្រោះថ្នាក់នោះ ផែនការថែទាំអង្គរនេះគឺជាគំរូដ៏អស្ចារ្យមួយនៃបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងពិភពលោកសហសម័យរបស់យើង ដោយបេតិកភណ្ឌវប្បធម៌ ដំណោះស្រាយដែលបានស្នើឡើង ហើយបើនិយាយអោយទូលំទូលាយជាងនេះទៀត ទស្សនីយភាពជាក់ស្ដែងដែលសម្ដែងដោយអ្នកដើរតួផ្សេងៗនៅលើឆាកជាតិ និងអន្តរជាតិ ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

ការពិនិត្យដ៏ហ្មត់ចត់នូវវិភាគទាននានាដែលមានគុណភាពសមទទួលនូវការកោតសរសើរនោះ លាតត្រដាងនូវអ័ក្សសំខាន់ៗ បី ដែលអាចចាត់ទុកដោយសមហេតុផលបានថាជាការចម្រើនជឿនលឿនចំពោះបទពិសោធន៍ខាងវិធីសាស្ត្រ ។ ទីមួយ ទិន្នន័យវិទ្យាសាស្ត្រជាបន្តបន្ទាប់ត្រូវការបកស្រាយឡើងវិញ ចំពោះការស្រាវជ្រាវថ្មី ឬដែលកំពុងតែប្រព្រឹត្តិទៅដែលចង្អុលទៅរកការសន្និដ្ឋានថ្មីៗ ទាក់ទិននឹងដំណើរប្រព្រឹត្តិទៅនៃតំបន់អង្គរ និងតំបន់ជាយក្រុង រចនាសម្ព័ន្ធប្រវត្តិសាស្ត្រ និងនយោបាយរបស់ខ្លួន ។ ទីពីរ ទំហំនៃការវិភាគថ្មីមួយទៅលើតំបន់នេះត្រូវតែចាប់អនុវត្តទាំងចំពោះលំហដោយបន្លាយព្រំដែនធម្មជាតិរបស់ខ្លួនទៅដល់តំបន់ទាំងមូល និងពេលវេលាដោយសង្កត់ធ្ងន់លើនិរន្តរភាពដែលឧប្បត្តិកឡើងរវាងសណ្ឋាននៃអត្ថិភាពក្នុងអតីតកាល និងសណ្ឋាននៃអត្ថិភាពនាពេលបច្ចុប្បន្ន ។ គឺទំហំពិសេសនេះហើយដែលផ្តល់សារសំខាន់ដល់ការស្រាវជ្រាវផ្នែកសារមន្ទីរវិទ្យាផ្អែកលើការបង្ហាញរបស់តំបន់បុរាណវិទ្យាមួយ ។ ជាចុងក្រោយកម្មវិធីអង្គរត្រូវភ្ជាប់ដោយមិនអាចយកចេញបានទៅនឹងការបង្កើតយុទ្ធសាស្ត្រលើកកំពស់ដែលច្នៃតម្រូវទៅតាមក្រុមវប្បធម៌ដ៏ស្មុគស្មាញមួយដោយមានសមាសធាតុទ្វេភាគ ដែលជាបុរាណវិទ្យា និងប្រាសាទ បរិស្ថាន និងសង្គម ហើយនិងសារមន្ទីរវិទ្យា និងអប់រំ ។

ទិដ្ឋភាពទាំងអស់នេះ វាច្បាស់លាស់ណាស់ ដែលច្បាប់ចេញផ្សាយពីរលេខជាប់គ្នា ពិសេសរបស់ Museum International មានបំណងដើម្បីអភិវឌ្ឍ តាមរយៈការផ្លាស់ប្តូរ ការវិភាគជាមូលដ្ឋាន និងការកត់សំគាល់ផ្នែកវិទ្យាសាស្ត្រ ការបង្ហាញនូវពត៌មាន និងអំណះអំណាងផ្នែកទ្រឹស្តីទាំងឡាយ ។ ក្នុងការធ្វើបែបនេះបាន វាមានបំណងផ្តល់សម្ភារៈដើម្បីឆ្លុះបញ្ចាំងនូវតួនាទីរបស់សហគមន៍អន្តរជាតិក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងបេតិកភណ្ឌវប្បធម៌ ។ ចំពោះរឿងនោះខ្ញុំសូមថ្លែងអំណរគុណចំពោះមិត្តជាទីស្រឡាញ់របស់ខ្ញុំគឺ ឡូត អារីសប៉េ និងអាហ្សេឌីន បៃសធាអ៊ូច ដែលបានធ្វើវិភាគទានដ៏មានតម្លៃចំពោះការងារអង្គការរបស់យើង ដូចបានបង្ហាញជាថ្មីម្តងទៀត នៅក្នុងលេខពិសេសនេះ ។ ដោយយល់ព្រមដើម្បីធ្វើការប្រៀបធៀបបទពិសោធន៍របស់ពួកគេ ចំពោះសំណួរនៃសារមន្ទីរអាវ្យធម៌តាមសំណូមពររបស់ខ្ញុំនោះ ដោយឆ្លងកាត់ការពិភាក្សាដ៏ស្មុគស្មាញ ពួកគេបានដាក់ចេញនូវទស្សនៈជាគោលគំនិតថ្មីៗជាច្រើន ។

ម៉ូនារ ប៊ូសេណាគី
ជំនួយការអគ្គនាយក ផ្នែកវប្បធម៌

អារម្ភកថា

របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ទស្សនាវដ្តីប្រកបដោយកិត្យានុភាពដ៏ខ្ពង់ខ្ពស់របស់យូណេស្កូឈ្មោះ សារមន្ទីរអន្តរជាតិ (MUSEUM International) ផ្សាយចេញលេខពិសេស ក្នុងការឧទ្ទិសដល់ប្រាសាទអង្គរនេះ បានបំពេញបំណងប្រាថ្នារបស់យើងគ្រប់ៗគ្នា។ នេះក៏ជារបៀបមួយ ក្នុងការធ្វើតុល្យការដំបូងលើការងារដែលបានចាប់ផ្តើម និងលទ្ធផលទទួលបានអំពីរមណីយដ្ឋាននៃបេតិកភណ្ឌពិភពលោក ក្នុងរយៈកាលមួយទសវត្ស គិតចាប់ពីសេចក្តីអំពាវនាវត្រូវបានថ្លែងជាឧឡារិក នៅពេលបានចេញផុតពីយុគសម័យសោកនាដកម្ម និងឈឺចាប់ខ្លោចផ្សារាល់ថ្ងៃដ៏យូរអង្វែងរបស់ប្រជាពលរដ្ឋយើង។
ជាការពិតណាស់ កាលពីឆ្នាំ ១៩៩១ យើងបានស្នើសុំអោយដាក់អង្គរក្រោមកិច្ចការពាររបស់ស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ និងសុំបញ្ចូលរមណីយដ្ឋាន និងតួប្រាសាទ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅយូណេស្កូ។

ទោះបីជាយើងនៅមានការខ្វះខាតទាំងមធ្យោបាយនានារបស់ជាតិ និងច្បាប់សំរាប់ជាទំរង់បែបបទក៏ដោយមកដល់ពេលនេះ យើងទាំងអស់គ្នា មានក្តីអំណររីករាយយ៉ាងជ្រាលជ្រៅ អង្គរលែងទទួលរងគ្រោះទៀតហើយ ផ្ទុយទៅវិញកំពុងឈានទៅបានស្គាល់ភាពសម្បូររុងរឿង។

ទស្សនាវដ្តីលេខពិសេសនេះ ក៏បានបើកច្រកមួយសំរាប់មើលទៅអនាគត លើទស្សនៈវិស័យថ្មីៗ ដែលធ្វើអោយយើងសប្បាយរីករាយបំផុត។

ពិតណាស់! អង្គរគឺជាសារមន្ទីរមួយមានជីវិតរស់រវើក។ ជាការសក្តិសមណាស់ដែលទស្សនៈថ្មីនេះត្រូវតែសំរេចឱ្យឃើញជាក់ស្តែងឡើងនៅសៀមរាប ត្រង់ចំណុចដើមនៃក្រុម "ព្រៃប្រាសាទដ៏ស្កុកស្កម្ភ" ដោយដាក់ឱ្យមានសារមន្ទីរមួយនៃខឿនវប្បធម៌ខ្មែរ។ យុវជនយើងនឹងឃើញនៅទីនោះ គ្រប់ហេតុផលដែលត្រូវរក្សាឥតឈប់ឈរនូវក្តីសង្ឃឹមហើយអ្នកប្រវត្តិសាស្ត្រ នឹងឃើញនូវសក្ខីភាពដែលគ្រាប់ពូជអាក្រក់ << ខ្មែរក្រហម >> មិនអាចនឹងដុះបានជាដាច់ខាត ព្រោះថាបើគេស្ថិតនៅក្រៅប្រវត្តិសាស្ត្រ គេត្រូវទទួលការថ្កោលទោសពីជាតិរបស់ខ្លួន...។

ខ្ញុំសូមឱ្យរាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ សម្តេច **ហ៊ុន សែន** អាចផ្តល់អាទិភាពមួយចំពោះគំរោងរៀបចំសារមន្ទីរថ្មីនេះ ដែលនឹងឧទ្ទេសចំពោះកិត្តិនាមរបស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាការវិនិយោគដ៏ថ្លៃថ្លាមួយសំរាប់អនាគតផង។ យើងសូមសម្តែងនូវកតវេទិតាដ៏ក្លៀវក្លា ចំពោះអ្នកគ្រប់គ្នានៅអង្គការយូណេស្កូ ដែលបានជ្រោមជ្រែងក្នុងការរៀបចំទស្សនាវដ្តីលេខពិសេសនេះ ហើយសូមកត់សំគាល់ថាជាព្រឹត្តិការណ៍សំខាន់មួយផងដែរ។ យើងសូមរក្សានូវអត្ថបទចំណាប់អារម្មណ៍មួយដោយឡែកជូនឯកឧត្តម Koïchiro Matsuura អគ្គនាយកអង្គការអន្តរជាតិ ដែលចាប់តាំងពីបានជាប់ឆ្នោត និងបន្ទាប់ពីដំណើរមកធ្វើទស្សនកិច្ចដ៏រីករាយក្នុងប្រទេសយើង តែងតែគាំទ្រដោយទឹកចិត្តសកម្ម និងជំរុញឱ្យដំណើរការនូវកម្មវិធីយ៉ាងសន្ទឹកសន្ធាប់នេះ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

សេចក្តីផ្តើម

របស់អគ្គនាយកអង្គការ យូណេស្កូ

ការថែរក្សាការពារមិនអាចកំរិតនៅត្រឹមតែការពង្រឹង ការស្តារ និងអនុវត្តន៍ជាក់ស្តែងប៉ុណ្ណោះទេ ។

ជាដំបូងហើយសំខាន់បំផុតនោះ ការថែរក្សាទាក់ទិនទៅនឹងការផ្តល់អត្ថន័យ ការព្យាយាមផ្សព្វផ្សាយពីតម្លៃ និងការចាត់ទុកថាជារបស់យើងទាំងអស់គ្នា ដែលមនុស្សជាតិបានទទួលរាប់សតវត្សមកហើយ ។

ការថែរក្សាការពារ និងអភិវឌ្ឍន៍តំបន់ប្រាសាទអង្គរ ជាកម្មវិធីមួយមានមហិច្ឆិតា ដែលត្រូវបានផ្តួចផ្តើមគំនិតនៅក្នុងសន្និសីទនាទីក្រុង Tokyo នៅក្នុងខែតុលា ឆ្នាំ១៩៩៣ ហើយដែលការសំរបសំរួលការងារនេះ ត្រូវបានគេប្រគល់មកឱ្យអង្គការយូណេស្កូ តាមការស្នើសុំរបស់អាជ្ញាធរកម្ពុជានោះ គឺជានិមិត្តរូបចំពោះការធ្វើប្រតិបត្តិការ និងក្រមសីលធម៌ ។ តំបន់អង្គរ ដែលជាទឹកដៃនៃសិល្បៈនិងប្រវត្តិសាស្ត្រ និងជាវត្ថុដ៏មានតម្លៃនៅក្នុងបញ្ជីមរតកពិភពលោកនោះ គឺជានិមិត្តរូបតែមួយគត់នៃតួនាទីដែលមរតកវប្បធម៌មាននៅពេលបច្ចុប្បន្ននេះ នៅក្នុងជីវិតនៃសង្គមទាំងឡាយ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ។

នៅខណៈដែលប្រវត្តិសាស្ត្រនៃតំបន់ប្រាសាទអង្គរវត្ត ពីដំបូងហាក់បីដូចជាប្រវត្តិសាស្ត្រនៃតំបន់បុរាណវិទ្យា ដែលផលប្រយោជន៍របស់វាស្ថិតនៅក្នុងការពង្រីកចំណេះដឹងនៃអារ្យធម៌ដែលបានសាបសូន្យទៅ ។ យុគសម័យនោះបានកន្លងផុតទៅជាយូរណាស់មកហើយ នៅពេលដែលវិទ្យាសាស្ត្រកេរមរតកបានផ្តល់ "ឋានៈជាសារមន្ទីរ" ដល់កេរដំណែលពីអតីតកាល ។ ទោះបីជាវាមានកិត្យានុភាពយ៉ាងណាក៏ដោយ នៅក្នុង និងក្រៅពង្សាវតារនៃរាជវង្សានុវង្ស និងការអភិវឌ្ឍន៍របស់រាជវង្សនោះ វាគឺជាប្រវត្តិសាស្ត្ររបស់ព្រះរាជាច្រើនអង្គទាក់ទងទៅនឹងតំបន់នោះ និងបរិស្ថានដែលបានទទួលការយកចិត្តទុកដាក់ នៅពេលដែលកម្មវិធីថែរក្សាអន្តរជាតិត្រូវបានអនុវត្តមួយជំហ៊ានម្តង១ ។ នៅពេលចាប់ផ្តើមដំបូងនៃដំណាក់កាលដ៏មានសំណាងថ្មីមួយ នៅក្នុងប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា បុនវុឌ្ឍិនៃប្រាសាទអង្គរ គឺជាការបង្ហាញជាក់ស្តែងមួយសំរាប់ប្រជាជនកម្ពុជាដែលចង់បានសេរីភាព ការបានមកវិញនូវវត្ថុអនុស្សាវរីយ៍ដ៏ល្បីល្បាញ និងបុនវុឌ្ឍិវប្បធម៌របស់ខ្លួន ។

រយៈពេលមួយទសវត្សកន្លងទៅ (១៩៩២-២០០១) នៃកម្មវិធីស្តារ និងលើកកំពស់ ការផ្លាស់ប្តូរបែបបទនៅក្នុងការយល់ដឹងជាទូទៅនិងជាពិសេស ភាពក្លៀវក្លានៃវប្បធម៌អាស៊ីបានធ្វើឱ្យមានទំហំថ្មីមួយចំពោះគោលជំហរសំខាន់នៃការគិតគូរថ្លឹងថ្លែងរបស់មនុស្សជាតិ ជាការយកចិត្តទុកដាក់រួមគ្នាមួយផ្តោតទៅលើមនុស្សជាតិលើការបង្កើតឡើង និងលើប្រព័ន្ធប្រាជ្ញា ស្មារតី និងទស្សនៈរបស់ពួកគេ ។ ទោះបីជាយ៉ាងណាក៏ដោយ សំរាប់តែហេតុផលនោះ កេរតំណែលអរូបិយនៃប្រាសាទអង្គរមិនមែនជាប្រភេទកេរតំណែលបន្ថែមមួយទៀតទេ ។ ជួនកាលប្រភេទបន្ថែមនេះ ជាប្រភេទមួយដែលចងជាប់ និងដែលអោបក្រសោបទាំងអស់ ។ វាគឺជាអ្វីដែលផ្តល់អត្ថន័យ និងតម្លៃ ចំពោះការងារអភិរក្សតំបន់ប្រាសាទអង្គរ ។ ផែនការសំរាប់សារមន្ទីរនៃអារ្យធម៌ប្រាសាទអង្គរជានិមិត្តរូប នៃមហិច្ឆិតាថ្មីនេះ តាមរយៈសារនានាដែលត្រូវបានបញ្ជូនមកអោយមនុស្សលោកដោយការងាររបស់ពួកគេ ។ បំណងប្រាថ្នានោះបង្កើតបានជាលទ្ធផលមួយនៃលទ្ធផលជាច្រើននៃការចែករំលែកជាអន្តរជាតិនូវតម្លៃនៃប្រាសាទអង្គរ ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ភាពជោគជ័យនៃកម្មវិធីថែរក្សាការពារប្រាសាទអង្គរវត្ត ដែលត្រូវបានទទួលស្គាល់ជាឯកច្ឆ័ន្ទ គឺដោយសារតែព្រះរាជតម្រិះដ៏ឈ្លាសវៃ និងការប្ដេជ្ញាព្រះទ័យរបស់ព្រះករុណាព្រះបាទនរោត្តមសីហនុ និងដោយសារតែកិច្ចខិតខំប្រឹងប្រែងដ៏អស្ចារ្យរបស់រាជរដ្ឋាភិបាលរបស់ព្រះអង្គ ដែលត្រូវបានជួយឧបត្ថម្ភយ៉ាងប្ដូរផ្ដាច់ដោយសហគមន៍អន្តរជាតិ ។ ជោគជ័យនេះក៏ជានិមិត្តសញ្ញាមួយផងដែរនៃសេចក្ដីត្រូវការប្រវត្តិសាស្ត្រ និងវត្ថុអនុស្សាវរីយ៍ ដើម្បីពង្រឹងសមត្ថភាពរបស់មនុស្សជាតិ អោយយល់ដឹងពីអនាគតផ្អែកលើបែបបទសេដ្ឋកិច្ច សង្គម និងវប្បធម៌ថ្មី ។

តាមរយៈការយកចិត្តទុកដាក់ដែលផ្ដោតទៅលើអតីតកាល ដើម្បីកសាងអនាគតដ៏ល្អប្រសើរមួយ តំបន់អង្គរផ្ដល់ឱ្យយើងនូវអត្ថន័យដ៏ជ្រាលជ្រៅមួយនៃកេរតំណែល គឺជាអត្ថន័យរបស់សារមន្ទីរមានជីវិតបើកចំហចំពោះជោគវាសនារបស់មនុស្សដែលបានបង្កើត ថែរក្សាការពារ និងបន្តថែរក្សាវាឱ្យនៅគង់វង្ស ។

Koïchiro Matsuura

បុព្វកថា

របស់សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ខ្ញុំសូមសំដែងនូវការពេញចិត្តចំពោះគំនិតផ្តួចផ្តើមដ៏ល្អរបស់អង្គការយូណេស្កូ ។ ដោយខិតខំប្រឹងប្រែងចេញផ្សាយលេខពិសេសរបស់សារមន្ទីរអន្តរជាតិនិយាយពីតំបន់ប្រាសាទអង្គរ អង្គការយូណេស្កូ បានសន្យាជូនយើងទាំងអស់គ្នាក្នុងការធ្វើដំណើរទៅរកអនាគតមួយ ។

គោលនយោបាយរបស់រដ្ឋាភិបាលយើងខ្ញុំគឺមិនធ្វើឡើងសំរាប់តែសកម្មភាពការងារប៉ុណ្ណោះទេ តែបើចាំបាច់ គឺគោលនយោបាយត្រូវធ្វើឡើងដើម្បីការពារ និងថែរក្សាមរតកវប្បធម៌មួយ ដែលត្រូវបានទទួលស្គាល់ថា ជាវត្ថុដ៏មានតម្លៃមួយរបស់មរតកវប្បធម៌ពិភពលោក ។ យើងចាត់ទុកមរតកនេះជាបញ្ហាអាទិភាពមួយដែលការការពារបែបនេះនឹងជួយសំរួលដល់ការលើកកំពស់ប្រាសាទអង្គរ និងផ្តល់នូវអត្ថន័យពេញលេញដល់ការងារអភិវឌ្ឍន៍ដែលមិនអាចខ្វះបាន ។

វាជាភារកិច្ចរបស់យើងទាំងអស់គ្នាក្នុងការតស៊ូប្រឆាំងនឹងភាពក្រីក្រ និងគាស់រំលើងមូលហេតុ និងផលវិបាករបស់វា ដើម្បីធានាថា យើងទាំងអស់គ្នារួមចំណែកទទួលបាននូវភាពថ្លៃថ្នូរ ការរៀនសូត្រពីស្មារតីនៃកេរមរតករបស់យើង និងជាមោទនភាពមួយដែលយើងទាំងអស់គ្នាជាអ្នកទទួលមរតកនៃប្រវត្តិសាស្ត្រដ៏អស្ចារ្យនេះ ។

ចំពោះខ្លឹមសារដ៏ច្រើនរបស់វា លេខចេញផ្សាយនៃសារមន្ទីរនេះប្រាប់យើងឱ្យដឹងថា តើយើងនៅមានការងារប៉ុន្មានទៀតដែលត្រូវធ្វើ និងថាតើយើងមានលទ្ធភាពប៉ុន្មានដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ ។ យើងប្តេជ្ញាចិត្តនឹងខិតខំធ្វើការងារបន្តឱ្យបានចប់ចុងចប់ដើម ។

ភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០២

ហត្ថលេខា

ហ៊ុន សែន

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

បុព្វកថា

ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានគណៈកម្មការជាតិកម្ពុជាសំរាប់យូណេស្កូ

ទំនាក់ទំនងដែលគណៈកម្មការជាតិរបស់យើងបានថែរក្សាយ៉ាងផ្ចិតផ្ចង់ជាមួយអង្គការយូណេស្កូ គឺពិតជាមានលក្ខណៈពិសេសខ្លាំងណាស់ ។ បន្ទាប់ពីមានសកម្មភាព និងកិច្ចសហការយ៉ាងជិតស្និទ្ធខ្លាំងក្លាជាច្រើនកន្លងមក លេខពិសេសនៃទស្សនាវដ្តី MUSEUM International នេះផ្តល់នូវសក្ខីភាពអោយកាន់តែឃើញច្បាស់ថែមទៀត ។ ស្របតាមព្រះរាជគន្លងរបស់ព្រះមហាក្សត្រជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង និងរបស់សម្តេចនាយករដ្ឋមន្ត្រី ប្រជាជនខ្មែរទាំងមូលសប្បាយរីករាយជាអតិបរមានូវឱកាសដ៏ប្រពៃនេះ ។

ដោយឡែក ពលរដ្ឋកម្ពុជាទាំងអស់កាន់តែមានមនសិកាយល់ដឹងច្រើនថែមទៀតពីសារៈសំខាន់នៃប្រាសាទអង្គរ ក្នុងអភិក្រមនៃកិច្ចអភិវឌ្ឍន៏ជាតិ ។ រមណីយដ្ឋានប្រកបដោយកិត្យានុភាពល្បីល្បាញនេះ ពុំមែនគ្រាន់តែជាកំណប់ទ្រព្យប៉ុណ្ណោះទេ តែគឺជាប្រភពកំណប់ទ្រព្យមួយមិនចេះរីងស្ងួតឡើយ ។ រាជរដ្ឋាភិបាលប្តេជ្ញាធានា យកចិត្តទុកដាក់ ធ្វើអោយមានការអភិវឌ្ឍន៏ក្នុងក្របខ័ណ្ឌនៃនយោបាយទេសចរណ៏ប្រកបដោយនិរន្តភាព និងគុណភាព ។ ផ្អែកលើការលើកតំលៃនៃប្រាសាទបែបសិល្បៈ និងបែបប្រវត្តិសាស្ត្រ លើបុនវុឌ្ឍីនៃវប្បធមិខ្មែរ លើការធ្វើអោយមានភាពសំបូរបែបក្នុងការកំសាន្តវិស័យទេសចរណ៏នេះ មានអត្ថន័យជាទេសចរណ៏វប្បធម៌ពិតប្រាកដ ដែលអង្គការយូណេស្កូបានជួយឧបត្ថម្ភគាំទ្រជានិច្ច ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ប្រវត្តិនៃតំបន់អង្គរ

ដោយ ប្រ៊ុយណូ ដាហ្សង់ Bruno Dagens

លោក Bruno Dagens គឺជាសាស្ត្រាចារ្យប្រវត្តិសាស្ត្របុរាណ និងបុរាណវត្ថុវិទ្យា អំពីអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ នៅសកលវិទ្យាល័យក្រុងប៉ារីស ៣ (University of Paris III) ។ លោកបានសិក្សា ប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យា នៅទីក្រុង Strasbourg ហើយដោយលោកជាសមាជិកនៃគណៈប្រតិភូបុរាណវត្ថុវិទ្យារបស់បារាំង លោកបានចូលរួមនៅក្នុងការជីកកកាយរកវត្ថុបុរាណ នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន នៅក្នុងតំបន់ Surkh Kotal និង Mundigak ។ ដោយលោកជាអតីតសមាជិកសាលាបារាំងចុងបូព៌ា (EFEO) លោកត្រូវបានគេចាត់តាំងឱ្យធ្វើការនៅតំបន់អង្គរ ហើយក្រោយមកគេចាត់តាំងអោយទៅធ្វើការនៅ Pondicherry ។ លោកបានបោះពុម្ពផ្សាយនូវឯកសារជាច្រើន ហើយឯកសារដែលលោកទើបតែបានបោះពុម្ពនាពេលថ្មីៗ នេះរួមមាន : អង្គរព្រៃថ្ម បោះពុម្ពនៅឆ្នាំ១៩៨៩ (មានបោះពុម្ពជាភាសាបារាំង ហើយបកប្រែជាភាសាអង់គ្លេស អ៊ីតាលី ជប៉ុន និងភាសាកូរ៉េ) វត្ថុចំនួន១០០ ត្រូវបានបាត់ : អំពើលួចប្លន់នៅប្រាសាទអង្គរ បោះពុម្ពឆ្នាំ១៩៩៣ បោះពុម្ពលើកទី២ (នៅឆ្នាំ១៩៩៧). Le Rauravàgama. Untraîté sivaite de rituel et de doctrine (Rauravagama ការអធិប្បាយនៃក្បួនវិធី និងលទ្ធិសេវៈ) (មានការបកប្រែ និងសរសេរផ្សេងៗ មានពីរភាគគឺបោះពុម្ពនៅឆ្នាំ២០០០ ដោយសហការជាមួយនឹង M-L- Barazer- Billoret) ។

ស្លាកស្នាមចាស់បំផុតនៃការរស់នៅរបស់មនុស្សនៅក្នុងតំបន់អង្គរ គឺជាសំណល់នៃការតាំងទីលំនៅ នាសម័យបុរេប្រវត្តិ ដែលត្រូវបានរកឃើញនៅកន្លែងផ្សេងៗជាច្រើននៅតំបន់អង្គរ ដោយលោក B. P. Groslier ហើយត្រូវបានចាត់ទុកថា មានតាំងពីសហស្សវត្សទី១មុនពេលយុគសម័យរបស់យើង[1] ។ ប៉ុន្តែគេនៅមិនទាន់បានដឹងច្បាស់នៅឡើយ រវាងពេលមានសំណល់ទាំងនេះ និងការចាប់ផ្តើមដំបូងនៃការរស់នៅលើតំបន់អង្គរនាសតវត្សទី ៧ ។
ចាប់តាំងពីពេលនោះមក ប្រាសាទរឹងមាំធ្វើពីឥដ្ឋ និងថ្ម និងទំនប់ធ្វើពីដីដ៏រឹងមាំបានកំណត់នូវប្រវត្តិសាស្ត្រ ជាបន្តបន្ទាប់របស់តំបន់អង្គររហូតមកដល់សតវត្សទី១៣ - ១៤ ថែមទាំងសតវត្សទី ១៦ទៀត ប្រសិនបើយើងរួមបញ្ចូលទាំងការកែប្រែគួរអោយកត់សំគាល់ក្រោយមកទៀត ចំពោះប្រាសាទបាពួន បាក់ខែង និងប្រាសាទអង្គរវត្ត មុនពេលដែលមានការកាប់ឆ្ការព្រៃ និងការស្តារឡើងវិញនៃតំបន់នោះ ដែលបានចាប់ផ្តើមនៅដើមសតវត្សទី២០ ។

ទោះបីជាយើងអាចបង្កើតបាននូវពង្សាវតារមួយគួរអោយជឿទុកចិត្ត ដោយផ្អែកលើការសិក្សាពីសិលាចារឹក និងការវិវត្តទ្រង់ទ្រាយក៏ដោយ ក៏ប្រវត្តិសាស្ត្ររបស់តំបន់អង្គរ ហើយតាមការសន្និដ្ឋានប្រវត្តិរបស់អ្នករស់នៅ "ទីក្រុងនេះ" គឺមានភាពស្មុគ្រស្មាញ និងសំាញ៉ាំ ។ ឧទាហរណ៍ ទោះបីជាប្រាសាទទាំងឡាយអាចធ្វើជាភស្តុតាងនៃការគោរពរបស់ស្តេចខ្មែរចំពោះបុព្វការីជនរបស់គេក៏ដោយ ក៏ការគោរពនោះមិនបានគិតដល់ការទទួលស្គាល់អ្នកបង្កើតដំបូងនៃប្រាសាទមួយ

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ប្រវត្តិនៃតំបន់អង្គរ

ដោយ ប្រ៊ុយណូ ដាហ្សង់ Bruno Dagens

ដែលស្ដេចមួយអង្គក្រោយទៀតគ្រាន់តែសាងសង់បង្ហើយ និងសម្ភោធ ដូចមានឧទាហរណ៍បង្ហាញស្រាប់នៅ ប្រាសាទបាគង និងប្រាសាទនៅលើកំពូលភ្នំបាក់ខែង ។ និន្នាការដែលគេទើបតែយកចិត្តខ្លាំងនាពេលថ្មីៗនេះ មានន័យថា ប្រវត្តិសាស្ត្ររបស់ទីក្រុងនេះ គឺវាមិនមែនត្រង់ស្លូដូចដែលគេបានគិតទុកពីយូរយោសមកហើយនោះទេ នៅពេលដែលប្រាសាទមួយចំនួនត្រូវបានធ្វើឡើងសំរាប់ការឡើងគ្រងរាជ្យ



© UNESCO/Mathieu Ravaux

១/ បឹងទន្លេសាប ជាបឹងដ៏ធំមួយដែលស្ថិតនៅភាគខាងត្បូងនៃក្រុងអង្គរ រីកឡើងជារៀងរាល់ឆ្នាំ ដោយសារទឹកជំនន់ នៃទន្លេមេគង្គ ស្ទឹងពួក និងស្ទឹងសៀមរាប ដែលជាស្ទឹងពីរយ៉ាងសំខាន់ ដែលហូរជុំវិញតំបន់អង្គរ ។
២/ ទឹក គឺជាកត្តាចាំបាច់មួយនៅតំបន់អង្គរ ដែលបណ្ដាញនៃអាងស្តុកទឹកមួយយ៉ាងធំគឺ "បារាយណ៍" ពូនិងប្រឡាយគ្របដណ្ដប់នៅលើផ្ទៃដីដ៏ធំ ដែលនាំអោយមានការលេចឡើងនូវគំនិតនៃ "ទីក្រុងធារាសាស្ត្រ" ។

របស់ស្ដេចមួយអង្គៗ ហើយប្រាសាទនីមួយៗ ត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃការអភិវឌ្ឍន៍ មួយលើករឺ ប្រហាក់ប្រហែលនឹងការអភិវឌ្ឍន៍មួយលើក[២] ។ ភាពមិនច្បាស់លាស់បន្ថែមកើតចេញមកពីប្រការថា មិនមែនប្រាសាទទាំងអស់សុទ្ធតែត្រូវបានចងក្រងឯកសារជាផ្លូវការនោះទេ ។ ពុំមានសិលាចារឹកនៅលើប្រាសាទអង្គរវត្តណាមួយ ដែលសរសើរចំពោះស្នាដៃ អ្នកសាងសង់ពិតប្រាកដរបស់វាគឺព្រះបាទសុរិយវរ្ម័នទី២ (គ្រឹះសករាជ ១១១៣-១១៥០) ឡើយ ។ ស្ថានភាពទាក់ទងនឹងប្រាសាទដទៃ ទៀត គឺមិនសូវមានភាពច្បាស់លាស់ទេ ។ ឧទាហរណ៍ ដូចជាយើងមិនស្គាល់ឈ្មោះរបស់ស្ដេចដែលរចនារូបរាង "ចុងក្រោយ" នៃប្រាសាទបាគងសតវត្សទី៩ មកដល់ដើមសតវត្ស ទី១២ ឡើយ ។ ដូចជាយើងមិនដឹងថាតើនរណា

ដែលបានសាងសង់ប្រាសាទអកយំ រឺប្រាសាទភិមានអាកាស ដែលជាគោលដ៏សំខាន់ នៅក្នុងទេសភាពប្រាសាទរបស់ទីក្រុង (អង្គរ) និងប្រវត្តិសាស្ត្ររបស់ វា ។

មានការលំបាកជាចុងក្រោយបំផុត ដែលជាការ (អភិវឌ្ឍន៍បែប) លើកទឹកចិត្តមួយដែរ : ប្រវត្តិសាស្ត្ររបស់ទីក្រុងកំពុងតែត្រូវបានសរសេរឡើងវិញទាំងស្រុង ។ មិនមានរយៈពេលណាមួយក្នុងមួយ

© UNESCO

ខែបាន (ក្នុងផុតទៅ) ដែលគ្មានក្រុមអ្នកស្រាវជ្រាវណាមួយដែលធ្វើការនៅកន្លែងផ្សេងៗគ្នានៃតំបន់អង្គរ មិនផ្ដល់ដំណឹងអ្វីអោយដឹងច្បាស់ រឺក៏រកឃើញអ្វីមួយថ្មី រឺបើគេមិនបដិសេធតថភាពល្អិតទាំងឡាយដែលមានយូរមកហើយនោះទេ ។ តំបន់នានានៃទីក្រុងអាតែន (Athens) និង ទីក្រុងរ៉ូម (Rome) អាចត្រូវបានកំណត់ដោយកំពស់កូនភ្នំ Acropolis រឺមួយក៏កូនភ្នំចំនួន៧ទៀត ។ តំបន់អង្គរត្រូវកំណត់បានប្រសើរជាងនេះដោយស្ទឹងសៀមរាបរួមជាមួយនឹងដៃរបស់វាគឺស្ទឹងពួក និងស្ទឹងរលួស ។ ហេតុផលសំរាប់ការជ្រើសរើសការតាំងលំនៅ គឺប្រហែលដោយសារតែស្ទឹងនេះជាប្រភពនៃភាពរុងរឿងផ្នែកសម្ភារៈរបស់តំបន់នោះ ហើយវាមានតួនាទីមួយសំខាន់នៅក្នុងការគូរផែនទី និងការកំណត់ទិមិត្តរូបរបស់ស្ទឹងនោះ ។ ស្ទឹងនោះហូរកាត់តំបន់អង្គរភ្ជាប់ពីភ្នំគូលេនដែលជាកំពូលទឹកនៃតំបន់អង្គរ និងជាទីតាំងប្រវត្តិសាស្ត្រខ្មែរដ៏សំខាន់ទៅទន្លេសាបជាបឹងទឹកសាបដ៏ធំសំបូរទៅដោយត្រីដែលបានចិញ្ចឹមអ្នកស្រុកនៅតំបន់ទំនាបអង្គរចាប់តាំងពីសម័យមុនប្រវត្តិសាស្ត្រមកម្លេះ ។ ប្រសិនបើភ្នំគូលេនត្រូវបានគេ

ប្រវត្តិ និង សង្គម

ទទួលស្គាល់ថា ដូចគ្នានឹងភ្នំមហេន្ទ្រាហនេដវា) ដែលជាទីគង់នៅនៃព្រះសិវៈ (Shiva) ដូចនៅក្នុងទេវកថា របស់ឥណ្ឌានោះស្ទឹងសៀមរាបអាចប្រៀបប្រដូចទៅនឹងទន្លេគង្គា (Ganges) រឺហៅអោយច្បាស់ជាងនេះថាព្រះនាងគង្គា (Ganga) ជាទន្លេអាទិទេព និងជាមហេសីទីពីររបស់ព្រះសិវៈ (Shiva) ដែលហូរចេញពីព្រះកេសរបស់ព្រះសិវៈ(Shiva) ចាក់ចូលទៅក្នុងមហាសមុទ្រ ។ ហេតុនេះហើយទើបស្ទឹងនេះផ្តល់លក្ខណៈបរិសុទ្ធចំពោះតំបន់អង្គរដោយបានហូរកាត់វានិងជួយពង្រឹងឋានៈរបស់អង្គរឱ្យក្លាយទៅជាទេពនគរមួយ ។ ប៉ុន្តែខុសគ្នាពីកូនភ្នំរបស់ទីក្រុងរ៉ូម (Rome) រឺ Acropolis ស្ទឹងពិសិដ្ឋនេះ គឺជាចំណុច (ទីតាំងដែលគ្មានស្ថេរភាព) : នៅពេលកន្លងទៅអ្នកសាងសង់ទីក្រុងនេះមិនរុញរាក្នុងការផ្លាស់ប្តូរ និងកែតំរូវទិសដៅផ្លូវទឹកអោយស្ថិតនៅជិតគំរោងការងាររបស់គេនោះទេ ។ ហេតុដូចនេះហើយប្រវត្តិរបស់ស្ទឹងវាស្របគ្នានឹងប្រវត្តិនៃការកាន់កាប់តំបន់អង្គរ ។ ក្រៅពីនេះទៀត ដោយធ្វើដំណើរបញ្ច្រាសខ្សែទឹកឡើងមកលើជនជាតិចាមបានមកដល់អង្គរនៅឆ្នាំ១១៧៧ ដើម្បីបំផ្លិចបំផ្លាញអង្គរដោយបង្កើត ដោយអចេតនាឱ្យមានរចនាបទស្ថាបត្យកម្មខុសពីធម្មតាដែលតំបន់ នោះមិនដែលធ្លាប់ជួបហើយវាជាផ្លូវមួយដែលលោកជីវ តាក្វាន់ (Zhou Daguan) នៅក្នុងឆ្នាំ១២៩៦ និងលោកហង់រី ម៉ូហូត៏ (Henri Mouhot) នៅក្នុងឆ្នាំ១៨៦០ បានមកដល់ទីក្រុងដែលអ្នកទាំងពីរផ្តល់នូវបទពិពណ៌នា "ជាប្រវត្តិសាស្ត្រ" មួយ ។ គួរតែត្រូវនិយាយបន្ថែមថា ការកាន់កាប់ជាក់លាក់នៃតំបន់កណ្តាលរបស់អង្គរ (ជោគជាំដោយស្ទឹងសៀមរាប) ចាប់ពីចុងសតវត្សទី៩ នោះគឺកើត ឡើងក្រោយការកាន់កាប់នៅតំបន់ជាយក្រុងភាគខាងលិច និងខាងកើតអង្គរ គឺតំបន់មួយត្រូវបានហូរកាត់ដោយស្ទឹងពួកហើយតំបន់មួយ ទៀតត្រូវបានហូរកាត់ដោយស្ទឹងរលួសដែលមានប្រភពមកពីភ្នំគូលេន ហើយដែលហូរចូលទៅក្នុងបឹងទន្លេសាបផងដែរ ។ ដោយត្រូវបានឆ្លងកាត់ដោយផ្លូវទឹកមួយក្នុងចំណោមផ្លូវទឹកទាំងនេះ និងមានព្រំប្រទល់ខាងកើតជាប់នឹងស្ទឹងពួកខាងលិចជាប់នឹងស្ទឹងរលួសវាលទំនាបតំបន់អង្គរដែលបើនិយាយអោយទូលំទូលាយទៅគឺកំណត់ត្រឹមទិសខាងជើង និងខាងត្បូងដោយប្រភព និងទិសដៅ (តម្បង្គាន) របស់ស្ទឹងទាំងនោះ ។ នៅភាគខាងជើង គឺជាខ្ពង់រាបដែលត្រូវបានគេស្គាល់ថាជាភ្នំគូលេន។ ភ្នំនេះបាំងទេសភាពប៉ុន្តែវាជាផ្នែករួមទាំងអស់នៃប្រវត្តិសាស្ត្រ និងជាជីវិតរបស់វាលទំនាបដែលវាលប់លើ ។ នៅផ្នែកខាងត្បូង គឺឆ្នេរបឹងទន្លេសាបដែលទំហំរបស់វានឹងអាច មានការប្រែប្រួលរាល់ឆ្នាំ ប៉ុន្តែវាមានទំហំធំគួរសមនៅពេលដែល ទំហំបឹងទាំងនេះប្រែប្រួលទៅតាមសង្វាក់ទឹកជំនន់របស់ទន្លេមេគង្គហើយផ្លាស់ប្តូរតាមការប្រែប្រួល (នៃអាកាសធាតុរលាយរបស់ទឹកកក) នៅភ្នំហិមាល័យ ។ ប៉ុន្តែវិសាលភាពនៃដីដែលមិនលិចទឹកហាក់បីដូចជាមិនប្រែប្រួលខ្លាំងនៅក្នុងសម័យប្រវត្តិសាស្ត្រទេ : វានៅជិតបឹងនេះហើយដែលគាត់ហៅថា "មាត់បឹង បុរាណវត្ថុវិទ្យា" ដែលលោក Groslier បានរកឃើញនូវការតាំងលំនៅសម័យបុរេ ប្រវត្តិសាស្ត្រមួយកន្លែង ។

ទីតាំងសំគាល់វត្ថុប្រវត្តិសាស្ត្រធម្មជាតិដទៃទៀត គឺកំពូលភ្នំភ្លើងសំខាន់បី ហើយទាំងពីនោះមានតែកំពូលទាំងនេះហើយដែលលេចផុតពីព្រៃ។ កំពូលភ្នំភ្លើងនីមួយៗ ទទួលបានប្រាសាទមួយនៅចុងសតវត្សទី៩ ហើយជាខាងក្រោយមកទៀតទទួលបានជីវិតសាសនាដ៏យូរអង្វែងដោយបន្តស្ទើរតែរហូតមកដល់សព្វថ្ងៃនេះ ។ ក្រៅពីភ្នំបាក់ខែងដែលមានសារៈសំខាន់ជាពិសេសដោយសារមានទីតាំងនៅចំកណ្តាលនោះនៅមានភ្នំក្រោមនៅខាងត្បូងព័ទ្ធជុំវិញដោយទឹកនៅពេលដែលបឹងទន្លេសាប ឡើងដល់កំពស់អតិបរិមា ។ ហើយនៅទិសឥសានមានភ្នំបុកដែលហាក់បីដូចជានៅដាច់ពីគេបន្តិចតែអាចមើលឃើញច្បាស់និងមានលក្ខណៈលេចធ្លោ ។

ភ្នំបាក់ខែងសមទទួលឈ្មោះថា ជាភ្នំកណ្តាលដែលជូនកាលគេដាក់ឈ្មោះនេះទៅអោយប្រាសាទដែលនៅលើកំពូលភ្នំនោះ ទោះបីជាទីក្រុងសំណាញ់ដែកបួនជ្រុងនេះត្រូវបានគេឃើញមានប្រាសាទនៅចំកណ្តាលមួយផ្នែកមុននេះ (របស់វា) បានប្រែក្លាយទៅជាដំណើរភ័ន្តគំនិតមួយក៏ដោយ[៥] ។ នៅក្នុងលក្ខណៈ "ធម្មជាតិ" របស់វាស្ទឹងសៀមរាបបានហូរកាត់ក្បែរទីនោះ ហើយរាជនីអង្គរវត្តជាប្រវត្តិសាស្ត្រត្រូវបានសាងសង់ឡើងស្ទើរតែនៅក្បែរជើងភ្នំបាក់ខែងតែម្តង ។

ភ្នំបាក់ខែងជាប្រគោលសំគាល់មួយនៃប្រវត្តិសាស្ត្ររបស់តំបន់អង្គរ : ការតាំងលំនៅសម័យបុរេប្រវត្តិសាស្ត្រគឺ ត្រូវបានគេរកឃើញនៅត្រើះស្ពានជើងភ្នំនេះ (បក្សីចាំក្រុងនៅទិសឥសាន) គឺជាប្រាសាទភ្នំដំបូង និងមានភាពសំាញ៉ាំដែលបានសង់ឡើងនៅតំបន់អង្គរនោះត្រូវបានធ្វើពិធីសម្ពោធនៅលើកំពូលនោះ ប្រហែលជាឆ្នាំ៩០០ (វាត្រូវបានគេប្រើជាគំរូយោងនៃវិទ្យាសាស្ត្រពីចំនួនមួយសម្រាប់



៣/ (ផែនទី) តំបន់អង្គរ និងប្រាង្គប្រាសាទដែលកត់សំគាល់នូវប្រវត្តិសាស្ត្ររបស់ខ្លួន ។

ប្រាសាទបាយ័ននៅក្នុងកំឡុងពេលនៃការស្ថាបនាទីក្រុងឡើងវិញដោយព្រះបាទជ័យវរ្ម័នទី៧ បន្ទាប់ពីការបំផ្លិចបំផ្លាញរបស់ពួកជនជាតិចាមនៅឆ្នាំ១១៧៧)[៦]។ ជាចុងក្រោយ គឺពុទ្ធបដិមាដ៏ធំមួយអង្គតាំងពីសតវត្សទី១៥ គង់នៅលើកំពូលភ្នំហើយតាមពិតទៅប្រាសាទនៅលើភ្នំនេះបង្កើតបានជាសញ្ញាមួយឃើញច្បាស់ជាងគេនៅក្នុងតំបន់។

ដើម្បីបញ្ចប់នូវការពិពណ៌នាត្រួសៗ ពីវត្ថុប្រវត្តិសាស្ត្រសំខាន់ៗ គេត្រូវនិយាយអំពីអាងស្តុកទឹកសិប្បនិម្មិត (ជលដ្ឋាន) ធំៗចំនួន៤ (បារាយណ៍) ដែលការសាងសង់និងការកែប្រែរបស់វា គឺជាផ្នែករួមមួយនៃប្រវត្តិសាស្ត្ររបស់វា។ នៅទិសអាគ្នេយ៍ ជលដ្ឋានបារាយណ៍លលៃ (ត្រូវបានបង្កើត និងកែប្រែនៅសតវត្សទី៩ ហើយទទួលបានទឹកពីស្ទឹងរលួស) នាពេលបច្ចុប្បន្ននេះត្រូវគ្របដណ្តប់ដោយវាលស្រែ ។ ចំណែកនៅទិសខាងកើត មានបារាយណ៍ខាងកើត (ស្ថាបនារវាងចុងសតវត្សទី៩ និងពាក់កណ្តាលសតវត្សទី១០ អាងស្តុកទឹកនៃស្ទឹងសៀមរាប) ហើយបានរីងស្ងួតអស់រយៈពេលជាយូរមកហើយ នៅទិសខាងលិចគឺមានបារាយណ៍ខាងលិច (សាងសង់នៅចុងសតវត្សទី១០-១១ ស្ទឹងសៀមរាប) នៅតែមានទឹកពេញជាងពាក់កណ្តាល ។ ជាចុងក្រោយនៅពេលថ្មីៗបំផុតគឺបារាយណ៍ព្រះខ័ន (សតវត្សទី១២-១៣ ស្ទឹងសៀមរាប) ដែលស្ថិតនៅលើខ្សែទឹកនៃបារាយណ៍ខាងលិច ដែលរីងស្ងួតអស់រយៈពេលជាយូរមកហើយដែរ[៧] ។

ប្រាសាទដែលអាចស្គាល់ភិនភាគច្បាស់ជាងគេដំបូងបំផុតដែលត្រូវបានស្ថាបនានៅលើតំបន់អង្គរស្ថិតនៅក្នុងទីតាំងមួយដែលយើងហៅថា ជាយក្រុងប៉ែកលិច (ខាងក្រោមនិងហួសពីខាងលើបារាយណ៍ខាងលិចនាពេលសព្វថ្ងៃ) ។ ដោយមានតាំងពីពាក់កណ្តាលទី២នៃសតវត្សទី៧ មកប្រាសាទទាំងនេះអាចជារាជធានីរបស់ព្រះបាទជ័យវរ្ម័នទី១ (ប្រហែលឆ្នាំ៦៥៧-៦៩០) ដែលធ្វើអោយវាក្លាយជារាជធានីទីមួយដែលត្រូវបានបង្កើតឡើងនៅក្នុងតំបន់នេះ (អង្គរ) ។ ក្រៅពីប្រាសាទតូចៗ ខ្លះ ដូចជាប្រាសាទព្រៃក្មេងយើងអាចចាត់ទុករយៈពេលនេះថា ជារយៈពេលចាប់ផ្តើមដំបូងនូវរូបរាងនៃប្រាសាទអកយំ ជាប្រាសាទភ្នំមុនគេដែលត្រូវបានកសាងភាគច្រើននៅក្នុងសតវត្សទី៨ ហើយបានបាត់បង់នៅដើមសតវត្សទី១១ នៅក្រោមទំនប់ខាងត្បូងនៃបារ៉ាយខាងលិច ។ រយៈពេលដដែលនេះថែមទៀតគេឃើញមានការរៀបចំស្ថាបនាកែប្រែមួយចំនួននៅរលួស (នៅប៉ែកអាគ្នេយ៍នៃតំបន់ប្រាសាទរលួស) តែនៅទីនោះទៀត សតវត្សទី៨ គឺជារយៈពេលដែលប្រាសាទសំខាន់ៗ ដំបូងបានលេចឡើងជាពិសេសនៅផ្នែកមួយចំនួននៃក្រុមប្រាសាទត្រពាំងផុង ។ ចុងសតវត្សទី៨ ក៏ប្រហែលជាពេលដែលប្រាសាទដំបូងៗ ត្រូវបានកសាងនៅក្នុងតំបន់អង្គរភាគកណ្តាល ជាអាទិ៍មានប្រាសាទភិមានអាកាសជាប្រាសាទភ្នំដែលមានប្រវត្តិសាស្ត្រសាំញ៉ាំ ហើយប្រាសាទនេះយ៉ាងយូរបំផុតត្រឹម ដើមសតវត្សទី១១ បានក្លាយទៅជាសមាសធាតុចម្បងនៃព្រះបរមរាជវាំង ។ ដោយកំណត់ថា ប្រាសាទដ៏មានសារៈសំខាន់នេះមានតាំង ពីសតវត្សទី៨ បង្ហាញប្រាប់យើងអំពីវត្តមានតាំងតែពេលនោះនៃក្រុមស្នូលសំខាន់មួយក្នុងកំណើតនៃប្រជាជនស្នូលនៅពេលនោះ និងទីប្រជុំអំណាចមួយនៅក្នុងតំបន់មួយដែលរហូតមកទល់ពេលថ្មីៗ នេះត្រូវបានគេជឿថាមានមនុស្សរស់នៅចាប់តាំងពីរជ្ជកាលព្រះបាទសុរិយវរ្ម័នទី១ តែប៉ុណ្ណោះ (ប្រហែលឆ្នាំ៨៨៩-៩១០) គឺនៅពេលឆ្លងចេញពី សតវត្សទី៩ ចូលទៅសតវត្សទី១០ ។

យើងដឹងថា ដើមសតវត្សទី៩ បានកត់សំគាល់នូវការផ្លាស់ប្តូរអភិវឌ្ឍន៍មួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដោយមានការចាក់គ្រឹះ នៅក្នុងឆ្នាំ៨០២ របស់ព្រះបាទជ័យវរ្ម័នទី២ (ប្រហែលឆ្នាំ៨០០-៨៥០) នៃអ្វីដែលគេស្គាល់ថាជា " រាជានិយមសម័យអង្គរ " ដែលមានលក្ខណៈជាការគោរពលទ្ធិទេវរាជ (អាទិទេពនៃដែនដីរបស់ព្រះរាជាណាចក្រ) ការគោរពនេះត្រូវបានប្រារព្ធឡើងនៅក្នុងបរិវេណនៃប្រាសាទភ្នំបែបនេះ ដែលការកសាងនៃប្រាសាទប្រភេទនេះ គឺជាការបង្ហាញនៃការឡើងគ្រោងរាជ្យដ៏អស្ចារ្យរហូតដល់សតវត្ស ទី១៣ ។ រាជានិយមទទួលបានឈ្មោះនេះដោយសារតែប្រការដែលថា ប្រាសាទជារាជធានីរបស់ខ្លួនរហូតដល់ក្រុមរាជវង្សានុវង្សបានបោះបង់ចោលទីក្រុងនេះនៅឆ្នាំ១៤៣១ វៀរលែងតែរយៈពេលមួយដ៏ខ្លីនៅក្នុងសតវត្សទី៩។

រហូតដល់ចុងសតវត្សទី៩ ការសាងសង់នៅផ្តោតទៅលើផ្នែកភូមិភាគរលួស ។ បន្តិចក្រោយមកព្រះបាទជ័យវរ្ម័នទី២ បានផ្លាស់រាជធានីរបស់ព្រះអង្គពីទីនោះ គឺពីភ្នំគូលេនជាទីដែលព្រះអង្គបានកសាងប្រាសាទសំខាន់ៗ មួយចំនួនហើយនៅកន្លែងនោះហើយដែល

ប្រវត្តិនៃតំបន់អង្គរ

ដោយ ប្រ៊ុយណូ ដាហ្សង់ Bruno Dagens

៤/ ប្រាសាទប្រែរូប កសាងឡើងនៅពាក់កណ្ដាលទីពីរនៃសតវត្សទី១០ ស្ថិតនៅចំងាយ ៥០០ម៉ែត្រ ពីទំនប់ខាងត្បូងនៃបារាយណ៍ខាងលិច ។

មហាក្សត្រអង្គរជាច្រើនបានមកតាំងមូលដ្ឋានជាបន្តបន្ទាប់[៨] ។ ចំណែករាជធានីថ្មីឈ្មោះថា ហរិហរាល័យ ត្រូវបានបង្កើតឡើងបន្ទាប់ពីព្រះបាទជ័យវរ្ម័នទី២ ដោយបុត្រារបស់ព្រះអង្គ (ជ័យវរ្ម័នទី៣ ឆ្នាំ៨៥០-៨៧៧) និងក្មួយរបស់ព្រះអង្គ (ឥន្ទ្រវរ្ម័នទី១ នៅឆ្នាំ៨៧៧-៨៨៩) ដែលទាមទារការសរសើរចំពោះអាងស្តុកទឹក (ជលដ្ឋាន) បារាយណ៍លលៃ (ដែលព្រះអង្គគ្រាន់តែបានកែប្រែប៉ណ្ណោះ) និងប្រាសាទនៅលើភ្នំបាគងដែលព្រះអង្គបានកសាងបង្ហើយ ។ម្យ៉ាងទៀត យើងត្រូវដឹងគុណព្រះអង្គផងដែរចំពោះការកសាងប្រាសាទព្រះគោ (ឧទ្ទិសចំពោះ ព្រះអយ្យកានិងព្រះអយ្យកោរបស់ព្រះអង្គ) ហើយប្រហែលព្រះអង្គ ជាអ្នកធ្វើការសំរេចព្រះទ័យផ្ដើមផ្លាស់រាជធានិទៅប្រថាប់នៅត្រង់ចំណុចកណ្ដាលតំបន់អង្គរ ដោយផ្ដើមសាងសង់ប្រាសាទភ្នំបាខែង និងជីកបារាយណ៍ខាងកើតផង ។ ការផ្លាស់ប្ដូរទីតាំងត្រូវបានបញ្ចប់នៅក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ ដែលបានយកព្រះនាមរបស់ព្រះអង្គ ដាក់ឈ្មោះអោយរាជធានីថ្មីរបស់ព្រះអង្គថា យសោធរបុរៈ (Yashoddharapura) ហើយការផ្លាស់ទីតាំងនេះទំនងជាត្រូវបាន ជំរុញឡើងដោយសេចក្ដីត្រូវការដើម្បីទូទាត់នូវភាពមិនគ្រប់គ្រាន់របស់បារាយណ៍លលៃដោយការបង្កើតអោយមានអាងស្តុកទឹកថ្មីមួយ ដែលទីក្រុងព្រះអង្គត្រូវបានខិតទៅកាន់តែជិត ។ ការផ្លាស់ប្ដូរទីតាំងកាន់អំណោចមិនអែនមានន័យថា ទីក្រុងហរិហរាល័យត្រូវបានបោះបង់ចោលនោះទេ ។ ប្រាសាទរបស់ទីក្រុងនេះត្រូវបានផ្ដល់នូវរូបចម្លាក់ អំណោយ និងការស្ថាបនាសំខាន់ៗ (ប្រាសាទបាគង) រហូតដល់ចុងសម័យអង្គរ ។ ព្រះបាទយសោវរ្ម័នទ្រង់បានកសាងប្រាសាទមួយ ដើម្បីឧទ្ទិសចំពោះព្រះអយ្យកោព្រះអយ្យកាបុព្វការីជនរបស់ព្រះអង្គ នៅលើកោះសិប្បនិម្មិតមួយនៅចំកណ្ដាលបារាយណ៍លលៃដែលព្រះអង្គបានកែច្នៃដើម្បីធ្វើឱ្យប្រសើរដល់ការសម្រេចបានលទ្ធផលវា ។ ព្រះអង្គក៏ត្រាស់បង្គាប់អោយមានការស្ថាបនានៅឯប្រាសាទព្រះគោផងដែរ ។ នៅក្នុងក្រុងយសោធរបុរៈ (Yashoddharapura) ជាឈ្មោះដែលអង្គរបានប្រើរហូតដល់ពេលដែលវាត្រូវបានបោះបង់ចោល ព្រះអង្គបានបញ្ចប់ការស្ថាបនាប្រាសាទភ្នំបាខែង (រួមជាមួយនឹងប្រាសាទតូចៗនៅជុំវិញជើងភ្នំ) និងបារាយណ៍ខាងកើត (ដែលត្រូវបានកែតំរូវជាច្រើនលើករវាងពេលនោះ និងពាក់កណ្ដាលសតវត្ស ទី១០) ។ ជលដ្ឋានបារាយណ៍បានធ្វើអោយមានការផ្លាស់ប្ដូរដល់វិសាលភាពតំបន់អង្គរយ៉ាងច្រើននៅពេលដែលស្ទឹងសៀមរាបត្រូវបានបង្វែរចរន្តទឹកឱ្យហូរឆ្ពោះទៅទិសខាងលិចវិញ ហើយស្ទឹងនេះហូរឆ្ពោះទៅទិសនិរតីដើមវិញនៅខាងចុងបារាយណ៍ (ស្ទឹងនេះត្រូវបានកែតំរូវម្ដងទៀតនៅក្នុងសតវត្សទី១២ សូមមើលខាងក្រោម) ។ លើសពីនេះទៀតបារាយណ៍ថ្មីហាក់បីដូច ជាទន្ទ្រានទៅលើការរាបចំសាងសង់កែតម្រូវពីដំបូង[៩] ។ ការងារដ៏ធំធេងជាច្រើនដែលព្រះបាទយសោវរ្ម័នបានទទួលធ្វើ មិនបានបញ្ចប់នៅកន្លែងនោះទេ ។

ប្រវត្តិ និង សង្គម

ព្រះអង្គបានស្ថាបនាស្ថាប័នសាសនានៅតាមមាត់ជលដ្ឋានបារាយណ៍ ដែលស្ថាប័នសាសនានីមួយៗ ធ្វើឡើងដើម្បីឧទ្ទិសដល់ការគោរពដំចម្បងនូវជីវិតសាសនារបស់ជនជាតិខ្មែរ ដែលនៅពេលនោះអ្នកគោរពព្រះសិវៈ (Shivaiste) អ្នកគោរពព្រះវិស្ណុ (Vishnuite) និងអ្នកកាន់សាសនាព្រះពុទ្ធ (Bouddhiste) មានបទបញ្ញាស្រដៀងគ្នា[10] ។ នៅចំកណ្ដាលជលដ្ឋានបារាយណ៍តែមួយនោះ ព្រះអង្គបានសាងសង់ប្រាសាទមួយមានរូបរាងដំបូងបង្អស់ដែលត្រូវបានគេស្គាល់ថា ប្រាសាទមេបុណ្យខាងកើត ។ ដូចជាព្រះបិតារបស់ព្រះអង្គដែរដែលបានកសាងប្រាសាទបីនៅលើកំពូលភ្នំក្រោម ព្រះអង្គបានសាងសង់នូវប្រាសាទស្រដៀងគ្នាមួយនៅលើភ្នំបុក គឺជាភ្នំក្រោយគេបង្អស់នៅក្នុងចំណោមភ្នំទាំងបីដែលកត់សំគាល់តំបន់ប្រាសាទអង្គរតាមដែលយើងបានឃើញមក ។ ជាចុងក្រោយរាជធានីថ្មីនេះ ប្រាដកជាមានរាជវាំងនៅទីនោះមែន ប៉ុន្តែទីតាំងពិតប្រាកដរបស់វាំងនេះពុំមានភាពច្បាស់លាស់គ្រប់គ្រាន់ដែលនិយាយនៅទីនេះ ។

ពាក់កណ្ដាលដំបូងនៃសតវត្សទី១០ គឺចាប់ពីការសោយទីវង្គតរបស់ព្រះបាទយសោវរ្ម័ន (ប្រហែលឆ្នាំ ៩០០) រហូតដល់រជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (ឆ្នាំ៩៤៤-៩៦៨) បានជួបប្រទះការផ្អាកការងារអភិវឌ្ឍន៍តំបន់អង្គរ ដែលត្រូវបានបោះបង់ចោលដោយក្រុមរាជវង្សានុវង្សប្រហែល២០ឆ្នាំ (ប្រហែល៩២៥-៩៤០) ដើម្បីជួយសាងសង់កោះកេរដែលជារាជធានីបណ្ដោះអាសន្នដែលត្រូវបានសាងឡើងនៅចំងាយប្រហែល៨០ គីឡូម៉ែត្រភាគឥសានអង្គរ ។ ក្រៅពីការកែតំរូវចំពោះជលដ្ឋានបារាយណ៍ខាងកើត ការអភិវឌ្ឍន៍ដែលអាចមើលដឹងបានរួមមានវិហារវិស្ណុនៃប្រាសាទក្រវ៉ាញ (កសាងចប់នៅប្រហែលឆ្នាំ៩២១) ហើយប្រាសាទបក្សីចាំក្រុងដែលត្រូវបានសាងសង់ចប់នៅរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ហើយទំនងជារចនាបទប្រាសាទដំបូង (បែបសាសនាព្រាហ្មណ៍) នៃប្រាសាទបាទជុំដែលបានក្លាយជាវិហារព្រះពុទ្ធសាសនាក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ។

ការយាងនិវត្តចូលមកកាន់កាប់អំណាចនៅអង្គរវិញ ក្នុងពេលដែលព្រះបាទរាជេន្ទ្រវរ្ម័នបានឡើងសោយរាជ្យ គឺជាសញ្ញាសម្រាប់ការផ្លាស់ប្ដូរថ្មីចំពោះស្ថានភាពនៅអង្គរ ។ ដោយលើកពេលនៅប្រាសាទកោះកេរ ព្រះរាជាឡើងគ្រងរាជ្យថ្មីបានទទួលនូវកេរតំណែលចាស់ : ព្រះអង្គត្រូវសាងសង់បង្ហើយប្រាសាទមួយចំនួន (បក្សីចាំក្រុង) ហើយសំខាន់បំផុតនោះ ព្រះអង្គត្រូវយាងត្រឡប់ចូលបារាយណ៍ខាងកើតវិញ ដែលនៅទីនោះព្រះអង្គបានលើកទំនប់ឱ្យកាន់តែខ្ពស់ដែលតំរូវអោយព្រះអង្គសាងសង់ឡើងវិញនូវប្រាសាទមេបុណ្យរបស់ព្រះបាទយសោវរ្ម័ន ដោយធ្វើវាឱ្យកាន់តែខ្ពស់ថែមទៀត ។ បន្ទាប់មកព្រះអង្គបានសាងសង់ប្រាសាទភ្នំខ្លួនរបស់ព្រះអង្គផ្ទាល់ គឺប្រាសាទប្រែរូប ដែលនៅទន្ទឹមគ្នានឹងប្រាសាទមេបុណ្យ នៅផ្នែកខាងត្បូងបារាយណ៍ (ហើយប្រហែលជាអាចនិយាយបានថា រាជវាំងត្រូវផ្លាស់ទៅផ្នែកនេះដែរ) ។ ការងារមួយទៀតដែលត្រូវបានធ្វើនៅក្នុងរជ្ជកាលរបស់ព្រះអង្គរួមមានការសាងសង់ស្រះស្រង់ជាអាងស្តុកទឹកដែលតូចជាងបារាយណ៍ ប៉ុន្តែ ដែលទំនងជាបានចូលរួមយ៉ាងច្រើននៅក្នុងប្រព័ន្ធធារាសាស្ត្ររបស់ទីក្រុង ហើយចុងក្រោយទោះបីជាវាស្ថិតនៅប៉ែកឥសាននៃតំបន់កណ្ដាលក៏ដោយក៏ប្រាសាទបន្ទាយស្រីដែលស្ថាបនាដោយព្រាហ្មណ៍ម្នាក់ក្នុងចំណោមរាជអាមាត្យរបស់ព្រះអង្គគួរតែលើកយកមកបង្ហាញ ។

ការងារសាងសង់សំខាន់ៗមួយចំនួន ដែលជានិច្ចជាកាលយើងមិនអាចកំណត់កាលបរិច្ឆេទច្បាស់លាស់នោះ បានប្រព្រឹត្តិទៅជាបន្តបន្ទាប់នៅតំបន់អង្គរនៅចុងសតវត្សទី១០ នៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (ប្រហែលឆ្នាំ៩៦៨-១០០០) ។ ការងារសាងសង់បានចាប់ផ្ដើមនៅប្រាសាទភ្នំឈ្មោះ ប្រាសាទតាកែវ (នៅជិតត្រើយម្ខាងនៃបារាយណ៍) ប៉ុន្តែការងារនេះត្រូវបានផ្អាកបន្ទាប់ពីប្រាសាទនេះត្រូវរន្ទះបាញ់ ហើយការងារសាងសង់បានចាប់បន្តជាថ្មី នៅដើមសតវត្សទី១១ ដោយមិនដែលបានធ្វើចប់សព្វគ្រប់ឡើយ ។ លើសពីនេះទៀតការងារសាងសង់ក៏បានចាប់ផ្ដើមផងដែរ នៅបារាយណ៍ខាងលិចដែលទំហំនៃជលដ្ឋាននេះមិនដែលធ្លាប់មានពីមុនមកទេ។ អាងស្តុកទឹកនេះត្រូវបានរៀបចំដំបូងគេហើយ បន្ទាប់មកត្រូវបានកែប្រែជាច្រើនលើកច្រើនសាក្នុងកំឡុងសតវត្ស ទី១១ និង ប្រហែលជានៅក្នុងសតវត្សទី១៣ និង១៤ (មុនពេលដែលមានការកែប្រែយ៉ាងច្រើនទៀតនៅសតវត្សទី ២០) ។ ការសាងសង់នោះបានប៉ះពាល់ដល់ប្រាសាទដទៃទៀតដែលបានសាងសង់រួចមកហើយ : ដូចជាប្រាសាទអកយំ (សូមមើលខាងលើ) ត្រូវបានរក្សាទុកខ្លះពីដំបូង ប៉ុន្តែលុះក្រោយមកក៏ត្រូវបានបាត់បង់អស់ទាំងស្រុង នៅក្រោមទំនប់ខាងត្បូង និងប្រាសាទដទៃជាច្រើនទៀត ដែលមិនសូវសំខាន់ក៏ត្រូវបានបាត់បង់ផងដែរ ។

សតវត្សទី១១ គឺនៅពេលដែលការងារចេះតែបន្តធ្វើនៅបារាយណ៍ខាងលិច ដែលមានបដិមាលទ្ធិសិវៈរង្វាស់កំពស់ទឹក (Shivaite) ពីដំបូងក្លាយជាបដិមាលទ្ធិវិស្ណុ ហើយនិងចាប់ធ្វើប្រាសាទតាកែវបន្តទៅទៀតនោះ គឺត្រូវបានកត់សំគាល់បានកាន់តែច្បាស់ដោយការរៀបចំសាងសង់អ្វីដែលនៅពេលនោះបានក្លាយជា (ប្រសិទបើវា

ប្រវត្តិនៃតំបន់អង្គរ

ដោយ ប្រ៊ុយណូ ដាហ្សង់ Bruno Dagens

មិនមែនត្រូវដូច្នោះទេរួចទៅហើយ) ទីតាំងនយោបាយ ដ៏សំខាន់អង្គរ។ ព្រះបាទសុរិយវរ្ម័នទី១ (Suryavarman ១០០២ - ១០៥០) បានសាងសង់កំផែងថ្មមួយព័ទ្ធជុំវិញប្រាសាទភិមានអាកាស (ដែលត្រូវបានកែតំរូវពីនៅពេលនោះ រឺមុននោះបន្តិច) ដោយកំណត់ព្រំដែននៃព្រះបរមរាជវាំង ។ ព្រះបរមរាជវាំងដែលមានអាគារធ្វើពីឈើ និងប្រក់ក្បឿងប្រហែលជាត្រូវតាំងនៅទីនោះរួចជាស្រេច យើងមិនបានដឹងទេ ។ ផ្ទុយទៅវិញយើងដឹងប្រាកដថា ព្រះបរមរាជវាំងនោះមិនត្រូវបានផ្លាស់ពីទីនោះទេ រហូតទាល់តែអង្គរត្រូវបានបោះបង់ចោល ។ នៅពេលជាមួយគ្នានោះដែរ ទីធ្លាខាងមុខព្រះបរមរាជវាំងត្រូវបានគេបង្កើតឡើង ។ ផ្លូវបរមរាជវាំងមួយត្រូវបានគេបិទនៅទិសខាងកើត ដោយអាគារទាំងឡាយដែលស្ថិតនៅស្របគ្នាដែលបានធ្វើវាអោយទៅជាចំណុចចាប់ផ្តើមនៃអ័ក្សផ្តេកមួយនាំឆ្ពោះទៅទិសខាងកើតអង្គរហើយកំណត់យកទេសភាពនៃរាជធានីដែរ ដែលបានក្លាយជាប្រាសាទប្រវត្តិសាស្ត្រមួយរបស់រាជធានី[11] ។ ព្រះបាទឧទ័យាទិត្យវរ្ម័នទី២ (Udayādityavarman II) (១០៥០-១០៦៦) បានចាប់ផ្តើមការងារសាងសង់បន្តពីព្រះបិតារបស់ព្រះអង្គ គឺព្រះបាទសុរិយវរ្ម័ន ទី១ (Suryavarman I) ហើយភ្លាមបានចាប់ផ្តើមសាងសង់ប្រាសាទភ្នំរបស់ព្រះអង្គ គឺប្រាសាទបាពួន នៅចំខាងត្បូងព្រះបរមរាជវាំង និង នៅលើអ័ក្សផ្តេកពីជើងទៅត្បូងដោយភ្ជាប់ប្រាសាទភិមានអាកាស ទៅភ្នំបាក់ខែង : ទោះបីជាស្ថិតនៅក្នុងកន្លែងមួយដែលមានទីធ្លាចង្អៀត និងមានលក្ខណៈសាមញ្ញចំពោះទិដ្ឋភាពមួយចំនួនក៏ដោយ ប្រាសាទនេះជាសញ្ញានៃការបន្តធ្វើគំរូបែបនេះដ៏សំខាន់មួយ ។ ចុងក្រោយ វាហាក់បីដូចជាទីស្ថានកប់ខ្មោចដ៏ធំមួយដែល Groslier និងលោក Courbin បានគាស់កកាយឃើញនៅខាងជើងស្រះស្រងនោះ បានត្រូវប្រើប្រាស់នៅពាក់កណ្តាលទី២ នៃសតវត្សទី១១។

មានគម្រោងការងារសំខាន់ពីរ នៅក្នុងរជ្ជកាលរបស់ព្រះបាទសុរិយវរ្ម័នទី២ (Suryavarman II) (ប្រហែលឆ្នាំ១១១៣-១១៤៥) រហូតទៅដល់ការបណ្តេញចេញពីអង្គរដោយពួកចាមនៅក្នុងឆ្នាំ១១៧៧ : គម្រោងមួយ គឺជាគម្រោងការងារបង្កើតទីតាំងសាសនាសំខាន់ថ្មីមួយដោយមានមាត្រដ្ឋានធំធេងដែលគេមិនដែលឮរហូតមកដល់ពេលនេះហើយគម្រោងការងារមួយទៀត គឺដាក់អ័ក្សផ្តេកចេញពីផ្នែកខាងកើត នៃព្រះបរមរាជវាំងនៅក្នុងទីតាំងដ៏លេចធ្លោមួយ ដែលតាមយើងដឹងបានចេញជារូបរាងនៅក្នុងសតវត្សទី១១ ។ ទំហំរបស់វាធ្វើអោយអង្គរវត្តក្លាយជាការរៀបចំសាងសង់ដូចនៅនគររូបនិយកម្មផងអភិវឌ្ឍន៍មួយស្ថាប័ត្យកម្មវត្តដូចឈ្មោះដែលវាទទួលបានក្រោយសម័យអង្គរបញ្ជាក់ប្រាប់យើង :"វត្តដែលជាទីក្រុងមួយ" ។ ទីតាំងនាំអោយផ្លូវបាតស៊្មីងរបស់វាមានការផ្លាស់ទីតាំងថ្មីមួយ (នៃបាតស៊្មីង) និងនាំអោយបានការអាក់ខានដទៃទៀតដែលយើងមិនដឹងទាល់តែសោះ។ វាបែរមុខទៅទិសខាងលិចប៉ុន្តែយើងមិនដឹងថាតើការតម្រង់ទិសដៅថ្មី គឺដោយសារការឧទ្ទិសចំពោះព្រះវិស្ណុ រឺក៏ដោយសារឧបសគ្គផ្សេងៗ នៃ របៀបរៀបចំក្រុងដែលគេបានដាក់បញ្ចូលទីជម្រកថ្មីនោះមកផង ឬយ៉ាងណាទេ។ កន្លែងទំនេរដ៏ធំនៃបរិវេណទី៤របស់វា (ហ៊ុំព័ទ្ធដោយគូដ៏ធំ) ប្រហែលជាទាក់ទងទៅនឹងតំបន់រស់នៅអាចជាព្រះសង្ឃគង់នៅទីនោះ (ដូចនឹងករណីមុនឆ្នាំ១៩៧៥) ប៉ុន្តែប្រហែលជាមាន ប្រជាជនធម្មតារស់នៅទីនោះផងដែរ សូមមើលខាងក្រោមទាក់ទងនឹងប្រាសាទអង្គរធំរបស់ព្រះបាទជ័យវរ្ម័នទី៧។ ដើម្បីធ្វើអោយកាន់តែល្អដល់ការតំរៀបប្រាសាទជាជួរនៅខាងកើតព្រះបរមរាជវាំងព្រះបាទសុរិយវរ្ម័នទី២ (Suryavarman II) រឺអ្នកស្នងរាជ្យ បន្ទាប់ពីព្រះអង្គបានកសាងប្រាសាទធម្មនន្ទ (Thommanon) នៅខាងជើងនៃខ្សែបន្ទាត់នេះ ដោយបន្ទាប់មកមានប្រាសាទដូចគ្នា ឈ្មោះចៅសាយទេវតានៅខាងត្បូងបន្ទាប់មកទៀតមានប្រាសាទបន្ទាយសំរែនៅខាងកើត និងចុងក្រោយ គឺប្រាសាទដទៃទៀតកំណត់អោយដាក់ចន្លោះគ្នានៅតាមបណ្តោយផ្លូវលំ (បន្ទាប់ពីពេលនោះមកជាផ្លូវ) ដែលនាំឆ្ពោះទៅរកប្រាសាទព្រះខ័នកំពង់ស្វាយដែលមានចំងាយប្រហែល ១០០ គីឡូម៉ែត្រពីអង្គរ ។ ហេតុដូចនេះដំណើរការមួយបានចាប់ផ្តើម ដោយដែនដីរបស់រាជធានីបានបន្ថែមលើដែនដីរបស់ព្រះរាជាណាចក្រ ។ ច្រើនឆ្នាំក្រោយមក ព្រះបាទជ័យវរ្ម័នទី២ បានសាងសង់សាលាឆទាន និងមន្ទីរពេទ្យពាសពេញអាណាចក្ររបស់ព្រះអង្គដោយបានចាប់ផ្តើមពីដំបូងចេញប្រាសាទអង្គរពីរដ៏ល្បីដែលធានាការគ្រប់គ្រងសមិទ្ធផលទាំងនេះ នៅក្នុងខណៈដែលព្រះអង្គបានធ្វើប្រាសាទភ្នំរបស់ព្រះអង្គជាផែនទីដ៏ប្រកបដោយភាពអាថ៌កំបាំង នៃព្រះរាជាណាចក្ររបស់ព្រះអង្គ។

ការឈ្លានពានរបស់ពួកជនជាតិចាមនៅក្នុងឆ្នាំ១១៧៧ បាននាំមកនូវការរៀបចំជាថ្មីនៃតំបន់រាជធានី ដោយរួមគ្នាជាមួយតំបន់នៃរាជាណាចក្រទាំងមូល ។ ការរៀបចំឡើងវិញនៃរាជធានីដែលជាអ្វីធ្វើឱ្យយើងមានការព្រួយបារម្ភនៅទីនេះ គឺមានភាពស្មុគស្មាញ ។ យើងនឹងកំរិតខ្លួនយើងឱ្យនៅត្រឹមតែការពិពណ៌នាពីទិដ្ឋភាពផ្សេងៗរបស់វាដោយមិនយកមកពិចារណានូវពេលវេលានៅក្នុងការគ្រងរាជដ៏យូរ អង្វែងរបស់ព្រះបាទជ័យវរ្ម័នទី៧ (ប្រហែលជាឆ្នាំ១១៨១-១២១៨) ដែលបានសាងសង់ទីក្រុងនៅលើតំបន់អង្គរ ។

ប្រវត្តិ និង សង្គម



៥/ ប្រាសាទបាពួន កសាងឡើងនៅពាក់កណ្តាលសតវត្សទី១១ ។ ការជួសជុលឡើងវិញនៃប្រាសាទភ្នំ ដែលមានទំហំធំគួរអោយកត់សំគាល់នេះ គឺត្រូវបានធ្វើឡើងដោយសាលាបារាំងចុងបូព៌ា (EFEO) ។

ដោយយាងត្រឡប់មកប្រាសាទអង្គរវត្ត និង ដោយពង្រីកនូវគំរោងទូទៅរបស់ព្រះអង្គ ព្រះអង្គបានព័ទ្ធជុំវិញប្រាសាទភ្នំរបស់ព្រះអង្គ គឺប្រាសាទបាយ័នដ៏ល្បីល្បាញដោយបរិវេណការពាររឹងមាំព័ទ្ធពីក្រៅដោយគូ និងមានប្រវែង៣ គីឡូម៉ែត្រតាមបណ្តោយមាត់គូនោះ ហើយសព្វថ្ងៃយើងហៅវាថា ជាប្រាសាទអង្គរធំ (អង្គរធំ រឺក្រុងធំ) : អង្គរមានន័យថា (ក្រុង) ។ ការសាងសង់បរិវេណគំរូវអោយមាន (ហើយប្រហែល ជាចុងក្រោយ) ការផ្លាស់ប្តូរទីតាំងបាតស្ទឹង ។ កន្លែងដ៏ធំទូលាយ ដែលត្រូវបានគេកំណត់នេះ បានផ្តល់ទីលំនៅដល់ប្រជាជនយ៉ាងច្រើន គួរសម ១៣ ប៉ុន្តែវាក៏បានព័ទ្ធជុំវិញក្រុមសំណង់សំខាន់ៗ ដែលមានសំណង់រៀបចំអភិវឌ្ឍន៍កាលពីដំបូងផងដែរ : សំខាន់ដូចជាបរមរាជវាំង និង ប្រាសាទភិមានអាកាស ទីលាន ឬ ទីធ្លាផ្លូវចូលព្រះបរមរាជវាំង និងប្រាសាទបាពួន ។ ពីខាងផ្លូវនិងប្រាសាទទាំងអស់នេះត្រូវបានបញ្ចូលយ៉ាងសមរម្យទៅក្នុងបរិវេណថ្មីនោះតាមរយៈ ការរៀបចំរចនាសម្ព័ន្ធថ្មីនៅក្នុងព្រះបរមរាជវាំង (ជលសីមា និង សំណង់ដទៃទៀត) ការរៀបចំសាងសង់អភិវឌ្ឍន៍ឡើងវិញនៃទីលានផ្លូវចូលព្រះបរមរាជវាំង (ការសាងសង់ទីលានជល់ដំរី និងប្រាសាទសួព្រ័តចំនួន ១០ទៀត) រឺការដាក់ច្រកទ្វារបន្ថែមនៅផ្នែកខាងកើតបរិវេណ ស្ថិតនៅត្រង់ជួរជាមួយគ្នានឹង ព្រះបរមរាជវាំង ។ ទីក្រុងដែលមានកំផែងព័ទ្ធជុំវិញនេះតំណាងឱ្យខ្លឹមសារជានិមិត្តរូបដ៏អស្ចារ្យដោយស៊ីគ្នាជាមួយនឹង ភាពជានិមិត្តរូបនៃប្រាសាទភ្នំនៅចំកណ្តាលបេះដូងរបស់វា ប៉ុន្តែការរៀបចំឡើងវិញក៏ទាក់ទងនឹងផ្នែកខាងក្រៅរបស់អង្គរធំផងដែរ ។ ប្រាសាទទាំងអស់ត្រូវបានសាងសង់តាមផ្នែកខាងក្រៅកំផែង ដែលប្រាសាទសំខាន់ជាងគេគឺប្រាសាទព្រះខ័នត្រូវបានសាងសង់នៅខាងជើងនៅលើតំបន់ជ័យជំនះលើពួកជនជាតិចាម ។ សំណង់បន្ថែមជាច្រើនទៀតរបស់ប្រាសាទព្រះខ័នរួមមានបារាយណ៍ ចុងក្រោយដែលត្រូវបានសាងសង់នៅអង្គរ : ប្រាសាទនៅចំកណ្តាល (នាគព័ន្ធ) ដែលធ្លាប់តែជាទីឡូម៉ែត្រមួយ និងរូបភាពលោកធាតុមួយ នោះទទួលរងនូវការផ្លាស់ប្តូរមួយចំនួនជាពិសេសដោយសារតែការបំបិតឆាប់ពេកស្ទះជលដ្ឋាន (ដំបូង) ។ ទៅផ្នែកខាងត្បូងបន្តិចមានប្រាសាទប្រាសាទ ២ក្រុមដែលមិនសូវជាសំខាន់ប៉ុន្មានទេតែពួកវា ក៏ជាប្រាសាទដែលគួរឱ្យចាប់អារម្មណ៍ផងដែរ គឺប្រាសាទតាព្រហ្មនិង ប្រាសាទបន្ទាយក្តីដែលស្ថិតនៅទល់មុខស្រះស្រង់ដែលត្រូវបានកែប្រែគំរូវតាមកាលៈទេសៈនៅពេលនោះ ។ កំផែងដ៏ធំព័ទ្ធជុំវិញសរណដ្ឋានទាំងនេះក៏ត្រូវបានយកគំរូតាមប្រាសាទអង្គរវត្តដែរ និងប្រើសំរាប់កំណត់ខ័ណ្ឌសីមានៃកន្លែងរស់នៅដែលស្ថិតនៅក្នុងការការពារដឹកនាំប្រាសាទ ។ ការកែប្រែដែលព្រះបាទជ័យវរ្ម័នបានធ្វើឡើងចំពោះ ទីក្រុងនោះមានមន្ទីរពេទ្យចំនួន ៤ គួរឱ្យកត់សំគាល់ដែលបិតនៅតាម អ័ក្សប្រហាក់ប្រហែលជានៅស្របគ្នាជាមួយនឹងច្រកទ្វារចូលទាំងបួន៤ របស់អង្គរធំ ។ ប៉ុន្តែព្រះអង្គបានកែប្រែតំបន់អង្គរទាំងមូល : នៅក្នុងពេលដែលព្រះអង្គបានសាងសង់សំណង់ថ្មីៗជាច្រើនទៀត ព្រះអង្គក៏បានសង់ប្រាសាទបន្ថែមទៀតផងដែរ នៅក្នុងតំបន់កណ្តាលផងនៅរលួសផង ។

ចាប់តាំងពីការចូលទីវង្គតរបស់ព្រះបាទជ័យវរ្ម័នទី៧ រហូតមកដល់ការបោះបង់ក្រុងអង្គរដោយក្រុមរាជវង្សានុវង្សនៅក្នុង ឆ្នាំ១៤៣១ តំបន់នោះបានប្រែប្រួលជាបន្តបន្ទាប់ទៅតាមកាលៈទេសៈនៃលក្ខ័ណ្ឌនយោបាយ និង សាសនាថ្មី ។ អាសនៈនៃអំណាចនយោបាយមិនផ្លាស់ប្តូរទេ គឺវាស្ថិតនៅក្រោមការដឹកនាំរបស់ព្រះបរមរាជវាំងដូចដែលត្រូវបានបញ្ជាក់ដោយ លោកជីវ តាក្វាន់ (Zhou Daguan)

ប្រវត្តិនៃតំបន់អង្គរ

ដោយ ប្រ៊ុយណូ ដាហ្សង់ Bruno Dagens

ប៉ុន្តែសភាពចុះខ្សោយរបស់វា គឺត្រូវបានបង្ហាញច្បាស់ដោយការបញ្ឈប់ការងារសាងសង់សំខាន់ៗ : ពីទីនេះតទៅ មានភាពគ្រប់គ្រាន់ក្នុងការសាងសង់ ប្រាសាទតូចៗមួយចំនួនដូចជា ប្រាសាទព្រះពិទូ (នៅទិសឥសានទីលានរាជវាំង) ដោយមានប្រើសម្ភារៈចាស់កែច្នៃដែលសមស្រប ចំពោះរបៀបរៀបចំដែលមានស្រាប់ដោយគ្មានកែប្រែវា ។ ជូនកាលការកែប្រែត្រូវបានធ្វើចំពោះក្រុមប្រាសាទចំបងៗដែលមានស្រាប់ដើម្បីកាត់បន្ថយនូវទំហំរបស់វា : ឧទាហរណ៍ ដូចជាប្រាសាទបាយ័នត្រូវបានព័ទ្ធជុំវិញដោយជញ្ជាំងធ្វើពីថ្មបាយក្រៀមដែលបានកាត់ផ្ដាច់ចេញពីផ្នែកដទៃទៀតនៃទីក្រុងដែលមានកំផែងនេះព័ទ្ធជុំវិញដែរ (ការធ្វើប្រតិបត្តិការបែបនេះប្រហែលជាត្រូវបានប្រព្រឹត្តទៅនៅជុំវិញចំណុចកណ្ដាល នៃប្រាសាទព្រះខ័នប្រាសាទតាព្រហ្ម និងប្រាសាទបន្ទាយក្ដី) ។ ការនិយមលទ្ធិសិវៈ(Shivaisation) នៃប្រាសាទ ព្រះពុទ្ធសាសនារបស់ព្រះបាទជ័យវរ្ម័នទី៧ (មកដល់ឆ្នាំ១២៤០) និងការវិលមករកព្រះពុទ្ធសាសនាវិញ នៅពេលពីរបីឆ្នាំក្រោយមកការផ្លាស់ប្ដូរទាំងនេះហាក់បីដូចជាត្រូវបានធ្វើតែរូបរាងខាងក្រៅតែប៉ុណ្ណោះ ចំពោះរចនាសម្ព័ន្ធរបស់តំបន់ប្រាសាទ ។ម្យ៉ាងវិញទៀត ជោគជ័យរបស់ព្រះពុទ្ធសាសនាហីនយានប្រហែលជាចាប់ពីចុងសតវត្សទី១៣ ត្រូវបានឆ្លុះបញ្ចាំងដោយការបន្ថែមវត្តអារាមជាច្រើនទៀត ជាពិសេសនៅក្នុងបរិវេណប្រាសាទអង្គរធំ : វត្តអារាមនីមួយៗត្រូវបានធ្វើនៅជុំវិញទីលានព្រះពុទ្ធសាសនា ដែលតំកល់ព្រះពុទ្ធបដិមាដែលគេសាងសង់ទ្រង់គ្រឿងក្នុងសមាធិមុទ្រធំៗ ត្រូវបានការពារដោយអាគារឈើ និងក្បឿង (ដូចរូបព្រះពុទ្ធដិមាទេពប្រណម្យនាពេលបច្ចុប្បន្ន) ។ ហើយចំពោះផ្នែកដទៃទៀត បណ្ដាញជលធាររបស់ទីក្រុងបានទទួលនូវការកែប្រែខ្លះៗ ប៉ុន្តែនោះគឺជាគម្លាតចុងក្រោយបង្អស់នៃបច្ចេកវិទ្យាមួយដែលប្រទេសកម្ពុជាមិនអាចលែលកប្រើប្រាស់បានទៀតទេ ។

មកដល់ចុងសតវត្សទី១៥ ការកែប្រែទេសភាពការសាងសង់ត្រូវបានធ្វើម្ដងទៀតចំពោះតំបន់អង្គរដោយត្រឹមត្រូវ ។ មនោសញ្ចេតនាចំពោះសាសនារួមជាមួយនឹងភាពរុងរឿងផ្នែកសម្ភារៈជាថ្មីម្ដងទៀតគឺត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសាងសង់នៃរូបព្រះពុទ្ធបដិមាពីរធំៗនៅលើប្រាសាទអង្គរទាំងឡាយ : ព្រះពុទ្ធរូបបរិនិព្វាននៅប្រាសាទបាពួនដែលត្រូវបានសាងសង់នៅជាន់ទី២នៃផ្នែកខាងលិចនៅតែមិនសូវមានគេកត់សំគាល់នៅឡើយ ទោះបីជាវាមានប្រវែង៦០ ម៉ែត្រក៏ដោយ ។ ម្យ៉ាងវិញទៀត ព្រះពុទ្ធរូបទ្រង់ព្រះភ្នែនដែលក្រសោបនូវមុខពីរ៉ាមីទខាងកើតទាំងមូលដែលត្រូវបានកសាងនៅលើកំពូលភ្នំបាក់ខែងត្រូវបានគេមើលឃើញពីគ្រប់ទិសទីទាំងអស់ដើម្បីបង្ហាញសំដែងមួយដែលគេបានប្រើចំពោះទេវរូមនៅលើតួប៉មដែលមានមុខប្រាសាទបាយ័ន ។ ពីរបីទសវត្សរកន្លងក្រោយមកក្រុមរាជវង្សានុវង្សបានយាងត្រឡប់មកគង់នៅអង្គរមួយរយៈខ្លី ហើយអង្គរវត្តត្រូវបានស្ដារឡើងវិញនៅក្នុងឆ្នាំ១៥៧៧ ។ អង្គរវត្តបានក្លាយទៅជាលក្ខណៈព្រះពុទ្ធសាសនាប្រហែលជានៅក្នុងសតវត្សទី១៤ ហើយវានៅតែជាបេះដូងនៃជីវិតផ្នែកសាសនារបស់អាណាចក្ររហូតដល់ដូចសព្វថ្ងៃនេះដែរ ។

តំបន់អង្គរហាក់បីដូចជាមានជីវិតរស់នៅដោយស្ងប់ស្ងៀមរហូតមកដល់សតវត្សទី២០ នៅពេលដែលគេបានកាប់គ្រាយសំអាតចេញព្រៃនៅក្នុងប្រាសាទទាំងឡាយហើយនាំឱ្យតំបន់អង្គរមានតំលៃខ្ពស់ផងត្រូវបានអភិវឌ្ឍន៍ ដោយនាំឱ្យមានការរំខានថ្មីមួយចំនួន ។ ជាឧទាហរណ៍ប្រាសាទតូចៗធ្វើអំពីឥដ្ឋ ចំនួនពីរ រឺបីបានបាត់បង់នៅពេលព្រលានយន្តហោះ ត្រូវបានពង្រីកនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ពីរបីឆ្នាំក្រោយមកការចាក់ដីបំពេញជលដ្ឋានបារាយណ៍ខាងកើតធ្វើឱ្យមានលទ្ធផលវិជ្ជមានមួយពីព្រោះវាធ្វើឱ្យមានការរកឃើញនូវប្រាសាទអកយំ ដែលត្រូវបានកប់បាត់តាំងពីសតវត្សទី១១ ។ បន្ទាប់ពីអង្គរវត្តត្រូវបានស្ដារឱ្យទទួលបាន តួនាទីជាទីជំរកសំរាប់រយៈពេលពីរបីឆ្នាំ សង្គ្រាមនាពេលថ្មីៗនេះ បាននាំអោយមានការចូលកាន់កាប់ជាថ្មីម្ដងទៀតរបស់ជនស៊ីវិល និងអ្នកកាន់សាសនាដោយមានការអភិវឌ្ឍន៍នៃភូមិពីរបី និងវត្តមួយចំនួនដែលបានប្រើសារជាថ្មីនូវទីតាំងព្រះពុទ្ធសាសនាចាស់ដើម្បីដាក់ព្រះពុទ្ធរូបទ្រង់ភ្នែនដែលជាបេះដូងនៃការបូជារបស់ពុទ្ធសាសនិកជនខ្មែរ ចាប់តាំងពីសតវត្សទី១៤មក (យ៉ាងឆាប់បំផុត) ។ ដោយរួមផ្សំជាមួយនឹងភាពសំខាន់ជានិរន្តរ៍របស់ប្រាសាទអង្គរវត្ត និងការស្ដារឡើងវិញនៃប្រាសាទមួយចំនួនដូចជាប្រាសាទទេពប្រណម្យនិងព្រះពុទ្ធរូបនៅបាយ័ន (សាងសង់ឡើងម្ដងទៀតនៅប្រហែលឆ្នាំ១៩៣៥) ឧទាហរណ៍នៃការខំប្រឹងជាថ្មីជាមួយនឹងអតីតកាលបានរំលឹកយើងថាប្រសិនបើគេត្រូវការនូវវត្ថុអនុស្សាវរីយ៍បែបនេះមួយអង្គរប្រាកដជា រាជធានីចក្រវាឡមួយដែលស្ថិតនៅតាមដងទន្លេគង្គ (Ganges) នៅចន្លោះភ្នំដែលជាអាស្រមរបស់ព្រះសិវៈ(Shiva) និងមហាសមុទ្រនោះពិតជាទីក្រុងអាទិទេព (ទេវនគរ) ប្រាកដមែន ។

ប្រវត្តិ និង សង្គម

កំណត់សំគាល់

[១] B.P Groslier : "ទីក្រុងជលសាស្ត្រ" *B.E.F.E.O.* [ព្រឹត្តិប័ត្រ E.F.E.O.] ភាគទី៦៦ ឆ្នាំ១៩៧៩ ទំព័រ ១៦១-២០២ បោះពុម្ពជាថ្មីរបស់ លោក *Groslier ក្រោមចំណងជើងថា" ភាពប្លែក នៃបូរាណ*វត្ថុវិទ្យាខ្មែរ ក្រុង ប៉ារិសឆ្នាំ១៩៩៧ ទំព័រ១៣១-១៧៥

[២] ចំពោះឧទាហរណ៍ល្អៗ សូមមើលការកែតំរូវដែលត្រូវបានស៊ើបអង្កេតនៅក្នុង J. Dumarcay. *បូរាណវត្ថុវិទ្យានិងតំរូវរបស់វានៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍* ក្រុងប៉ារីស បណ្ណាល័យ Oriens ឆ្នាំ១៩៩៨ ៗ នៅក្នុង J. ។ Dumarcay and P. Royere *បូរាណវិទ្យាវត្ថុខ្មែរ ពីសតវត្សទី៨ ដល់សតវត្សទី១៣* Leiden-Boson-Cologne. Brill.២០០១

[៣] អំពីប្រាសាទបាគង សូមមើល C. Pottier " សំគាល់ចំពោះប្រាសាទបាគង និង ការបង្កើតឡើង នៃប្រាសាទនេះ B.E.F.E.O. ភាគទី៨២ ឆ្នាំ១៩៩៦ ទំព័រ៣៣៩-៣៤៨ និង Dumarcay and Royere. op.cit ទំព័រ៤៩-៥០ ។

[៤] សំរាប Zhou Daguan ហៅ ជីវតាក្វាន សូមមើល P. Pelliot (*កំណត់ហេតុប្រវត្តិសាស្ត្រស្តីពី ទំនៀមទំលាបកម្ពុជា ដោយជីវ តាក្វាន់*) ក្រុងប៉ារីស ឆ្នាំ១៩៥១ H. Mouhot *ធ្វើដំណើរទៅភាគកណ្តាលនៃតំបន់ ឥណ្ឌូចិន (សៀម) ប្រទេសកម្ពុជា និងប្រទេសលាវនៅក្នុងកំឡុងឆ្នាំ១៨៥៨ -១៨៥៩ និង ឆ្នាំ១៨៦០ មាន ២ភាគ ក្រុងឡុងដ៏ ឆ្នាំ១៨៦៤ និងការបោះពុម្ពឡើងវិញ) និងការធ្វើដំណើរនៅក្នុងរាជាណាចក្រថៃ កម្ពុជា លាវ និងកន្លែងភាគកណ្តាលដទៃទៀតរបស់ឥណ្ឌូចិន* ក្រុងប៉ារីសឆ្នាំ១៨៦៨ (និងការបោះពុម្ព ឡើងវិញ)

[៥] សូមមើលកាលពីថ្មីៗបំផុត C. Pottier ការស្វែងរកក្រុងគលបុរៈ (Goloupura) នៅក្នុង B.E.F.E.O. ភាគទី៨៧-១ឆ្នាំ២០០០ ទំព័រ៧៩-១០៧

[៦] អំពីនិមិត្តរូបនៃប្រាសាទបាក់ខែង សូមមើល J. Filliozat (និមិត្តរូបនៃប្រាសាទបាក់ខែង) B.E.F.E.O ។ ភាគទី៤៤ ឆ្នាំ១៩៥៤ ទំព័រ៥២៧-៥៥៤ អំពីទំនាក់ទំនងទៅនឹងប្រាសាទបាយ័ន សូមមើល B. Dagens (កំពូលមុខរបស់ប្រាសាទបាយ័ន និងលេខ១០៨) *ព្រឹត្តិប័ត្រសិក្សាឥណ្ឌូ* ភាគទី៦ ឆ្នាំ១៩៨៨ ទំព័រ ១៧៧-១៩៩

[៧] ទំហំនៃជលដ្ឋានបារាយណ៍ យោងតាមលោក Groslier " ទីក្រុងជលសាស្ត្រ" op.cit ៖

	បណ្តោយ	ទទឹង
បារាយណ៍លលៃ	៣៨០០ ម	៧០០ ម
បារាយណ៍ខាងកើត	៧១២០ ម	១៧០០ ម
បារាយណ៍ខាងលិច	៨ ០០០ម	២១០០ ម
បារាយណ៍ព្រះខ័ន	៣៥០០ ម	៩០០ ម

[៨] សូមមើល J. Boulet and B. Dagens " ទីតាំងបូរាណវត្ថុវិទ្យានៅក្នុងតំបន់ប្រាសាទភ្នំគូលេន" សិល្បៈអាស៊ី ភាគទី២៧ ឆ្នាំ១៩៧៣

[៩] បាក់បីដូចជាថា ដីមួយផ្នែកជាកម្មសិទ្ធិរបស់ប្រាសាទកុតិស្វារៈ(Kutishvara) នៅខាងត្បូងបារាយណ៍ត្រូវបានលិចទឹកបាត់ ។ សូមមើល Dumarcay and Royere. op. cit ទំព័រ ២២និង៥៥ ។

[១០] អាស្រម (Ashrama) ទាំងនេះធ្លាប់ជាវត្ត សាលារៀន និងផ្ទះសំណាកសំរាប់អ្នកដំណើរ cf. G Coedes *អត្ថបទសិលាចារឹកនៃខ្មែរ* I ទំព័រ២៤០

[១១] កាន់ជាច្បាស់ថែមទៀត ការអភិវឌ្ឍន៍ឡើងវិញនេះរួមទាំងការបង្កើតឃ្លាំង ខាង ត្បូងដែលបំពេញបន្ថែមដល់ឃ្លាំងខាងជើង (ដែលត្រូវបានសាងសង់ឡើង នៅចុង សតវត្សទី១០) ហើយឃ្លាំងនៃកំពូលទាំងពីរនេះដែលលាតសន្ធឹង ស៊ីមេទ្រីគ្នា និងបែរមុខទៅទិសខាងលិចនោះ គឺជាសមាសធាតុពីរដំបូង របស់ប្រាសាទ ស្ទូព៌ត ដែលព្រះបាទជ័យវរ្ម័នបានបង្កើនរហូតដល់ទៅ១២ ។

[១២] សូមមើល P. Courbin ការជីកកកាយស្រះស្រង់ P) នៅក្នុង J. ។ Dumarcay (អភិរក្សអង្គរ ឆ្នាំ១៩៦៣-១៩៧៣) ក្រុងប៉ារីស EFEO ឆ្នាំ១៩៨៨

[១៣] ការជីកកកាយដែលកំពុងតែប្រព្រឹត្តិទៅនៅក្នុងប្រាសាទអង្គរធំគួរតែបំភ្លឺ ដល់បញ្ហានេះ ។

ធនធានមនុស្ស និងការអភិវឌ្ឍន៍វប្បធម៌ : ករណីសិក្សានៃប្រាសាទទាំងឡាយនៅអង្គរ

ដោយ បណ្ឌិត យ៉ូស៊ីអាគិ អ៊ីស៊ីហ្សាវ៉ា Dr. Yoshiaki Ishizawa

Dr. Yoshiaki Ishizawa គឺជាប្រធានបេសកកម្មអន្តរជាតិស្តីពីអង្គរនៃសាកលវិទ្យាល័យ Sopiha និងជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យសម្រាប់ការសិក្សាបរទេស នៃសាកលវិទ្យាល័យ Sophia ក្រុងតូក្យូ ប្រទេសជប៉ុន ។ លោកបានបោះពុម្ពផ្សាយសៀវភៅជាច្រើនស្តីពីអង្គរដូចជា: តាមបណ្តោយព្រះរាជវិថីនៃទីកដីអង្គរ (New York Weetherhill) ទីក្រុងញូវយ៉ក ឆ្នាំ១៩៩៩ អង្គរ Iseki no Kokogaku (ការសិក្សាបែបបុរាណវិទ្យាទៅលើអង្គរ) បោះពុម្ពដោយ Nakao Yoshiharu, Rengo Shuppan, ទីក្រុងតូក្យូ ខែមេសា ឆ្នាំ២០០០ អង្គរ Iseki Lo Shakai Bunka Hatten-Iseki, Jumin, Kankyo ការអភិវឌ្ឍន៍សង្គមវប្បធម៌ទៅលើតំបន់ក្រុមប្រាសាទអង្គរ ព្រមទាំងមនុស្ស និង ធម្មជាតិ) បោះពុម្ពដោយ Tsuboi Yéshiharu, Rengo Shuppan, ទីក្រុងតូក្យូ ខែមីនា ឆ្នាំ២០០១ ។ ការស៊ើបអង្កេតទៅលើក្រុមប្រាសាទអង្គរ វិទ្យាស្ថានវប្បធម៌អាស៊ី សាកលវិទ្យាល័យ Sophia លេខ៨ ខែមេសា ឆ្នាំ២០០១ ។

ពិព័រណ៍សិល្បៈ និងទេសចរណ៍

ការតាំងពិព័រណ៍សិល្បៈខ្មែរ ត្រូវបានផ្តួចផ្តើមឡើងដោយសន្និសីទខ្មែរស្តីពីសន្តិភាពក្នុងឆ្នាំ១៩៩១ ។ ការតាំងពិព័រណ៍នេះត្រូវបានធ្វើឡើងនៅទីកន្លែងផ្សេងៗ គ្នា នៅក្នុងប្រទេសចំនួនបីផ្សេងៗគ្នា : គឺ Grand Palais នៃទីក្រុងបារីស ក្នុងប្រទេសបារាំង សារមន្ទីរទីក្រុងប្រជុំជនដ៏ធំនៃទីក្រុងញូយកនៅក្នុងសហរដ្ឋអាមេរិក និងនៅក្នុងប្រទេសជប៉ុន បន្ទាប់ពីការចចារ និងការរៀបចំដ៏យូរ ចាប់ពីឆ្នាំ១៩៩២ នៅសារមន្ទីរទីក្រុងប្រជុំជនដ៏ធំក្នុងទីក្រុងតូក្យូ ឆ្នាំ១៩៩៧ និងនៅសារមន្ទីរទីក្រុងអូសាកាក្នុងទីក្រុងអូសាកានៅ ឆ្នាំ១៩៩៨ ។

វប្បធម៌ខ្មែរនៅអាស៊ីអាគ្នេយ៍ គឺជាវប្បធម៌ដ៏ល្បីល្បាញមួយក្នុងពិភពលោក ដូចវប្បធម៌រ៉ូម៉ាំង និងក្រិចដែរ ។ វប្បធម៌ដ៏ល្បីល្បាញក្នុងពិភពលោក ។ នៅក្នុងវប្បធម៌នេះ រូបភាពទាំងឡាយនៃចម្លាក់សុទ្ធតែមានក្បូរក្បាច់រចនាវិសេសៗទាំងអស់ព្រមទាំងបង្កប់នូវអត្ថន័យដ៏ធំធេងនៅក្នុងប្រាសាទនីមួយៗ។ សន្តតិវង្សអង្គរបានកែច្នៃទស្សនៈលោកធាតុរបស់ឥណ្ឌាហើយបានធ្វើការអភិវឌ្ឍន៍ទស្សនៈលោកធាតុរបស់ខ្មែរខ្លួនឯង។ រូបបដិមាដែលធ្វើឡើងពីថ្មភក់ និងចម្លាក់មានលក្ខណៈស្រដៀងគ្នាទៅនឹងរូបបដិមា និងចម្លាក់បុរាណរបស់ឥណ្ឌាដែរ ឧទាហរណ៍ ដូចជាការឈរកាច់ដងខ្លួនជា៣ គន្លាក់ Tribangha

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

ធនធានមនុស្ស និងការអភិវឌ្ឍន៍វប្បធម៌ : ករណីសិក្សានៃប្រាសាទទាំងឡាយនៅអង្គរ

ដោយ បណ្ឌិត យ៉ូស៊ីអាគិ អ៊ិស៊ីហ្សាវ៉ា Dr. Yoshiaki Ishizawa

ដែលលក្ខណៈនេះមានដូចគ្នានៅក្នុងចម្លាក់ឥណ្ឌាបុរាណដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជនជាតិកម្ពុជាបានធ្វើការកែច្នៃយ៉ាងច្រើនឱ្យទៅជាទំរង់ពិសេសរបស់ខ្លួន ដូចជា : ភ្នែក ត្រចៀក ច្រមុះ ។ល។ និង ។ល។ ដែលឥឡូវនេះក៏បានក្លាយមកជាលក្ខណៈខ្មែរទាំងស្រុងទៅហើយ ។ សមត្ថភាពខាងសិល្បៈរបស់ប្រជាជនខ្មែរបានផ្តល់កំណើតដល់ចម្លាក់ដ៏អស្ចារ្យជាលក្ខណៈខ្មែរ ។ ខ្ញុំជឿថា ដូចជាជនជាតិអាស៊ីភាគច្រើនដែរ វាជាច្បាប់ធម្មជាតិដែលយើងត្រូវដកពិសោធន៍នូវអារម្មណ៍ស្វែងយល់ ពីវត្ថុចម្លាក់ផ្សេងៗទាំងនេះ ជាអាទិ៍ដូចជាចម្លាក់លិប និង ចម្លាក់ផ្សេងៗទៀត ដែលធ្វើអោយមានការរំភើបនឹងចង់មើល ។

កម្ពុជាក្នុងឆ្នាំ២០០១ ត្រៀមខ្លួនរួចជាស្រេចសម្រាប់វិស័យទេសចរណ៍ ។ ស្ថានភាពបច្ចុប្បន្ន គឺរឿង១ នៃស្ថេរភាពនយោបាយហើយសន្តិភាព និង សណ្តាប់ធ្នាប់ សាធារណៈនៅលើទឹកដីអង្គរខេត្តសៀមរាប ត្រូវបានថែរក្សាយ៉ាងប្រុងប្រយ័ត្ន ។ ភ្ញៀវទេសចរអឺរ៉ុបជាច្រើនកំពុងតែមកទស្សនាប្រទេសនេះ ហើយភ្ញៀវទេសចរមកពីអាស៊ីហូរចូលមកពីប្រទេសផ្សេង១ ដូចជា : តៃវ៉ាន់ ហុងកុង និងជប៉ុន ។ បច្ចុប្បន្ននេះ គេអាចឃើញភ្ញៀវទេសចរជាច្រើននៅអង្គរវត្តនិងប្រាសាទផ្សេងៗទៀត ។ ប្រជាជនកម្ពុជារីករាយនឹងទទួលពួកគេទាំងនោះ ដោយសារវិស័យទេសចរណ៍ គឺជាប្រភពនៃការងារសម្រាប់មនុស្សជាច្រើន ។ កម្ពុជាគឺជាទឹកដីដែលអំណោយផលដោយធម្មជាតិ ។ ស្រូវ ពោត កៅស៊ូ ជាដើម គឺជាផលិតផលកសិកម្មជាច្រើនដែលអាចនាំចេញទៅក្រៅ ក៏ប៉ុន្តែទេសចរណ៍ និងឧស្សាហកម្មពាក់ព័ន្ធបច្ចុប្បន្ននេះ គឺជាមធ្យោបាយដ៏ចម្បង ក្នុងការដោះដូរជាមួយបរទេស ។ ខែដែលល្អបំផុតក្នុងការមកទស្សនាកម្ពុជា គឺ ខែធ្នូ ខែមករា និងខែកុម្ភៈ ។ រដូវប្រាំង គឺចាប់ពីខែធ្នូ រហូតដល់ ខែមិថុនា ហើយរដូវវស្សាចាប់ពីខែកក្កដា រហូតដល់ ខែវិច្ឆិកា ។ ផ្ទុយទៅវិញ វាក្តៅនិងស្ងួតខ្លាំងនៅខែមីនា ។

សាស្ត្រាចារ្យ B. Groslier ការណែនាំអោយស្គាល់របស់ខ្ញុំចំពោះប្រវត្តិសាស្ត្រ និងសិលាចារឹកវិទ្យាខ្មែរ

នៅឆ្នាំ១៩៦១ ខ្ញុំបានជួបសាស្ត្រាចារ្យ B. Groslier ដែលជាអ្នកប្រាជ្ញដ៏ល្បីម្នាក់ខាងផ្នែកអភិរក្ស និងជួសជុលក្រុមនៃប្រាសាទអង្គរតាមរយៈ Paul Rietsch ជាសាស្ត្រាចារ្យមួយរូបដែលបានផ្តល់អភ័យឯកសិទ្ធិអោយខ្ញុំបានចូលសិក្សានៅសាកលវិទ្យាល័យ Sophia ។ ព្រឹត្តិការណ៍ដ៏មានភ័ព្វសំណាងនេះ គឺជាចំណុចចាប់ផ្តើមនៃការស្រាវជ្រាវរបស់ខ្ញុំនៅលើប្រាសាទកម្ពុជា ។ នៅឆ្នាំដដែលនោះ ខ្ញុំបានធ្វើការនៅក្នុងប្រទេសកម្ពុជា ជាអ្នកស្រាវជ្រាវវ័យក្មេងម្នាក់នៅពេលដែលសាស្ត្រាចារ្យ B. Groslier បានណែនាំរូបខ្ញុំអោយស្គាល់ពីប្រវត្តិសាស្ត្រខ្មែរ និងសិលាចារឹកចំណាស់ខ្មែរ ដែលជាទូទៅគេហៅថាជាសិលាចារឹកវិទ្យា ។ ខ្ញុំនៅតែចាំដំបូន្មានរបស់គាត់ដែលខ្ញុំយល់ឃើញថាមានភាពពាក់ព័ន្ធគ្នាសព្វថ្ងៃនេះ : ការយល់ដឹងទូលំទូលាយពីវប្បធម៌និងប្រវត្តិសាស្ត្រខ្មែរ និងធ្វើការសហការជាមួយអ្នកស្រាវជ្រាវកម្ពុជា ។

ខ្ញុំតែងតែមានអារម្មណ៍ដ៏ជ្រាលជ្រៅចំពោះប្រាសាទកម្ពុជាទាំងនេះហើយខ្ញុំអាចយល់ពីអារម្មណ៍ដែលប្រាសាទទាំងនេះបានជិតជាប់នៅក្នុងបេះដូងរបស់កម្ពុជា ។ ដោយមានលក្ខណៈធំធេង និងប្រកបដោយតុល្យភាព ប្រាសាទទាំងអស់នេះស្ថិតនៅក្នុងព្រៃ ដែលធ្វើអោយវាក្លាយជាប្រភពនៃការទាក់ទាញអារម្មណ៍ ។

មរតកវប្បធម៌នៅក្នុងតំបន់អាស៊ីអាគ្នេយ៍

មានប្រាសាទដ៏ល្បីល្បាញជាច្រើននៅតំបន់អាស៊ីអាគ្នេយ៍ : រាជធានីប្រវត្តិសាស្ត្របាកាន (Pagan) ស្ថិតនៅមាត់ច្រាំងខាងឆ្វេងនៃទន្លេអ៊ីរ៉ាវ៉ាឌី (Irrawaddy) ក្នុងប្រទេសភូមា ដែលបច្ចុប្បន្ននេះមានព្រះវិហារ ព្រះពុទ្ធសាសនាជាង២២០ និងទីក្រុងសុខោទ័យ (Sukothai) ចំណាស់នៃប្រទេសថៃ ដែលមានព្រះវិហារ ព្រះពុទ្ធសាសនាជិត១៥០ ។ ប្រាសាទមួយទៀតគឺបូរ៉ូប៊ូដួរ (Borobudur) នៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលជាប្រាសាទព្រះវិហារព្រះពុទ្ធសាសនាដ៏ធំដែលធ្លាប់មានអតីតកាលដ៏រុងរឿងមួយ ។ ប្រាសាទដទៃទៀតក៏មានកំពស់និងទំហំទទឹងធំៗស្មើគ្នាដែរ និងប្រកបទៅដោយធាតុកន្ត្រាក់អារម្មណ៍ជាច្រើន ។

បើប្រៀបធៀបទៅនឹងសំណង់ផ្សេងៗគ្នាទាំងនេះ បរិវេណអង្គរគឺធំជាងគេបង្អស់ ហើយជាងនេះទៅទៀត ចម្លាក់ និងចម្លាក់ក្បាច់លិបរបស់អង្គរវត្តមានការទាក់ទាញអារម្មណ៍យ៉ាងខ្លាំង ។ "gopura"

ប្រវត្តិ និង សង្គម

គោបុរះក្លោងទ្វារ ឬកំពូលប្រាសាទមានលក្ខណៈធំអស្ចារ្យ ព្រមទាំងមានប្រវត្តិរឿងខ្លីៗឆ្លាក់នៅលើជញ្ជាំងទៀតផង ។ រឿងទេវកថាប្រវត្តិសាស្ត្ររបស់ឥណ្ឌាដ៏ល្បីល្បាញពីរគឺរឿង រាមកេរ្តិ៍ និងរឿងមហាភារតៈ (Mahabharata) ត្រូវបានឆ្លាក់នៅលើ

១/ សាស្ត្រាចារ្យ អ៊ិស៊ិ ហ្សាវ៉ា (Ishizawa) ក្នុងកំឡុងពេលមួយនៃវគ្គបណ្តុះបណ្តាលផ្សេងៗ ស្តីអំពីរមណីយដ្ឋានប្រាសាទបន្ទាយក្តី (សតវត្សរ៍ ១២-១៣) ២០០១ ។
២/ ការរកឃើញក្នុងកំឡុងពេលធ្វើការងារក្នុងមូលដ្ឋាននៅតំបន់ប្រាសាទបន្ទាយក្តីនេះ ទីកន្លែងសំងាត់ មួយដែលមានរូបសំណាកព្រះពុទ្ធជាច្រើន ២០០១ ។

ជញ្ជាំងជារចនាបថខ្មែរជាមួយនឹងបំណែកស្រាយជាខ្មែរផងដែរ នោះគឺជាការពិតមួយដែលជាចំណាប់អារម្មណ៍ដល់អ្នកស្រាវជ្រាវ ។ រាជបុរីទីមួយដែលត្រូវបានកសាងឡើងនៅប្រហែលសតវត្សទីប្រាំបួននោះពីមុនត្រូវបានគេស្គាល់ថាជាយសោធរបុរៈ (Yasodharapura) ។ ព្រះរាជាជាច្រើនដែលគ្រងរាជ្យនៅរាជបុរីនោះ បន្តកសាងទីក្រុងប្រាសាទ និងវត្តជាបន្តបន្ទាប់ រហូតដល់រាជបុរីនោះបានធ្លាក់ចុះនៅឆ្នាំ១៤៣១ ។ សំណង់ពិសេសនេះ មិនត្រឹមតែយកតាមការរៀបចំទំហំនៃកំពូលស្រួចបីប្រាសាទ និងច្រកចេញចូលប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅពេលជាមួយគ្នានោះវាក៏ជាផែនទី ធរណីមាត្រទេវសិរីមេរុមួយផងដែរ ។

គោលគំនិតធំៗបីរបស់យើងស្តីពីធនធានមនុស្ស

យើងកំពុងតែធ្វើអង្កេត និងការងារជួសជុលឡើងវិញនូវប្រាសាទចំនួនពីរដែលជាមជ្ឈមណ្ឌលសំរាប់បណ្តុះបណ្តាលផងដែរ ។ មួយគឺប្រាសាទបន្ទាយក្តីដែលបានកសាងឡើងនៅចុងសតវត្សទី១២ ។ វាប្រាសាទនេះធ្វើឡើងពីថ្មភក់ ថ្មបាយក្រៀម និងឥដ្ឋ ហើយជាតំបន់មួយក្នុងចំណោមតំបន់ទាំងឡាយដែលយើងបានជ្រើសរើស ជាទីកន្លែងដ៏ស័ក្តិសមបំផុតសម្រាប់បណ្តុះបណ្តាលសិស្សានុសិស្សកម្ពុជា ។ មួយទៀតគឺផ្លូវចូលភាគខាងលិចនៃប្រាសាទអង្គរវត្តដែលជាផ្លូវដើរក្រាលថ្ម ។ យើងសំគាល់ដោយបង្កាន់ដៃដែលតុបតែងទៅដោយរូបចំលាក់នាគ (អាទិទេពពស់) ។

យើងដើរតាមគោលគំនិតធំៗ ចំនួនបី នៅក្នុងការងារជួសជុលនេះ ។ ទីមួយគឺការថែរក្សា និងការជួសជុលឡើងវិញនៃប្រាសាទទាំងឡាយនៅក្នុងប្រទេសកម្ពុជា ដោយជនជាតិកម្ពុជា សម្រាប់ប្រជាជនកម្ពុជា ។ នេះគឺជាអ្វីដែលយើងត្រូវចាត់ទុកជាចំណុចសំខាន់ចំបងហើយវាពាក់ព័ន្ធទៅនឹងកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សមួយ ។ ទីពីរ

ធនធានមនុស្ស និងការអភិវឌ្ឍន៍វប្បធម៌ : ករណីសិក្សានៃប្រាសាទទាំងឡាយនៅអង្គរ

ដោយ បណ្ឌិត យ៉ូស៊ីអាគិ អ៊ិស៊ីហ្សាវ៉ា Dr. Yoshiaki Ishizawa

គឺការប្រកាន់យកនូវទស្សនៈរយៈពេលវែងនៃការងារថែរក្សានិងការស្ដារឡើងវិញ។ នេះ គឺចង់និយាយថា ការថែរក្សានូវទំនាក់ទំនងជិតស្និទ្ធរវាងការស្រាវជ្រាវ និងការសិក្សាទាក់ទិនទៅនឹងសកម្មភាពថែរក្សាប្រាសាទនិងតំបន់អង្គរ ។ នេះមានន័យថាបន្ទាប់ពីមានការស៊ើបអង្កេតនិងការឆ្លុះបញ្ចាំងដ៏ម៉ត់ចត់និងល្អិតល្អន់មួយមក យេងគួរចូលរួមនៅក្នុងការងារថែរក្សានិងស្ដារឡើងវិញនេះ។ ទីបីគឺការប្ដេជ្ញាចិត្តជួយឆ្ពោះទៅរកការបង្កើត និងការថែរក្សានូវតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងវប្បធម៌សង្គមរបស់សហគមន៍ក្នុងស្រុកនៅក្នុងតំបន់អង្គរ។

ការទទួលបាននូវកិច្ចសហប្រតិបត្តិការពីប្រជាជនក្នុងភូមិដើម្បីការងារជួសជុលនិងការងារផ្សេងៗទៀត គឺជាភាពចាំបាច់បំផុត។ ដូចនេះ យើងបានចាប់ផ្ដើមចាប់តាំងពីឆ្នាំ១៩៩៣ ក្នុងការបណ្ដុះបណ្ដាលនៅមូលដ្ឋានដល់និស្សិតកម្ពុជា និងសិក្ខាកាមមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅរាជធានីភ្នំពេញ។ យើងបានជ្រើសរើសនិស្សិតចំនួនប្រាំនាក់មកពីផ្នែកបុរាណវត្ថុវិទ្យានិងនិស្សិតប្រាំនាក់ទៀតមកពីផ្នែកស្ថាបត្យកម្ម។ នេះចង់និយាយថា យើងបានសំរេចយកនិស្សិតដប់នាក់សម្រាប់វគ្គដំបូងនេះ ។ ក៏ប៉ុន្តែក៏មានវគ្គសិក្សាកំរិតខ្ពស់ និងថ្នាក់ខ្ពស់ៗ ផ្សេងទៀតៗផងដែរ។ ឥឡូវនេះយើងស្ថិតនៅក្នុងឆ្នាំទីប្រាំបួននៃកម្មវិធីរបស់យើងហើយ ។

យើងបានជ្រើសរើសនិស្សិតបីនាក់ ពីក្រុមសិក្ខាកាមនេះដើម្បីបន្តវគ្គសិក្សាកំរិតខ្ពស់ជាងនេះមួយនៅប្រទេសជប៉ុន ។ និស្សិតទាំងនោះឥឡូវនេះស្ថិតនៅក្នុងកម្មវិធីថ្នាក់បណ្ឌិតផ្នែកការសិក្សាតំបន់នៅឯសាលារៀនជាន់ខ្ពស់សម្រាប់ការសិក្សាក្រៅប្រទេសនៅសាកលវិទ្យាល័យ Sophia តាមរយៈកម្មវិធីអាហារូបករណ៍ដែលរៀបចំឡើង the Shinnyo-En ជាក្រុមសាសនាព្រះពុទ្ធមួយនៅក្នុងទីក្រុងតូក្យូ។ អាហារូបករណ៍បែបនេះ មានសារៈសំខាន់ពីព្រោះនៅក្នុងកំឡុងសម័យប៉ុលពត អ្នកអភិរក្សជាច្រើនបានចាកចេញពីកម្ពុជា ហើយជាអកុសលមិនដែលវិលត្រឡប់មកវិញទេ។ ប៉ុន្តែមានបីនាក់បានវិលត្រឡប់មកវិញ ហើយឥឡូវនេះកំពុងតែធ្វើការនៅទីកន្លែងផ្សេងៗ ក្នុងឋានៈជានាយក ។ ឥឡូវនេះ យើងកំពុងស្ថិតក្នុងតំណាក់កាលបន្តកម្មវិធីបណ្ដុះបណ្ដាលសម្រាប់សិស្សកម្ពុជា ពីកំរិតដំបូងរហូតដល់កំរិតខ្ពស់បំផុតខាងជំនាញឯកទេស។

មជ្ឈមណ្ឌលវប្បធម៌និងបណ្ដុះបណ្ដាល Sophia នៅព្រះរាជាណាចក្រកម្ពុជា

អ្នកឯកទេសបារាំង បានចូលរួមនៅក្នុងការងារអភិរក្សចាប់ពីឆ្នាំ១៩៥៨ ហើយក្នុងកំឡុងពេលនោះ មានតែសាលាបារាំងចុងបូព៌ា (the Ecole Française d'Extreme Orient) (EFEO) ទេដែលទទួលខុសត្រូវការងារនេះ។ បន្ទាប់ពីទទួលបាននូវឯករាជ្យក្នុងឆ្នាំ១៩៥៣មក តំណាងរបស់ EFEO ក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យ Groslier នៅទីនោះ (EFEO) ជាទីប្រឹក្សាជាសាស្ត្រាចារ្យបណ្ដុះបណ្ដាលនិស្សិតកម្ពុជា។ ជាអកុសលក្នុងកំឡុងរបបប៉ុលពត ចំនួនអ្នកជំនាញការត្រូវបានកាត់បន្ថយស្ទើរដល់កំរិតសូន្យហើយយើងនៅសល់តែបីនាក់តែប៉ុណ្ណោះ ។

ទោះជាយ៉ាងណាក៏ដោយយើងបានចាប់ផ្ដើមជាថ្មីម្ដងទៀត ជាមួយនឹងកម្មវិធីបណ្ដុះបណ្ដាលសម្រាប់ជនជាតិកម្ពុជា ដែលយើងមានបំណងចង់បន្តសម្រាប់រយៈពេលដប់ប្រាំ ឬម្ភៃឆ្នាំ។ ដោយសារការអប់រំនៅសាកលវិទ្យាល័យត្រូវការរយៈពេលបួនឆ្នាំ ហើយវគ្គសិក្សាជាន់ខ្ពស់មានរយៈពេលប្រាំមួយឆ្នាំ នោះគឺយើងត្រូវការរយៈពេលសរុបដប់ឆ្នាំ។ ការបណ្ដុះបណ្ដាលជាក់ស្ដែងមានជាអាទិ៍ ដូចជាកម្មវិធីបណ្ដុះបណ្ដាលនៅមូលដ្ឋានត្រូវការរយៈពេលប្រាំឆ្នាំ ហើយក្រៅពីនេះនិស្សិតចាំបាច់ត្រូវធ្វើអង្កេតវាស់វែង និងជួសជុលប្រាសាទផ្សេងៗទៀត ដើម្បីទទួលបាននូវបទពិសោធន៍ និងធ្វើការសិក្សាទូលំទូលាយមួយ។ ក្រៅពីនេះពួកគេត្រូវទទួលចំណេះដឹងច្រើនជាងនេះខាងបច្ចេកទេស និងការអនុវត្តន៍ការងារជួសជុលវិញនេះផងដែរ ។

ប្រវត្តិ និង សង្គម

នោះគឺសរុបមានរយៈពេលម្ភៃឆ្នាំ ដែលជាកម្មវិធីរយៈពេលវែង។ មជ្ឈមណ្ឌលវប្បធម៌ និងបណ្តុះបណ្តាល Sophia (ភូមិទ្រាំងខ្ញុំ) ខេត្តសៀមរាបនៅតំបន់អង្គរត្រូវបានបង្កើតឡើងសម្រាប់សិក្ខាកាមកម្ពុជា។ ក្រុមសាស្ត្រាចារ្យអន្តរជាតិមកពីប្រទេសជប៉ុន បារាំង អូស្ត្រាលី បែលហ្ស៊ិក និងសហរដ្ឋអាមេរិក ធ្វើការបង្រៀន ការបណ្តុះបណ្តាលផ្ទាល់នៅក្នុងមូលដ្ឋាន និងឧទ្ទេសនាម នៅឯមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់យើង ។

កម្មវិធីបណ្តុះបណ្តាល ហាក់ដូចជាមានរយៈពេលវែងពេកក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ និងមានតំលៃសម្រាប់ប្រជាជនកម្ពុជា។ យើងអញ្ជើញបណ្ឌិតមកពីប្រទេសដ៏ទៃទៀត និងធ្វើការពិភាក្សាគ្នា ជាមួយពួកគេនោះ មានជាអាទិបណ្ឌិតបារាំង អ្នកជំនាញការអូស្ត្រាលី និងអ្នកជំនាញការខាងច្បាប់ អ្នកជំនាញការបុរាណវិទ្យា និងខាងរុក្ខវិទ្យា។ ចំពោះការសិក្សាពីរុក្ខវិទ្យាមានសារសំខាន់ខ្លាំងណាស់សម្រាប់ការងាររបស់យើងនៅក្នុងព្រៃឈើតំបន់ត្រូពិច ។

ជាទូទៅ ក្រុមប្រាសាទអង្គរប្រើប្រាស់ថ្មជាចំបង ដូចជា : ថ្មភក់ ថ្មបាយក្រៀម និង ឥដ្ឋ ។ នោះគឺជាអ្វីដែលគេត្រូវសង្កេតមើលបច្ចុប្បន្ននេះ ទោះបីវាមានពិតតែក្នុងករណីប្រាសាទទាំងនោះក៏ដោយ ។ នៅក្នុងសម័យបុរាណ នៅជុំវិញប្រាសាទគឺជាអាគារធ្វើពីឈើជាច្រើន ឧទាហរណ៍ ព្រះរាជវាំង និងគេហដ្ឋានរបស់មន្ត្រីមួយចំនួន និងវត្តអារាម។ យើងឃើញមានភស្តុតាងនៃសំណង់ឈើ នៅក្នុងប្រាសាទថ្មដែលដំបូលធ្វើពីឈើ និងគ្រឹះធ្វើពីថ្ម ដែលនោះគឺជារបត់អន្តរកាលមួយប្រភេទនាសម័យកាលនោះ ។

វាជាការប្រសើរជាងក្នុងការដែលយើងផ្ទេរទៅជាកម្មវិធីរបស់កម្ពុជានូវជំនាញរបស់ជប៉ុន នៅក្នុងការជួសជុលប្រាសាទដែលធ្វើអំពីឈើ ក៏ដូចជាធ្វើអំពីថ្ម : វិធីសាស្ត្រ និងបច្ចេកទេសរបស់គេ និងជំនាញរបស់យើងខាងការថែរក្សា និងគ្រប់គ្រងប្រព័ន្ធកំព្យូទ័រ ។

ជនជាតិបារាំង បានផ្តល់នូវវិភាគទានរបស់គេតាំងពីឆ្នាំ១៩០៨ ហើយសាលាបារាំងចុងបូព៌ា the Ecole Française d'Extreme Orient (EFEO) បានចូលរួមនៅក្នុងការងារជួសជុលឡើងវិញចាប់តាំងពី ៦០ឆ្នាំមុនមកម្ល៉េះ។ វិធីសាស្ត្ររបស់បារាំងត្រូវបានគេចាត់ទុកថាល្អបំផុតសម្រាប់ការជួសជុល ហើយយើងសូមសរសើរចំពោះបច្ចេកទេសរបស់បារាំងនេះ ។ម្យ៉ាងទៀតកម្ពុជាធ្លាប់តែស្ថិតនៅក្រោមអាណានិគមរបស់គេ ឯកសារដែលទាក់ទិនទៅនឹងការងារសំណង់ ដូចជាប្លង់អត្ថបទគូរប្លង់ ផែនទីជាដើម ជាកម្មសិទ្ធិរបស់គេ ។

យូណេស្កូ ជាអង្គការឆ័ត្រសម្រាប់ក្រុមអង្កេតការណ៍អន្តរជាតិ

សាលាបារាំងចុងបូព៌ា EFEO ត្រូវបានគេពិគ្រោះយោបល់ជាមួយសម្រាប់ការងាររយៈពេលវែងនេះ ហើយបន្ទាប់ពីបារាំងមកអ្នករួមសហការណ៍ជាសំខាន់ៗរបស់យើង គឺមកពីមូលនិធិប្រាសាទពិភពលោកនៃក្រុងញូវយ៉កសហរដ្ឋអាមេរិក ជាក្រុមអង្គការក្រៅរដ្ឋាភិបាលវប្បធម៌ មួយទទួលបន្ទុកព្រះខ័ន ដែលជាប្រាសាទមួយនៅក្រៅអង្គរធំ។ ក្រុមឥណ្ឌូនេស៊ី ដែលកំពុងសហការជាមួយយើង គឺជាក្រុមរដ្ឋាភិបាលអមជាមួយអគ្គនាយកវប្បធម៌ នៅក្នុងក្រសួង អប់រំ និងអ្នកជំនាញការឥណ្ឌូនេស៊ីប្រាំពីរនាក់ មកពីទីក្រុងហ្សាកាតា កំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា។ ប្រទេសឥណ្ឌូនេស៊ីបានចូលរួមនៅក្នុងការងារជួសជុលចាប់តាំងពីឆ្នាំ១៩៧២ ហើយបទពិសោធន៍របស់គេក្នុងការថែរក្សាប្រាសាទបូរ៉ូប៊ូឌួរ (Borobudur) ដ៏ធំធ្វើអោយជំនាញរបស់គេខាងការងារថ្មមានតំលៃយ៉ាងខ្លាំង ។

មានក្រុមចំនួនពីរមកពីប្រទេសជប៉ុន : គឺក្រុមរដ្ឋាភិបាលជប៉ុនមួយសម្រាប់ការថែរក្សាអង្គរ (JSA) មកពីក្រសួងការបរទេសដែលពាក់ព័ន្ធទៅនឹងប្រាសាទបាយ័ន និងក្រុម Sophia ផ្ទាល់របស់យើង ដែលទទួលបន្ទុក ប្រាសាទបន្ទាយក្តី និងផ្លូវដើរខាងលិចនៃប្រាសាទអង្គរវត្ត។ ក្រុមទាំងនេះ ឥឡូវកំពុងស្ថិតនៅក្នុងខេត្តសៀមរាប ហើយកំពុងតែរួមចំណែកដល់ការងារជួសជុលនៅកម្ពុជាវិញ។ ក្នុងចំណោមក្រុមផ្សេងៗទៀត មានក្រុមអង្កេតវាស់វែងអង្គរមួយ មកពីប្រទេស

ធនធានមនុស្ស និងការអភិវឌ្ឍន៍វប្បធម៌ : ករណីសិក្សានៃប្រាសាទទាំងឡាយនៅអង្គរ

ដោយ បណ្ឌិត យ៉ូស៊ីអាគិ អ៊ិស៊ីហ្សាវ៉ា Dr. Yoshiaki Ishizawa

ហុងហ្គ្រី និងក្រុមចំរុះរួមមានអ្នកជំនាញការមកពីប្រទេសអ៊ីតាលី និងអាល្លឺម៉ង់ ដែលកំពុងធ្វើការនឹងប្រាសាទព្រះគោ និងប្រាសាទប្រែរូប ។ អង្គការយូណេស្កូ បំរើការជាអង្គការតែមួយសម្រាប់ក្រុមអង្កេតវាស់វែងអន្តរជាតិផ្សេងៗ ដោយបានផ្តួចផ្តើមគំនិតរៀបចំ សន្និសីទរបស់គណៈកម្មាធិការបច្ចេកទេសរៀងរាល់ឆ្នាំ ដើម្បីអនុញ្ញាតអោយក្រុមផ្សេងៗរាយការណ៍ជូនពីសកម្មភាពការងាររបស់ពួកគេ ។

យើងក៏បានទទួលកិច្ចសហការពីរដ្ឋាភិបាលកម្ពុជា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈភ្នំពេញ និងអ្នកជំនាញការកម្ពុជាជាច្រើន ដែលបានចូលរួមនៅក្នុងការងារស្រាវជ្រាវ និងបង្រៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់យើង ។ ទោះជាយ៉ាងណាក៏ដោយ យើងប្រឈមមុខនឹងកង្វះខាតពេលវេលា និងថវិកា : ឧទាហរណ៍យើងបានចូលរួមនៅក្នុងការងារអង្កេតយ៉ាងធំលើកដំបូង ចំណែកការបណ្តុះបណ្តាលនៅមូលដ្ឋានមានពេលវេលាកំណត់ ។ យើងអាចធ្វើការខិតខំប្រឹងប្រែងអោយអស់ពីសមត្ថភាពដើម្បីទទួលបានលទ្ធផលអោយបានឆាប់ៗតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ប្រជាជនជប៉ុនត្រូវការរៀនសូត្រពី ប្រជាជននៃទ្វីបអាស៊ី

ដោយមានការចូលរួមពីប្រជាជនខាងក្រោមនេះ យើងនឹងបើកកម្មវិធីបណ្តុះបណ្តាលអន្តរជាតិជាបន្តបន្ទាប់ : Arahi Hisao ជាស្ថាបត្យករជប៉ុន ថ្នាក់បណ្ឌិតមួយរូប នៃសាកលវិទ្យាល័យ Leuven ប្រទេសបែលហ្ស៊ិក កញ្ញា Marui Masako និង លោក Tabata Yukitsugu ជាបុរាណវត្ថុវិទូជប៉ុន ដែលជាបេក្ខជនថ្នាក់បណ្ឌិត នៅឯសាកលវិទ្យាល័យ Sophia និងកំពុងស្នាក់នៅខេត្តសៀមរាប និស្សិតបញ្ចប់ការសិក្សាប្រចាំឆ្នាំមកពីសាកលវិទ្យាល័យនានា មកដល់ក្នុងឋានៈជាអ្នកជំនួយការ និងអ្នកស្ម័គ្រចិត្តមកពីប្រទេសបារាំង កូរេ និងប្រទេសផ្សេងៗទៀត ។

ក្នុងកំឡុងកិច្ចប្រជុំ គេនិយាយភាសាអង់គ្លេស បារាំង ខ្មែរ ជប៉ុន ថៃ ។ល។ និង ។ល។ ប៉ុន្តែមានអ្នកបកប្រែ ។ មានភាសាការងារប្រមាណជាប្រាំមួយ ឬប្រាំពីរភាសា រាប់ទាំងភាសាបាហាសាឥណ្ឌូនេស៊ី និងភាសាខ្មែរ ដែលបន្ទាប់មកត្រូវបានគេបកប្រែជាភាសាផ្សេងៗ ។ ហេតុនេះ ត្រូវការចំណាយពេលវេលាច្រើន ក្នុងកិច្ចប្រជុំនីមួយៗ ដែលអូសបន្លាយរយៈពេលប្រហែលពីបីទៅបួនម៉ោង ។

ខ្ញុំចង់អោយក្មេងជំនាន់ក្រោយ និងជាពិសេសប្រជាជនជប៉ុនបានចូលរួមជាមួយយើងខ្ញុំ និងចូលរួមនៅក្នុងសកម្មភាពរបស់យើង ។ ទោះបីពួកគេមិនមែនជាអ្នកជំនាញក៏ដោយ ក៏ពួកគេនៅតែអាចរស់នៅក្នុងតំបន់អង្គរ និងជាជំនួយដល់គ្នាទៅវិញទៅមកបានដែរ ។ វាជាការចាំបាច់សម្រាប់យើងជាជនជាតិជប៉ុន ដើម្បីរៀនសូត្រពីវប្បធម៌អាស៊ីផ្សេងៗ និងពីប្រាសាទនានាដែលមានឥឡូវនេះ ប៉ុន្តែយើងក៏ចាំបាច់ត្រូវទាក់ទងជាមួយប្រជាជនក្នុងភូមិដើម្បីបានជាគំនិតសម្រាប់សកម្មភាពដែលគ្រប់គ្រងជីវិតរបស់គេដូចជាការធ្វើកសិកម្មលើវាលស្រែជាដើម ។ ទាំងនេះ គឺសុទ្ធតែជាបញ្ហាដែលមានចំណាប់អារម្មណ៍ដ៏ជ្រាលជ្រៅ ដែលយើងជាជនជាតិជប៉ុន ត្រូវរៀនសូត្រពីប្រជាជនអាស៊ីហើយវាជាអ្វីដែលខ្ញុំនឹងធ្វើសំណូមពរដល់ក្មេងៗជំនាន់ក្រោយ ។

សិល្បៈ និងសិប្បកម្មបុរាណសម្រាប់អនាគតកាល

ដោយ គីរី ស្គុលហ្ស៍ Kiri Schultz

ក្នុងនាមជាអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ លោកស្រី គីរី ស្គុលហ្ស៍ Kiri Schultz បំរើការងារជាអ្នកឯកទេសខាងសិប្បកម្មដោយដៃ និងជាអ្នកសំដែង សិល្បៈមួយរូប ជាមួយគម្រោង "ការចូលរួមរបស់សហគមន៍ នៅក្នុងតំបន់ការពារ" ក្នុងខេត្តសៀមរាប ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៨ និង ជាមន្ត្រីជំនួយការខាងកម្មវិធីវប្បធម៌ ជាមួយអង្គការយូណេស្កូក្នុងរាជធានីភ្នំពេញ ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ។ លោកស្រីមានសញ្ញាប័ត្រអនុបណ្ឌិត ខាងសិល្បៈ អាស៊ីអាគ្នេយ៍ និងបុរាណវត្ថុវិទ្យា មកពីសាលាសម្រាប់សិក្សាពីអាស៊ី និងអាព្រិច (Oriental and African Studies) នៃសាកល វិទ្យាល័យទីក្រុងឡុងដ៏ ។

នៅពេលឃើញប្រាសាទលើកទីមួយ ក្នុងចិត្តពោរពេញទៅដោយការចាប់អារម្មណ៍ និងកោតស្ញប់ស្ញែងដ៏អស្ចារ្យ ហើយវាទាល់តែចំណាយពេលវេលារាប់ខែឆ្នាំ ដើម្បីរុករកតំបន់នោះ ទើបគេអាចយល់ពីបញ្ហាសំាញុំដែលប្រឈមមុខនឹងស្ថាបត្យករនៅអង្គរបាន ។ នៅក្នុងសម័យកាលទំនើបនេះ ខ្ញុំមិនសរសេរអំពីកិច្ចការប្រឈមមុខនឹងស្ថាបត្យករខាងប្រាសាទទេ ប៉ុន្តែខ្ញុំសរសេរអំពីអ្វីដែលជាផែនការគ្រប់គ្រងរយៈពេលវែងសម្រាប់សំណង់បុរាណទាំងនោះ ។

ព្រះរាជក្រិត្យលេខ នស/រកត/០០១ ដែលឡាយព្រះហស្ថលេខាដោយសម្តេចព្រះនរោត្តម សីហនុ ក្នុងឆ្នាំ១៩៩៤ បានបង្កើតឡើងនូវអត្ថបទស្របច្បាប់ជាក់លាក់ទាក់ទិនទៅនឹងឧទ្យានបុរាណវត្ថុអង្គរ ។ នៅក្នុងគោលបំណងរយៈពេលវែងរបស់ខ្លួន អនុក្រិត្យនោះបានបញ្ជាក់យ៉ាងជាក់លាក់ពីការចូលរួមរបស់សហគមន៍នានា និងសិប្បកម្មរបស់គេនៅក្នុងការថែរក្សាតំបន់វប្បធម៌នៅក្នុងខេត្តសៀមរាប ។ ការបង្កើតអាជ្ញាធរអប្សរារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានត្រួតពិនិត្យដោយថ្នាក់ជាតិ ដោយក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុក វប្បធម៌ជាតិ កាន់តែជួយដល់ការត្រួតពិនិត្យរូបបដិមាទាំងនេះ ក៏ដូចជាអនុសាសន៍ទាំងឡាយដែលធ្វើឡើងក្នុងគម្រោងកំណត់ តំបន់ និងកំណត់ទីតាំងបរិស្ថាន (ZEMP) ។ ទាក់ទងទៅនឹងប្រធានបទនៃអត្ថបទនេះ របាយការណ៍សង្ខេបរបស់ ZEMP គាំទ្រដល់ការអភិវឌ្ឍន៍សកម្មភាពសេដ្ឋកិច្ច ដោយថ្លឹងថ្លែងជាមួយនឹងបរិស្ថាន ធម្មជាតិដែលនៅជុំវិញ និង

បោះពុម្ពដោយ រោងពុម្ព ស្ទឹងសង្គរ. ការិយាល័យ. ៤០ ផ្លូវ ១០៣៩ សង្កាត់ ភ្នំពេញ

សិល្បៈ និងសិប្បកម្មបុរាណសម្រាប់អនាគតកាល

ដោយ គីរី ស្គុលហ្ស៍ Kiri Schultz

ការទទួលបាននូវភាពចំរុះនៃវប្បធម៌ ជីវិតសត្វនិងរុក្ខជាតិ និងសេដ្ឋកិច្ច។ បំណងនៃផែនការទាំងនេះ គឺដើម្បីដោះស្រាយកង្វល់ដែលចេះតែបន្តនៃការធ្វើអោយមានស្ថេរភាពផ្នែកស្ថាបត្យកម្ម និងការងារជួសជុលនៅប្រាសាទផង និងដើម្បីទទួលស្គាល់នូវបរិស្ថានទូលំទូលាយជាងនេះដែលមាននៅជុំវិញប្រាសាទទាំងនោះផង។ បរិស្ថានទាំងនេះរាប់បញ្ចូលទាំងមនុស្សនៅក្នុងភូមិដែលនៅពាសពេញឧទ្យាននោះ ភូមិទាំងឡាយដែលមានសារសំខាន់ជាប្រវត្តិសាស្ត្រពិតប្រាកដ ដែលកំណត់ជាមុននូវការចូលរួមជាអន្តរជាតិ ហើយដែលមានប្រជាជនរស់នៅ ដែលមានទំនាក់ទំនងដ៏ជ្រៅទៅនឹងដី (រាប់បញ្ចូលទាំង "សត្វស្រុក និងសត្វព្រៃ") អ្នកតា (ជាពាក្យសាំញ៉ាំមួយ ដែលខ្ញុំបកប្រែថាជា "spirits" ជំនឿ, ព្រលឹង ទីនេះ) និងប្រាសាទនានាដែលនៅជាប់នឹងភូមិរបស់ពួកគេ ។

ការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ការពារ

ឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាជនទាំងឡាយនៅក្នុងរង្វង់ព្រំប្រទល់ឧទ្យានអង្គរ កម្មវិធីរបស់អង្គការអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ បានចាប់ផ្តើមនូវគម្រោងសាកល្បងមួយក្នុងឆ្នាំ១៩៩៥។ វត្ថុបំណងដំបូង របស់កម្មវិធីនេះ គឺដើម្បីធ្វើការដោយផ្ទាល់ជាមួយសហគមន៍គោលដៅដោយជួយដល់ពួកគេ ក្នុងការកំណត់ តំរូវការនិងដំណោះស្រាយ ខណៈពេលជាមួយគ្នានោះ គឺការពារបរិស្ថានធម្មជាតិ និងថែរក្សាសម្បត្តិវប្បធម៌ តែមួយគត់របស់តំបន់នេះ ។

គម្រោងដែលមានឈ្មោះថា "ការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ការពារ"[១] មានក្រុមមួយដែលមានសមាសភាពចំនួនដប់បីនាក់ ដែលសុទ្ធតែជាអ្នកឯកទេសជាតិ និងអន្តរជាតិ និងអ្នកធ្វើការនៅមូលដ្ឋាន។ ដោយដឹកនាំការងារមូលដ្ឋានរបស់ខ្លួនតាមរយៈការស្រាវជ្រាវសកម្មភាពចូលរួម បុគ្គលិកបានធ្វើការដោយផ្ទាល់ជាមួយអ្នកភូមិ នៅក្នុងភូមិប្រាំពីរ[២] ដែលមានប្រជាជនសរុបប្រមាណ ៨០៤៨ នាក់ ។

ការងារដំបូងដែលបានធ្វើឡើង ក្នុងដំណាក់កាលសាកល្បងពីរឆ្នាំគឺ១៩៩៥-១៩៩៧ ផ្តោតការយកចិត្តទុកដាក់ទៅលើការព្យាយាមស្គាល់អ្នកភូមិដោយបង្កើតជា "ដៃគូការងារ" នៅក្នុងភូមិនីមួយៗ និងការបណ្តុះបណ្តាល និងកំដរអ្នកភូមិក្នុងការធ្វើផែនទីសហគមន៍របស់ពួកគេ (ពីទំនាក់ទំនងក៏ដូចជាលក្ខណៈភូមិសាស្ត្រ) និងកំណត់តំរូវការខាងសេដ្ឋកិច្ចសង្គម ។ វិធីសាស្ត្រស្រាវជ្រាវដែលត្រូវបានប្រើប្រាស់តាំងពីពេលចាប់ផ្តើមមកនោះ គឺការស្រាវជ្រាវសកម្មភាពជាលក្ខណៈចូលរួម និងនៅឆ្នាំ១៩៩៧ សកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានមួយចំនួនបានកើតឡើង ដោយតំរូវទៅតាមតំរូវការរបស់មនុស្សម្នាក់ៗនៅក្នុងភូមិ ។

គោលដៅចំនួនពីរត្រូវបានជ្រើសរើសសម្រាប់អភិវឌ្ឍន៍ក្នុងដំណាក់កាលបន្ទាប់ គឺសមាសភាពបរិស្ថានមួយ និងមួយទៀតដែលផ្តោតទៅលើសិប្បកម្មដោយដៃ ។ ការចូលរួមរបស់ខ្ញុំជាមួយគម្រោងនេះ បានចាប់ផ្តើមឡើងនៅចុងរដូវប្រមូលផលក្នុងឆ្នាំ១៩៩៧ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយសមភាគីកម្ពុជា និងក្រុមការងារគម្រោងជាតិ ។

ទោះបីជាល័ក្ខខ័ណ្ឌយោងរបស់ខ្ញុំពីដំបូង មានគោលបំណងផ្តោតទៅលើសិប្បកម្មបុរាណ និងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូចក៏ដោយ ក៏ទំនាក់ទំនង និងការស្រាវជ្រាវជារៀងរាល់ថ្ងៃជាមួយអ្នកភូមិបាននាំមកនូវគម្រោងទាំងឡាយ ដែលមានគោលដៅផ្តោតទៅលើការសំដែងសិល្បៈបុរាណ។ ប្រជាជនចាស់ៗ នឹកឃើញឡើងវិញពីតន្ត្រីបុរាណមុនរបបខ្មែរក្រហម ហើយជាពិសេសតន្ត្រីករដែលលេងភ្លេងនៅក្នុងឱកាសនានាដូចជា ពិធីអាពាហ៍ពិពាហ៍ និងបុណ្យសពជាដើម។ ចំពោះហាងវីដេអូ ដែលមាននៅក្នុងភូមិ (បញ្ឆាំងដោយអាគុយឡានឬម៉ាស៊ីនភ្លើងដែលប្រើប្រេងសាំង) ក៏ដូចជានៅក្នុងក្រុងដែរ នៅពេលដែលយើងបានសាកល្បងសំដែងបែបបុរាណដោយផ្ទាល់ កុមារក្នុងភូមិហាក់ដូចជាចូលចិត្តនឹងការបង្ហាញពីវប្បធម៌ក្នុងស្រុកនេះណាស់។

កុមារស័ក្តិសមនឹងទទួលសិទ្ធិក្នុងការចូលរួមជាមួយការសំដែងសិល្បៈអំពីវប្បធម៌ផ្ទាល់របស់គេ ។ បើតាមការកត់សំគាល់ដោយសាមញ្ញនោះ គេនៅតែពិបាកនឹងរស់ជាថ្មីម្តងទៀតនៅក្នុងសង្គមក្រោយសង្គ្រាមមួយបែបនេះណាស់។ នៅពាសពេញប្រទេសកម្ពុជា ប៉ុន្តែប្រហែលជាពិសេសនៅអង្គរ ការរស់ឡើងវិញនូវវប្បធម៌បែបនេះបានហើយនឹងបន្តមានការលំបាកចំពោះមុខជាច្រើនទៀត។ ការលំបាកដ៏សំខាន់នោះ គឺថាតើការរស់ឡើងវិញបែបនេះ ត្រូវបានធ្វើឡើងជាពិសេសសម្រាប់ប្រជាជនដែលគ្រួសាររបស់គេធ្លាប់តែជាអ្នករស់នៅក្នុងខេត្តសៀមរាបជាយូរមកហើយ ឬត្រូវបានធ្វើឡើងដើម្បីបង្កើនចំនួនភ្ញៀវទេសចរអោយមកទស្សនាតំបន់នេះ ។

ប្រវត្តិ និង សង្គម



១/២/៣/ ការរស់ឡើងវិញនៃសិល្បៈប្រពៃណី និងតំលៃសាសនា ប្រមូលផ្តុំប្រជាជនក្នុងតំបន់អោយចូល រួមក្នុងការការពារថែរក្សា និងកែលំអសកម្មភាព តាមរយៈមហោស្រព និងតាមរយៈការសំដែងទស្សនា ដែលមានលក្ខណៈជា ល្ខោន ឬតន្ត្រី ។

ការសំដែងសិល្បៈ

នៅក្នុងភូមិមួយ ដែលធ្លាប់តែផលិតខ្លុយ (bamboo flutes) ដើម្បីលក់ទៅអោយភ្ញៀវទេសចរ នៅតាមប្រាសាទនានានោះ យើងបានចាប់ផ្តើមបើកថ្នាក់តន្ត្រីមួយនៅក្នុងសាលារៀនភូមិដែលបង្រៀនដោយគ្រូបង្រៀនតន្ត្រី ដ៏មានទេពកោសល្យម្នាក់ ។ ថ្នាក់រៀននេះរួមមានដំណើរទស្សនាចរដ៏ទៀងទាត់របស់កុមារ ទៅកាន់ផ្ទះរបស់មនុស្សចាស់ក្នុងភូមិម្នាក់ដែលបានលេងទ្រអ៊ូ និងនៅតែចងចាំយ៉ាងច្បាស់នូវការលេងតន្ត្រីបុរាណ និងតន្ត្រីពិធីអាពាហ៍ពិពាហ៍ ។ ដំណើរទស្សនកិច្ចចុះតាមមូលដ្ឋានក៏បានធ្វើឡើងទៅលើសាលារៀនពីរក្នុងខេត្តសៀមរាប ដែលគ្រប់គ្រងដោយមន្ទីរវប្បធម៌ខេត្ត ដែលទីនោះកុមារជក់ចិត្តយ៉ាងខ្លាំងជាមួយនឹងការហ្វឹកហាត់ជាក់ស្តែងនៃតន្ត្រី និងរបាំចំនួន៣ ។

នៅក្នុងថ្នាក់រៀនវិញកុមារបានស្តាប់ភ្លេងបុរាណភ្លេងប្រពៃណី និងភ្លេងការ និងថាតើភ្លេងបែបនេះ ផ្លាស់ប្តូរយ៉ាងណាខ្លះ (ផ្លាស់ប្តូរយ៉ាងខ្លាំង) តាំងពីទសវត្សឆ្នាំ១៩៦០ មក ។ ដោយបានផ្លាស់ប្តូរពីការស្វែងរីបអួសប្រចាំថ្ងៃ ដោយដើរលក់ខ្លុយឬស្សីអោយភ្ញៀវទេសចរ កុមារមានលទ្ធភាពអាចស្តាប់ និងស្វែងយល់ពីវប្បធម៌តន្ត្រីដោយខ្លួនឯងបាន ។

នៅក្នុងភូមិមួយផ្សេងទៀត គម្រោងនេះបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកដឹកនាំក្រុមរបាំត្រុដិ ដោយធ្វើសំណើមួយទៅអាជ្ញាធរខេត្ត ដើម្បីសំដែងនៅតាមប្រាសាទ ក្នុងពេលចូលឆ្នាំខ្មែរ ។ ត្រុដិគឺជាប្រភេទរបាំមួយពិសេស ប្រចាំខេត្តសៀមរាប[៩] ហើយនៅក្នុងភូមិនេះវាផ្សេងពីត្រុដិនាងម៉ៅ ដែលសំដែងដោយសិស្សនៃមន្ទីរវប្បធម៌ខេត្ត ។ របាំត្រុដិនេះ លេងដោយឧបករណ៍ដែលធ្វើអោយចាប់អារម្មណ៍ខ្លាំង ដូចជាប៊ី ស្គរ និងប្រម៉ាញ់ ដេញចាប់សត្វប្រើសដែលគេសំដែងជាប្រពៃណីពីផ្ទះមួយទៅផ្ទះមួយក្នុងភូមិ ហើយត្រូវបញ្ចប់នៅជុំចុងក្រោយនៅប្រាសាទ ។ យើងធ្វើការជាមួយក្រុមនោះ ដើម្បីបង្កើតជាដំណើរសម្តែងសិល្បៈ ពីកន្លែងមួយទៅកន្លែងមួយជុំវិញឧទ្យានអង្គរ ដែល ដំបូងរួមទាំងភូមិនោះផងដែរ បន្ទាប់មកភូមិជិតខាង និងពង្រីកជាវង្វង់ធំជាងនេះដោយសំដែងទៅកន្លែងប្រាសាទតែម្តង ។

ការស្រាវជ្រាវ និងការអភិវឌ្ឍន៍សិប្បកម្ម

គម្រោងដែលផ្តោតទៅលើសិប្បកម្មដោយដៃ ត្រូវបានបង្កើតឡើងខុសៗគ្នានៅក្នុងភូមិនីមួយៗ ។ ការស្រាវជ្រាវលើកដំបូងមានបំណងបង្កើតនូវប្រវត្តិរបស់សិប្បកម្មក្នុងភូមិនីមួយៗ មានទាំងការ

សិល្បៈ និងសិប្បកម្មបុរាណសម្រាប់អនាគតកាល

ដោយ គិរី ស្គុលហ្ស៍ Kiri Schultz



៤/ ការសិក្សាឡើងវិញពីទំរង់សិល្បៈបុរាណតន្ត្រីតាមគំរូនេះអាស្រ័យលើការស្តាបនាឡើងវិញ និងសកម្មភាពផលិតកម្មនៃឧបករណ៍តន្ត្រីប្រពៃណី ។

ប្រមូលសម្ភារៈ និងការនាំសម្ភារៈមកអោយ និងគំរូសង្គមនៃផលិតកម្ម និងការលក់ដូរ ។

ការចងចាំពីសង្គមមានភាពមិនច្បាស់លាស់ទាល់តែសោះចំពោះតំរូវការរបស់អ្នកស្រាវជ្រាវ ដែលពួកគេមានអារម្មណ៍គិតថា គេចាំបាច់ត្រូវការឈ្មោះ និងកាលបរិច្ឆេទជាក់លាក់ ក៏ប៉ុន្តែលទ្ធផលដ៏គួរអោយចាប់អារម្មណ៍មួយនៃការស្រាវជ្រាវរបស់យើង គឺការតាមដានមើលការត្បាញអំបោះនៅក្នុងភូមិបី ។ នៅក្នុងភូមិមួយនៅជិតនឹងបារាយណ៍ខាងលិច បុរសម្នាក់ស្លៀកសារុង៥ និងរំលឹកឡើងវិញនូវការត្បាញសារុងសូត្រនៅក្នុងភូមិរបស់គាត់ ។ ស្ត្រីចំណាស់ម្នាក់ទៀតនៅក្នុងភូមិជាមួយគ្នា នៅតែមានឧបករណ៍ត្បាញ ទោះបីជាគាត់មិនអាចមានលទ្ធភាពទិញវត្ថុធាតុដើមបានក៏ដោយ ។ នៅក្នុងភូមិមួយទៀតនៅតាមផ្លូវទៅកាន់បារាយណ៍ខាងកើតមានស្ត្រីចំនួនប្រាំបីនាក់ដែលចេះត្បាញ ។ ចំណេះដឹងរបស់ពួកគេ មិនមែនបានមកពីប្រវត្តិដ៏វែងនៃការត្បាញនៅក្នុងភូមិនោះទេ ក៏ប៉ុន្តែបានមកពីតំបន់ដែលពួកគេបានរស់នៅប្រមូលផ្តុំក្នុងសម័យខ្មែរក្រហម ។ នៅក្នុងតំបន់នេះ សមាគមណ៍តម្បាញត្រូវបានបណ្តុះបណ្តាល និងដាក់អោយធ្វើការត្បាញអំបោះនឹង (និងសូត្រ) ក្រមា ដែលជាប្រភេទក្រណាត់ម្យ៉ាងប្រើប្រាស់ដោយប្រជាជនទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ក្រៅពីស្ត្រីទាំងប្រាំបីនាក់នេះ មានស្ត្រីចំណាស់ពីរនាក់នៅក្នុងភូមិម្នាក់ដែលបានរៀនក្រុងកាលពី

ប្រវត្តិ និង សង្គម

ពេលគាត់នៅពីក្មេង និងម្នាក់ទៀតដែលពូកែខាងមូរធ្វើចេសកប្បាស ។

បំណងរបស់យើងនៅក្នុងការណែនាំពីការត្បាញឡើងវិញស្ថិតក្នុងបរិបទនៃកម្មវិធីអភិវឌ្ឍន៍សហគមន៍ដ៏ទូលំទូលាយជាងនេះ មិនធ្វើឡើងដូចៗគ្នានៅក្នុងភូមិទាំងអស់នោះទេ ។ ហើយក៏មិនណែនាំអោយប្រើនូវជំនាញមួយដូចជាការត្បាញសូត្រ ទៅដល់ភូមិទាំងឡាយដែលជាក់ស្តែងសេដ្ឋកិច្ចអាចប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យលើអាកាសធាតុ (នៅក្នុងតំបន់ដែលកសិកម្មដំណើរការដោយទឹកភ្លៀង) និងផលដែលប្រមូលបាននោះទេ។ ការត្បាញសូត្រអាចមានតំលៃខ្ពស់ ដើម្បីរក្សានូវការងារក្រៅរដូវមួយ អាចមិនទទួលជោគជ័យនៅពេលលក់ នៅពេលដែលតំបន់ដទៃទៀតនៃប្រទេសផលិតនូវសូត្រដែលមានគុណភាពខ្ពស់ "ហូល" ដោយមិននិយាយពីការផ្គត់ផ្គង់ក្នុងស្រុកតិចតួចសម្រាប់ដុំសរសៃសូត្រនេះផងទេ។ គម្រោងត្បាញកអំបោះ ត្រូវបានស្នើ និងតាក់តែងឡើង នៅក្នុងភូមិមួយហើយអង្គការ UNV បានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយគម្រោងសម្រាប់ការផ្តល់ឳកាសសម្រាប់ទិញគ្រាប់ ការផលិតឧបករណ៍ប្រើ និងឧបករណ៍សម្រាប់ត្បាញ ការទិញវត្ថុធាតុដើម និង (យ៉ាងហោចណាស់) ទំនាក់ទំនងចុងក្រោយទៅនឹងទីផ្សារ ។

សិប្បកម្មដែលមិនមែនធ្វើពីឈើធំៗផ្សេងៗទៀត នៅតែគេធ្វើនៅក្នុងភូមិ ដូចជាលបទ្រូចាប់ត្រី កន្ទេល ខ្លុយឬស្សី និង ស្នុកត្បាញពីស្លឹកត្នោត (ហើយជាញឹកញាប់ត្រូវបានប្រើប្រាស់ដើម្បីខ្ចប់ស្ករផែន) ។ សិប្បកម្មដែលប្រើប្រាស់ផលិតផលឈើ មានដូចជារទេះគោ ពូថៅ ដាវក្នុងស្រោម ត្រដោកគោ រនាត ទ្រអ៊ូ និង ទ្រសោ និងស្គរ ។ ដោយធ្វើការដើម្បីថែរក្សាតុល្យភាពរវាងសិប្បកម្មបុរាណ និងបង្កើតសិប្បកម្មថ្មីសម្រាប់ទីផ្សារ ក៏ដូចជាលើកទឹកចិត្តដល់ការផលិតផលិតផលមិនមែនឈើ សិក្ខាសាលានានាត្រូវបានធ្វើឡើងស្តីពីគំរូ និងការអភិវឌ្ឍន៍សិប្បកម្ម និងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ។ ដំណើរទស្សនកិច្ចចុះមូលដ្ឋាន ត្រូវបានរៀបចំឡើងទៅកាន់ប្រាសាទនានា ដែលទាក់ទិនទៅនឹងភូមិនីមួយៗ ក្នុងគោលបំណងដើម្បីសិក្សាពីគំរូនិងការប្រើប្រាស់ជាច្រើនរបស់វា នៅក្នុងជីវិតរបស់ប្រជាជននាសម័យកាលនោះ (ប្រាសាទបាយ័នគឺជាគំរូជាក់ស្តែង) ។

កម្មវិធី REPLIC ចាត់ចែងដោយ Chantiers Ecoles និងមន្ទីរអប់រំខេត្ត សហការធ្វើដំណើរទស្សនកិច្ចចុះមូលដ្ឋានទៅកាន់តំបន់របស់គេនៅទីក្រុងសៀមរាប និងទៅកាន់កសិដ្ឋានសូត្រនៅក្នុងស្រុកពួក ។ អ្នកភូមិធ្វើទស្សនកិច្ចសិក្សាទៅកាន់ទីផ្សារក្នុងក្រុងក៏ដូចជាហាងលក់សម្ភារៈសិប្បកម្មដោយដៃនៅជាយក្រុង ។ ការបណ្តុះបណ្តាលជំនាញសិប្បកម្មតែមួយគត់ ដែលត្រូវបានបើកឡើង គឺជាកន្លែងធ្វើក្រដាសកែច្នៃ[៦] នៅពេលគម្រោងសិប្បកម្មចំនួនពីរនៅរាជធានីភ្នំពេញកំពុងតែផលិតផលិតផលនេះ ហើយវាមិនមាននៅទីផ្សារខេត្តសៀមរាបទេ។

គេណែនាំដល់អ្នកភូមិអោយប្រើពាក្យពិសេសពីរ បើទោះបីជាមានអត្ថន័យមិនដាច់ដោយឡែកពីគ្នាក៏ដោយគឺពាក្យ "សិប្បកម្មដោយដៃ" និង "វត្ថុអនុស្សាវរីយ៍" ។ បុព្វបុរសរបស់គេបានរស់នៅក្នុងបរិស្ថានមួយ ដែលអាណានិគមនិយមបារាំងព្យាយាមអនុវត្តកសិដ្ឋានសូត្រ ដែលក្នុងនោះមានប្រវត្តិទេសចរណ៍អឺរ៉ុបមួយ តាំងពីឆ្នាំនានានៅដើមសតវត្សទី២០ ហើយដែលក្នុងនោះមានចំនួនភ្ញៀវទេសចរ (ជាពិសេសចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០) កាន់តែកើនឡើងមកពីទូទាំងពិភពលោក ។ អ្នកភូមិទទួលស្គាល់ជាទំលាប់ថាភ្ញៀវទេសចរចង់យកទៅផ្ទះវិញនូវបំនែកខ្លះជាតំណាង " វប្បធម៌ខ្មែរយើង " ដោយបាននិយាយថាភ្ញៀវទេសចរ ទិញសិប្បកម្មពីផ្សារពីព្រោះ ១) ពួកគេចូលចិត្តបំណែកនោះ ២) ពួកគេចង់ជួយអ្នកភូមិក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចរបស់គេ ៣) ពួកគេចង់ជួយអ្នកភូមិអោយស្រួលបួលឡើងវិញ ពីឆ្នាំក្រោមរបបខ្មែរក្រហម និង ៤) ពីព្រោះវត្ថុអនុស្សាវរីយ៍នោះនឹងធ្វើអោយគេនឹកឃើញកម្ពុជានៅពេលពួកគេត្រឡប់ទៅផ្ទះវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅកន្លែងណាដែលគំនូរ និងផលិតកម្មមានភាពច្របូកច្របល់ គេព្យាយាមវាយតំលៃពីលក្ខណៈនៃទីផ្សារ ។ យើងលើកទឹកចិត្តអ្នកភូមិអោយពិនិត្យមើលហាងនៅតាមទីផ្សារក្នុងស្រុក ដើម្បីមើលនូវអ្វីដែលមានដាក់លក់ក៏ដូចជាប្រៀបធៀបតំលៃ ។

សិល្បៈ និងសិប្បកម្មបុរាណសម្រាប់អនាគតកាល

ដោយ គីរី ស្គុលហ្ស៍ Kiri Schultz

ទីផ្សារ

នៅខណៈដែលធ្វើការស្រាវជ្រាវនៅភូមិប្រចាំថ្ងៃទៅលើប្រភេទសិប្បកម្មដែលបានផលិតសម្ភារៈដែលប្រើ និងសម្រាប់គោលបំណងអ្វីនោះ យើងបានពិនិត្យជាមួយអ្នកភូមិអំពីបរិស្ថានធំទូលាយជាងនេះនៅក្នុងឧទ្យាន និងនៅក្នុងទីក្រុងសៀមរាបផងដែរ ។ ក្រុមការងារគម្រោងបានបញ្ចប់នៅខែមករា ឆ្នាំ១៩៩៨ នូវការអង្កេតទីផ្សារនៃបរិស្ថានជុំវិញឧទ្យាន និងក្រុង[៧] ។ នេះរួមមានការធ្វើជំរឿននៃតូបលក់ទំនិញដែលកំពុងតែដំណើរការនៅជិតប្រាសាទនៅពេលនោះ (ក៏ដូចជាអ្នកដែលលក់សិប្បកម្មនៅក្នុងប្រាសាទ ដែលយើងហៅថាជាអ្នកលក់ចល័ត) ហាងវត្ថុអនុស្សាវរីយ៍ក្នុងសណ្ឋាគារក្រុង "ផ្សារចាស់នៅជុំវិញស្ទឹងសៀមរាប និងផ្សារលើ (ផ្សារខាងលើដែលមិនសូវពឹងផ្អែកលើពាណិជ្ជកម្មជាមួយភ្ញៀវទេសចរប៉ុន្មានទេ តែសម្រាប់តំរូវការប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាដែលរស់នៅ និងប្រកបរបររកស៊ីតាមរយៈខេត្តពិសេសនេះ) ។

លទ្ធផលនៃការធ្វើអង្កេត គឺកាន់តែច្បាស់ចំពោះអ្នកដែលមកទស្សនាផ្សារសៀមរាបជាប្រចាំ : សិប្បកម្មដោយដៃ ដែលកំពុងត្រូវបានគេលក់ក្នុងខេត្តសៀមរាប អាចយកមកពីខេត្តផ្សេងៗនៃកម្ពុជា (ពោធិសាត់គឺជាខេត្តដែលបានផ្គត់ផ្គង់សិប្បកម្មច្រើនជាងគេក្នុងកំឡុងពេលសិក្សាស្រាវជ្រាវនេះ) ហើយកាន់តែច្រើនឡើងៗ សិប្បកម្មជាច្រើនមកពីតំបន់ផ្សេងៗនៃអាស៊ីអាគ្នេយ៍ ចេញពីការឆ្លងព្រំដែនផ្ទាល់នៅប៉ោយប៉ែត ឬតាមរយៈទីផ្សារ និងពាណិជ្ជករក្នុងរាជធានីភ្នំពេញ ។ សូម្បីនៅក្នុងព្រំប្រទល់ឧទ្យាន "អ្នកលក់ចល័ត" ហាក់បីដូចជាកំពុងតែលក់សិប្បកម្មកាន់តែច្រើនឡើង ដោយយកមកពីខាងក្រៅកម្ពុជាទៀតផង ។

កិច្ចការចំពោះមុខទាំងនេះ ដែលកំពុងតែប្រឈមមុខជាមួយជាងហត្ថករ និងសិប្បករនៅក្នុងភូមិ មិនមែនថ្មីទេ ។ ក្នុងកំឡុងឆ្នាំនៃការគ្រប់គ្រងរបស់បារាំងនៅឆ្នាំ១៩១៨ លោក Georges Groslier បានប្រយុទ្ធនឹងបញ្ហាពីរ ដែលនៅតែប្រឈមមុខចំពោះសិប្បករបុរាណនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងការបង្កើតសាលារៀនជាតិសិល្បៈកម្ពុជា លោកបានគាំទ្រដល់ការបង្កើតឡើងវិញនូវទំរង់សិល្បៈបុរាណ និងបដិសេធចោលនូវការប៉ុនប៉ងដើម្បីកែលំអនូវ "គំរូនៃទំនៀមទំលាប់"[៨] ។ លោក Groslier ក៏មិនបានព្យាយាមដាក់សិល្បៈអោយទំនេរដែរ ប៉ុន្តែបានឃើញសិល្បៈនៅក្នុងពិភពលោកមួយដែលទទួលឥទ្ធិពលតំរូវការរបស់អ្នកប្រើប្រាស់និងទីផ្សារ ដូច្នេះ ការបង្កើតឡើងនូវសាជីវកម្មកម្ពុជាមួយ "Corporations Cambodgiennes" គឺជាការភ្ជាប់ទំនាក់ទំនងរវាង ជាងហត្ថករជាមួយនឹងផ្នែកសាធារណៈ និងពាណិជ្ជកម្ម ។

វាមានសារៈប្រយោជន៍ក្នុងការកត់សំគាល់ថា ជិតមួយជំនាន់ក្រោយមក ការងារជាមួយជាងហត្ថករបុរាណ ជួបប្រទះនូវបញ្ហាដូចគ្នាជាច្រើន ។ នៅឆ្នាំដែលមានទឹកជំនន់ចំពោះរដូវប្រមូលផល អ្នកភូមិមិនអាចមានមធ្យោបាយធ្វើការផលិតសិប្បកម្មឡើយ ។ មានសម្ពាធសេដ្ឋកិច្ចសង្គមទៅលើបុគ្គលក្នុងការផលិតអ្វីដែលនឹងត្រូវលក់លើទីផ្សារ ហើយដូច្នេះដើម្បីចំលងនូវអ្វីដែលអ្នកជិតខាងអាចផលិតបាន ។ មានសម្ពាធទៅលើគ្រួសារក្នុងការបញ្ជូនកូនទៅដើរលក់វត្ថុអនុស្សាវរីយ៍នៅតាមប្រាសាទនានា ឬឈរនៅមុខប្រាសាទ សូម្បីតែនៅពេលដែលដឹងថាការសំរេចចិត្តបែបនេះអាចមានន័យថា យកកូនចេញពីសាលារៀនក៏ដោយ ។ មានសម្ពាធបរិស្ថានទៅលើជាងហត្ថករទាំងនេះ អោយលក់អ្វីដែលអាចជារបស់ល្អស្អាត នៅក្នុងផ្នែកជាច្រើននៃពិភពលោក ដូចជាចំលាក់ (ឈើខ្លឹមជាដើម) ប្រឆាំងនឹងអ្វីដែលមាននិរន្តនភាពខាងផ្នែកបរិស្ថាន (ដូចជាត្រដោកគោធ្វើពីឬស្សី) ។ មានសំម្ពាធខាងក្រៅពីទីផ្សារក្នុងក្រុងសៀមរាបដែលនាំមកនូវ សិប្បកម្មកាន់តែច្រើន មិនត្រឹមតែមកពីផ្នែកផ្សេងៗនៃកម្ពុជាទេ ក៏ប៉ុន្តែថែមទាំងប្រទេសដ៏ទៃទៀតនៅក្នុងតំបន់ផងដែរ នៅតែរីករាយធ្វើអោយភ្ញៀវទេសចរនៅមានជំនឿថា ពួកគេទិញសិប្បកម្មដែលធ្វើនៅក្នុងស្រុក ជិតៗអង្គរ ។

ការអភិវឌ្ឍន៍នូវជំនាញបច្ចេកទេស និងសហគមន៍អន្តរជាតិ

គេនឹងនៅតែត្រូវការការបណ្តុះបណ្តាលជំនាញបច្ចេកទេសខាងសិល្បៈបុរាណ នៅពេលដែលតំបន់សៀមរាបរីកដុះដាល និងបន្តតំរង់ខ្លួនទៅកាន់សហគមន៍ធំទូលំទូលាយជាងនេះ ។ ប្រាសាទនានាគឺជា

ប្រវត្តិ និង សង្គម

ភស្តុតាងយ៉ាងប្រត្យក្សនៃជំនាញមួយ ដែលត្រូវបានអភិវឌ្ឍន៍ឡើងនៅជុំវិញខេត្តសៀមរាប ពីដើមសតវត្សទីប្រាំបួន (ប្រសិនបើមិនមានមុននេះទេ) : ចំលាក់ថ្ម ។ ចំលាក់ដ៏ល្អនៅលើថ្មដុត (ដូចជាស៊ីម៉ងត៍ត្រើម) និងបន្ទាប់មកទៀតមានថ្មភក់ ក៏ដូចជាភាពពិតប្រាកដដែលគេត្រូវការសម្រាប់កាត់ថ្មបាយក្រហម សំដៅទៅលើជំនាញដែលសិប្បករមាននៅពេលនោះ និងបង្ហាញថាជំនាញបន្ថែមទៀត ត្រូវតែមានក្នុងការឆ្លាក់ឈើ ។

ទោះបីជាការបណ្តុះបណ្តាលបែបនេះហួសពីដែនកំណត់របស់គម្រោងអង្គការ UNV[៤] ក៏ដោយ ក៏ការបណ្តុះបណ្តាលនៅថ្នាក់កណ្តាល និងជំនាញខាងសិល្បៈបុរាណដូចជាការឆ្លាក់ថ្ម ត្រូវបានបង្កើតឡើងនៅក្នុងខេត្តសៀមរាប ក្រោមកម្មវិធី REPLIC ដែលផ្តល់មូលនិធិដោយសហគមន៍អឺរ៉ុប ។ សម្ព័ន្ធរបស់ Chantiers Ecoles d'Angkor (ស្ថាប័នសាធារណៈមួយដែលបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡាកម្ពុជា និងសម្ព័ន្ធបង្រៀន និងអប់រំអចិន្ត្រៃយ៍បារាំង) និងបណ្តាញនៃរោងជាងជនបទ "Les Artisans d'Angkor" គម្រោងផ្តល់នូវការបណ្តុះបណ្តាលជំនាញ ដល់សិប្បករនាពេលអនាគត ការធ្វើពាណិជ្ជកម្មផលិតផល និងទីផ្សារ (ការរកទីផ្សារ) ក៏ដូចជាជំនួយដល់ការតាំងទីលំនៅថ្មី (ដែលទើបនឹងអនុវត្តថ្មីៗនេះ) និងកូនជាង ដល់សិស្សដែលបានទទួលសញ្ញាប័ត្ររួចវិលត្រឡប់មកកាន់ភូមិរបស់គេវិញ ។

ទាំងគម្រោង REPLIC ទាំងគម្រោងរបស់អង្គការ UNV មានលក្ខណៈអន្តរជាតិខាងផ្តល់ថវិកា និងការធ្វើផែនការ បានព្យាយាមផ្តល់ជាកិត្តិយស និងថែរក្សាសម្ផស្ស និងសារៈសំខាន់នៃជាងហត្ថកម្មបុរាណ នៅក្នុងតំបន់មួយដែលឫសគល់នៃសិល្បៈល្បីៗ មានភាពច្បាស់ក្រលែតនៅក្នុងប្រាសាទអង្គរ ។ វានឹងមានសារៈសំខាន់ចំពោះកម្មវិធីបែបនេះ ដើម្បីបន្តនូវការពិភាក្សាគ្នា ប្រសិនបើពួកគេត្រូវដោះស្រាយគំរូវរបស់សហគមន៍គោលដៅ អោយបានសមរម្យនោះ ។

ការងារនៃការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ការពារនៅតែមានគោលបំណងផ្តោតទៅលើថ្នាក់ភូមិ និងបានធ្វើការជាមួយជាងហត្ថករ និងគ្រួសាររបស់គេដើម្បីស្រាវជ្រាវសម្ភារៈ និងគំរូនៃផលិតកម្មដែលមាននៅក្នុងតំបន់ នៅចុងសតវត្សទី២០ ។ បរិស្ថាននេះស្ថិតនៅក្នុងសភាពនៃការប្រែប្រួល ទទួលរងឥទ្ធិពលផ្នែកមីក្រូសេដ្ឋកិច្ចនយោបាយ អាកាសធាតុ និងប្រហែលជាលើសពីគេទាំងអស់នោះ គឺទេសចរណ៍ ។ ការចូលរួមជាអន្តរជាតិប្រកបដោយការទទួលខុសត្រូវ និងយល់ពីតំរូវការ ជាមួយអ្នកភូមិនៅក្នុងសួនឧទ្យានវប្បធម៌បុរាណអង្គរ ត្រូវតែដោះស្រាយបញ្ហាទាំងនេះ និងចាំបាច់ត្រូវតែអោយប្រជាជនចូលរួមនៅក្នុងផែនការ ដែលនឹងជះឥទ្ធិពលដល់សហគមន៍របស់គេ និងជីវិតគ្រួសាររបស់ពួកគេ ។ សហគមន៍មនុស្សនៅក្នុងតំបន់អង្គរ ជាការពិតបានផ្តល់នូវប្រវត្តិសាស្ត្រ និងវប្បធម៌ហើយទាំងនេះគឺជាប្រជាជនដែលមានភាពវៃឆ្លាត និងសមត្ថភាពសំរបសំរួល ដើម្បីប្រឈមមុខនឹងអនាគតកាល ។

កំណត់សំគាល់

១ គម្រោង CMB/98/V04 ការចូលរួមទ្រទ្រង់សហគមន៍នៅក្នុងឧទ្យានអង្គរផ្តល់មូលនិធិដោយរដ្ឋាភិបាលជប៉ុន ត្រូវបានអនុម័តនិងចាប់ផ្តើម ។ គម្រោងនេះគឺជាការបន្តនៃគម្រោង CMB/93/V04 ការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ការពារ ។

២ ភូមិបួនក្នុងចំណោមភូមិទាំងប្រាំពីរនេះ ស្ថិតនៅខាងក្នុងឧទ្យាន និងភូមិមួយទៀតនៅក្នុងរង្វង់នៃឧទ្យានត្រូវបានបន្ថែមទៅក្នុងបញ្ជីនេះនៅក្នុងរយៈពេលពីរឆ្នាំនៃការអនុវត្តន៍គម្រោង ។ ភូមិផ្សេងៗទៀតត្រូវទទួលរងដោយបញ្ញត្តិរបស់រដ្ឋាភិបាលដែលគ្រប់គ្រងឧទ្យាន ទោះបីជាស្ថិតនៅឆ្ងាយពីប្រាសាទទាំងនោះក៏ដោយ ។ នៅពេលដែលភូមិទីប្រាំបីនេះ ត្រូវបានរាប់បញ្ចូល ចំនួនប្រជាជនសរុបនឹងកើតឡើងជិតដល់ទៅចំនួន ១០.០០០នាក់ ។

៣ ខ្ញុំសូមអរគុណចំពោះកិច្ចសហប្រតិបត្តិការ និងជំនួយដែលផ្តល់ដោយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជាគ្រូនិងសិស្សនៅសាលារៀនផ្ទាល់ ។

៤ក៏ដូចជានៅបាត់ដំបង និង ខេត្តសុរិន ប្រទេសថៃដែរ ។ សម្រាប់ការពិពណ៌នាពីប្រភេទសំដែង ក៏ដូចជាផ្នែកពាក់ព័ន្ធរបស់វា សូមមើល Toni Samantha Phim and Ashley Thompson, របាំនៅប្រទេសកម្ពុជា Dance in Cambodia, Oxford University Press, 1999.

សិល្បៈ និងសិប្បកម្មបុរាណសម្រាប់អនាគតកាល

ដោយ គីរី ស្គុលហ្ស៍ Kiri Schultz

៥ ជាធម្មតាត្បាញជាក្រឡាការូសម្រាប់ប្រើប្រាស់ដោយបុរស

៦ អ្នកភូមិចងចាំក្រដាសសំបកឈើ ដែលកំពុងធ្វើនៅក្នុងភូមិនៅមុនទសវត្សឆ្នាំ១៩៧០ ។

៧ ការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ដែលទទួលការការពាររបស់អង្គការ ការធ្វើអង្កេតទីផ្សារសិប្បកម្ម : សៀមរាប ខែមករា ឆ្នាំ១៩៩៨

៨ Penny Edward, Cambodge: ការធ្វើកសិកម្មរបស់ជាតិមួយ ឆ្នាំ១៨៦០-១៩៤៥ និក្ខេបបទបណ្ឌិត សាកលវិទ្យាល័យម៉ូណាស ១៩៩៩ ទំព័រ២១៧ ។ បណ្ឌិត Edwards ផ្តល់នូវការសំយោគដ៏គួរអោយចាប់អារម្មណ៍មួយនៃការជំរុញលើកទឹកចិត្តរបស់លោក Groslier នៅពីក្រោយការបង្កើតនាយកដ្ឋានវិចិត្រសល្បៈកម្ពុជា ក្នុងឆ្នាំ១៩១៩ (ដែលរាប់បញ្ចូលទាំងសាលារៀនសិល្បៈកម្ពុជា) សារមន្ទីរ Albert Sarraut ឆ្នាំ១៩១៩ និង ១៩២៤ the Ecole des Beaux Arts in Phnom Penh . អំណះអំណាងមួយដ៏មានតំលៃចំពោះការសាងសង់អត្ត សញ្ញាណ សិល្បៈមួយ និងស្ថាប័នរបស់វាក្នុងប្រទេសកម្ពុជា ក្នុងកំឡុងសតវត្សទី២០ គឺ : Ingrid Muan, និយាយពីអង្គរក្នុងអាយុកាលនៃការស្តារឡើង វិញ ១៩១៨-២០០០ និក្ខេប បទបណ្ឌិត សាកលវិទ្យាល័យ Columbia ២០០១ ។

៩ នៅខណៈដែលទាំងគម្រោងសិប្បកម្ម និង គម្រោងសិល្បៈសំដែង ត្រូវបានផ្តួចផ្តើមឡើងនៅក្រោមម្លប់ទូលំទូលាយជាងនេះនៃកម្មវិធីអភិវឌ្ឍន៍សហគមន៍ នៅក្នុងភូមិគោលដៅ ។

ការអភិវឌ្ឍន៍វប្បធម៌សង្គមតាមរយៈទំនាក់ទំនងអន្តរជំនាន់

ដោយ ណូបូ អិនដូ Nobuo Endo

Nobuo Endo ជាមន្ត្រីជាន់ខ្ពស់ខាងផ្នែកស្រាវជ្រាវ នៅវិទ្យាស្ថានវប្បធម៌អាស៊ី សាកលវិទ្យាល័យ Sophia ទីក្រុងតូក្យូ និងជាអ្នកជំនាញការវប្បធម៌មួយរូប ដែលត្រូវបានចាត់តាំងអោយធ្វើជាទីប្រឹក្សារបស់អង្គការ UNV ប្រចាំអាជ្ញាធរអប្សរា នៃរាជរដ្ឋាភិបាលកម្ពុជា ។ លោកទទួលបន្ទុកចំពោះការបង្កើតវិធីសាស្ត្រអភិវឌ្ឍន៍សហគមន៍ ដែលផ្តោតទៅលើមរតកវប្បធម៌ដោយប្រកាន់យកនូវវិន័យបែបវិស្វកម្ម ក្រោមចំណងជើងថា " វិធីសាស្ត្រវិស្វកម្ម តំបន់ប្រវត្តិសាស្ត្រ (HSEM) " ។ ចាប់តាំងពីឆ្នាំ១៩៩៣ លោកបានធ្វើការអនុវត្តន៍ HSEM នៅកម្ពុជាអោយទៅជាការថែរក្សា ការអភិវឌ្ឍន៍ និងការគ្រប់គ្រងឧទ្យានអង្គរដើម្បីទុកជា "តំបន់រស់រវើកមួយ" ។ ការបោះពុម្ពផ្សាយទាំងឡាយរបស់លោក រួមមាន : សៀវភៅដែលបាននិពន្ធជាមួយ Y. Ishizawa "ការសិក្សាស្តីពីការថែរក្សាវិមាន និងតំបន់នានា និងការអភិវឌ្ឍន៍វប្បធម៌សង្គម វិធីសាស្ត្រថ្មីមួយនៃវិស្វកម្មតំបន់ប្រវត្តិសាស្ត្រ វិទ្យាស្ថានវប្បធម៌អាស៊ី សកលវិទ្យាល័យ Sophia ទីក្រុងតូក្យូ ឆ្នាំ១៩៩៣ ។

ការអភិវឌ្ឍន៍សង្គមវប្បធម៌របស់សហគមន៍នៅក្នុងឧទ្យានអង្គរ

ឧទ្យានអង្គរនៅក្នុងខេត្តសៀមរាប គឺជាតំបន់នៃអត្តសញ្ញាណជាតិមួយសម្រាប់ប្រទេស និងប្រជាជនកម្ពុជា ។ ឧទ្យាននេះមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃផ្ទៃដីកម្ពុជា ហើយវាជាតំបន់មួយដែលពោរពេញទៅដោយប្រាសាទ និងតំបន់ប្រវត្តិសាស្ត្រជាច្រើនដែលភាគច្រើនត្រូវបានបង្កើតឡើងនៅក្នុងសតវត្សទី៩ ដល់ទី១៣ ។ ដោយសារត្រូវបានគេចុះឈ្មោះនៅក្នុងបញ្ជីមរតកពិភពលោកនៅឆ្នាំ១៩៩២ ឧទ្យាននេះត្រូវបានការពារដោយអាជ្ញាធរអប្សរាជាអង្គការមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងតែឆ្លើយតប ទៅនឹងតំរូវការក្នុងការត្រួតពិនិត្យ និងបន្ធូរបន្ថយសំពាធពីការអភិវឌ្ឍន៍សកម្មភាពឧស្សាហកម្ម និង ពាណិជ្ជកម្ម ក៏ដូចជាតំរូវការរបស់ប្រជាជនក្នុងស្រុកដែលកំពុងតែតស៊ូដើម្បីរក្សានូវទំនៀមទំលាប់រស់នៅបែបបុរាណរបស់ពួកគេ ។ ទាំងនេះនាំមកនូវការបង្កើតឡើង នូវតំបន់ដែលត្រូវបានទទួលការការពារចំនួនប្រាំកំរិត ។ ប្រជាជនប្រមាណជាហុកសិបបួនពាន់នាក់ (៦៤០០០នាក់) កំពុងតែរស់នៅក្នុងតំបន់ដែលទទួលការការពារ១ និង២ ។ នៅក្នុងឧទ្យានដែលមានទំហំប្រមាណបួនរយគីឡូម៉ែត្រការេនោះ អ្នកភូមិកំពុងរស់នៅជុំវិញប្រាសាទប្រវត្តិសាស្ត្រ និងសប្បាយរីករាយនឹងការប្រកបរបរកសិកម្ម

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

ការអភិវឌ្ឍន៍វប្បធម៌សង្គមតាមរយៈទំនាក់ទំនងអន្តរជំនាន់

ដោយ ណូប៊ូ អិនដូ Nobuo Endo

នៅក្នុងព្រៃជិតៗនោះ ។ ការការពារប្រាសាទ គឺជាទិដ្ឋភាពមួយនៃកម្មវិធីនេះ សមាសភាពមនុស្ស និងតំរូវការនូវសកម្មភាពអភិវឌ្ឍន៍យូរអង្វែងក៏ស្ថិតនៅចំចំណុចកណ្តាលនៃការខិតខំនេះដែរ ។

គម្រោងអភិវឌ្ឍន៍សហគមន៍មួយរបស់អង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិ ដែលមានឈ្មោះថា "ការចូលរួមរបស់សហគមន៍យូរអង្វែងនៅក្នុងឧទ្យានអង្គរ" ត្រូវបានអនុវត្តឡើងពីខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ខែមេសា ២០០១ ។ គម្រោងនេះគាំទ្រនូវសកម្មភាពចូលរួមពីថ្នាក់មូលដ្ឋានដោយអ្នកភូមិ ដោយមានគោលបំណងផ្តោតទៅលើការអភិវឌ្ឍន៍ដោយខ្លួនឯង ។ អង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិបានអញ្ជើញដៃគូថ្មីមួយពីប្រទេសជប៉ុន គឺ សកលវិទ្យាល័យ Sophia ទីក្រុងតូក្យូ ហើយចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៩មក ខ្ញុំបានចូលរួមជាមួយគម្រោងនេះ ដើម្បីអនុវត្តនូវវិធីសាស្ត្រ អភិវឌ្ឍន៍សហគមន៍មួយដែលផ្តោតទៅលើប្រាសាទនិងតំបន់អង្គរ ដែលមានឈ្មោះថា "វិធីសាស្ត្រវិស្វកម្មតំបន់ប្រវត្តិសាស្ត្រ (HSEM)" ។ HSEM ផ្តល់តំលៃទៅលើសហវិជ្ជមាននៃសមាសភាព ជាមូលដ្ឋាននៃសហគមន៍ចំនួនបី គឺ អ្នកភូមិ ប្រាសាទអង្គរ និងព្រៃឈើ សម្រាប់ការអភិវឌ្ឍន៍វប្បធម៌សង្គម ដែលសហគមន៍ទាំងឡាយនៅក្នុងឧទ្យានអង្គរចង់បាន ។

រៀនសូត្រពីអតីតកាលដ៏រស់រវើក

កើតនៅក្នុងបរិស្ថានមួយដែលគ្រប់គ្រងដោយច្បាប់ធម្មជាតិ បុរស និងស្ត្រីបានបង្កើតនូវវប្បធម៌របស់គេ ដោយប្រើវិធីផ្សេងៗ ជាបន្តបន្ទាប់ចំពោះបរិស្ថានធម្មជាតិ ។ ហេតុដូច្នេះវប្បធម៌រួមមានអ្វីៗទាំងអស់ទាំងមើលឃើញ (រូបិយ) និងមើលមិនឃើញ (អរូបិយ) ។ តាមបទពិសោធន៍ របស់បុព្វបុរសយើង គុណភាពដ៏ប្រសើរនៃស្មារតី និងសម្ភារៈនេះ ធ្វើអោយមាននូវជីវិតមួយប្រកបទៅដោយភាពសប្បាយរីករាយ និង កាន់តែសមរម្យថែមទៀត ។ យើងអាចរៀនសូត្រពីគំនិតភាពឆ្លាតវៃ ក៏ដូចជាជំនាញបែបបុរាណ ដែលពួកគេបានបង្កើតឡើង ជាផ្នែកៗនៃពតិមានវប្បធម៌ដែលបានរក្សាទុក និងបញ្ចូលទៅក្នុងបទពិសោធន៍ ការចងចាំ និង ភាពឆ្លាតវៃរបស់មនុស្សចាស់ៗគឺ "យាយ" និង "តា" ឬជីដូន និងជីតានៅក្នុងភាសាខ្មែរ ។

នៅក្នុងប្រទេសកម្ពុជា ប្រជាជនមានជំនឿថា ភាពចំណាស់ធ្វើអោយមនុស្សម្នាក់កាន់តែមានបញ្ញាឆ្លាតវៃក្នុងសកម្មភាព និងការវែកញែករកខុសត្រូវ ធ្វើអោយគាត់ក្លាយជាប្រភពនៃដំបូន្មានដ៏ល្អមួយ ។ ហេតុដូច្នេះ មនុស្សចាស់ត្រូវបានគេគោរពកោតក្រែងយ៉ាងខ្លាំង និងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសហគមន៍ ។ ជាទូទៅមនុស្សបីឬបួនជំនាន់ កំពុងរស់នៅជាមួយគ្នានៅក្នុងប្រទេសកម្ពុជា នៅក្រោមដំបូលផ្ទះតែមួយ ។ ការរៀបចំបែបនេះ ធ្វើអោយមនុស្សក្មេងៗ ទទួលបាននូវចំណេះដឹងដ៏មានតំលៃពីជីដូនជីតារបស់ពួកគេ តាមរយៈការផ្ទេរវប្បធម៌បុរាណពីមនុស្សចាស់ទៅមនុស្សក្មេងនៅក្នុងជីវិតប្រចាំថ្ងៃរបស់គេ ។ យើងអាចនិយាយដោយគ្មានការរារែកថា មនុស្សចាស់ គឺជាមនុស្សដែលពោរពេញទៅដោយធនធានសម្រាប់ការអភិវឌ្ឍន៍វប្បធម៌សង្គមរបស់សហគមន៍មួយ ។

សកម្មភាពរបស់*យាយតា*
នៅក្នុងករណីភូមិគោកត្នោត

HSEM បានស្នើសុំនូវសកម្មភាពយាយតា សម្រាប់គម្រោងសម្រាប់ការអភិវឌ្ឍន៍វប្បធម៌សង្គមរបស់សហគមន៍នៅក្នុងឧទ្យាន ។ សកម្មភាពយាយតា ត្រូវបានផ្តួចផ្តើមឡើងនៅក្នុងភូមិចំនួនបីជា គម្រោងសាកល្បង ។ ការបង្កើតក្រុមយាយតា នៅក្នុងភូមិគោកត្នោត គឺជាគំរូសកម្មភាពមួយនៅក្នុងគម្រោង ។

ភូមិគោកត្នោត ស្ថិតនៅចំងាយ២០ គីឡូម៉ែត្រពីក្រុងសៀមរាប ខេត្តសៀមរាប ភាគខាងជើងបារាយណ៍ខាងលិច ។ នេះគឺជាអាងស្តុកទឹករាងចតុកោណកែង ទទឹង២ គីឡូម៉ែត្រ និងបណ្តោយ៨គីឡូម៉ែត្រ សាងសង់ឡើងនៅក្នុងកំឡុងសតវត្សទី១០ និងទី១១ សម្រាប់ប្រជាជន និងកសិកម្ម ។ ប្រជាជននៃភូមិនោះ គិតត្រឹមខែមករា ឆ្នាំ២០០០ មានប្រហែល ១.៨៩០ នាក់ និង៣៤០គ្រួសារ ។ មានយាយតាចំនួន ១១០នាក់ អាយុលើសពី ៥០ឆ្នាំ ។

ប្រវត្តិ និង សង្គម



© By Courtesy of the author 1

© By Courtesy of the author 2

១/២/ ចំពោះប្រជាជនចាស់ៗនៅក្នុងភូមិ ការពិពណ៌នា និងការបង្ហាញពីបទពិសោធន៍ និងពីចំណេះដឹង គឺជាមធ្យោបាយក្នុងការលើកតម្កើងចំណេះដឹងប្រពៃណី ក៏ដូចជាការប្រតិបត្តិអនុវត្តន៍ក្នុងការផ្តល់ការចងចាំពីជីវិតរស់នៅអោយដល់កូនចៅជំនាន់ក្រោយ ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៩៩ កិច្ចប្រជុំមួយដើម្បីបង្កើតក្រុមយាយតា ត្រូវបានធ្វើឡើងនៅមជ្ឈមណ្ឌលប្រមូលផ្តុំសាធារណៈក្នុងភូមិគោកត្នោត ។ ប្រជាជនចំណាស់ៗប្រមាណជាហុកសិបនាក់ បានចូលរួមនៅក្នុងអង្គប្រជុំនោះ ។ ដើម្បីផ្តល់នូវបរិយាកាសដ៏រស់រវើកមួយដល់អង្គប្រជុំនោះ បទចំរៀងមួយដែលមានចំណងជើងថា "យាយតា" ត្រូវបានគេចាក់កំដរ ហើយយាយៗបាននាំគ្នារាំជារង្វង់ ។ ដោយឃើញពួកគេថ្មី និងអាចសប្បាយរីករាយបាន សកម្មភាពដំបូងទាំងនេះជំរុញអោយពួកគេទទួលបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព ក្នុងការរៀបចំសកម្មភាពក្រុម យាយតាផ្សេងៗទៀត ។ បន្ទាប់ពីការបង្ហាញនោះមក យាយតាដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ ត្រូវបានបែងចែកជាបីក្រុម គឺក្រុមខាងលិច ក្រុមកណ្តាល និង ក្រុមខាងកើត ។ បន្ទាប់មក បុគ្គលិកគ្រប់គ្រងចំនួនប្រាំពីរ ត្រូវបានជ្រើសរើសដោយការបោះឆ្នោតតាមលក្ខណៈប្រជាប្រិយ ធ្វើដោយមនុស្សចាស់ៗទាំងនោះក្នុងចំណោមពួកគេរួមមាន : ប្រធាន អនុប្រធាន ប្រធានដឹកនាំរដ្ឋបាល និងប្រធានដឹកនាំក្រុមតូចៗទាំងបី ។

ប្រធានដឹកនាំក្រុមតូចៗទាំងបី បានជ្រើសរើសឈ្មោះជានិមិត្តសញ្ញាសម្រាប់ក្រុមនីមួយៗពីផ្កានិងដើមឈើ ល្បីៗនៅកម្ពុជាដូចជា : "ផ្ការំចេក" សម្រាប់ក្រុមខាងលិច ផ្កាពណ៌ក្រហមដែលមានក្លិនល្អ គឺ "ផ្កាល្ហុង" សម្រាប់ក្រុមកណ្តាល ផ្កាពណ៌សនៃដើមស្វាយឈ្មោល គឺ "ស្វាយចន្ទី" សម្រាប់ក្រុមខាងកើត ជាផ្កាស ឬ ពណ៌លឿងនៃផ្លែស្វាយចន្ទី ។

តាម្នាក់ ជាគ្រូទាយ បានត្រឡប់ទៅផ្ទះគាត់វិញ ហើយមកវិញដោយមានសៀវភៅកំណត់ត្រាមួយ ។ នោះ ជាវិធីសម្រាប់រៀបចំអាពាហ៍ពិពាហ៍បុរាណ និងរូបភាពតុបតែងសម្រាប់ពិធីនោះ ។ គាត់បាននិយាយថា "ខ្ញុំសប្បាយរីករាយ ដោយមានឱកាសផ្ទេរចំណេះដឹងរបស់ខ្ញុំ អោយមនុស្សក្មេងៗនៅក្នុងសកម្មភាពនេះ" ។ លក្ខខ័ណ្ឌនៃអាយុសម្រាប់សមាជិកភាព គឺជាប្រធានបទមួយ ។ លោកយាយម្នាក់ បានស្នើសុំអោយមានអាយុលើសពី៥០ ឆ្នាំឡើងទៅ ក៏ប៉ុន្តែលោកយាយម្នាក់ទៀតបាននិយាយថា "ខ្ញុំអាយុ ៤៨ឆ្នាំ ប៉ុន្តែខ្ញុំចង់ចូលរួមជាមួយក្រុមជាសមាជិកពេញសិទ្ធិ " ។ សំណូមពររបស់គាត់ត្រូវបានគេទទួលយកធ្វើអោយល័ក្ខខ័ណ្ឌអាយុអាចបត់បែនបាន ។

ការអភិវឌ្ឍន៍វប្បធម៌សង្គមតាមរយៈទំនាក់ទំនងអន្តរជំនាន់

ដោយ ណូបូ អិនដូ Nobuo Endo

ការចាប់ផ្តើមដំណើរការណ៍ផ្ទេរចំណេះដឹងបុរាណ

ពីខែមករា ដល់ខែមីនា ឆ្នាំ២០០០ ក្រុមនីមួយៗ បានជួបប្រជុំហើយបំពេញនៅលើប័ណ្ណ "យាយ" ឬ "តា" ។ នៅលើប័ណ្ណនោះ គេមិនត្រឹមតែសរសេរតែឈ្មោះ និងថ្ងៃខែឆ្នាំកំណើតប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងមានសរសេរប្រធានបទទាំងឡាយដែលពួកគេចាប់អារម្មណ៍ និងមានជំនាញ ដែលនឹងត្រូវបំពេញដោយការធ្វើបទសម្ភាសន៍ជាក្រុម ។ រូបថតសំគាល់សម្រាប់ប័ណ្ណទាំងនេះ ត្រូវបានធ្វើឡើង ។ ប្រធានបទដែលពួកគេមានជំនាញ ត្រូវបានសរសេរចូល ហើយក្រុមនីមួយៗ បានជ្រើសរើសប្រធានបទមួយសម្រាប់សកម្មភាពតាមក្រុម ។

យាយតានៅក្នុងក្រុមខាងលិច ផ្តល់អាទិភាពយ៉ាងខ្ពស់បំផុតទៅលើសកម្មភាពក្រុមចំពោះតន្ត្រីបុរាណ ចំរៀងបុរាណ និងពិធីបុរាណនានា ។ ពួកគេក៏មានជំនាញនៅក្នុងផ្នែកផ្សេងៗ ទៀតដែរដូចជា តម្បាញបាក់បែបបុរាណ ត្បាញកន្ទេល និងកន្ត្រកផ្តៅ កិច្ចការពេទ្យឆ្មប ធ្វើទ្រូចាប់ត្រី ធ្វើអាចារ្យ (មនុស្សចាស់ដែលបំរើការនៅក្នុងវត្ត) ការការពារព្រាយបិសាច ធ្វើនំអាពាហ៍ពិពាហ៍បុរាណ និងការព្យាបាលរបៀបបុរាណ ។ល។ និង ។ល។ តាមរយៈជំនាញទាំងនេះ ពួកគេបានជ្រើសរើសយក " ការត្បាញកន្ទេលបុរាណធ្វើពីដើមរំចេក " ។ ក្រុមយាយ និងតាកណ្តាល បង្ហាញពីចំណាប់អារម្មណ៍របស់ពួកគេនៅក្នុងសកម្មភាពទាន់សម័យ ដូចជា : ភាពយន្ត កីឡា និង ភាពយន្តឯកសារវីដេអូ ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល និងស្តាប់ចំរៀងប្រជាប្រិយ ។ ប៉ុន្តែ តាមរយៈការបោះឆ្នោតពីការនិយមចូលចិត្ត ពួកគេបានជ្រើសរើសយកតន្ត្រីបុរាណពិណពាទ្យ សម្រាប់ពិធីព្រះពុទ្ធសាសនានានា ។ ដូចគ្នានេះដែរ ក្រុមខាងកើត បានជ្រើសរើសយក " ការត្បាញកន្ត្រក/កញ្ច្រែងបុរាណធ្វើពីផ្តៅ " ។

នៅក្នុងរដូវវស្សា ពីខែឧសភាដល់ខែតុលា យាយៗតាៗ រវល់នឹងការងាររបស់ពួកគាត់នៅផ្ទះ និងនៅក្នុងស្រែប៉ុន្តែ នៅឆ្នាំ២០០០ ក្រោយពីរដូវវស្សាកន្លងផុតទៅភ្លាម សកម្មភាពក្រុមយាយៗ តាៗ ក៏បានចាប់ផ្តើមម្តងទៀត ។ នៅខែវិច្ឆិកា សកម្មភាពគូរគំនូររបស់ក្រុមទាំងបី បានចាប់ផ្តើមនៅក្នុងភូមិគោកត្នោត ។ នេះគឺជាសកម្មភាពសម្រាប់ធ្វើជាឧបករណ៍ជំនួយ ដើម្បីពន្យល់ពីប្រធានបទរបស់ក្រុមទាំងបី ។ សម្ភារៈសម្រាប់គូររូបភាពដូចជាក្រដាស និងពណ៌ (ពណ៌ខ្មៅ ក្រហម បៃតង និង លឿង) ត្រូវបានរៀបចំ ។ ក្រដាសដែលអាចកែច្នៃឡើងវិញបានត្រូវបានទិញមកពីភូមិទឹកសែន ។ សកម្មភាពធ្វើក្រដាសដែលអាចកែច្នៃបានទាំងនេះ ត្រូវបានផ្តួចផ្តើមឡើងជាសកម្មភាពបង្កើនប្រាក់ចំណូល ចាប់តាំងពីឆ្នាំ១៩៩៨ នៅក្នុងភូមិប្រាដាក និងភូមិទឹកសែន ។ ទំហំក្រដាសនោះគឺ ៧៣ សម X ៧៣ សម ។

មនុស្សចាស់ៗ បានព្យាយាមគូរគំនូរនៅលើក្រដាសនោះ ប៉ុន្តែការព្យាយាមលើកទីមួយគឺមិនបានលទ្ធផលអ្វីទេ ។ វាជាបទពិសោធន៍របស់មនុស្សចាស់ដំបូងក្នុងការគូរនេះ ។ ពីរសប្តាហ៍ក្រោយមក វគ្គគូរគំនូរលើកទីពីរត្រូវបានធ្វើឡើងប៉ុន្តែរយៈពេល២ម៉ោងមិនគ្រប់គ្រាន់ឡើយដើម្បីគូរគំនូរអោយបានចំនួនពីរក្នុងក្រុងនីមួយៗ ។ នៅដើមខែមករា ឆ្នាំ២០០១ ការព្យាយាមទីបីត្រូវបានធ្វើឡើងទៀត ហើយពេលនេះ ពួកគេបានបញ្ចប់ការគូររូបភាពមួយចំនួនរួមទាំងគំនូរពីរបន្ថែមដែលបង្ហាញអំពីរបៀបរស់នៅរបស់ប្រជាជននៅអតីតកាល និងបច្ចុប្បន្នកាលក្នុងភូមិគោកត្នោត ។

នៅចុងខែមករា ឆ្នាំ២០០១ នៅកន្លែងស្តុកស្រូវក្នុងភូមិការហ្វឹកហាត់សម្រាប់ការបង្ហាញពីវប្បធម៌ និងរបៀបរស់នៅបែបបុរាណត្រូវបានប្រារព្ធឡើង ដោយមានការចូលរួមពីមនុស្សចាស់ចំនួនសាមសិបនាក់ និងមានលោកយាយម្នាក់ មកពីភូមិប្រាដាកធ្វើជាអ្នកសង្កេតការណ៍ ។ ខ្ញុំបានបង្ហាញពីគំនិតរបស់ខ្ញុំទៅលើបច្ចេកទេសនៃការបង្ហាញនេះ ។ ជាអាទិ៍ "វិធីសាស្ត្រសំនួរ និងចម្លើយ" ដែលក្នុងនោះមនុស្សចាស់បង្ហាញសំនួរ និងចំលើយ ដែលត្រូវនឹងសំនួរនោះដល់កុមារ និងទស្សនិកជន ។ ខ្ញុំបានសំណូមពរអោយយាយៗតាៗ និយាយឃើតៗអោយខ្លាំងៗ និងច្បាស់ៗ ដោយចង្អុលទៅរូបភាព ដែលពួកគេបានរៀបចំជាមុនដោយប្រើឈើសម្រាប់ចង្អុល ។ អ្នកដឹកនាំក្រុមនីមួយៗ បានធ្វើតាមវិធីនេះ ហើយការហ្វឹកហាត់បានបង្ហាញអោយឃើញពីប្រសិទ្ធភាពក្នុងការរៀនសូត្រពីបច្ចេកទេសនៃការបង្ហាញ ។

ប្រវត្តិ និង សង្គម

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០១ គឺជាថ្ងៃប្រវត្តិសាស្ត្រសម្រាប់សកម្មភាពរបស់ក្រុមយាយតា ។ អ្នកចូលរួមមានវត្តមានសរុបចំនួនបីរយហាសិបនាក់ ។ មានអ្នកភូមិចំនួនមួយរយសែសិបនាក់ និងសិស្សចំនួនមួយរយកៅសិបនាក់ មកពីសាលាបឋមសិក្សាមួយក្នុងភូមិអមដោយគ្រូចំនួនបីនាក់ ។ ព្រះសង្ឃចំនួនប្រាំមួយអង្គ និងអ្នកស្រាវជ្រាវខ្មែរ និងអន្តរជាតិចំនួនម្ភៃនាក់ ក៏បានចូលរួមផងដែរ ។ អ្នកបង្ហាញជាយាយៗ ចំនួនបីនាក់ បានពន្យល់ពីសារៈសំខាន់ និងអត្ថន័យវប្បធម៌ និងរបៀបរស់នៅបែបបុរាណ ។ វិធីធ្វើកន្ទេលបុរាណ ក៏ដូចជាកន្ត្រក និងឧបករណ៍ភ្លេង ពិណពាទ្យត្រូវបានពន្យល់ ។ ខណៈដែលកុមារសប្បាយរីករាយនឹងការសំដែងរបស់ជីដូនជីតារបស់គេ ការបង្ហាញចំនួនបីមានឥទ្ធិពលយ៉ាងខ្លាំងទៅលើអ្នកចូលរួមទាំងអស់ ជាពិសេសទៅលើសិស្ស និងគ្រូបង្រៀន ។ គ្រូសាលាបឋមសិក្សាបានបញ្ជាក់ថា " ជីដូនជីតារបស់យើង គឺជាគ្រូនៃវប្បធម៌ និងរបៀបរបបរស់នៅបែបបុរាណរបស់យើង " ដែលធ្វើអោយយាយៗតាៗក្នុងភូមិគោកត្នោតកាន់តែពេញចិត្តនឹងសកម្មភាពរបស់គេជាងមួយឆ្នាំមកនេះ ។

ការបង្ហាញពី " សៀវភៅដែលផ្តោតទៅលើវប្បធម៌ " នៅក្នុងភូមិនីមួយៗ នឹងធ្វើជាប្រធានបទនៃសកម្មភាពនាពេលអនាគត ។ ការបង្ហាញនេះ នឹងត្រូវបានធ្វើឡើងដោយការប្រមូលនិង សរសេរជាពត៌មានវប្បធម៌ រួមទាំងប្រភពដើមនៃឈ្មោះនិងប្រវត្តិរបស់ភូមិនោះ ។ សៀវភៅទាំងនេះ នឹងត្រូវរក្សាទុកនៅក្នុងបណ្ណាល័យតូចមួយក្នុងភូមិ ជាសៀវភៅសិក្សាមួយស្តីពីវប្បធម៌ និងរបៀបនៃការរស់នៅបែបបុរាណរបស់ភូមិ ។ គេរំពឹងថា ចៅៗ នឹងត្រូវបានជំរុញលើកទឹកចិត្តអោយទទួលបាននូវពត៌មានវប្បធម៌ តាមរយៈការប្រើប្រាស់សៀវភៅទាំងនេះដែលសរសេរឡើងដោយជីដូនជីតា ដែលនឹងសប្បាយរីករាយក្នុងការរួមចំណែកដល់ការថែរក្សា និងការចំលងវប្បធម៌បុរាណ និងរបៀបនៃការរស់នៅបែបបុរាណដល់ចៅៗជាទីស្រឡាញ់របស់គាត់ ។ ពត៌មានវប្បធម៌នៅក្នុងសៀវភៅដែលផ្អែកទៅលើវប្បធម៌ដែលបានជ្រើសរើសមួយចំនួន នឹងត្រូវបានបកប្រែជាភាសាបរទេសផ្សេងៗ សម្រាប់ភ្ញៀវទេសចរ ។

ការជំរុញអោយមាននូវវប្បធម៌ដ៏រស់រវើកថ្មីមួយ

គេអាចនិយាយថា សហគមន៍មួយដែលមនុស្សចាស់ទទួលបាននូវជីវិតមួយដ៏សប្បាយរីករាយ គឺជាសហគមន៍មួយប្រកបដោយផា-សុខភាព ហើយដែលគេប្រាថ្នាចង់បាន ។ តើសកម្មភាពក្រុមយាយតាទាំងនេះមានន័យដូចម្តេច សម្រាប់ការអភិវឌ្ឍន៍សហគមន៍? នេះគឺជាសំនួរធ្ងន់ធ្ងរសម្រាប់យើង ។ ដូចដែលបានរៀបរាប់ខាងលើហើយថា តាំងពីបរមបុរាណមកយាយតាត្រូវបានគេគោរព ។ ពួកគេមានមុខងារទាំងស្មារតី និងការអនុវត្តន៍ ជាសមាជិកស្នូលនៅក្នុងគ្រួសារមួយ និងសហគមន៍មួយ ដោយសារតែបទពិសោធន៍ដ៏ច្រើន ចំណេះដឹងភាពវាងវៃ និងសុឆន្ទៈដែលពួកគេមាន ដើម្បីបង្រៀនមនុស្សក្មេងៗ ។ ដើម្បីធ្វើអោយសកម្មភាពទាំងនេះមាននិរន្តភាព និងមានលក្ខណៈជាប្រព័ន្ធ គេចាំបាច់ត្រូវរៀបចំមនុស្សចាស់ៗទៅជាក្រុមយាយតា និងសម្រាប់សកម្មភាពក្រុមយាយតាអោយគេអនុវត្ត មិនត្រឹមតែដោយសហគមន៍ក្នុងស្រុកប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងសម្រាប់អ្នកពាក់ព័ន្ធនានាដែរ ដូចជាអង្គការក្រៅរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសហគមន៍សាសនា ។

បើមុខងារសំខាន់ៗនៃការអប់រំតាមសាលារៀន គឺត្រូវផ្តល់ដល់សិស្សនូវចំណេះដឹង និងជំនាញជាមូលដ្ឋានដើម្បីទទួលបាននូវចំណេះដឹងនោះ ជំនាញដែលបានផ្តល់ដោយមនុស្សចាស់នៅក្នុងសហគមន៍ គួរតែត្រូវថែរក្សា និងផ្ទេរវប្បធម៌និងរបៀបរស់នៅបែបបុរាណ ។ មនុស្សក្មេងៗ អាចយល់ពីតថភាពនៃការរស់នៅ នៅក្នុងសហគមន៍ ។ ហើយនៅក្នុងដំណើរការណ៍នៃការអភិវឌ្ឍន៍នូវវិធីសាស្ត្រជាក់ស្តែងជាងនេះមួយ អោយទៅរកស្ថានភាពរស់នៅបែបទំនើប បង្កើតបាននូវវប្បធម៌រស់នៅថ្មីរបស់ខ្លួនគេផ្ទាល់ ។

សារមន្ទីរមួយនៃអារ្យធម៌អង្គរ : ក្តីសង្ឃឹម និងសំណើ

ដោយឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍

បច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អតីតអនុប្រធានទីពីរសភាជាតិកម្ពុជា ឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍ បានបញ្ចប់ការសិក្សាផ្នែកបូរាណវិទ្យា និងសារមន្ទីរវិទ្យានៅទីក្រុងប៉ារីស ប្រទេសបារាំង ។ តាំងពីដើមរហូតមក ឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍ បានចូលរួមយ៉ាងជិតដិតក្នុងការពិភាក្សាផ្សេងៗ ទាក់ទិននឹងលក្ខណៈនៃកម្មវិធីថែរក្សាការពារជាអន្តរជាតិ ។

កាលណាយើងនិយាយដល់តំបន់អង្គរ សម័យកាលអង្គរ ឬអារ្យធម៌អង្គរនោះ យើងកំពុងតែពោលសំដៅដល់ផ្នែកនៃភូមិសាស្ត្រ និងកាលវេលាមួយដែលមានទំហំធំជាងទំហំកម្ពុជាសព្វថ្ងៃនេះទៅទៀត ។ អារ្យធម៌អង្គរមិនបានចាប់ផ្តើមនៅគ្រិស្តសករាជ៨០២ ឬនៅលើតំបន់សព្វថ្ងៃនេះឡើយ ។ វាបានចាប់ផ្តើមរីកចម្រើនមុនសម័យកាលនោះទៅទៀត ហើយបានបន្តរហូតដល់ពេលដែលតំបន់នោះត្រូវបានគេបោះបង់ចោលនៅគ្រិស្តសករាជប្រហែលជា ១៤៣២ ។ រាជធានីខុសៗគ្នាមួយចំនួនបានរស់នៅ ឬរស់នៅដំណាលគ្នា ដូចមានតំបន់រលួសនៃសតវត្សទី៩ និងតំបន់ប្រាសាទកោះកេរនៃសតវត្សទី១០ ជាសាក្សីស្រាប់ ។ តំបន់អង្គរមានមនុស្សរស់នៅតាំងពីសម័យបុរេប្រវត្តិ យ៉ាងហោចណាស់ក៏តាំងពីយុគលោហៈដែរ ប្រមាណបួនប្រាំរយឆ្នាំមុនគ្រិស្តសករាជ ។ កំណាយនាពេលថ្មីៗដោយក្រុមសាលាបារាំងចុងបូព៌ានៅតំបន់ប្រាសាទព្រៃក្មេង និងប្រាសាទអកយំដែលសុទ្ធតែមុនសម័យអង្គរបានបង្ហាញអំពីនិរន្តភាពនៃប្រវត្តិនៃជនជាតិ និងអារ្យធម៌ទាំងប៉ុន្មានដែលបានវិភាគទានបង្កើតអារ្យធម៌អង្គរ ។ អាស្រ័យហេតុនេះនាំអោយឃើញថា វាមានអារ្យធម៌បន្តបន្ទាប់គ្នាមក ។

ក្របខ័ណ្ឌសារមន្ទីរវិទ្យាថ្មីមួយ

តើយើងអាចអោយនិយមន័យទៅលើទស្សនៈ និងក្របខ័ណ្ឌសារមន្ទីរវិទ្យានៃសារមន្ទីរអារ្យធម៌អង្គរដូចម្តេច? ភ្ញៀវទេសចរត្រូវការដឹងអំពីប្រវត្តិដ៏យូរលង់ដែលបានកើតមានមុនការស្ថាបនាប្រាសាទអង្គរ និងសារមន្ទីរនៃអារ្យធម៌អង្គរដែលនឹងធ្វើអោយមាន ការស្វែងយល់កាន់តែប្រសើរឡើងអំពីបរិបទ និងការអភិវឌ្ឍន៍របស់វា ។ ប៉ុន្តែតើកិច្ចការបែបហ្នឹងអាចស្ថិតនៅលើទស្សនៈសារមន្ទីរវិទ្យាអ្វី? តើបទបង្ហាញគួរតែតាមលំដាប់លំដោយពង្សាវតារ និងប្រវត្តិសាស្ត្រដែលស៊ីគ្នាជាមួយនឹងរចនាបថផ្សេងៗ និងដែលគ្របដណ្តប់ផ្ទៃដីមិនត្រឹម

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

សារមន្ទីរមួយនៃអារ្យធម៌អង្គរ : ក្តីសង្ឃឹម និងសំណើ

ដោយឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍

តែកម្ពុជាបច្ចុប្បន្ន ប៉ុន្តែថែមទាំងប្រទេសថៃ វៀតណាម និងលាវថែមទៀតដែរឬទេ? ឬថាតើគួរតែមានការផ្តោតអារម្មណ៍ទៅលើសម័យអង្គរដែលតាមអ្នកប្រាជ្ញបារាំងថា បានចាប់ផ្តើមនៅក្នុងឆ្នាំ៨០២ ជាមួយការយាងមកដល់នៃ ព្រះបាទជ័យវរ្ម័នទី២ និងដែលចប់ទៅវិញនៅប្រហែលជាឆ្នាំ១៤៣២ នៅពេលដែលមណ្ឌលនេះត្រូវបោះបង់ចោលដោយព្រះបាទចៅពញាយ៉ាតតែប៉ុណ្ណោះឬ? ប៉ុន្តែទោះបីជាផ្លូវដោះស្រាយចុងក្រោយត្រូវបានប្រើក៏ដោយ ក៏ក្របខ័ណ្ឌភូមិសាស្ត្រនៃអារ្យធម៌អង្គរលាតសន្ធឹងហួសព្រំដែនកម្ពុជាបច្ចុប្បន្នឆ្ងាយណាស់ ។ ភស្តុតាងបុរាណវត្ថុវិទ្យាត្រូវបានគាំទ្រដោយនិរុត្តិសាស្ត្រ ព្រោះឈ្មោះថា "អង្គរ" ដែលមកពីសំស្ក្រឹត នគរ (ទីក្រុង/ក្រុង) នោះត្រូវបានភ្ជាប់ទៅនឹងទស្សនៈបុរាណចំពោះពាក្យ arts ហើយ polis ដែលមានន័យថា ផ្នែកនៃដែនដីមួយជាប់រាជធានី ដែលបន្ទាប់មក លាតសន្ធឹងទៅដល់ដែនដីឯទៀតទាំងអស់ក្រោមការត្រួតត្រារបស់ខ្លួន ។

គោលបំណងរបស់សារមន្ទីរ

ប្រសិនបើសារមន្ទីរអារ្យធម៌ត្រូវបានបង្កើតឡើងលើមូលដ្ឋានឬកាលប្បវត្តិវិទ្យាបែងចែកប្រវត្តិសាស្ត្រតាមសម័យកាលដែលគ្របដណ្តប់ បុរេប្រវត្តិអង្គរសម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរ ឬកម្ពុជាកណ្តាលហើយចុងក្រោយកម្ពុជាសព្វថ្ងៃដែលយើងអះអាងថា ជាអ្នកទទួលមរតកនៃសម័យអង្គរ (បើយើងចង់សំរួលទស្សនៈនៃប្រវត្តិសាស្ត្រ) បន្ទាប់មកចម្ងល់មួយទៀតក៏កើតឡើងទាក់ទិននឹងទស្សនៈសារមន្ទីរសាស្ត្រដែលមានតួនាទីបង្ហាញពិព័រណ៍ដោយវិទ្យាសាស្ត្រ ឬដោយគិតដល់ការផ្សព្វផ្សាយចំនេះដឹងអារ្យធម៌នេះដល់អ្នកចេះដឹងសាមញ្ញ? ក្នុងករណីចុងក្រោយនេះកម្មវិធីនេះគួរក្រសោបនូវសកម្មភាពច្នៃប្រឌិតរបស់មនុស្សជាតិទាំងអស់ដោយផ្អែកលើទស្សនៈអារ្យធម៌ : ប្រវត្តិអក្សរសាស្ត្រព្រមទាំងប្រពៃណីទំនៀមទំលាប់ និងការសម្តែងសិល្បៈ និងវប្បធម៌រាប់បញ្ចូលទាំងសិល្បៈ ខាងវិជ្ជាធ្វើម្ហូប (ម្ហូបអាហារ) ដែលជាគ្រឹះនៃអារ្យធម៌ ។ ទំនាក់ទំនងរវាងលោកខាងកើត និងលោកខាងលិចដែលយើងឃើញមានឥទ្ធិពលចាប់ពីចុងសតវត្សទី១៥ ក៏ជាផ្នែកនៃប្រវត្តិសាស្ត្រអង្គរផងដែរព្រោះបានកើតចេញពីកំណត់ជាសាក្សីនៃពួកប័ទុយហ្គេ និងអេស្ប៉ាញ៉ុល នៅក្នុងសតវត្សទី១៦ និងសតវត្សទី១៧ ដូចជារបស់ម៉ីរមូតូ សាម៉ូរ៉ៃ ជប៉ុន និងយូរក្រោយមកសាសនទូតជនជាតិបារាំងលោកឪពុក សាល បូយ៉ឿវ៉ូក្ស៊ី (Charles Buillevaux) និងអ្នកធម្មជាតិវិទូជាតិបារាំង លោក ហង់រី ម៉ូហូត៍ (Henri Moht) នៅសតវត្សទី១៩។

ហើយយើងក៏មិនអាចមិនទទួលស្គាល់ប្រភពចិន ដែលត្រូវបានប្រើប្រាស់ដើម្បីប្រមូលឡើងវិញនូវប្រវត្តិសាស្ត្រតំបន់ និងដើម្បីបញ្ចេញអោយបានដឹងជាប្រាកដនូវសច្ចសីលភាពនៃសិលាចារឹកសំស្ក្រឹតដែលរៀបរាប់ពីប្រវត្តិសាស្ត្រដោយបោះបង់ចោលហេតុការណ៍កាលិក ។

ការធ្វើជាសារមន្ទីរវប្បធម៌មួយដែលជាឃ្លាំងឯកសារសាក្សីនៃអតីតកាលដែលកន្លងទៅយូរហើយ និងដែលទើបតែកន្លងទៅថ្មីៗ មិនមែនមិនសមស្របជាមួយតម្រូវការ ដើម្បីធ្វើជាកន្លែងមួយផងដែរសម្រាប់ការប្រជុំសិល្បៈ ដែលត្រូវបានជំរុញដោយទ្រង់ទ្រាយនៃបទបង្ហាញដ៏សមរម្យមួយសម្រាប់ភ្ញៀវចូលទស្សនាសារមន្ទីរ ដែលនឹងចូលមកស្វែងរកការសប្បាយ និងចំណេះដឹងថ្មីៗ ។ ដោយសារការប្រើបច្ចេកវិជ្ជាចក្ខុសោតទស្សន៍ ភ្ញៀវទេសចរ ជាពិសេសភ្ញៀវទេសចរក្មេងៗអាចក្លាយជាតួឯកសកម្ម និងមិនគ្រាន់តែជាអ្នកមើលអសកម្មនៃការរស់ឡើងវិញនៃអតីតកាលប៉ុណ្ណោះទេ ។

សារមន្ទីរ ឬវិទ្យាស្ថាននៃបច្ចេកវិជ្ជានៅ Washington D.C. ដែលមានមធ្យោបាយធំធេងសំរាប់អប់រំដោយការកំសាន្តស្របនឹងការប្រើប្រាស់ភាពយន្ត ដើម្បីបង្កើតអារម្មណ៍យល់ឃើញដូច ជាពិតយាត្រាដោយភាពយន្តឆ្លើយតបទៅការស្វែងរកការអស្ចារ្យ ដោយនាំវិញ្ញាណអ្នកទស្សនានៃវិចារណញ្ញាណ ។ យើងអាចស្រមៃឃើញដូច្នេះដែលយាត្រាឆ្ពោះទៅអតីតកាលនៃវិញ្ញាណយើងដោយមធ្យោបាយចក្ខុសោតទស្សន៍ ។ នេះគឺជាសុបិន្តចូលក្នុងអតីតកាល ដូចជាវិទ្យាស្ថានបច្ចេកវិទ្យា Washington D.C. នាំអោយយើងសុបិន្តទៅអនាគតកាល ។ ក្នុងន័យនេះដែរ សារមន្ទីរ បាសាដា នៃអារ្យធម៌ទាំងឡាយឆ្លើយតបទៅនឹងសុបិន្តចូលទៅអតីតកាលដោយមធ្យោយ ភាពយន្ត និងចក្ខុសោតទស្សន៍ ។ សារមន្ទីរនេះឆ្លើយតបទៅនឹងគំរោងការដែលយើងចង់និយាយច្រើនជាង = សារមន្ទីរវិទ្យាអង្គរ សារមន្ទីរ នៃអារ្យធម៌ ។

គម្រោងមជ្ឈមណ្ឌលទេសចរណ៍ដែលត្រូវបានដាក់សំណើដោយអាជ្ញាធរអប្សរា ដែលជាអ្នកទទួលខុសត្រូវតំបន់អង្គរ ចំពោះបេតិកភណ្ឌពិភពលោក ដែលគេបានកត់ប្រាសាទអង្គរទាំងឡាយចូលក្នុងបញ្ជីគេ (ដោយចូលរួមជាមួយសាជីវកម្មជប៉ុនមួយ) ឆ្លើយតបនឹងតម្រូវការមួយផ្នែកសម្រាប់ផ្លូវដោះស្រាយខាងសារមន្ទីរវិទ្យាដោយផ្តោតលើទស្សនៈអារ្យធម៌ ដែលអង្គរគឺជានិមិត្តសញ្ញានៃឈ្មោះដែលកើតចេញពីទីកន្លែងនេះ ។ អង្គរនឹងតែងតែជាឈ្មោះមួយដែលត្រូវនឹកស្រមៃឃើញជាមួយ ឬហួសការពិចារណាដល់ទំហំ និងកាលវេលា ។

ទំហំនៃបរិបទវប្បធម៌

ប្រវត្តិសាស្ត្រអង្គរ គឺជាប្រវត្តិសាស្ត្រនៃតំបន់ដ៏ធំបំផុតមួយផងដែរ ។ ទំនាក់ទំនងទៅវិញទៅមកឆ្លាស់គ្នាជាអរិភាព និងមិត្តភាព រវាងមហាអំណាចតំបន់ពោលគឺអង្គរ ឬកម្ពុជា និងចម្ប៉ា គេមិនអាចយល់បាន ដោយគ្មានការរៀបរាប់អំពីឥទ្ធិពលអារ្យធម៌ឥណ្ឌា និងទម្ងន់ផ្នែកនយោបាយវប្បធម៌ និងពាណិជ្ជកម្មចិនឡើយ ។ យើងក៏ត្រូវធ្វើការរៀបរាប់អំពីឥណ្ឌូចិនផងដែរ គឺថាតំបន់ភូមិសាស្ត្ររវាងប្រទេសឥណ្ឌា និងចិនដែលគ្របដណ្តប់ពិលិចទៅកើតនូវប្រទេសភូមា ថៃ (ឬសៀម) ម៉ាឡេស៊ី ឬផ្នែកនៃស្រីវិជ័យ ប្រទេសលាវ កម្ពុជា និងចម្ប៉ា ឬប្រទេសវៀតណាមសព្វថ្ងៃ ។ តំបន់ប្រជុំកោះដែលរាប់បញ្ចូលក្នុងតំបន់ទំនាក់ទំនងវប្បធម៌ គឺកោះជ្វា កោះសុម៉ាត្រា កាលីម៉ាន់ថាន (ប័រណេអូ) និងកោះសុឡាវេស៊ី (សិលិប៊ី) ដែលបង្កើតបានប្រទេសឥណ្ឌូនេស៊ីសព្វថ្ងៃ និងប្រជុំកោះហ្វីលីពីន ។ នៅក្នុងបរិបទសាសនា និងវប្បធម៌ដ៏ទូលំទូលាយនេះ ធម្មកេរ្រ្ត គឺប្រជាជន និងក្រុមជនជាតិភាគតិចផ្សេងៗគ្នាជាច្រើន បានប៉ះទង្គិចគ្នាដោយវាសនាដទៃទៀតពីគ្នា ។ ក្រុមជនជាតិមន-ខ្មែរ ជាផ្នែកនៃក្រុមអូស្ត្រូអាស៊ីបានបង្កើតផ្នែកតំបន់ឯកភាពមួយនៅក្នុងអាណាចក្ររៀងៗខ្លួនរបស់ពួកគេមុនការមកដល់នៃពួកឧត្តរ ។ នៅអែបជិតពួកគេ ពួកម៉ាឡាយូ (Malay) អ្នករកស៊ីឈ្មួញតាមសមុទ្រ និងចោរសមុទ្រ ដោយឱកាសបានតាំងទីលំនៅតាមឆ្នេរនៃទន្លេ អណ្ណាម (វៀតណាមកណ្តាលសព្វថ្ងៃនេះ) ប្រទេសម៉ាឡេស៊ី និងឥណ្ឌូណេស៊ីបច្ចុប្បន្ន ។ ពួកម៉ាឡាយូក៏បានបន្តទៅធ្វើប្រជាភិវឌ្ឍន៍នៅលើកោះម៉ាដាកាស្កាដ៏ឆ្ងាយផងដែរ ។ ក្រោយមកមានក្រុមជនជាតិចិនខាងត្បូង គឺពួកតៃស និងតៃខ្មៅដែលនៅតែរស់នៅលើទឹកដីវៀតណាមខាងជើង ប្រទេសថៃ និងលាវសព្វថ្ងៃ ហើយចុងក្រោយ គឺពួកយួនខ្លួនគេហ្នឹងឯង ឬតាមចិនហៅ ថាយូហោន និងតាមបារាំងថា ពួកអណ្ណាម ។ ឈ្មោះយួននេះមកពីពាក្យសំស្ក្រឹតយវនៈ ដែលកើតចេញពីជនជាតិយានីដ៏ឆ្ងាយដែលបានមកកាន់ប្រទេសឥណ្ឌាជាមួយព្រះបាទអាឡិចសាន់ឌឺព្រះមហាធិរាជ (Alexandre Le Grand) ។

ហើយសារមន្ទីរអារ្យធម៌អង្គរមិនអាចមិនទទួលស្គាល់នូវបញ្ហានៃពួកជនជាតិទាំងឡាយ ដែលមានមួយចំនួននៅតែរស់នៅក្នុងតំបន់អង្គរ និងដែលបានរួមចំណែកចំពោះការបង្កើតអង្គរបានឡើយ ។ មានពួកព័រ គួយ សំរែ ចារាយ និងភ្នងដែលត្រូវលើកយកមកនិយាយ ។ ក្នុងកំឡុងប្រវត្តិសាស្ត្រអង្គរ កាលពេលកន្លងទៅដ៏យូរ ហើយក៏មានព្រឹត្តិការណ៍បន្តបន្ទាប់នៃការធ្វើអន្តោប្រវេសន៍ពីប្រទេសឥណ្ឌាផងដែរ ប្រសិនបើគេពិចារណារឿងនាងសោមា ដែលជាបុត្រីនៃស្តេចនាគ និងព្រះអង្គម្ចាស់ព្រាហ្មណ៍នាមកោណ្ឌញ្ញដែលបានឈ្នះម្ចាស់ក្សត្រីយ៍ដោយសារអាវុធ និងសម្រស់មន្តស្នេហ៍ ហើយធ្វើអារ្យធម៌នីយកម្មចំពោះរូបនាង ដោយបោះក្រណាត់មួយផ្ទាំង ទៅបិទបាំងរាងកាយអាក្រាតរបស់នាង ។ មានព្រះអង្គកោណ្ឌញ្ញទី២ មួយទៀត ដែលគេបានពិពណ៌នានៅសតវត្សទី៥ នៃគ្រិស្តសករាជ ។

គេមិនអាចពិភាក្សាបញ្ហាប្រជាជន និងបរិបទវប្បធម៌ដែលពួកគេរស់នៅដោយមិនបានប៉ះពាល់បញ្ហាជំនឿ សាសនានិងទស្សនវិជ្ជាដែលតាមប្រពៃណីអាស៊ីនិងឥណ្ឌា ត្រូវផ្សារភ្ជាប់ទៅនឹងសកម្មភាពមនុស្សជាតិផ្សេងៗទៀត ដូច្នេះដែរនៅអាស៊ីគេមិនបែងចែករវាងវិស័យលោកិយ និងសាសនាទេ រវាងកាយ និងព្រលឹងតាមព្រះពុទ្ធសាសនានេប៉ាល់ និងទីបេដែរ ។ យោងតាមលោក ហ្សង់ ប៊ុសសិលិយេថា (Jean Boisselier) រូបសាស្ត្រសតវត្សទី១៣ នៃពោធិសត្វ អវលោកិតេស្វារៈនៅប្រាសាទបន្ទាយឆ្មារបានបង្ហាញថា ព្រះពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយចូលមកប្រទេសកម្ពុជាចេញពីប្រទេសក្រៅពីប្រទេសឥណ្ឌា និងសេរីលង្កាដោយផ្ទាល់គេមិនស្គាល់គំនិតព្រលឹងដូចនៅគ្រិស្តសាសនាមុនព្រះពុទ្ធ ។ ក្នុងន័យនេះសាសនាហិនយានក្នុងសាខាថេរវាទ ព្រះពុទ្ធសាសនាមហាយានបាននាំអោយមានឥទ្ធិពលលើខ្មែរយើងនាសតវត្សទី១៣ ជាពិសេសព្រះបាទជ័យវរ្ម័នទី៧... ផ្តើមពីជំនឿជីវចរដែលទទួលស្គាល់ពិធីបូជាលិង្គព្រះឥសូរ រហូតដល់ការពិភាក្សាលើបញ្ហាអាទិទេពអព្ភោហារិកដកចេញពីគម្ពីរវេទ ហើយរហូតដល់ព្រះពុទ្ធសាសនា ដែលវាសនាគ្រិស្តអាទិទេពចេញ អារ្យធម៌ទាំងឡាយបានកើតឡើង ហើយបានកំនត់ចង្វាក់កាល ដល់ជីវភាពអ្នកស្រុកដោយពិធីបុណ្យ និងទំនៀមទំលាប់របស់គេ ។ ប្រាសាទអង្គរវត្តនៅតែស្ថិតនៅជាមជ្ឈមណ្ឌលធុតុង្គនៃអ្នកកាន់ព្រះពុទ្ធសាសនាមួយអស់រយៈពេលជាយូរមកហើយ ជនជាតិជប៉ុនឈ្មោះ សាមូរ៉ៃ ម៉ូរីម៉ូតូ (Samurai Morimoto) ដែលបានមកទស្សនកិច្ចប្រាសាទអង្គរវត្តនៅសតវត្សទី១៧ បានយល់ថា វាជាឧទ្យាន ជេតពននៅក្នុងប្រទេសឥណ្ឌាជាទីកន្លែងដែលព្រះពុទ្ធបានគង់នៅមួយគ្រា ។ ជនជាតិសៀម ដូចជនជាតិខ្មែរដែរ បានបន្តគោរពប្រាសាទនេះជាច្រើនជំនាន់មកហើយ ដូចយើងអាចឃើញរូបចម្លាក់ព្រះពុទ្ធជាច្រើន នៅក្នុងថែវមួយនៃថែវជាច្រើនរបស់វា ។ អង្គរនៅពេលនោះ គឺជាទីក្រុងនិយមព្រះវិស្ណុ ត្រូវបានផ្លាស់ប្តូរមកជាវត្តព្រះពុទ្ធសាសនាមួយ ហេតុនេះទើបមានការបន្ថែមពាក្យ វត្ត ដែលមានន័យថា វត្តជាភាសាខ្មែរ ឬនគរវត្តជាភាសាបាលី ។

កំផែងនៃប្រាសាទអង្គរវត្ត និងកំផែងប្រាសាទបាយ័ន ផ្តល់ឯកសារយោងសំរាប់ប្រវត្តិសាស្ត្ររបស់ប្រជាជននៃតំបន់នោះ ប្រវត្តិសាស្ត្រនៃជនជាតិសៀម និងចាម ក្នុងចំណោមប្រជាជនដទៃទៀត និងប្រជាជននៃតំបន់ផ្សេងទៀត ដូចជាចិន ជាដើម ហើយនិងផ្តល់នូវឯកសាររូបភាពមួយ នៃការកើតមាននៃទំនាក់ទំនងរវាងប្រជាជនទាំងនោះ ដែលសុទ្ធតែជាការផ្តោតអារម្មណ៍ដ៏សំខាន់នៃវិធីសាស្ត្រអប់រំរបស់សារមន្ទីរនោះ ។

សារមន្ទីរមួយនៃអារ្យធម៌អង្គរ : ក្ដីសង្ឃឹម និងសំណើ

ដោយឯកឧត្ដម សឺន ស៊ូប៊ែរ្ដិ៍

១. ទិដ្ឋភាពសង្គ្រាម រួមជាមួយទិដ្ឋភាពជីវិតប្រចាំថ្ងៃនៅលើចំលាក់លើបន្ទៅប្រាសាទបាយ័ន (សតវត្សទី ១២-១៣)។ ក្នុងរូបចំលាក់នេះ ពួកចាមអាចសំគាល់បានដោយសារមានសំលៀកបំពាក់ អាវរឹបដៃវែង និងមួកដ៏ចម្លែកៗរបស់ពួកគេដែលមានទំរង់ជាផ្កាផ្កាប់មកក្រោម មកធ្វើសង្គ្រាមដើម្បីឈ្លានពានកាប់ប្រទេសកម្ពុជា។ គេអាចឃើញផងដែរនូវរូបជនជាតិចិន ដែលស្ថិតលើថ្មចំលាក់លើបមួយផ្សេងទៀត មានលក្ខណៈជាទិដ្ឋភាពក្នុងផ្សារ។





២/ ត្រូវបានបង្កើតឡើងនៅចុងសតវត្សទី១៩ ការអភិរក្សប្រាសាទអង្គរវត្តឥឡូវនេះ គឺជាសំណង់ទំនើបថ្មីមួយដែលបំពាក់ទៅដោយ មធ្យោបាយនៃការជួសជុលស្តារឡើងវិញសំខាន់ៗ ។
៣/បន្ទប់មួយនៃទិសក្តារៈបូជារបស់ខ្មែរនៅក្នុងសារមន្ទីរជាតិក្រុងភ្នំពេញដែល រក្សាសម្ភារកម្មវត្ថុបុរាណដ៏ដ៏ល្បីល្បាញ ។ ធម្មានរូបមនុស្ស គឺជាវត្ថុដ៏ប្រពៃ និង ជាទីពេញចិត្ត ដែលជាតំណាងអោយព្រះក្នុងសិល្បៈខ្មែរបុរាណដែលប្រកាន់នូវបទ ដ្ឋានធម្មាក់វិទ្យានៃព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ប៉ុន្តែក៏បង្ហាញផងដែរពីការងារ មួយចំនួននៃការបង្កើតថ្មីរបស់ខ្មែរ ។

ការពិចារណាសាមញ្ញមួយចំនួន

បញ្ហានៃលក្ខណៈបច្ចេកទេសមួយទៀត ទាក់ទិននឹងការសិក្សា សាកល្បងរបស់គម្រោងសារមន្ទីរ ក៏ត្រូវតែយកចិត្តទុកដាក់ផងដែរ : ភាពស៊ីសង្វាក់គ្នានៃសារមន្ទីរ និងសំភារៈសំណង់របស់វា ជាមួយនឹង បរិស្ថានដែលមានស្រាប់ នៅទីនេះមានបញ្ហា ៥ ឬ ៦ ដែលគេលើកជា សំនួរ = ១) សំណង់សារមន្ទីរ និងសំភារៈសំណង់កុំអោយទាស់នឹង បរិស្ថាន ២) រងជួសជុល និងបរិវេណដែលត្រូវមានក្នុងសារមន្ទីរនោះ ៣). សំភារៈបច្ចេកទេស និងអ្នកជំនាញដែលមានសកម្មភាពពេញ លេញ ៤) បញ្ហាអ្នកទទួលខុសត្រូវជាអ្នកជំនាញផង ៥) ការទំនាក់ ទំនងរវាងការគ្រប់គ្រងសារមន្ទីរនេះ និងអាជ្ញាធរអប្សរា ដែលទទួល ខុសត្រូវការការពារ និងការគ្រប់គ្រងតំបន់អង្គរ ៦) ទំនាក់ទំនងរវាង គំរោងនេះនឹងអភិរក្សប្រាសាទអង្គរទាំងឡាយ ។ ភាពអាចទទួលបាន នៃរោងជាងសំរាប់ការជួសជុល និងការងារស្តារឡើងវិញ ហើយនិង ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងការត្រួតពិនិត្យ ដែលស៊ីគ្នារបស់ពួកវា ។ មានសារសំខាន់ស្មើគ្នាដែរនោះ គឺទំនាក់ទំនង រវាងគម្រោងបែបនេះ ការគ្រប់គ្រងរបស់វា និងការការពារប្រាសាទ អង្គរនានា និងអាជ្ញាធរអប្សរា ដែលត្រូវការឱ្យនិយមន័យ និងប្រកាស ប្រាប់ឱ្យគេឯងដឹងឮ ។

តួនាទីរបស់សហគមន៍អន្តរជាតិ

ក្រោយពីសង្គ្រាម និងរបបផ្តាច់ការនិយមពីរទសវត្សមក ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ មានការចុះខ្សោយយ៉ាងខ្លាំង និងខ្វះធនធានចាំបាច់សំរាប់កិច្ចការមួយលើមាត្រដ្ឋាននេះ ។ មានតែសហគមន៍អន្តរជាតិតែប៉ុណ្ណោះដែលបានផ្តើមគំនិត និងរ៉ាប់រ៉ង ការទទួលខុសត្រូវ រាប់បញ្ចូលទាំងការទទួលខុសត្រូវហិរញ្ញវត្ថុសំរាប់ គម្រោងមួយបែបនេះ ។ ការបង្កើតគណៈកម្មាធិការសំរបសំរួលអន្តរ ជាតិសំរាប់កម្មវិធីការពារ ដែលមានបារាំង និងជប៉ុនធ្វើជាសហប្រធាន និងដែលមានអង្គការយូណេស្កូជាអ្នកផ្តល់លេខាធិការដ្ឋានបំពេញនូវតួនាទី ការនេះ។ គណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការដែលជួបប្រជុំគ្នា ពីរដងក្នុងមួយឆ្នាំ មានសមត្ថកិច្ចលើគ្រប់វិស័យតាមមធ្យោបាយណា មួយ ដែលទាក់ទងទៅនឹងការការពារតំបន់អង្គរ និងប្រវត្តិសាស្ត្រ របស់វា ។ តាមពិតអង្គរផ្តល់នូវគំរូដ៏អស្ចារ្យមួយនៃកិច្ចសហប្រតិបត្តិ ការអន្តរជាតិ : ប្រទេសបារាំងជាមួយសាលាបារាំងចុងបូព៌ាប្រទេស ជប៉ុន ជាមួយសកលវិទ្យាល័យសុភីយ៉ា និងភ្នាក់ងារសហប្រតិបត្តិការ

សារមន្ទីរមួយនៃអារ្យធម៌អង្គរ : ក្តីសង្ឃឹម និងសំណើ

ដោយឯកឧត្តម សឹន ស៊ូប៉ែរ្តិ៍

អន្តរជាតិជប៉ុន ឥណ្ឌូនេស៊ី ចិន សហរដ្ឋអាមេរិក ជាមួយមូលនិធិប្រាសាទពិភពលោក អាល្លឺម៉ង់ និង ហុងគ្រី ជាមួយមូលនិធិអង្គរ អង្គការទាំងអស់ចូលរួមក្នុងកម្មវិធីស្តារ និងធ្វើកំណាយបុរាណវិទ្យា ។

4 Hervé/Abbadie

៤/បទ្ទប់មួយក្នុងចំណោម បទប់សិល្បៈខ្មែរនៅសារមន្ទីរជាតិសិល្បៈអាស៊ីហ្គីរ៉ម៉េត នៅក្រុងប៉ារីស ក្នុងការដាក់តាំងបង្ហាញថ្មីរបស់គេ ។

កិច្ចសហប្រតិបត្តិការប្រចាំតំបន់គឺរតអាស៊ានគួរតែត្រូវបានគេពង្រឹងឡើង ការចូលរួមរបស់ប្រទេសអាស៊ានក្នុងការជួសជុលតំបន់អង្គរបច្ចុប្បន្នគួរអោយប្រាថ្នាចង់បានបំផុត ប៉ុន្តែយើងត្រូវការសង្កត់ធ្ងន់ថា ដោយសារប្រវត្តិសាស្ត្រថ្មីៗ និងដែលកន្លងទៅយូរហើយ ការមិនទុកចិត្តគ្នានៅខ្លាំងក្លាពេក យើងមិនអាចរំពឹងទុកនូវកិច្ចសហប្រតិបត្តិការបែបនេះបានទេ ។ បញ្ហាដែលមានសារសំខាន់បំផុតស្ថិតនៅក្នុងការបង្កើតដ៏ល្អិតល្អន់នូវគំនិតសារមន្ទីរវិទ្យាដោយយកចិត្តទុកដាក់ និងការវិវត្តន៍នៃការរៀបចំសារមន្ទីរសម័យបច្ចុប្បន្ននេះ ។ តើយើងមានច្បាប់មួយហើយ ឬនៅសំរាប់ការគ្រប់គ្រងសារមន្ទីរអារ្យធម៌ទៅតាមរបៀបនេះ? តើយើងចង់បានមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិ និងតំបន់មួយដោយមានបណ្ណាល័យ និងមជ្ឈមណ្ឌលឯកសារត្រឹមត្រូវ? ហើយហេតុអ្វីមិនមានមជ្ឈមណ្ឌលប្រត្យាស្ថាប័ន និងស្រាវជ្រាវបូរាណវិទ្យា នៃតំបន់ដែលមានសំភារៈទំនើបជាទីបំផុត អាចឆ្លើយតបទៅនឹងតំរូវការ នៃការពិសោធន៍វិទ្យាសាស្ត្រនៃការបូន ១៤ និងរបៀបឯទៀតៗនៃបច្ចេកទេសពិសោធន៍ដូចវិជ្ជាវាស់កាលតាមដើមឈើ ។ល។ ទោះយ៉ាងណាក៏ដោយសម្បត្តិមរតកខ្មែរគឺជាបញ្ហាដែលនាំអោយប្រជាជនកម្ពុជាមានកង្វល់ជាបឋម និងមុនគេបង្អស់ ។ អាស្រ័យហេតុនេះយើងមានបំណងធ្វើការសង់មតិមួយអំពីអារម្មណ៍របស់ប្រជាជនខ្មែរចំពោះប្រធានបទនោះ ពីព្រោះជំនាញរបស់អ្នកជំនាញអន្តរជាតិ ត្រូវតែស៊ីសង្វាក់គ្នាទៅនឹងតម្រូវការសង្គមនៃក្រុមប្រជាជនក្នុងការស្រាវជ្រាវ និងស្ថាបនាឡើងវិញនូវប្រវត្តិសាស្ត្ររបស់ពួកគេ ។

ក្នុងគ្រប់ករណីគោលគំនិតនៃសារមន្ទីរអារ្យធម៌របៀបនេះត្រូវស្ថិតនៅលើកង្វល់ដែលសំដៅទៅតែការមានប្រយោជន៍ ។ ស្ថាបត្យកម្មមិនត្រូវយកគំរូបទដ្ឋានរចនាបថនៃបច្ចេកទេសសាងសង់ប្រាសាទអង្គរ ឬវត្តអារាម ព្រះពុទ្ធសាសនា បើធ្វើអោយមានការិតដល់គំរោងដែលសំដៅទៅតែការមានប្រយោជន៍ ។ ក្រៅពីនេះល័ក្ខខ័ណ្ឌ អាកាសធាតុភាពខុសគ្នារវាងសំនើមនៃរដូវវស្សា និងភាពស្ងួតនៃរដូវប្រាំងបង្កើតជាបញ្ហាអភិរក្ស ដែលជាលក្ខណៈរបស់យើង ហើយខុសពីប្រទេសត្រជាក់ដូចជាប្រទេសកាណាដា ។ បញ្ហាម៉ាស៊ីនត្រជាក់ដែលនាំអោយបរិយាកាសក្នុងបរិវេណសារមន្ទីរមិនល្អចំពោះរូបវិចិត្រ រូបចំឡាក់ឬឈើ ។ បញ្ហាទូទៅនៃការអភិរក្ស និងថែរក្សានៅសារមន្ទីរកើតឡើងនៅទីនេះ ដូចជានៅតំបន់ទាំងមូលនៅអង្គរ ។

ដើម្បីសន្និដ្ឋានបញ្ចប់ប្រសិនបើស្ថាបត្យកម្ម គោថិក (Gothic) និងសិល្បៈគោថិក (Gothic) ដែលត្រូវបានបង្កើតឡើង និងអភិវឌ្ឍន៍នូវក្នុងតំបន់អ៊ីលដឺហ្វ្រង់ (Il-de-France) សំរេចបាននូវភាពស៊ីគ្នាផ្នែករចនាបថតាមរយៈការផ្សព្វផ្សាយទៅកាន់តំបន់ផ្សេងៗនៃទ្វីបអឺរ៉ុប ចំពោះវិសាលភាពដែលគេបាននិយាយថា សិល្បៈគោថិកគឺជាការបង្ហាញសិល្បៈ និងស្ថាបត្យកម្មបារាំងនៅក្នុងទ្វីបអឺរ៉ុបនោះ វិសាលភាពដូចគ្នា មានសម្រាប់សិល្បៈខ្មែរដែលគំនិតមេចេញខ្លួនជ្រាបដោយសាសនា បានជះឥទ្ធិពលលើផ្នែកខ្លះរបស់អាស៊ីប៉ែកអាគ្នេយ៍គឺចាប់ពីប្រទេសភូមា ដល់ចម្ប៉ា ពីវៀងចាន់ លាវ ដល់សមុទ្រចិនខាងត្បូង ។ ប្រសិនបើលោក លេអូប៉ូល សិនហ៊ោ (Léopold Senghor) បានប្រើពាក្យ ឱ្យលក្ខណៈជនជាតិខ្មៅ (negritude) ដើម្បីលើកំពស់កេរ្តិ៍ឈ្មោះ និងអត្តសញ្ញាណរបស់អាហ្វ្រិកស្បែកខ្មៅនោះពាក្យឱ្យលក្ខណៈជនជាតិខ្មែរ (Khmeritude) ដែលបានបង្កើតចេញពីប្រភពហ្នឹងហើយ បានបន្តក្នុងសេចក្តីសំដែងផ្សេងៗទៀត ឬបានជំនួសអារ្យធម៌ជាច្រើនដែលជាញាតិពួកមននោះ ក៏អាចត្រូវបានប្រើជាទស្សនៈមួយដើម្បីស្ថាបនាស្ថានប្រវត្តិសាស្ត្រជាតិ និងប្រវត្តិសាស្ត្រតំបន់ហើយអះអាងឡើងវិញនូវអត្តសញ្ញាណកម្ពុជា ក្នុងតំបន់ហួសព្រំដែនជាតិដូចគ្នាដែរ ។ គំនិតនៃវិធីសាស្ត្រសារមន្ទីរវិទ្យាដែលនឹងពិភាក្សាឡើងវិញនូវប្រវត្តិសាស្ត្រនៃអារ្យធម៌អង្គរនោះ គឺសមរម្យឥតខ្ចោះសំរាប់បង្ហាញនូវរយៈពេលជាច្រើនសតវត្សរបស់ប្រវត្តិសាស្ត្រ និង ភាពចំរុះនៃវប្បធម៌ដ៏អស្ចារ្យ ដែលបានផ្សព្វផ្សាយចេញពីចំណុចភូមិសាស្ត្រមួយតូចតែមានសារៈសំខាន់មួយនៅក្នុងលំហ : គឺអង្គរ ។

ពិធីបុណ្យក្នុងរឿងរាមកេរ្តិ៍ មរតកអង្គរដែលគ្មានរូបរាង

ដោយ សម្តេចរាជបុត្រី ព្រះរៀមនរោត្តម បុប្ផាទេវី

តាមរបៀបខ្មែរ រឿងរាមកេរ្តិ៍ ឬរ៉ាម៉ាយ៉ាណៈ ដែលជាបទនិពន្ធពាក្យកាព្យ ចំពោះភាពរុងរឿងនៃព្រះរាម ដែលលើកតម្កើងភាពយុត្តិធម៌នោះ មានវត្តមានច្រើនបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូចលោក បឺណាត ហ្វីលីប គ្រួសលីយេ (Bernard-Phillippe Groslier) ជាអ្នកអភិរក្សអង្គរម្នាក់ដែលបានបូជាកម្លាំងកាយចិត្តចំពោះការការពារ និងការពន្យល់បំភ្លឺអង្គរនោះ បានគូសបញ្ជាក់ថា "ដោយបានរួមចំណែកចំពោះប្រពៃណីភាសាសំស្ក្រឹតផង ចំពោះភាពថ្លៃប្រឌិតភាសាខ្មែរផង ការងារនេះ (រឿងរាមកេរ្តិ៍) គឺជារឿងមួយដែលតំណាងអោយសិល្បៈអក្សរសាស្ត្រខ្មែរដ៏ប្រសើរបំផុត ជាសិល្បៈមួយបែបដែលប្រមូលរួបរួមនូវសិល្បៈល្ខោន និងជាប្រភពមួយនៃការជំរុញទឹកចិត្តសម្រាប់វិចិត្រករជាច្រើន " ។

តាមពិត សព្វថ្ងៃនេះមានភស្តុតាងគ្រប់គ្រាន់នៃវត្តមាននេះទាំងតាមរយៈការសូត្រកំណាព្យ ដោយអ្នកនិទានរឿងបុរាណជាការសូត្រម្យ៉ាងដែលជួនកាលក្លាយទៅជាការសូត្របំពេរដោយអ្នកចម្រៀងនាពិធីបុណ្យតាមភូមិក៏មាន ឬតាមរយៈសិល្បៈល្ខោនផ្សេងៗ ដូចជារបាំកាយវិការ ល្ខោន របាំ និង នាដសាស្ត្រក៏មាន ។ លើសពីនេះទៀត វាគឺជា Corps de dance នៃរបាំព្រះរាជទ្រព្យដែលយើងបានស្តារជីវិត គុណភាព និងប្រជាប្រិយភាពក្រោមព្រះរាជូបត្ថម្ភជាបន្តរបស់ព្រះករុណា (ព្រះបាទ នរោត្តម សីហនុ វរ្ម័ន) ដែលបង្ហាញយ៉ាងច្បាស់នូវពលសម្បទានៃប្រពៃណីចំណាស់នេះ ។ ជាធម្មតា

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ពិធីបុណ្យក្នុងរឿងរាមកេរ្តិ៍មរតកអង្គរដែលគ្មានរូបរាង

ដោយ សម្តេចរាជបុត្រី ព្រះរៀមនរោត្តម បុប្ផាទេវី

របាំព្រះរាជទ្រព្យបង្ហាញនូវឈុត ឆាក ដ៏គួរអោយរំភើបបំផុតនៃរឿងរាមកេរ្តិ៍ ដែលនៅតែផ្តោតទៅលើតួអង្គព្រះរាម ការតស៊ូរបស់ព្រះអង្គ ជ័យជំនះនិងការអភិសេក ជាអវសានរបស់ព្រះអង្គព្រមទាំងបានផ្តោតទៅលើអគ្គមហេសីរបស់ព្រះអង្គ គឺនាងសិតាដែលទទួលរងនូវគ្រោះអកុសល និងការក្បត់ ទម្រាំតែដល់ពេលដែលគេទទួលស្គាល់នូវគុណធម៌របស់នាងជាចុងក្រោយ ។



Hans Liesen 1

១/ ប្រាសាទព្រះខ័ន (សតវត្សទី១២-១៣) នៅទិសឥសាន្តនៃប្រាសាទអង្គរ ផ្តល់មកនូវការតុបតែងបែបស្ថាបត្យកម្មប្រវត្តិសាស្ត្របុរាណសំរាប់ការសំដែងរបាំប្រពៃណីរបស់ព្រះរាជាណាចក្រកម្ពុជា ។

២/ ឈុត/ឆាក ក្នុងរឿងរាមកេរ្តិ៍ ផ្តល់លំដាប់រឿងល្ខោនរូបភាពសំរាប់ការរស់ឡើងវិញនៃជីវិតសិល្បៈជាពិសេសរោងល្ខោន ។ សុគ្រីព ដែលត្រូវបានបង្ហាញនៅទីនេះ គឺជាស្តេចស្វា ដែលចងសម្ព័ន្ធភាពជាមួយព្រះរាមដែលជាអ្នកសំលាប់បងរបស់ខ្លួនគឺ ពាលី ត្រូវបានគេឆ្លាក់រូបយ៉ាងធំជាចម្លាក់លិបនៅលើហោជាងនៃប្រាសាទអង្គរ ក្បាច់ចំលាក់លើជញ្ជាំងនៃគោពុរៈ នៅប្រាសាទបន្ទាយស្រី ។ (ពាក់កណ្តាលទី២សតវត្សទី១០)

រូបសាស្ត្រអង្គរបញ្ជាក់ យ៉ាងច្បាស់នូវលក្ខណៈបុរាណ និងនិរន្តរភាព នៃប្រពៃណីនេះ ។ ជាងចម្លាក់ខ្មែរបានប្រើនិទានកថាដ៏មានប្រជាប្រិយនេះ ចំពោះគុណប្រយោជន៍ដ៏អស្ចារ្យរបស់ពួកគេដូចបានបង្ហាញនៅលើ ប៉ាណូអធិប្បាយ តូចៗនៃប្រាសាទបាពួន (សតវត្សទី១១) ដែលបង្ហាញ ពីឈុតឆាកតស៊ូ និងសង្គ្រាមជាច្រើន ហើយក៏ថែមទាំងបង្ហាញព្រះរាម និងនាងសិតា នៅពេលភពប្រសព្វរឿងលំបាកផ្សេងៗ។

យើងគួររំលឹកឡើងវិញថា ព្រះរាមជាស្តេចដ៏ត្រឹមត្រូវ និងដ៏មានព្រះរាជតម្រិះខ្ពស់ ជាព្រះអង្គម្ចាស់ដែលចេះគិតគូរដល់ដំបូន្មាន និងប្រពៃណីពីដូនតានោះ គឺជាអវតារនៃព្រះវិស្ណុ ។ មុនពេលពិសោធន៍ការរំងាប់តណ្ហាក្រោមការគំរាមកំហែងនៃវាសនាដ៏អាក្រក់ ព្រះអង្គត្រូវអត់ធននឹងការឈឺចាប់ដ៏គ្រោតគ្រាតជាច្រើន ។ ជាដំបូង ព្រះអង្គត្រូវបានបំបរបង់ចេញពីនគរនៃបិតារបស់ព្រះអង្គ ដើរស្វែង



UNESCO/Anne Lemaistre 2

រកទីជម្រកនៅក្នុងព្រៃទណ្ឌកៈ ហើយត្រូវពួកយក្សតាមធ្វើបាបជាញយៗ ។ ព្រះអង្គត្រូវបានកំដរដោយព្រះអនុជព្រះនាមព្រះល័ក្ខណ៍ និង អគ្គមហេសីនាមនាងសិតា ។ ព្រះនាងត្រូវបានចាប់ដោយយក្សរាពណ៍ ដែលប្រាថ្នាយកព្រះនាងធ្វើជាមហេសីរបស់ខ្លួន។ ព្រះរាមបានរកនាងឃើញហើយបានរំដោះនាងដោយបានពួកទ័ពស្វាដែលបានមកជួយព្រះអង្គ ដើម្បីកំចាត់ក្រុងរាពណ៍ នៅក្នុងចម្បាំងនៃរឿងព្រេងក្រោមការដឹកនាំរបស់ស្តេចស្វាសឈ្មោះហនុមាន ។ នៅពេលព្រះអង្គយាងនិវត្តចូលនគរវិញព្រះរាមបានគ្រងរាជ្យ ប៉ុន្តែបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ ។ ជាអវសានព្រះអង្គយាងត្រឡប់ទៅកាន់ឋានសួគ៌វិញ ដើម្បីទទួលយកនូវរូបសន្ធត់ជាព្រះវិស្ណុរបស់ព្រះអង្គ។

តាមលក្ខណៈខាងក្រៅរឿងនេះ និងព្រឹត្តិការណ៍ចលាចលនានារបស់វាបានប្រគល់ខ្លួនយ៉ាងងាយស្រួល ចំពោះការតំណាងទាំងផ្នែកល្ខោន និងផ្នែកប្រៀបធៀប ។ ជាវិបាកវាស្ទើរតែមិនគួរអោយភ្ញាក់ផ្អើលទេ ដែលឃើញរឿងនេះទាក់ទងគ្នា ប្រកបដោយវិត្ថារ

ប្រវត្តិ និង សង្គម

កម្មវិធីលើសលប់ ជាមួយផ្ទាំងគំនូរជាប់ជញ្ជាំងនានា នៃប្រាសាទព្រះកែវមរកតនៅក្នុងព្រះបរមរាជវាំងនាទីក្រុងភ្នំពេញ (ផ្ទាំងគំនូរដែលបច្ចុប្បន្នកំពុងតែរងគ្រោះថ្នាក់ ហើយដែលនឹងសមទទួលបាននូវអ្នកឧបត្ថម្ភដ៏បរិបូរណ៍) ។ ដូចពោលមកខាងលើរឿងរ៉ាម៉ាយ៉ាណះ/រាមកេរ្តិ៍នៅតែជាប្រធានបទមួយនៃការពេញនិយម នៃទស្សនីយភាពល្ខោន (របាំកាយវិការ និងល្ខោនខោល) និងនាដសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រជាប្រិយភាពដែលរឿងនេះទទួលបានដែលមិនធ្លាប់មានសាធារណជនណាម្នាក់បដិសេធចាប់តាំងពីសម័យអង្គរដ៏អស្ចារ្យមកនោះ បានពន្យល់នូវភាពសម្បូរបែបនៃមរតកវប្បធម៌ខ្មែរ ហើយនិងការផ្សារភ្ជាប់ដែលមិនអាចរំលាយបានរវាងសមាសធាតុពីរដែលជាក់ស្តែង និងដែលគ្មានរូបរាងរបស់វា ។

តាមលោក ចច គ្រូសលីយេ (Georges Groslier) ដែលបានស្ថាបនាសាលាវិចិត្រសិល្បៈ និងសារមន្ទីរជាតិនៃទីក្រុងភ្នំពេញ (ឆ្នាំ១៩១៩) ដែលបានទាញចំណាប់អារម្មណ៍ចំពោះការផ្សារភ្ជាប់នេះថាវាគឺ វិចិត្រករម្នាក់ដែលមានវេទយិតភាពអស្ចារ្យ (និងជាស្ថាបត្យករម្នាក់) ។ លោកបានសរសេរថា "នៅក្នុងសិល្បៈសព្វថ្ងៃមានភស្តុតាងនៃភាពជាប់នៅមួយកន្លែងវិសាមញ្ញមួយ និងភាពអចិន្ត្រៃយ៍នៃបច្ចេកទេសសោភ័ណភាពពិសេសមួយ ដែលគេយល់បានប្រាំបួនដង ក្នុងដប់ដង នៅលើចម្លាក់ជាប់សាច់នៃអង្គរ និងនៅក្នុងប្រាសាទនានានៃសម័យដំបូងបំផុត" ។

ការរបកវណ្ណវង់ ៖ ជម្ងឺខូចទ្រង់ទ្រាយនៃចម្លាក់ ប្រាសាទអង្គរវត្ត

ដោយ ហាន លេសិន Hans Leisen

ហាន លេសិន បានទទួលមហាបរិញ្ញាប័ត្រផ្នែកភូគព្ភសាស្ត្រ និងជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យ វិទ្យាសាស្ត្រអនុវត្តន៍នៃទីក្រុងកូឡូញ ប្រទេសអាល្លឺម៉ង់ ។ ដោយជាប្រធានគំរោងអភិរក្សអប្សរាអាល្លឺម៉ង់ (GACP) ។

ប្រាសាទទាំងឡាយនៅតំបន់អង្គរ និងក្បាច់ចម្លាក់របស់វា គឺជាស្នាដៃការងារសិល្បៈថ្មមួយចំនួនដ៏អស្ចារ្យបំផុតរបស់ពិភពលោក ដែលក្នុងនោះ អង្គរវត្តជាប្រាសាទដ៏ធំជាងគេ និងសំខាន់ជាងគេបំផុត ។ ប្រាសាទនេះមានឈ្មោះល្បីល្បាញដោយមានចម្លាក់លើបជាប់សាច់នៅនឹងថៃវជាច្រើននៃកំពែងទី៣ ។ នៅតាមជញ្ជាំងប្រាសាទមានក្បាច់ចម្លាក់ចម្រុះគ្នាជាច្រើនដោយបង្ហាញអំពីឈុតឆាកនៃរឿងទេវកថា ទេវតា និងអ្នករាំរបាំអប្សរា ព្រមទាំងគំនូរក្បាច់ជាលក្ខណៈផ្កាផង ។ ក៏ប៉ុន្តែដោយហេតុថា ក្បាច់ចម្លាក់ និងផ្នែកដែលតុបតែងផ្សេងៗត្រូវបានឆ្លាក់នៅនឹងកន្លែងផ្ទាល់ និងដោយសម្ភារៈសំណង់ដែលគេប្រើ គឺជាថ្មបាយក្រៀមសម្រាប់រចនាសម្ព័ន្ធបង្កប់ និងថ្មភក់សម្រាប់ផ្នែកដែលអាចមើលឃើញដោយភ្នែកតាមជញ្ជាំងប្រាសាទដែលប៉ះទៅនឹងអាកាសធាតុ បច្ចុប្បន្នកំពុងរងការទទួលនូវការខូចខាតយ៉ាងខ្លាំង ។

តាំងពីឆ្នាំ១៩៩៥មក សភាពកាន់តែយ៉ាប់យ៉ឺននៃក្បាច់ចម្លាក់ និងការអភិរក្សរបស់វាគឺជាប្រធានបទមួយនៃការសិក្សារបស់អ្នកវិទ្យាសាស្ត្រ និងអ្នកអភិរក្សនៃគម្រោងអភិរក្សអប្សរា អាល្លឺម៉ង់ (GACP) ។ ដោយការខូចខាតកាន់តែរាលដាលខ្លាំងឡើងគម្រោងនេះក៏ត្រូវបានបង្កើតឡើងដើម្បីរៀបចំផែនការ និងចាប់អនុវត្តវិធានការអភិរក្សមួយចំនួន និងដើម្បីបណ្តុះបណ្តាលកម្មករកម្ពុជាផ្នែកការអភិរក្ស ។ សកម្មភាពនៃការធ្វើឯកសារការសិក្សាស្រាវជ្រាវ ការធ្វើតេស្ត និងការសាកពិសោធន៍ ការអភិរក្ស ព្រមទាំងការអភិរក្សអនុវត្តត្រូវរៀបចំឡើង នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរវិន័យរបស់ប្រធានគម្រោង និស្សិត អ្នកអភិរក្សដែលមានបទពិសោធន៍ កម្មករកម្ពុជាដែលបានទទួលការបណ្តុះបណ្តាលនិងអ្នកជំនាញភូគព្ភសាស្ត្រ (ភូគព្ភវិទូ)

បោះពុម្ពដោយ រោងពុម្ព ស្មើអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ការរបកវណ្ណៈរំង : ជម្ងឺខូចទ្រង់ទ្រាយនៃចម្លាក់ ប្រាសាទអង្គរវត្ត

ដោយ ហាន លេសិន Hans Leisen

គឺមីរីទូ និងមីក្រូជីវៈវិទូ មកពីប្រទេសអាល្លឺម៉ង់ ។ (GACP) ត្រូវបានរៀបចំចាត់ចែងដោយក្រសួងអភិរក្ស និងក្រសួងវិទ្យាសាស្ត្ររូបភាពនៃសកលវិទ្យាល័យ វិទ្យាសាស្ត្រអនុវត្តន៍ក្រុងកូឡូញ (UASC) ។

ទោះបីជាស្ថាបត្យកម្ម និងរូបភាពនៃប្រាសាទនោះគួរអោយចាប់អារម្មណ៍យ៉ាងណាក៏ដោយស្នាមញញឹមដ៏ដឹស្ងប់ស្ងៀមទន់ភ្លន់បានដក់ជាប់ក្នុងអារម្មណ៍នៃចម្លាក់អប្សរា និងទេវតាក្នុងបេះដូងនៃភ្ញៀវទេសចរទាំងឡាយ ។ ចាប់ពីដំណាក់កាលទី១នៃការងាររបស់យើងនៅឆ្នាំ១៩៩៥ វាច្បាស់ថាកិច្ចប្រឹងប្រែងផ្នែកអភិរក្សរបស់យើងត្រូវតែចាប់ផ្តើមជាមួយផ្ទៃលំអមុខលើ ។ ផ្នែកទាំងនេះបានទទួលរងនូវឥទ្ធិពលអាកាសធាតុដោយផ្ទាល់ដោយការថែរក្សាមិនដិតដល់និងឈានទៅរកការបាត់បង់ទាំងស្រុងហើយ ត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់ ។

សេចក្តីពន្យល់ខាងក្រោមនេះ គឺជាសេចក្តីថ្លែងការណ៍ទូទៅទាក់ទិននឹងថ្មធម្មជាតិ ការសឹករិចរិលដោយសារអាកាសធាតុរបស់វា និងសេចក្តីផ្តើមសង្ខេបអំពីទស្សនៈនិងគោលបំណងនៃការអភិរក្សថ្ម ។

គោលការណ៍នៃការអភិរក្ស ប្រាសាទថ្មធម្មជាតិ

ថ្ម គឺជាការផ្គុំគ្នានៃអំបិលខណិជ ហើយវាខុសគ្នាយ៉ាងច្រើនទៅតាមគុណភាព ។ ក្រោយពីការបង្កើត វាទទួលរងការទ្រុឌទ្រោមផ្នែករូប គីមី និងជីវៈ ។ គន្លឹះស្វែងយល់ការពុកផុយនៃថ្មធម្មជាតិ គឺការសិក្សាលើគុណភាព សម្ភារៈ លើស្ថានភាពពិសេសនៃប្រាសាទនៅនឹងកន្លែងរបស់ពួកវា និងការសិក្សាដោយធ្វើពិសោធន៍ ។ ដូច្នេះផែនការអភិរក្ស និងស្តារឡើងវិញមួយត្រូវបង្កើតឡើង ហើយចាប់អនុវត្តបន្ទាប់ពីធ្វើការពិនិត្យទីកន្លែង និងទីពិសោធន៍ ។ យើងត្រូវតែយល់ថាការធ្វើអភិរក្ស និងជួសជុលកែលំអឡើងវិញនីមួយៗ មិនត្រឹមតែជួយថែរក្សាប្រាសាទប៉ុណ្ណោះទេ ក៏ប៉ុន្តែអាចពាក់ព័ន្ធជាមួយគ្រោះថ្នាក់ច្រើនសន្ធឹកថែមទៀតផង ។ ការខូចខាតលើរូបចម្លាក់ និងផ្នែកខាងមុខនៃប្រាសាទដែលយើងឃើញសព្វថ្ងៃ ជារឿយៗបណ្តាមកការគិតគូរមិនបានល្អ និងការស្រាវជ្រាវមិនបានដិតដល់ ។

ដោយមិនអាចទទួល យកបានទាំងតាមទស្សនៈវិទ្យាសាស្ត្រ និងតាមទស្សនៈសោភ័ណភាពនិយម ការលាបដ៏ក្រាស់ឃ្មុកដោយជ័រដែលមានជាតិអាស៊ីដច្រើន ដែលអាចមើលឃើញបាននោះកំពុងតែរារាំងដល់វិធានការអភិរក្សពិតប្រាកដ ហើយវានឹងបណ្តាលអោយមានការពុកផុយតទៅមុខទៀត ។

ការងារនៅនឹងកន្លែង

លក្ខខ័ណ្ឌមុនជាមូលដ្ឋានគ្រឹះ និងដែលមិនអាចអត់បាននៃការធ្វើអន្តរាគមន៍អភិរក្សនៃវិទ្យាសាស្ត្រនោះ គឺការចងក្រងឯកសារនៃវត្ថុដោយមានការធ្វើឯកសាររូបថត ឯកសារខ្មៅអាត់នៃកិច្ចការស្តារកាលពីមុន ការគូសផែនទីនៃសម្ភារៈ ព្រមទាំងសភាពនៃការថែរក្សារាប់បញ្ចូលទាំងការធ្វើឯកសារនៃអន្តរាគមន៍នៅនឹងកន្លែង ដូចជាការធ្វើវិភាគចំណុចសាកល្បង និងវិធានការអភិរក្ស ។ ហេតុដូច្នោះហើយ GACP បានបង្កើត និងបានបង្ហាញប្រព័ន្ធឯកសារពេញលេញមួយដែលរួមមានឯកសាររូបថតសខ្មៅ និងពណ៌ ខ្មៅអាត់ 3-D Laser មួយ ទិន្នន័យមួយ ដែលមានបញ្ជីការងារសម្រាប់វត្ថុទោលនីមួយៗ និងបែបបទឯកសារនៅនឹងកន្លែងមួយសម្រាប់បទអន្តរាគមន៍ជាឯកត្តជន ។ ចំពោះការគូសផែនទី និងឯកសារក្រាហ្វិកនៃសម្ភារៈ ការពុកផុយ អន្តរាគមន៍របស់យើងផ្ទាល់ និង អន្តរាគមន៍មុនៗនោះ កំនែថ្មីនៃ AutoCAD ដែលត្រូវបានកែប្រែជាពិសេសមួយ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការដ៏ស្មុគ្រស្មាញនូវឯកសារ និងតម្រូវការពិសេសនៃអ្នកជួសជុលឡើងវិញជាជនជាតិខ្មែរដើម្បីអោយមានភាពងាយស្រួលក្នុងការសិក្សា ។

ផ្អែកលើមូលដ្ឋាននៃឯកសាររូបថត ក្បាច់ចម្លាក់អប្សរា និងទេវតាទាំងអស់ ព្រមទាំងហោជាងត្រូវបានធ្វើផែនទីទៅតាមសម្ភារៈ ការខូចខាត និងបច្ចេកទេសនៃការធ្វើរបស់វា ។

ដើម្បីកំណត់ចំនួននូវចំណាប់អារម្មណ៍ជាគោលលើការថែរក្សាផ្ទៃលំអនៃប្រាសាទអង្គរវត្ត និងដើម្បីទទួលបាននូវទិដ្ឋភាពទូទៅនៃស្ថិតិភារកិច្ចមួយក្នុងចំណោមភារកិច្ចដ៏មានសារៈសំខាន់បំផុតនោះ គឺការបែងចែកថ្នាក់នៃក្បាច់ចម្លាក់ទាំងអស់ ។ ថ្នាក់ពុកផុយមានចាប់

ប្រវត្តិ និង សង្គម

១/ លូមា៉ កកាស្តិនគី សំភារៈស្ទង់ធ្វើពីកែវ ភ្ជាប់បញ្ច្រាស់ទៅនឹងកំពែង ដើម្បីវាស់ការជ្រាបទឹកចូលក្នុងថ្ម តាមរយៈការស្រូបចូលតាមរន្ធតូចៗ ។ លទ្ធផលទទួលបានពីការវាស់ស្ទង់ផ្តល់ផងដែរនូវការពង្រឹងរបស់អ្នកអភិរក្ស ។

ពីកំរិតទី១ ដែលមានន័យថាស្ទើរតែមិនទទួលការសឹករិចរិលដោយសារអាកាសធាតុរហូតដល់កំរិតទី៦ ដែលមានន័យថា ផ្នែកច្រើនបំផុតនៃក្បាច់ចម្លាក់បានបាត់បង់អស់ ហើយចម្លាក់ដែលនៅសេសសល់ងាយបាក់បែកបំផុត ។ ជំហ៊ានបន្ទាប់មកទៀត គឺការធ្វើផែនទីពិស្តារបង្ហាញការពុកផុយនៃក្បាច់ចម្លាក់ ។ ដំណើរការពុកផុយដ៏ខ្លាំងបំផុតមួយដែលហៅ ថាការរបកវិណ្ឌវង់ត្រូវបានរកឃើញពាសពេញប្រាសាទអង្គរវត្ត ។ ផ្ទាំងនៃផ្ទៃថ្មខាងក្រៅរហូតដល់កម្រាស់ប្រាំសង់ទីម៉ែត្រដាច់ចេញពីស្រទាប់ក្នុងនិងជាអវសានត្រូវបាត់បង់អស់ ។ នេះគឺជាបាតុភូតពុកផុយដ៏ធ្ងន់ធ្ងរបំផុត ហើយតាមការគណនារបស់យើងជាងសាមសិបភាគរយនៃក្បាច់ចម្លាក់អណ្តែតរបស់ប្រាសាទអង្គរកំពុងទទួលរងនូវការខូចខាតជាលក្ខណៈបែបនោះ ។ បន្ថែមលើនេះទៀតមានបាតុភូតបំផ្លិចបំផ្លាញផ្សេងៗ ទៀតដូចជា : ការបាក់បែកនេះជាដុំតូចៗ និងការកកនៃជាតិអំបិល ។

ឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតក្នុងការទទួលពត៌មានអំពីថាមភាពនៃដំណើរការសឹករិចរិលនោះ គឺការតាមដានរូបថត ។ ការស្រាវជ្រាវឯកសារកាលប្បវត្តិបានបង្ហាញនូវរូបថតជាប្រវត្តិសាស្ត្រនៃក្បាច់ចម្លាក់អណ្តែតជាច្រើននៃប្រាសាទអង្គរវត្ត ដែលធ្វើអោយយើងអាចស្ទាបស្ទង់នូវដំណើរការនៃការពុកផុយបាន ។ រូបភាពនៃក្បាច់អណ្តែតពីរ ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៣ ដោយលោកដិលវើត (Delvert) ។ នៅពេលដែល GACP បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៥ ផ្នែកនៃក្បាច់អណ្តែតដ៏ច្រើនសន្ធឹកត្រូវបានបំផ្លិចបំផ្លាញហើយ ។ នៅរវាងនិទាឃរដូវ និងសរទរដូវនៃឆ្នាំ១៩៩៦ ផ្នែកដ៏ធំមួយទៀតនៃក្បាច់អណ្តែតត្រូវបានបាត់ ។ វិធីសាស្ត្រនៃការប្រៀបធៀបនេះប្រាប់យើងអំពីល្បឿននៃដំណើរការនៃសភាពដុនដាបនិងធ្វើអោយយើងបានដឹងថា តើយើងត្រូវអនុវត្តជាបន្ទាន់នូវវិធានការអភិរក្សដូចម្តេច ។

ជំហ៊ានសំខាន់មួយទៀតនៅក្នុងគម្រោងអភិរក្សនេះ គឺការចុះបញ្ជីទិន្នន័យអំពីស្ថានភាពធាតុអាកាសនៅក្នុងបរិស្ថាននៃប្រាសាទដែលត្រូវថែរក្សា ។ ថ្មទទួលរងឥទ្ធិពលពីធាតុអាកាសដែលវានៅចំ ។ ថ្មធម្មជាតិ ជាសម្ភារៈ ដែលមានរន្ធតូចៗ មានប្រតិកម្មទៅលើបម្រែបម្រួលធាតុអាកាសដូចជាកំដៅ និងត្រជាក់ ឬសំណើមដោយសារទឹកភ្លៀង និងសម្ងួតជាបន្តបន្ទាប់ ។ នៅប្រាសាទអង្គរវត្ត ផ្នែកខាងក្រៅនៃថ្មត្រូវទទួលរងកំដៅ ក្នុងកំឡុងពេលថ្ងៃ (រហូតដល់ ៥៥អង្សាសេនៃសីតុណ្ហភាពផ្ទៃត្រូវបានកត់ត្រា) ហើយនិងសីតុណ្ហភាពក្នុងអំឡុងពេលយប់ ទឹកភ្លៀងមូសុងខ្លាំង និងការប្រែប្រួលភ្លាមៗនៅក្នុងសំណើមខ្យល់ ។ ថ្មរីកតាមកំដៅនៅពេលកំដៅឡើង ហើយទទួលរងកំនើនទឹក នៅពេលមានភ្លៀងច្រើន ដោយធ្វើអោយមានកម្លាំងច្រោះមកលើថ្ម ដែលដើរតួជាកត្តាពុកផុយ ។

ការស្រាវជ្រាវលើការលាបពណ៌លើប្រាសាទ និងរូបចម្លាក់នានា

ដូចសំណង់ថ្មប្រវត្តិសាស្ត្រភាគច្រើនដែរ ប្រាសាទអង្គរវត្តត្រូវបានលាបថ្នាំ ហើយភស្តុតាងគ្រប់គ្រាន់នៃការលាបថ្នាំនេះមាននៅលើក្បាច់ចម្លាកលឹប នៅលើផ្នែកផ្សេងៗទៀតនៃប្រាសាទ និងនៅលើរូបចម្លាក់នានា ។ ក្រៅពីនេះក៏នៅមានភស្តុតាងផងដែរចំណោះការស្រោបបិទពីលើ និងសិលាចារឹកដែលលាបពណ៌ផងដែរ ។

ភាពលំបាកនៃការឈានរកវិធី គឺស្ថិតនៅលើការស្វែងយល់ពីលំដាប់ពេលនៃការលាបថ្នាំច្រើនស្រទាប់ ព្រមទាំងការអភិរក្សរបស់វា ។

ប្រវត្តិ និង សង្គម



១ [illegible]

ពិកិរិតទី១ ដែលមានន័យថាស្ទើរតែមិនទទួលការសឹករិចរិលដោយសារអាកាសធាតុរហូតដល់កំរិតទី៦ ដែលមានន័យថា ផ្នែកច្រើនបំផុតនៃក្បាច់ចម្លាក់បានបាត់បង់អស់ ហើយចម្លាក់ដែលនៅសេសសល់ងាយបាក់បែកបំផុត ។ ជំហ៊ានបន្ទាប់មកទៀត គឺការធ្វើផែនទីពិស្តារបង្ហាញការពុកផុយនៃក្បាច់ចម្លាក់ ។ ដំណើរការពុកផុយដ៏ខ្លាំងបំផុតមួយដែលហៅ ថាការរបកវីយ៉ូរ៉ង់ត្រូវបានរកឃើញពាសពេញប្រាសាទអង្គរវត្ត ។ ផ្ទាំងនៃផ្ទៃថ្មខាងក្រៅរហូតដល់កម្រាស់ប្រាំសង់ទីម៉ែត្រដាច់ចេញពីស្រទាប់ក្នុងនិងជាអវសានត្រូវបាត់បង់អស ។ នេះគឺជាបាតុភូតពុកផុយដ៏ធ្ងន់ធ្ងរបំផុត ហើយតាមការគណនារបស់យើងជាសមាមាត្រភាគរយនៃក្បាច់ចម្លាក់អំណ្ណែតរបស់ប្រាសាទអង្គរកំពុងរងនូវការខូចខាតជាលក្ខណៈបែបនោះ ។ បន្ថែមលើនេះទៀតមានបាតុភូតបំផ្លិចបំផ្លាញផ្សេងៗ ទៀតដូចជា : ការបាក់បែកនេះជាដុំតូចៗ និងការកកនៃជាតិអំបិល ។

ឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតក្នុងការមនុស្សមានអំពីផាមភាពនៃដំណើរការសឹករិចរិលនោះ គឺការតាមដានរយៈពេល ។ ការស្រាវជ្រាវឯកសារកាលប្បវត្តិបានបង្ហាញនូវរូបថតជាប្រវត្តិសាស្ត្រនៃក្បាច់ចម្លាក់អំណ្ណែតជាច្រើននៃប្រាសាទអង្គរវត្ត ដែលធ្វើអោយយើងអាចស្គាល់ពីដំណើរការនៃការពុកផុយបាន ។ រូបភាពនៃក្បាច់អំណ្ណែតពីរ ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៣ ដោយលោកដិលវើត (Delvert) ។ នៅពេលដែល GACP បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៥ ផ្នែកនៃក្បាច់អំណ្ណែតដ៏ច្រើនសន្ធឹកត្រូវបានបំផ្លិចបំផ្លាញហើយ ។ នៅរវាងទិទាយរដូវ និងសរទរដូវនៃឆ្នាំ១៩៩៦ ផ្នែកដ៏ធំមួយទៀតនៃក្បាច់អំណ្ណែតត្រូវបានបាត់ ។ វិធីសាស្ត្រនៃការប្រៀបធៀបនេះប្រាប់យើងអំពីល្បឿននៃដំណើរការនៃសភាពដុនដាបនិងធ្វើអោយយើងបានដឹងថា តើយើងត្រូវអនុវត្តជាបន្ទាន់នូវវិធានការអភិរក្សដូចម្តេច ។

ជំហ៊ានសំខាន់មួយទៀតនៅក្នុងគម្រោងអភិរក្សនេះ គឺការចុះបញ្ជីទិន្នន័យអំពីស្ថានភាពធាតុអាកាសនៅក្នុងបរិស្ថាននៃប្រាសាទដែលត្រូវថែរក្សា ។ ថ្មទទួលរងឥទ្ធិពលពីធាតុអាកាសដែលវានៅចំ ។ ថ្មធម្មជាតិ ជាសម្ភារៈ ដែលមានរន្ធតូចៗ មានប្រតិកម្មទៅលើបម្រែបម្រួលធាតុអាកាសដូចជាកំដៅ និងត្រជាក់ ឬសំណើមដោយសារទឹកភ្លៀង និងសម្ងួតជាបន្តបន្ទាប់ ។ នៅប្រាសាទអង្គរវត្ត ផ្នែកខាងក្រៅនៃថ្មត្រូវទទួលរងកំដៅ ក្នុងកំឡុងពេលថ្ងៃ (រហូតដល់ ៥៥អង្សាសេនៃសីតុណ្ហភាពផ្ទៃត្រូវបានកត់ត្រា) ហើយនិងសីតុណ្ហភាពក្នុងអំឡុងពេលយប់ ទឹកភ្លៀងមូសុងខ្លាំង និងការប្រែប្រួលភ្លាមៗនៅក្នុងសំណើមខ្យល់ ។ ថ្មរីកតាមកំដៅនៅពេលកំដៅឡើង ហើយទទួលរងកំទេចទឹក នៅពេលមានភ្លៀងច្រើន ដោយធ្វើអោយមានកម្លាំងគ្រោះមកលើថ្ម ដែលដើរតួជាកត្តាពុកផុយ ។

ការស្រាវជ្រាវលើការលាបពណ៌លើ ប្រាសាទ និងរូបចម្លាក់នានា

ដូចសំណង់ថ្មប្រវត្តិសាស្ត្រភាគច្រើនដែរ ប្រាសាទអង្គរវត្តត្រូវបានលាបថ្នាំ ហើយភស្តុតាងគ្រប់គ្រាន់នៃការលាបថ្នាំនេះមាននៅលើក្បាច់ចម្លាកលិប នៅលើផ្នែកផ្សេងៗទៀតនៃប្រាសាទ និងនៅលើរូបចម្លាក់នានា ។ ក្រៅពីនេះក៏នៅមានភស្តុតាងផងដែរចំណោះការស្រោបបិទពិលើ និងសិលាចារឹកដែលលាបពណ៌ផងដែរ ។

ភាពលំបាកនៃការឈានរកវិធី គឺស្ថិតនៅលើការស្វែងយល់ពីលំដាប់ពេលនៃការលាបថ្នាំច្រើនស្រទាប់ ព្រមទាំងការអភិរក្សរបស់វា ។

ការរបកវណ្ណ៍វង់ : ជម្ងឺខូចទ្រង់ទ្រាយនៃចម្លាក់ ប្រាសាទអង្គរវត្ត

ដោយ ហាន លេសិន Hans Leisen

សម្រាប់ហេតុផលនេះ ការវិភាគបែបវិទ្យាសាស្ត្រលើសម្ភារៈផ្សំផ្សេងៗនៃស្រទាប់នានាកំពុងតែត្រូវបានអនុវត្តឡើង នៅពេលព្រមគ្នាជាមួយការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ និងការស្រាវជ្រាវឯកសារកាលប្បវត្តិដ៏ប្រុងប្រយ័ត្ន ។ សកម្មភាពស្រាវជ្រាវទាំងនេះវាចាំបាច់ណាស់ ពីព្រោះការវិភាគវិទ្យាសាស្ត្រនេះ អាចបង្ហាញនូវសមាសធាតុនៃសម្ភារៈផ្សំទាំងឡាយ ប៉ុន្តែមិនអាចផ្តល់ពត៌មានទាក់ទិននឹងរយៈពេលនៃការលាបថ្នាំរបស់វាទេ ។ ហើយតាមពិត ជារឿយៗប្រភេទនៃសម្ភារៈដែលគេប្រើប្រាស់នោះពុំមានការផ្លាស់ប្តូរជាច្រើនសតវត្សមកហើយ ។ អាស្រ័យហេតុនេះ ការស្វែងយល់សមាសធាតុរបស់វានឹងមិនជួយដល់ការស្វែងយល់ជាប្រវត្តិសាស្ត្រនៃការលាប ថ្នាំថ្នោះទេ ។ ជាឧទាហរណ៍នៅកន្លែងខ្លះថ្នាំក្រហមត្រូវបានឃើញមាននៅលើផ្នែកថ្មដែលពុកផុយទៅហើយៗ នេះបង្កើតឱ្យមានសំណើថា ក្នុងប្រវត្តិសាស្ត្ររបស់ប្រាសាទមានការលាបស្រទាប់ថ្នាំពិសេសណាមួយត្រូវបានកំពុងប្រើប្រាស់ ។

ការស្រាវជ្រាវពិសេសមួយត្រូវបានគេធ្វើឡើង លើរូបចម្លាក់ព្រះវិស្ណុដែលស្ថិតនៅក្លោងទ្វារខាងលិចដែលគេហៅថា តាររាជ ដែលកំពុងបង្ហាញសញ្ញានៃការបាក់បែកនិងពុកផុយ ។ រូបចម្លាក់ដ៏សំខាន់នេះគ្របដណ្តប់ដោយពណ៌ច្រើនស្រទាប់និងការស្រោបព្រមទាំងស្រទាប់ពណ៌ខ្មៅពាសពីលើផង ។ ការស្រាវជ្រាវដែលកំពុងដំណើរការបង្ហាញថា ពណ៌ក្រហមប្រហែលជាម្រ័ក្សណ៍ខ្មុកដែលត្រូវគេផ្សំគ្នាជាមួយជ័រធម្មជាតិ ។ មានភស្តុតាងផងដែរនៃស្រទាប់បំរុងព្រមទាំងស្រទាប់ពាសពីក្រៅពណ៌ខ្មៅ ដែលស្ទើរតែកើតមកពីផ្សែងធូបដែលអ្នកគោរពបានអុជពីក្រោមរូបចម្លាក់នេះអស់ជាច្រើនសតវត្សមកហើយ ។ ទោះជាយ៉ាងណាក៏ដោយស្រទាប់ផ្សេងៗទាំងនេះកំពុងតែបង្ហាញសញ្ញានៃការដាច់ចេញ ហើយអាស្រ័យហេតុនេះពួកវានឹងត្រូវការរូបរួមចូលគ្នា និងត្រូវការសំអាតមុនពេលអនុវត្តការរូបរួមចូលគ្នានៃរូបចម្លាក់នេះ ។ បើមិនដូច្នោះទេ ផ្នែកជាច្រើននៃការជួសជុលថែរក្សាការលាបថ្នាំជាប្រវត្តិសាស្ត្រនេះនឹងត្រូវបាត់បង់ជាព្រាកដ ។ សេចក្តីលំអិតនៃប្រតិបត្តិការអភិរក្សកំពុងតែត្រូវបានពិនិត្យផ្ទៀងផ្ទាត់បញ្ចប់ហើយ នឹងចាប់អនុវត្តដោយត្រូវមានការយល់ព្រមពីអាជ្ញាធរអប្សរាកម្ពុជា និងអ្នកជំនាញនៃអង្គការយូណេស្កូ នៅដើមឆ្នាំ២០០២ នេះសិន ។

វិធីសាស្ត្រស្រាវជ្រាវសម្ភារៈនៅនឹងកន្លែង

ក្រៅពីការធ្វើឯកសារ និងការធ្វើផែនទី វិធីសាស្ត្រស្រាវជ្រាវផ្សេងមួយចំនួនទៀតត្រូវបានប្រើប្រាស់ដើម្បីទទួលបាននូវការស្វែងយល់អោយកាន់តែស៊ីជម្រៅទៅលើគុណភាពសម្ភារៈ និងសភាពនៃការថែរក្សាចម្លាក់ក្បាច់ ។ ទឹកដើរតួនាទីជាកត្តាកំណត់មួយនៅក្នុងដំណើរការពុកផុយទាំងអស់ ។ ដូច្នេះសមត្ថភាពរបស់ថ្មធម្មជាតិដើម្បីស្រូបយកទឹកនោះ គឺជាគុណភាពដ៏សំខាន់បំផុតមួយដែលត្រូវកំណត់ ។ ដោយមានទឹកធម្មតាពេញបំពង់ខាស្តិន (Karsten Pipe) ចំនួនទឹកដែលជ្រាបចូលទៅក្នុងថ្មតាមសកម្មភាពដែលស្រូបចូលតាមសរសៃតូចៗ អាចត្រូវបានកំណត់ចំនួន ។ រង្វាស់នេះផ្តល់នូវពត៌មានបន្ថែមអំពីការកែប្រែនៃសម្ភារៈថ្មដែលបង្កឡើងដោយការសឹករិចរិលដោយសារអាកាសធាតុ ។ ចំនួននៃការស្វែងយល់ដើរតួជាមូលដ្ឋានមួយសម្រាប់ការប៉ាន់ស្មានលើចំនួន នៃភ្នាក់ងារអភិរក្សដែលយើងនឹងត្រូវការសម្រាប់សកម្មភាពថែរក្សាផ្សេង ៗ ។ គុណភាពសំខាន់បំផុតមួយទៀតនោះ គឺកម្លាំងមេកានិចនៃសម្ភារៈថ្ម ។ ដំណើរការសឹករិចរិលធ្វើអោយកម្លាំងថ្មប្រែប្រួល ។ វិធីសាស្ត្រពីរយ៉ាងត្រូវប្រើនៅក្នុង GACP ដើម្បីកំណត់គុណភាពមេកានិច ដូចជាកម្លាំងនៅផ្ទាល់នឹងតំបន់ដោយគ្មាន ឬមានការខូចខាតិចតួចបំផុតដល់សម្ភារៈ ។

រង្វាស់ល្បឿនសម្លេងខ្ពស់បំផុត (Ultra Sound Velocity) ដែលគ្មានការបំផ្លិចបំផ្លាញ វាស់ល្បឿន និងគណនាពេលវេលានៃការបញ្ជូនរលកដែលហ្វ្រេកង់ស៍លើសពី ២០គីឡូអែក្ស៍ រវាងឧបករណ៍បញ្ជូនសម្លេង និងឧបករណ៍ទទួលសម្លេង ។ ល្បឿននៃរលកដែលហ្វ្រេកង់ស៍លើសពី ២០គីឡូអែក្ស៍ នៅក្នុងសម្ភារៈថ្មនេះ ត្រូវទាក់ទងគ្នាជាមួយកម្លាំងមេកានិច និងសភាពនៃការពុកផុយនៃសម្ភារៈដែលវារត់ឆ្លងកាត់ ។ ការវាស់វែងដែលត្រូវបានធ្វើឡើងនៅតាមចម្លាក់នានានៃប្រាសាទអង្គរវត្តបានបង្ហាញនូវភាពខុសប្លែកគ្នាដ៏ធំ និង បង្ហាញនូវសភាពដុនដាបនៃចម្លាក់ក្បាច់អណ្តែតទាំងនោះ ។

ប្រវត្តិ និង សង្គម

វិធីសាស្ត្រនេះក៏ត្រូវបានអនុវត្តផងដែរសម្រាប់ការត្រួតពិនិត្យគុណភាពក្រោយពីប្រព្រឹត្តិកម្មអភិរក្សមួយត្រូវបានអនុវត្ត ។ ការកំណត់នៃការតស៊ូទប់ទល់ នឹងការខួងរបស់សម្ភារៈផ្ដល់នូវពត៌មានអំពីការអភិវឌ្ឍន៍នៃកម្លាំងនៅក្នុងជម្រៅ ។ វាគឺជាវិធីសាស្ត្រមួយដែលមានការខូចខាតតិចតួច ។ ប្រហោងតូចមួយមានផ្ចិតបីម្លីលីម៉ែត្រត្រូវបានខួងចូលទៅក្នុងថ្ម ហើយការប្រឆាំងរបស់សម្ភារៈថ្មទៅនឹងការរលចូលនៃម៉ាស៊ីនខួងនោះត្រូវបានកត់ទុកជាឯកសារ ។ ការវាស់វែងនៃការប្រឆាំងនឹងម៉ាស៊ីនខួងបង្ហាញនូវកំរិត និងប្រភេទនៃការធ្លាក់ចុះនៃសម្ភារៈថ្ម ព្រមទាំងលទ្ធផលនៃប្រព្រឹត្តិកម្មអភិរក្សផង ។

២/ ការអនុវត្តន៍បច្ចេកទេសសំលេងខ្លាំង ដើម្បីកំណត់គុណភាពមេកានិករបស់ថ្ម ។

បុព្វហេតុនៃការខូចខាតមួយទៀត គឺ ភាពកខ្វក់ជាមួយអំបិលដែលអាចរលាយបានដែលអាចបង្កើតនូវដំណើរតឹងនៃមេកានិចចំពោះសម្ភារៈដែលមានរន្ធតូចៗ បានមានថ្ម ជាដើម ។ ការវិភាគនៃសារជាតិអំបិលត្រូវបានវាស់វែងដោយការសាកល្បងបណ្ដូលម៉ាស៊ីនខួងតូចៗ ដែលមានផ្ចិត ១២មីល្លីម៉ែត្រ ។ នៅប្រាសាទអង្គរវត្តអំបិលដែលអាចរលាយបានពីស្រទាប់ពាសលើផ្ទៃកក្រៅផ្សេងៗ ដូចជាជាតិនីត្រាត កំបោរបាយអ និងប្រូផាត ហើយនិងការបូកស៊ីម៉ង់ត៍ ដែលគេប្រើពីដើម ត្រូវបានធ្វើវិភាគ ។ ភាពរស់រវើករបស់ពួកវាអាចត្រូវបានឃើញពាសពេញប្រាសាទ ជាពិសេសក្បាច់ចម្លាក់ទេវតាដ៏មានតម្លៃនៅឯទីជម្រកកណ្ដាល ដែលមានសភាពដុនដាបធ្ងន់ធ្ងរខុសពីគេដោយសារដំណើរការនៃការឡើងក្រាម ។

សកម្មភាពផ្ទៃកមីក្រូជីវៈក៏អាចមានផលដែលធ្វើអោយខូចខាតដល់ថ្មផងដែរ ។ វាអាចត្រូវបានរកឃើញដោយបច្ចេកទេស ពិសេសជាច្រើនមានការវាស់ការដកដង្ហើមជាដើម ។

ការរបកវណ្ណ៍វង់ : ជម្ងឺខូចទ្រង់ទ្រាយនៃចម្លាក់ ប្រាសាទអង្គរវត្ត

ដោយ ហាន លេសិន Hans Leisen

ការធ្វើតេស្តនៅមន្ទីរពិសោធន៍

ក្រៅពីការវាស់វែងនៅនឹងកន្លែង មានការធ្វើតេស្តជាច្រើននៅទីពិសោធន៍ ដើម្បីកំណត់ភិនភាគសម្ភារៈថ្ម ។ ខណិជវិទ្យារបស់ថ្មនៃប្រាសាទអង្គរវត្តត្រូវបានធ្វើវិភាគ ហើយលក្ខណៈរូប ដូចជាការស្រូបទឹកចូលតាមសរសៃតូចៗ កំណើនទឹក និងកំដៅ ការមានរន្ធតូចៗដែលទឹកអាចជ្រាបបាន ការបំភាយចំហាយទឹក ភាពដែលជ្រាបទឹក កម្លាំង



៣/ a 7 b/ គំនូសតាងពីរបង្ហាញពីស្ថានភាពអាកាសធាតុពីរផ្សេងគ្នា : ៣ a/ ផ្តល់អានុភាពរបស់ថ្មភក់ កម្សោយមួយដែលបណ្តាលមកពីអាកាស (ប្រហាក់ប្រហែលនិងនំម្សៅ) ៣ b/ បង្ហាញពីស្ថានភាពអនុភាពខ្លាំង ជាងមុន និងការថយចុះនៃអនុភាពដែលមានកំរាស់ ២.៥សម ។ ក្នុងករណីទាំងពីរនេះ ការអភិរក្សថៃទាំជួស ជុលបង្ហាញអោយឃើញលទ្ធផលជាវិជ្ជមានអនុភាពបានកើនឡើង (បន្ទាត់ខ្មៅ) និងការធន់នឹងការស្វានច្រើន ឬតិចពីផ្ទៃខាងលើចូលផ្ទៃខាងក្នុង ។

និងភាពយឺតត្រូវបានពិនិត្យ ។ លើសពីនេះទៀត សម្ភារៈអភិរក្សទាំងឡាយ ដូចជាឧបករណ៍រួបរួមថ្ម និងបាយអ សម្រាប់ការបំពេញតំណ និងការចាក់បញ្ចូលក៏ត្រូវបានប្រើ និងធ្វើតេស្តផងដែរ ។ ដំណើការចុះដុនដាបនៃថ្ម គឺជាប្រព័ន្ធដ៏ស្មុគស្មាញបំផុតដែលតាមទំនាក់ទំនងជាន់គ្នា និងជាប់ឥទ្ធិពលទៅវិញទៅមក ។ គំរូនៃការរបកវីណ្ណវង់ដែលជាបាតុភូតពុកផុយមួយដ៏ធ្ងន់ធ្ងរនៅប្រាសាទអង្គរវត្តនោះត្រូវបានពន្យល់ដូចខាងក្រោម ។

កត្តាមួយក្នុងចំណោមកត្តាសំខាន់បំផុតជាច្រើននោះ គឺសម្ភារៈថ្មខ្លួនវាហ្នឹងឯង ។ ថ្មនៅប្រាសាទអង្គរវត្ត គឺជាថ្មភក់ម្យ៉ាងដែលមានចំនួននៃជាតិអំបិលខណិជដីឥដ្ឋដ៏ច្រើនសន្ធឹកសន្ធាប់ ។ ជាតិអំបិលខណិជដីឥដ្ឋមានរចនាសម្ព័ន្ធជាស្រទាប់មួយ ។ ក្រាមនីមួយៗត្រូវបានបង្កើតឡើងដោយបន្ទះស្តើងៗ ដែលត្រូវបានរក្សាទុករួមគ្នាដោយកម្លាំងរូបដ៏ខ្សោយ ។ ក្នុងកំឡុងពេលមានការប៉ះទង្គិច នៃទឹកភ្លៀង ឬសូម្បីតែលទ្ធផលនៃការផ្លាស់ប្តូរសំណើមខ្យល់ ក៏ម៉ូលេគុលទឹកអាចចូលទៅតាមចន្លោះស្រទាប់ក្រាមទាំងនេះ ហើយពង្រីកមាឌនៃក្រាម



នោះបានដែរ ។ ផ្ទុយទៅវិញក្នុងកំឡុងរយៈពេលស្ងួតទឹកបញ្ចេញចំហាយហើយរចនាសម្ព័ន្ធក្រាមក៏រួញទៅ ។ អត្រាខ្ពស់បំផុតនៃកំណើនទឹករហូតដល់បួនមីល្លីម៉ែត្រក្នុងថ្មមួយត្រូវបានគេអង្កេតឃើញនៅក្នុងថ្មភក់នៃប្រាសាទអង្គរវត្ត ។ ដំណើរការជាសាមាយិក (តាមកាល) ទាំងនេះធ្វើអោយរចនាសម្ព័ន្ធថ្មចុះខ្សោយ ។ ព្រឹត្តិការណ៍នេះដោយផ្សំជាមួយព្រឹត្តិកម្មអំបិល ជាយថាហេតុនាំទៅរកការចុះដុនដាបនៃសម្ភារៈថ្មដែលមិនអាចជៀសវាងបាន ។ លើសពីនេះទៀត ថ្មត្រូវបានធ្លាក់ជាបន្តដោយឥទ្ធិពលកំដៅនៃដំណើរការត្រជាក់ដ៏គួរអោយភ្ញាក់ផ្អើលក្នុងកំឡុងពេលខ្យល់ព្យុះត្រូពិច ។

ប្រវត្តិ និង សង្គម

ដំណើរការទាំងនេះបង្កើតនូវកន្លែងដែលចុះខ្សោយមួយនៅក្នុងថ្មភក់នៃប្រាសាទអង្គរវត្តជម្រៅពីពីរទៅបីសង់ទីម៉ែត្រ ។ នៅក្នុងកន្លែងនេះកម្លាំងចំណងត្រូវបានបំផ្លាញទាំងស្រុង ហើយដោយហេតុនេះសំបកថ្មខាងក្រៅ ត្រូវដាច់ចេញហើយរបេះធ្លាក់នៅពេលណាមួយបន្ទាប់មក ។ ផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់នៃការរបកវីណ្ឌវង់



៤/ ការវាស់ស្ទង់ការធន់នឹងការស្ទាន នៅលើថ្មបែកបាក់ ។

នៃការសឹករិចរិលប្រភេទនេះនោះ គឺថា ដំណើរការនៃការធ្លាក់ចុះដែលកើតមានឡើងយ៉ាងយូរដោយគ្មានការបង្ហាញសោតទស្សន៍ឡើយ ។ ស្រាប់តែនៅថ្ងៃមួយ ផ្នែកខាងក្រៅដ៏មានតម្លៃទាំងដុំត្រូវបានបំផ្លាញដោយការរបេះធ្លាក់ហើយអ្វីដែលនៅសេសសល់ គឺមានតែផ្ទៃថ្មដែលគគ្រើមតែប៉ុណ្ណោះដោយគ្មានសោភ័ណភាព និងគ្មានតម្លៃជាប្រវត្តិសាស្ត្របន្តិចសោះឡើយ ។ ដំណើរការបំផ្លិចបំផ្លាញនេះធ្វើអោយគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ផ្ទៃខាងក្រៅដ៏មានតម្លៃនៃក្បាច់អណ្តែត ហើយកំពុងតែសកម្មយ៉ាងខ្លាំងក្រៃលែង ។

ការអភិរក្ស

ការតភ្ជាប់ឡើងវិញនូវផ្ទាំងសិលាដែលរលុងអោយជាប់នឹងផ្ទៃខាងក្នុងនៃផ្ទាំងសិលានោះ គឺជាសកម្មភាពអភិរក្សដំបូងនៅប្រាសាទអង្គរវត្ត ហើយប្រតិបត្តិការនេះទាមទារនូវការរៀបចំដ៏ប្រុងប្រយ័ត្ន ។ សម្ភារៈបំពេញត្រូវតែបង្កើតឡើងយ៉ាងពិសេស ហើយត្រូវតែធ្វើតេស្តយ៉ាងហ្មត់ចត់សម្រាប់ថ្មប្រភេទពិសេសនេះ ។ ដោយដឹងថា ជាងសាមសិបភាគរយនៃចម្លាក់ក្បាច់អណ្តែតនៃប្រាសាទអង្គរវត្តកំពុងទទួលរងនូវការរបកផ្ទាំងវីណ្ឌវង់នៅក្នុងតំណាក់កាលផ្សេងៗ និងដោយដឹងថាចម្លាក់ជាច្រើនត្រូវបានគម្រាមកំហែងដោយការបាត់បង់ភ្លាមៗនោះអន្តរាគមន៍មុនការរួបរួមចូលគ្នាមួយទៅលើចម្លាក់អប្សរាដែលពុកផុយដ៏ធ្ងន់ធ្ងរបំផុតប្រហែលជាបីរយរូប និងទៅលើទម្រមួយចំនួនត្រូវបានធ្វើឡើង ។ ក្នុងបំណងដើម្បីរារាំងការបាត់បង់ផ្ទាំងថ្មដ៏មានតម្លៃតទៅទៀត បំណែកដែលស្ថិតក្នុងគ្រោះអាសន្ននៃការរលំបានរួចផុតពីគ្រោះថ្នាក់ជាបណ្តោះអាសន្នដើម្បីអនុញ្ញាតអោយមានវិធានការអភិរក្សពិតប្រាកដនៅពេលក្រោយទៀត ។ បច្ចេកទេសមុនការរួបរួមចូលគ្នាត្រូវបង្កើតឡើងជាពិសេសសម្រាប់ស្ថានភាពនីមួយៗ នៅប្រាសាទអង្គរវត្ត ។ បច្ចេកទេសផ្សេងៗត្រូវបានប្រើ គឺចាប់ពីបច្ចេកទេសដែលគេប្រើក្នុងការអភិរក្សនៃផ្ទាំងគំនូរសម្រាប់ទប់បំណែកតូចៗរហូតដល់បច្ចេកទេសដាក់កន្លាស់ពីក្រោម និងបច្ចេកទេសបញ្ចូលគ្នាដ៏ស្មុគ្រស្មាញ ដែលបច្ចេកទេសទាំងអស់នេះអាចនឹងប្តូរបញ្ច្រាសទៅវិញបាន ។ រូប ១៤.ក និង ខ បង្ហាញពី បច្ចេកទេសដែលមានរណបម្នាងសិលាដែលគេរុំទប់ឆ្អឹងអេប៉ុកស៊ីស្រដៀងគ្នានឹងរណបម្នាងសិលាដែលគេរុំទប់ឆ្អឹង ដែលគេប្រើក្នុងវិជ្ជាពេទ្យ ឬក្នុងការពង្រឹងជាមួយខ្សែសន្ទចដែរ ។ មិនតែប៉ុណ្ណោះ កម្មវិធីមួយសម្រាប់កិច្ចការ មុនការរួបរួមចូលគ្នានៃបំណែកដែលមានគ្រោះថ្នាក់ដទៃទៀតនៃប្រាសាទអង្គរវត្ត ដូចជាទម្រ និងធ្នឹមផ្សេងៗ ព្រម ទាំងបំណែកពុកផុយធ្ងន់ធ្ងរនៃចម្លាក់លឹបនៅក្នុងថែវនានា កំពុងតែត្រូវបានអនុវត្តន៍ ។

ផែនការអភិរក្សសម្រាប់រូបចម្លាក់អប្សរា និងទេវតា ព្រមទាំងទម្រធ្នឹម និងក្បាច់ចម្លាក់លឹបជាច្រើនទៀត គឺត្រូវបានផ្តោតលើការបំពេញតំណដោយបាយអ និងស៊ីម៉ង់ត៍ (ការបំពេញស្នាមប្រេះ និងតំណ) និងការបញ្ចូលផ្ទាំងថ្មវីណ្ឌវង់ជាមួយបាយអ និងគ្រឿងភ្ជាប់ដែលតាមលក្ខណៈរូប គីមី និងតាមលក្ខណៈសោភ័ណភាពដែលសម្រួលទៅតាមថ្មភក់ដើមបានល្អ និងការរួបរួមចូលគ្នាជាចុងក្រោយ

ការរបកវណ្ណ៏វង់ : ជម្ងឺខូចទ្រង់ទ្រាយនៃចម្លាក់ ប្រាសាទអង្គរវត្ត

ដោយ ហាន លេសិន Hans Leisen

ជាមួយបណ្តុំលោហៈនៃរ៉ាឌីកាល់អេតានជាសម្ភារៈមួយប្រភេទដែលមានគុណភាពស្រដៀងនឹងថ្មដែរ ។ ការតភ្ជាប់ឡើងវិញនូវផ្ទាំងថ្មដែលរលុងដោយការបញ្ចូលបាយអបំពេញត្រូវបានអនុវត្តឡើងដោយបច្ចេកវិជ្ជាដ៏ពិសេសមួយ ។ អន្តរាគមន៍នេះមិនត្រឹមតែនាំទៅរកការពង្រឹងរូបចម្លាក់ទូទៅប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងនាំទៅរកការស្តារឡើងវិញនៃគុណភាពជ្រាបចូលតាមសរសៃតូចៗរបស់ថ្មដែលជាបុរេលក្ខខ័ណ្ឌចាំបាច់មួយសម្រាប់ការរួបរួមថ្មចូលគ្នាតាមការចាក់បំពេញ ។ ការបំពេញបញ្ចូលគ្នានៃសាធាតុភ្ជាក់ងាររួបរួមត្រូវបានស្តាបនាឡើងនៅចន្លោះ អាការៈរូបនៃសារធាតុខនិជ ។ គោលបំណងនៃវិធានការទាំងនេះ គឺ ដើម្បីបន្ថយដំណើរការដែលនឹងបង្កនូវការបាត់បង់ចម្លាក់អំណែតនៅប្រាសាទអង្គរវត្តដ៏ស្រស់ស្អាតដោយជៀសមិនរួច ។

ការបណ្តុះបណ្តាល

ការងារនេះកំពុងតែត្រូវបានអនុវត្តឡើងជាមួយក្រុមខ្មែរមួយមកពីការិយាល័យអភិរក្សអង្គរ និងនិស្សិតជាន់ខ្ពស់ នៃសកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្ត នៅទីក្រុងកូឡូញ ។ ក្រៅពីការអភិរក្សចម្លាក់លឹប គោលបំណងចម្បងរបស់គម្រោងនេះ គឺការបណ្តុះបណ្តាលអ្នកមានវិជ្ជាជីវៈកម្ពុជាក្មេងៗនៅមូលដ្ឋាន នៅក្នុងវគ្គសិក្សាដែលគេហៅថា វគ្គសិក្សាតាណើ និងបណ្តុះបណ្តាលអ្នកមានវិជ្ជាជីវៈ មកពីមហាវិទ្យាល័យបុរាណវិទ្យា និងស្ថាបត្យកម្មនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈភ្នំពេញហើយនិងនិស្សិតរបស់យើងផ្ទាល់ ។ កម្មវិធីបណ្តុះបណ្តាលផ្តល់ការយកចិត្តទុកដាក់ពិសេសចំពោះការថែទាំប្រាសាទអង្គរវត្តព្រមទាំងចំពោះអន្តរាគមន៍អភិរក្ស ។

សន្និដ្ឋាន

គម្រោងអភិរក្សអប្សរាអាល្លឺម៉ង់ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ក្នុងបំណងដើម្បីសម្រេចផែនការអភិរក្ស អនុវត្តវិធានការថែរក្សា និងធ្វើអោយស្ថាបត្យករ និងកម្មករមូលដ្ឋានមានឯកទេសក្នុងវិស័យនៃការថែរក្សាថ្ម ។ គម្រោងនេះត្រូវបានរៀបចំចាត់ចែងដោយសកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្តន៍នៅទីក្រុងកូឡូញ ។ ការធ្លាក់ដុនដាបយ៉ាងឆាប់រហ័ស និងសភាពពុកផុយដ៏លឿនដែលត្រូវបានសង្កេតឃើញនៅក្នុងចម្លាក់ថ្មជាងបីរយហាសិបដុំបាននាំអោយមានសកម្មភាពរួបរួមចូលគ្នាជាបន្ទាន់មួយ ។ ការស៊ើបអង្កេតដំណាលគ្នាទៅលើប៉ារ៉ាម៉ែត្រសម្ភារៈ កត្តាបង្កការខូចខាត និងលទ្ធភាពអភិរក្សកំពុងតែត្រូវបានអនុវត្ត ។ សម្ភារៈអភិរក្សសមស្របកំពុងតែត្រូវបានពិនិត្យនៅក្នុងតំបន់ធ្វើតេស្តនានានៅប្រាសាទអង្គរវត្ត ។

សកម្មភាពស្រាវជ្រាវ និងវិធានការថែរក្សាទាំងអស់ត្រូវបានអនុវត្តដោយក្រុមវិន័យចម្រុះ ដែលមានលោកគ្រូអ្នកគ្រូ និងនិស្សិតនៃសកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្តន៍នៃទីក្រុងកូឡូញ អ្នកឯកទេសពីខាងក្រៅ ព្រមទាំងអ្នកអភិរក្ស និងកម្មសិក្សាការីអឺរ៉ុប និងកម្ពុជាជាច្រើនទៀត ។

ការថែរក្សាការពារតួប៉មប្រាសាទបាយ័ន និងប្រាសាទសួព្រ័ត

ដោយ តាក់កេស៊ិ ណាកាហ្កាវ៉ា Takeshi Nakagawa

តាក់កេស៊ិ ណេកាហ្កាវ៉ា ជាប្រវត្តិវិទូស្ថាបត្យកម្មម្នាក់ បង្រៀននៅសកលវិទ្យាល័យវ៉ាសេដា និងជាអគ្គនាយកក្រុមការពារអង្គរ របស់រដ្ឋាភិបាលជប៉ុន ។

ប្លង់មេនៃប្រាសាទបាយ័ន

ឥឡូវយើងអាចមើលឃើញនឹងភ្នែកនូវលទ្ធផលគ្មានពីរនៃមនោគតិខាងស្ថាបត្យកម្មរបស់ប្រជាជនខ្មែរ ។ និមិត្តសញ្ញានៃប្រវត្តិសាស្ត្រវប្បធម៌របស់ខ្លួន និងការអភិវឌ្ឍន៍ជាតិខ្មែរជាបណ្ដើរៗ ។ រចនាបថស្ថាបត្យកម្មខ្មែរ ដែលមានប្រភពនៅក្នុងប្រទេសឥណ្ឌា បានផ្សព្វផ្សាយពាសពេញតំបន់ឥណ្ឌូចិន និងអាស៊ីប៉ែកអាគ្នេយ៍អស់រយៈពេលជាច្រើនសតវត្ស និងបានអភិវឌ្ឍន៍ក្នុងការផ្លាស់ប្ដូរវប្បធម៌ជាមួយប្រទេសជាតិជាច្រើន និងជាមួយប្រទេសជិតខាងនានា·។

ការបង្ហាញនៃមនោគតិស្ថាបត្យកម្មនេះត្រូវបានរកឃើញនៅកណ្ដាលប្រាសាទអង្គរធំ ពោលគឺប្រាសាទបាយ័ននេះឯង ដែលជារចនាសម្ព័ន្ធដ៏សំខាន់បំផុតមួយនៅក្នុងប្រវត្តិសាស្ត្រស្ថាបត្យកម្មខ្មែរដោយគ្មានមន្ទិលសង្ស័យ ។ នៅតែពោរពេញទៅដោយអាថ៌កំបាំង និងសម្រស់ប្រាសាទនេះស្ថិតនៅជិតបេះដូង និងព្រលឹងប្រជាជន និងជាមណ្ឌលដ៏សំខាន់មួយសម្រាប់ទេសចរណ៍ ។ ប៉ុន្តែវាជាប្រាសាទមួយដែលជិតនឹងបាក់បែកហើយ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់អ្នកជំនាញមួយចំនួន ជាពិសេស គឺអ្នកជំនាញរបស់សាស្ត្រាចារ្យ ហ្សាក ឌូម៉ាសី (Jacques Dumarcay) និងសាស្ត្រាចារ្យ ខ្លូត ហ្សាក់ (Claude Jacques) យ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។

JSA មានបំណងដោះស្រាយបញ្ហានេះដោយមានកិច្ចសហប្រតិបត្តិការពីក្រុមទាំងឡាយ និងប្រជាជនកម្ពុជាទាំងអស់ដែលកំពុងបំរើការនៅតំបន់អង្គរ និងដោយមានការចូលរួមពីអ្នកជំនាញទាំង

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ការថែរក្សាការពារតួប៉មប្រាសាទបាយ័ន និងប្រាសាទសួព្រ័ត

ដោយ តាក់កេស៊ិ ណាកាហ្កាវ៉ា Takeshi Nakagawa

ឡាយនៅជុំវិញពិភពលោកយើងនេះ ។ អាស្រ័យហេតុនេះ JSA បន្តបញ្ចេញអោយគេបានដឹងឮអំពីប្លង់មេនៃប្រាសាទបាយ័ន ក្នុងបំណងដើម្បីកំណត់មតិយោបល់ និងជំហានដែលត្រូវការដើម្បីជួយសង្គ្រោះបរិវេណប្រាសាទបាយ័ននេះ ។ JSA ក៏បានរៀបចំសន្និសីទបាយ័នផងដែរ ដែលជាសកម្មភាពចម្បងក្នុងការផ្សៀងផ្ទាត់លទ្ធផលនៃសកម្មភាពអភិវឌ្ឍន៍កន្លងទៅរបស់ខ្លួន ។ របាយការណ៍រយៈពេលមធ្យមអំពីលទ្ធផលដែលសម្រេចបានកន្លងមក ឯកសារនេះក៏មានរាប់បញ្ចូលបញ្ហាដែលត្រូវការសកម្មភាពបន្ទាន់ផងដែរ ។

សំយោគនៃសកម្មភាព (៨ឆ្នាំ ១៩៩៤-២០០១)

ការស្ទង់មតិ និងសារពើភ័ណ្ឌតាមលំដាប់លំដោយខាងក្រោមនេះ ត្រូវបានអនុវត្តកាលពី ៨ឆ្នាំកន្លងទៅ ក្នុងគោលបំណងដើម្បីបង្កើតប្លង់មេសម្រាប់ការថែរក្សាការពារ និងការស្តារឡើងវិញនៃបរិវេណប្រាសាទបាយ័ន ។ ការស្ទង់មតិ និងសារពើភ័ណ្ឌទាំងនេះគ្របដណ្តប់នូវការស៊ើបអង្កេតដែលត្រូវបានធ្វើឡើងនៅក្នុងវិស័យសំខាន់ៗជាច្រើន មានជាអាទិ៍ ស្ថាបត្យកម្ម ប្រវត្តិសាស្ត្រសិល្បៈ បុរាណវត្ថុវិទ្យា នរពន្ធុវិទ្យា ភូគព្ភសាស្ត្រ បរិស្ថាន និងវិទ្យាសាស្ត្រអភិរក្ស ។

ការស៊ើបអង្កេតផ្នែកស្ថាបត្យកម្ម

ដោយស្ថិតកណ្តាលអង្គរធំ ប្រាសាទបាយ័នជាដំបូងត្រូវបានស្ថាបនាឡើង ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (ប្រហែល១១៨១-១២១៨) ជាប្រាសាទបែបព្រះពុទ្ធសាសនាមហាយាន ។ ក្រោយមកវាត្រូវបានគេផ្លាស់ប្តូរទៅជាប្រាសាទបែបសាសនាព្រាហ្មណ៍ហើយពីរបីឆ្នាំក្រោយ មកក៏ត្រូវបានគេប្តូរទៅជាប្រាសាទបែបព្រះពុទ្ធសាសនាហីនយានវិញ ។ រហូតមកដល់សព្វថ្ងៃនៅតែជាបូជនីយដ្ឋានមួយរបស់អ្នកកាន់ព្រះពុទ្ធសាសនាដដែល ។ ប្រាសាទនេះបែរមុខទៅទិសខាងកើតហើយមានប្លង់រាងចតុកោណកែងដែល (ផ្នែកខាងមុខ) មានប្រវែង ១៣០ ម៉ែត្រ និង (ជ្រុង) មានប្រវែង១៤០ម៉ែត្រ ។ ផ្នែកមុខនៃទិសខាង កើតត្រូវចូលតាមទីលានមួយហើយនៅជ្រុងខាងជើង និងជ្រុងខាងត្បូងនៃទីលាននេះ គឺជាស្រះរាងបួនជ្រុងទ្រវែង (ចតុកោណកែង) ។ ប្រាសាទនេះមានបីជាន់ : ជាន់លើ (ទីលានកណ្តាល) ជាន់កណ្តាល និងទីលានក្រោម ។ បណ្ណាល័យស្ថិតនៅជ្រុងខាងជើង និងជ្រុងខាងត្បូងនៃថែវខាងក្រៅ ។ ព្រមជាមួយទម្រង់ស្ថាបត្យកម្មនៃបរិវេណនេះ គឺលក្ខណៈពិសេសនៃស្ថាបត្យកម្មប្រាសាទបាយ័នផ្សេងៗទៀត : ក្បាច់អណ្តែតលំអដែលឆ្លាក់នៅលើជញ្ជាំងថែវនានា និងកំពូលមុខដែលស្ថិតនៅផ្តុំគ្នាដ៏ច្រើន ។

ការអង្កេតលើស្ថាបត្យកម្មគ្របដណ្តប់នៃទីកន្លែង និងលក្ខណៈជាច្រើន : ប្រព័ន្ធបង្ហូរទឹកបំណែកបាក់បែកនៃកំពូលមុខនៅលើទីលានខ្ពស់បំផុតនៃប្រាសាទបាយ័ន ថែវខាងក្រៅ និងថែវខាងក្នុង ទេវតាឈរ និងការទ្រេតនៃកំពូលប្រាសាទទាំងឡាយ ។ ការស៊ើបអង្កេតលើប្រព័ន្ធបង្ហូរទឹកនៃប្រាសាទបាយ័ន និងបញ្ហារបស់វាបានកើតឡើងចាប់ពីខែសីហា ឆ្នាំ១៩៩៧ ដល់ខែមករា ឆ្នាំ១៩៩៨ ហើយត្រូវបានបោះពុម្ពផ្សាយនៅក្នុង"របាយការណ៍ប្រចាំឆ្នាំស្តីអំពីការស្ទង់មតិផ្នែកបច្ចេកទេសនៃប្រាសាទទាំងឡាយនៅតំបន់អង្គរ" របស់ JSA នៅ ឆ្នាំ១៩៩៨។ គោលបំណងនៃការស៊ើបអង្កេតនេះ គឺដើម្បីសំអាតប្រព័ន្ធបង្ហូរទឹកនៅបរិវេណប្រាសាទបាយ័ន បញ្ជាក់អោយច្បាស់ នូវទីតាំងនៃបំពង់បង្ហូរទឹក នៅក្នុងបរិវេណប្រាសាទ ហើយនិងដើម្បីចាត់ប្រភេទនៃបំពង់បង្ហូរទឹកដែលត្រូវបានប្រើជាក្រុម ។ លើសពីនេះទៀតយើងបានច្នៃមធ្យោបាយដ៏រហ័ស និងដ៏មានប្រសិទ្ធភាពនៃការដោះស្រាយជាមួយការធ្លាក់ភ្លៀង ជោគជាំនៅរដូវវស្សាដើម្បីការពារចំនួនច្រើននៃវេទិការចនាសម្ព័ន្ធ មិនអោយចុះខ្សោយ ។

ការអង្កេតលើផ្នែក ដែលទទួលរងគ្រោះរបស់ប្រាសាទបាយ័ន និងការថែទាំរបស់វាបានចាប់ផ្តើមពីខែឧសភា ឆ្នាំ១៩៩៧ ។ នៅពេលនោះ មានកន្លែងជាងបីរយត្រូវបានកត់ត្រាទុកនៅក្នុងបញ្ជីនៃបំណែកដ៏ប្រកបដោយគ្រោះថ្នាក់នៃប្រាសាទបាយ័ន ។ រហូតមកដល់សព្វថ្ងៃយើងបានផ្តល់ទម្របណ្តោះអាសន្ននៅកន្លែងទាំងឡាយដែលត្រូវការបន្ទាន់ ។ ទោះជាយ៉ាងណាក៏ដោយយោងតាមឯកសារថ្មីៗរបស់យើងចំនួននៃបំណែកដ៏ប្រកបដោយគ្រោះថ្នាក់នៅក្នុងបរិវេណទាំងមូលបានកើនឡើងរហូតដល់ទៅ៥០០កន្លែងជាការធ្លាក់ចុះនៃរចនាសម្ព័ន្ធដ៏គួរអោយភ្ញាក់ផ្អើលមួយដែលទាមទារការយកចិត្តទុកដាក់ពិសេស ។

ការអង្កេតលើដំណាក់កាលនៃការសាងសង់កំពូលមុខនៅ

ប្រវត្តិ និង សង្គម

លើទីលានខ្ពស់បំផុតនៃប្រាសាទបាយ័នពាក់ព័ន្ធនឹងស្នាមដានដ៏គួរអោយកត់សម្គាល់ទាំងឡាយដែលត្រូវបានរាវរកឃើញ ដែលអាចផ្តល់ពន្លឺលើគម្លាតចំណេះដឹងទាក់ទងនឹងដំណាក់កាលសាងសង់ប្រាសាទបាយ័ន ។ ដោយនៅក្នុងដំណាក់កាលដំបូងនៅឡើយការស៊ើបអង្កេតត្រូវការការសិក្សាលំអិតបន្ថែមដើម្បីផ្តល់អត្ថន័យចំពោះស្នាមដានដែលធ្វើអោយងឿងឆ្ងល់ផ្សេងៗទៀត ។

ការស៊ើបអង្កេតលើស្ថានភាពបច្ចុប្បន្ននៃថែវខាងក្នុង និងថែវខាងក្រៅចាំបាច់ត្រូវធ្វើការប្រៀបធៀបស្ថានភាពបច្ចុប្បន្នរបស់វាជាមួយនឹងអ្វី ដែលត្រូវបានកត់ត្រានៅក្នុងរូបថតដោយ លោក ហង់រី ឌូហ្វ៊័រ (Henri Dufour) និងលោក សាល សាប៉ូកស៍ (Charles Carpeaux) នៅ ឆ្នាំ១៩០១ ។ រូបថតទាំងនោះបង្ហាញភស្តុតាងថាផ្នែកខ្លះនៃថែវទាំងនេះត្រូវបានផ្លាស់ប្តូរ ។ អាស្រ័យហេតុនេះពួកវាគឺជាសម្ភារៈ យោងដ៏មានតម្លៃក្នុងការកំណត់វិធីសាស្រ្តអភិរក្សចម្លាក់លិបនៃថែវខាងក្នុង និងថែវខាងក្រៅ ។

ការស៊ើបអង្កេតលើស្ថានភាពបច្ចុប្បន្ននៃរូបទេវតាឈរនៃប្រាសាទបាយ័នត្រូវបានធ្វើឡើង ដើម្បីកំណត់ស្ថានភាពពិតប្រាកដ និងកំរិតនៃការខូចខាតមកលើចម្លាក់ទាំងនេះ ។ ស្ថានភាពបច្ចុប្បន្នរបស់ពួកគេត្រូវបានកត់ត្រាដោយគំនូសព្រាង ដែលនឹងជាមូលដ្ឋាននៃសំណើរបស់យើងសម្រាប់ការស្តារឡើងវិញនៃរូបចម្លាក់ទេវតាឈរ ។ ការស៊ើបអង្កេតនេះនឹងត្រូវបន្ត ដើម្បីធ្វើការបកស្រាយនូវផ្នែកនៃប្រវត្តិនៃការកសាងប្រាសាទបាយ័ននេះ ។

ទំនោរនៃកំពូលប្រាសាទបាយ័នទៅរកការទ្រេតត្រូវបានវាស់ដោយប្រើឧករណ៍មួយប្រភេទហៅថា Plump Bob ។ លទ្ធផលនៃតេស្តនេះចង្អុលប្រាប់ហេតុថា កំពូលប្រាសាទជាច្រើនហាក់ដូចជាទ្រេតចេញក្រៅវេទិការបស់ខ្លួន (ការផ្តុំគ្រឹះ) ។ វាផ្តល់ជាយោបល់ថាមានទំនាក់ទំនងមួយដែលគួរយកមកគិតពិចារណារវាងទិសនៃការទ្រេត និងបញ្ហានៃការចាក់គ្រឹះ ។ ដំណើរសឹកនៃដីបំពេញខាងក្នុងនៃវេទិកានោះត្រូវបានគេវិនិច្ឆ័យថាជាបុព្វហេតុមួយនៃការទ្រេតនេះ ។ ការស៊ើបអង្កេតបន្ថែមនឹងត្រូវអនុវត្តឡើងដើម្បីសិក្សាអំពីបុព្វហេតុ និងវិធានការតបនៃការវិលជុំ ។

ការស្រាវជ្រាវដំបូងៗ ត្រូវបានអនុវត្តទៅលើប្រភេទនៃគ្រឿងប្រក់ដំបូលដែលត្រូវបានប្រើនៅក្នុងបរិវេណប្រាសាទបាយ័នដើម្បីស្វែងរកគំរូដំបូលសម្រាប់បណ្ណាល័យខាងជើង ។ ការសិក្សាអំពីថ្មប្រាសាទបាយ័នដែលរលំ និងដែលនៅរាយប៉ាយ ព្រមទាំងបំណែក នៃកំផែងថែវខាងក្នុង និងខាងក្រៅដែលបាត់បង់ក៏ត្រូវបានធ្វើឡើងផងដែរ ។

ការស៊ើបអង្កេតផ្នែកបុរាណវិទ្យា

ដើម្បីចេះប្រើបច្ចេកទេសខ្មែរបុរាណនៅក្នុងការងារស្តាររបស់យើង យើងត្រូវការស៊ើបអង្កេតនូវលក្ខណៈបច្ចេកទេសនៃការកសាងគ្រឹះនៃបណ្ណាល័យខាងជើង ។ ពត៌មានអំពីពង្សាវតារនៃការស្ថាបនារបស់វាអាចទទួលបានតែតាមរយៈការជីកកកាយបុរាណវត្ថុតែប៉ុណ្ណោះ ហើយការងារនេះយើងបានអនុវត្តនៅឆ្នាំ១៩៩៥ រួចហើយ ។ មុនពេលការរំលាយបណ្ណាល័យខាងជើងនៃប្រាសាទបាយ័នចោលការអង្កេតការណ៍ផ្នែកបុរាណវត្ថុត្រូវបានអនុវត្ត ។ ការស៊ើបអង្កេតលើកម្រាលឥដ្ឋ និងជ្រុងអាគ្នេយ៍នៃវេទិកាជាន់លើរបស់វា ព្រមទាំងជ្រុងពាយ័ព្យនៃវេទិការបស់ខ្លួន ត្រូវធ្វើឡើងដោយឡែកៗ ពីគ្នានៅខែកក្កដាឆ្នាំ១៩៩៧ និងខែកុម្ភៈ ឆ្នាំ១៩៩៨ ។ ស្រដៀងគ្នានេះដែរ ដើម្បីស្វែងយល់អោយបានពេញលេញអំពីមុខងារនៃរចនាសម្ព័ន្ធទីធ្លាខាងក្នុង និងដំណើរការសាងសង់នៃប្រាសាទបាយ័ន យើងបានចាប់ផ្តើមការស៊ើបអង្កេត និងការជីកកកាយនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ។ ការជីកកកាយដោយមានទ្រង់ទ្រាយជារណ្តៅដ៏វែង បានចាប់ផ្តើមនៅត្រង់ថែវខាងក្នុង និងចប់ទៅវិញនៅត្រង់វណ្ឌមណ្ឌលខាងក្រៅនៃថែវខាងក្រៅ (ផ្លូវមូលខាងក្រៅនៃបរិវេណប្រាសាទបាយ័ន) នៅជ្រុងខាងកើតនៃមុខប្រាសាទបាយ័នខាងជើង ។

កម្មវិធីអភិរក្សប្រាសាទសួព្រ័ត

ដោយស្ថិតនៅជ្រុងខាងកើតនៃព្រះលានស្តេចនៅចំកណ្តាលអង្គរ ប្រាសាទសួព្រ័តរត់ស្របគ្នានឹងព្រះបរមរាជវាំងដែរ ។ ផ្លូវដ៏ឆ្ងាយចេញពីខាងមុខព្រះបរមរាជវាំងទៅខ្លោងទ្វារជ័យទម្លុះចូលចំកណ្តាលបរិវេណនៃប្រាសាទនេះ ដែលមានទីលានជាច្រើន និងកំពូល១២ ។ មានក្រុមកំពូលប្រាំមួយពីរក្រុមដោយក្រុម១នៅជ្រុងខាងជើង និង

ការថែរក្សាការពារតួប៉មប្រាសាទបាយ័ន និងប្រាសាទសួព្រ័ត

ដោយ តាក់កេស៊ិ ណាកាហ្កាវ៉ា Takeshi Nakagawa

១/ ប្រាសាទសួព្រ័ត ពាក់កណ្ដាលទី២នៃសតវត្សទី១៣ ស្ថិតនៅតាមបណ្ដោយតំបន់ភាគខាងកើតនៃ ព្រះបរមរាជវាំងមានកំពូលតូចៗ ចំនួន១២ ដែលគោលបំណងរបស់វាស្ថិតនៅជាអាថិកំបាំងនៅឡើយ ។ រូបភាពដោយអ្នកនិពន្ធ ។

២/ រន្ទាចាំបាច់សំរាប់ការងារជួសជុលប្រាសាទសួព្រ័ត ត្រូវបានធ្វើឡើងដោយក្រុមរដ្ឋាភិបាលជប៉ុន ដើម្បីការការពារនិងថែរក្សាប្រាសាទអង្គរ (JSA) ។ រូបភាពដោយអ្នកនិពន្ធ

ក្រុមមួយទៀតនៅជ្រុងខាងត្បូងនៃផ្លូវកណ្ដាល ។ កំពូលប្រាសាទប្រាំនៅក្នុងក្រុមនីមួយៗ បែរមុខទៅរកព្រះលានស្ដេចចំណែកឯកំពូលមួយនៅក្នុងក្រុមនីមួយៗបែរមុខទៅរកផ្លូវកណ្ដាល ។ កំពូលប្រាសាទទាំងអស់មានកំពស់បីថ្នាក់ ហើយថ្នាក់នីមួយៗ មានបន្ទប់តូចមួយនៅពីមុខ ។ កំពូលទាំងប្រាំមួយនៅក្នុងក្រុមខាងជើងត្រូវបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍របស់យើងពី N1 ដល់ N6 តាមលំដាប់នៃចម្ងាយរបស់វាចេញពីផ្លូវកណ្ដាល ។ ស្រដៀងគ្នានេះដែរ កំពូលទាំងប្រាំមួយនៃក្រុមខាងត្បូងត្រូវបានកំណត់ជា S1 ដល់ S2 ។

មានស្រះរាងបួនជ្រុងទ្រវែងនៅពីក្រោយកំពូល N1 ដល់ N3 និង S1 ដល់ S3 ។ ហើយនៅកំពូលខាងក្រោយ N4 ដល់ N5 និង S4 ដល់ S5 គឺជាឃ្លាំងខាងជើង និងឃ្លាំងខាងត្បូង ។ ក្រុមនៃទីលានវាវែងជាងដោយទិសខាងជើង និងខាងត្បូងរបស់វា ។ វាប្ដូរទិសនៅត្រង់មុំខាងស្ដាំទៅទិសខាងកើតនៅជ្រុងខាងត្បូងនៃ N2 និងកាត់តាមបណ្ដោយជ្រុងខាងជើងនៃ N1 ។ ទាំងនៅចុងខាងជើង និងចុងខាងកើតនៃទីលានទាំងនេះ នៅមានច្រើនទៀតដែលពន្យល់បកស្រាយ ។ ទីលាននៃក្រុមខាងត្បូងទាំងឡាយក៏ស្ថិតក្នុងការស៊ីសង្វាក់គ្នាដែលចែកចេញដូចជាកាំកង់ទៅកាន់ផ្លូវកណ្ដាលផងដែរ ។ ទីលានទាំងអស់លយចេញនៅខាងមុខកំពូលនីមួយៗ វៀរលែងតែត្រង់កំពូល N4 និង N5 ជាកន្លែងដែលកំពូលទាំងនោះមានរាងជាសញ្ញាលេខបូក ។ លើសពីនេះទៀត ពុំមានស្នាមដាននៃទីលានណាត្រូវបានរកឃើញនៅ N1 និង S1 តាមបណ្ដោយផ្លូវកណ្ដាលឡើយ ។

ប្រាសាទសួព្រ័តមានន័យថា "ប្រាសាទនៃអ្នករបាំខ្សែព្រ័ត" ។ ដូចអត្ថន័យបានបង្ហាញ កំពូលប្រាសាទប្រហែលជាអាចបម្រើគោលបំណងនេះ ហើយប្រហែលជាអាចត្រូវបានគេប្រើជាតុលាការផងដែរ ។ គេមានជំនឿថា ទាំងនេះប្រហែលជាត្រូវបានស្ថាបនាឡើងនាសម័យប្រាសាទបាយ័ន ចុងសតវត្សទី១២ ដល់ដើមសតវត្សទី១៣ ទោះជាដូច្នោះក្ដីអំណះអំណាងនេះតម្រូវអោយមានការបញ្ជាក់អោយបានច្បាស់លាស់ថែមទៀត ។

ការស្ទង់មតិនៃស្ថានភាពបច្ចុប្បន្ននៃតួប៉មប្រាសាទទាំងនេះត្រូវបានរៀបចំឡើងដោយ JSA តាំងពី ឆ្នាំ១៩៩៤ ម្ល៉េះ ។ ផ្នែកទាំង

ប្រវត្តិ និង សង្គម

សម្បូរនៃការងារនេះ គឺការគូរប្លង់មហេតុលប្លង់កំពស់ និងផ្នែកខ្វាត ខ្វែងគ្នានៃកំពូលប្រាសាទមួយចំនួន ។ ម្យ៉ាងវិញទៀត ការងារស្តារប្រាសាទសួព្រ័តដែលទទួលអនុវត្តដោយក្រុមបារាំងបានផ្តោតទៅលើការជួសជុលបន្ទាន់ នៃផ្នែកដែលស្ថិតក្នុងសភាពគ្រោះថ្នាក់របស់វា និងការដាក់ឡើងវិញនូវថ្មដែលបានធ្លាក់ ។ ជាពិសេស កំពូល N3 បានទទួលការងារស្តារឡើងវិញ ដែលមានគំនូសប្លង់ផ្សេងៗ និងប្លង់ពុះផងដែរ ។

កម្មវិធីអភិរក្សចាំបាច់ត្រូវមានការអង្កេតលើរចនាសម្ព័ន្ធនៃវេទិកា ។ រចនាសម្ព័ន្ធវេទិកា និងបញ្ហាគ្រឹះ គឺជាសំណួរដ៏សំខាន់បំផុតដែលត្រូវតែដោះស្រាយអោយបានមុនការធ្វើផែនការនៃវិធីសាស្ត្រថែរក្សាការពារ ។ ដើម្បីប៉ាន់ប្រមាណទ្រង់ទ្រាយ និងជម្រៅនៃរចនាសម្ព័ន្ធគ្រឹះ និងស្រទាប់ខ្សាច់នោះ ការជីកកកាយតិចតួចនៅខាងក្រៅវេទិកា និងការធ្វើតេស្តដោយប្រើដែកខួងនៅក្នុងវេទិកាត្រូវបានធ្វើឡើងនៅ N1 ។ លទ្ធផលបានបង្ហាញថាគ្រឹះដីដើមនៅជុំវិញតួប៉ម N1 ត្រូវបានប៉ាន់ប្រមាណឃើញថានៅក្រោមគ្រឹះដីបច្ចុប្បន្នប្រហែលជាមួយម៉ែត្រ ហើយថាថ្មបាយក្រៀមបួនដុំទៀតត្រូវបានរកឃើញនៅក្រោមដី ។ ទម្រង់ផ្នែកនៃកំពែងថ្មបាយក្រៀមក្រោមដីមិនត្រង់ទេហើយអាចទ្រេតទៅខាងក្រៅមូលដ្ឋានរបស់វា ។ នេះមានន័យថា សម្ពាធបន្ទុកទទឹងដែលកើតមកពីរចនាសម្ព័ន្ធជាន់លើមិនត្រូវបានទ្រដោយស្រទាប់ខ្សាច់ ឬដោយកំផែងថ្មបាយក្រៀមឡើយ ។

កម្មវិធីថែរក្សាការពារមានបំណងជំរុញកិច្ចខំប្រឹងប្រែងដើម្បីយកព្រះបរមរាជវាំងមកធ្វើជាទីឋាន វប្បធម៌ដ៏មានសារប្រយោជន៍មួយ ។ ការតម្រូវតាមស្តង់ដារសុវត្ថិភាពគួរប្រព្រឹត្តទៅព្រមគ្នាជាមួយការអភិវឌ្ឍន៍នេះ ។ ចំពោះរឿងនេះការបង្កើតគំរូស្តារឡើងវិញសម្រាប់កំពូលធ្វើពីថ្មបាយក្រៀមមួយ និងការបង្កើតវិធីសាស្ត្រនៃការស្តារសម្ភារៈសម្រាប់ផ្ទាំងថ្មបាយក្រៀមត្រូវបានផ្តល់អនុសាសន៍យ៉ាងច្រើន ។ ដើម្បីបង្កើតយុទ្ធសាស្ត្រស្តារឡើងវិញបែបហេតុការណ៍និយមសម្រាប់កំពូលប្រាសាទទាំងឡាយនៅនៅទីលានព្រះរាជាយើងបាន បែងចែកស្ថានភាពរបស់កំពូលប្រាសាទនានាដោយការពិនិត្យមើលស្ថានភាព នៃការធ្លាក់ចុះ (ស្ថានភាពគ្រឹះគ្រោះថ្នាក់) នៃតួប៉មទាំង ១២ ដោយឡែកៗ ពីគ្នាដើម្បីអោយវិធានការតបទាំងបួនខាងក្រោមអាចអនុវត្តបាន ។ វិធានការតបបួនប្រភេទត្រូវបានរកឃើញ ។

គ្រឹះ១ ប្រតិបត្តិការស្តារឡើងវិញគួរតែចាប់ផ្តើមឡើងអោយបានឆាប់តាមដែលអាចធ្វើទៅបានដោយប្រើយុទ្ធសាស្ត្ររុះរើនិងតំលើងឡើងវិញ ។ (តួប៉ម N1)

គ្រឹះ២ រុះរើនិងតំលើងឡើងវិញដោយផ្អែករួមគ្នារាប់បញ្ចូលទាំងការលំអស្ថានភាពដីផង (តួប៉ម N2)

គ្រឹះ៣ តម្រូវអោយមានការអង្កេត និងការតាមដានដ៏ប្រុងប្រយ័ត្ននៅពេលដែលកំពុងរង់ចាំការងារស្តារជាក់ស្តែងចាប់ផ្តើម ។ ប្រព្រឹត្តិកម្មបន្ទាន់បណ្តោះអាសន្នសមរម្យនឹងត្រូវតែផ្តល់តាមតម្រូវការ ។ (តួប៉ម N3 N4 N5 N6 S1 S2 S3 S4 និង S5)

គ្រឹះ៤ ទុកអោយប្រាសាទនៅដូចសព្វថ្ងៃ ពីព្រោះស្ថានភាពបច្ចុប្បន្នរបស់វាបានរឹងមាំគ្រាន់បើហើយ ។ បែបនេះ នឹងធ្វើអោយវាអាចបង្ហាញដំណើរការដុនដាបនៃរចនាសម្ព័ន្ធនៃកំពូលប្រាសាទខ្មែរ នៃវិធីសាស្ត្រសាងសង់ប្រភេទនេះ ។ បង្អិតតំបន់នេះអោយទៅជិតភ្ញៀវទេសចរ ។ (តួប៉ម S6)

ការស្តារឡើងវិញនៃថែវកំពូល N2

JSA បានផ្តល់អនុសាសន៍កាលពីខែមករា ឆ្នាំ២០០១ ដើម្បីស្នើសុំចាប់ផ្តើមការងារនៅលើតួប៉ម N2 ដែលត្រូវបានបែងចែកថ្នាក់នៅក្នុងគ្រឹះ២ ដូចពោលខាងលើ ។ យើងមានជំនឿថា បទពិសោធន៍ និងចំណេះដឹងដែលនឹងទទួលបានពីការងារលើកំពូល N2 នេះ នឹងជួយសម្រួលយ៉ាងច្រើននូវការងារខ្នាតធំលើតួប៉ម N1 ដែលត្រូវធ្វើបន្ទាប់ពីការងារលើកំពូល N2 នេះ ។ ជាក់ស្តែងតាមការធ្វើពិសោធន៍យើងត្រូវការផ្ទៀងផ្ទាត់លទ្ធភាពផ្សេងៗនៃការប្រើប្រាស់ឡើងវិញនូវ

ការថែរក្សាការពារតួប៉មប្រាសាទបាយ័ន និងប្រាសាទសួព្រ័ត

ដោយ តាក់កេស៊ិ ណាកាហ្គាវ៉ា *Takeshi Nakagawa*

សម្ភារៈថ្មបាយក្រៀមពីដើមដែលមានសភាពដុនដាប ក្នុងការងារតំលើងឡើងវិញ ដោយប្រើទ្រឹស្តីអាណាស្ទីឡូ (Anastylosis) . លើសពីនេះទៀត យើងរំពឹងថា នឹងទទួលបាននូវការអភិវឌ្ឍន៍មួយចំនួនក្នុងបច្ចេកទេសបញ្ចូលគ្នា និងបច្ចេកទេសជួសជុលសម្រាប់ផ្ទាំងថ្មបាយក្រៀមដែលបាក់បែក ឬដែលសឹករិចរឹល ។ ការសិក្សានឹងត្រូវអនុវត្ត : សម្រាប់ស្ទាបស្ទង់វិធីសាស្ត្រដែលត្រូវការសម្រាប់ការកែលំអស្ថានភាពដី ដោយមានការបង្ហាប់ដីនៅក្នុងតំបន់ជុំវិញស្រះ សម្រាប់វិធានការតបដែលនឹងត្រូវចាត់ឡើង ដើម្បីការពារ ឬបញ្ឈៀសការរលំ និងការធ្លាក់នៃសារធាតុថ្មនៅក្នុងរចនាសម្ព័ន្ធរាងកោងនៃការលយចេញរបស់ថ្ម និងសម្រាប់ការគ្រោងរចនាសម្ព័ន្ធទាំងបាំងសាច ដើម្បីការពារការជ្រាបទឹក ។

វិធីសាស្ត្រអន្តរវិន័យនៅក្នុងវិស័យបុរាណវិទ្យា ស្ថាបត្យកម្ម ប្រវត្តិស្ថាបត្យកម្ម និងវិស្វកម្មអាចនាំមកនូវដំណោះស្រាយដែលគួរអោយយល់បានមួយសម្រាប់បញ្ហាសំខាន់ៗ ទាំងនេះ ។

ចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០០០ កំណាយតាមដាន ៤ បានធ្វើឡើងនៅកណ្តាលក្នុងទីលាននៃប្រាសាទសួព្រ័ត ។ ក្នុងកំឡុងបេសកម្មទាំងនេះ រណ្តៅទាំងអស់៧ត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដែលលយចេញខាងមុខតួប៉ម N1 និង N2 ដើម្បីរាវរករូបសណ្ឋាន និងមុខងារនៃតំបន់នេះនៅក្នុងតំណាក់កាលដំបូងៗនៃជីវិតសរបស់វា និងដើម្បីប្រៀបធៀបដំណាក់កាលទាំងនេះទៅនឹងរបៀបដែលគេមើលឃើញ និងបកស្រាយវានៅពេលសព្វថ្ងៃនេះ ។ វត្ថុដែលកកាយបានត្រូវបានបែងចែកតាមថ្នាក់ និងធ្វើឯកសារតាមប្រភេទនីមួយៗ ។ វត្ថុធំៗមួយចំនួនត្រូវបានបែងចែកតាមថ្នាក់ ធ្វើកាតាឡុក និងរក្សាទុកនៅក្នុងមណ្ឌលនៅក្បែរនោះ ប៉ុន្តែវត្ថុតូចៗ ត្រូវបានរក្សាទុកនៅក្នុងរោងជាងរបស់ JSA នៅក្នុងខេត្តសៀមរាប ។

ទោះបីជាការស៊ើបអង្កេតរបស់យើងនៅមិនទាន់ចប់សព្វគ្រប់នៅឡើយក៏ដោយ ក៏យើងបានរៀបចំរបាយការណ៍បណ្តោះអាសន្នមួយ ដោយរំពឹងថា នឹងមានរបាយការណ៍ដ៏ពិស្តារជាងនេះមួយ ស្តីអំពីលទ្ធផលនៃការស្រាវជ្រាវជាសន្និដ្ឋាននៃលក្ខណៈពិសេសដែលត្រូវបានរាវរកឃើញតាមរយៈការស៊ើបអង្កេត និងការជីកកកាយ ។

កំណត់សំគាល់

របាយការណ៍ប្រចាំឆ្នាំស្តីអំពីការស្ទាបស្ទង់ផ្នែកបច្ចេកទេសនៃប្រាសាទនៅតំបន់អង្គរឆ្នាំ២០០០ ប្រធាន : ណាកាហ្កាវ៉ា តាក់កេស៊ិ (Nakagawa Takeshi) ខែធ្នូឆ្នាំ២០០០ ក្រុមការពារអង្គររបស់រដ្ឋាភិបាលជប៉ុន/យូណេស្កូ/មូលនិធិបរធនិកជប៉ុនសម្រាប់ការថែរក្សាការពារមរតកវប្បធម៌ពិភពលោក ។

វិធានការណ៍ពិសេសៗសំរាប់តំបន់មួយដែលមានតម្លៃដ៏វិសេសវិសាល

ដោយ អាហ្សេឌីន បែសឆាអ៊ូច Azedine Beschaouch

លោក អាហ្សីឌីន បែសឆាអ៊ូច (Azedine Beschaouch) គឺជាទីប្រឹក្សារបស់អគ្គនាយករងទទួលបន្ទុកផ្នែកវប្បធម៌ក្នុងអង្គការយូណេស្កូ សំរាប់កម្មវិធីថែរក្សាការពារអង្គរជាលក្ខណៈអន្តរជាតិ ។ ក្នុងនាមជាប្រធានគណៈកម្មាធិការ បេតិកភណ្ឌពិភពលោកនោះ លោកមានតួនាទីសំខាន់ក្នុងដំណើរការធ្វើការសំរេចចិត្តដើម្បីចុះឈ្មោះ ប្រាសាទអង្គរវត្តទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងក្នុងការអនុវត្តន៍កម្មវិធីរក្សាការពាររបស់វា ។ លោកក៏ទទួលបន្ទុកនៅក្នុងលេខាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិ (ICC) ផងដែរ ។

តាមហេតុផលដ៏ត្រឹមត្រូវ តាមក្រមសីលធម៌ និងនៅពេលនិយាយអំពីបេតិកភណ្ឌវប្បធម៌ មានសកម្មភាពសំខាន់ៗមួយចំនួនដែលទាមទារអោយយើងបង្ហាញពីភាពអង់អាចក្លាហាន ហើយនៅពេលដែលចាំបាច់ត្រូវបង្ហាញនូវការពេញចិត្តយ៉ាងមុតមាំ ដើម្បីអនុវត្តវិធានការថែរក្សាការពារ ជៀសវាងរង់ចាំមើលដំណើរការថែរក្សាការពារ ។ ការចុះឈ្មោះប្រាសាទអង្គរវត្តចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីខែធ្នូ ឆ្នាំ១៩៩២ គឺក្នុងន័យនេះ ជាឧទាហរណ៏មួយដែលជានិច្ចកាលតែងតែជាប្រធានបទមួយសំរាប់ការឆ្លុះបញ្ចាំង ។ តាមភាពពិត គឺមានប្រាសាទដ៏វិសេសវិសាលជាច្រើន ដែលជាតំបន់លាតសន្ធឹងទៅឆ្ងាយ ដែលក្នុងនោះដើមឈើ និងថ្មដាទាំងឡាយប្រទាក់ប្រទិនគ្នាយ៉ាងស្អិតរមួត និងសមាសភាពស្ថាបត្យកម្មដែលនឹកស្រមៃឃើញទស្សនៈវិស័យដ៏អស្ចារ្យនៅក្នុងមនោគតិ ។ នៅពាក់កណ្តាលសតវត្សទី១៩ អ្នកស្រាវជ្រាវ និងសាសនទូតបានធ្វើការអង្កេតនូវ "ប្រស្នាដ៏អស្ចារ្យ" មួយរបស់រាជធានីខ្មែរដ៏ធំសម្បើមនេះ ហើយចូលរួមក្នុងការអភិវឌ្ឍន៏ក្នុងទ្វីបអឺរ៉ុបចំពោះគំនិតនៃ "អាថិកំបាំងរបស់អង្គរ" ដែលជាអរិយធម៌មួយប្រហាក់ប្រហែលគ្នាទៅនឹងទំហំនៃអរិយធម៌ពិភពលោកសំខាន់ៗផ្សេងទៀតជាច្រើនដូចជា ប្រាសាទពីរ៉ាមីត ប្រាសាទរបស់ប្រទេសឥណ្ឌា និងវត្តរបស់ប្រទេសចិន ដែលទីក្រុងមួយមានលក្ខណៈដូចជាទីក្រុងរ៉ូម (Rome) របស់អាស៊ីអាគ្នេយ៏នេះដែរ ។ ជាការពិតណាស់មុននឹងចូលទៅក្នុងមនោគតិរបស់ជនជាតិអឺរ៉ុប អង្គរ គឺជាទីឆ្ងាយដាច់ស្រយាលសំរាប់អ្នកការទូត និងអ្នកជំនួញនៃអាណាចក្រមជ្ឈិម ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៥ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

វិធានការណ៍ពិសេសៗសំរាប់តំបន់មួយដែលមានតម្លៃវិសេសវិសាល

ដោយ អាហ្សេឌីន បែសឆាអ៊ូច Azedine Beschaouch



២/ តំបន់វប្បធម៌ដែលត្រូវបានការពារ (តំបន់ ១-២-៣-៤-៥) ក្នុងតំបន់សៀមរាប ត្រូវបានបង្កើតឡើង ដោយយោងទៅតាមគម្រោងគ្រប់គ្រងបរិស្ថាន និងការអភិរក្សតំបន់ (ZEMP) ត្រូវបានបង្កើតឡើងដោយ រាជក្រឹត្យចុះថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៩១ ។ ការអភិរក្សតំបន់អង្គរ ទទួលបានអត្ថប្រយោជន៍ពីក្របខ័ណ្ឌការងារតែមួយគត់នៃវិធានការរដ្ឋបាល ច្បាប់ និងបរិស្ថាន ។ ដោយ ឯកឧត្តម វ៉ណ្ណ មូលីវ៉ណ្ណ ។

ប្រវត្តិ និង សង្គម

ការពន្យល់បកស្រាយមួយអំពីរឿងនេះត្រូវបានផ្តល់តាមរយៈដំណើរ ផ្សងព្រេងនៅក្នុងសម័យ ម៉ាកូ ប៉ូឡូ ចាប់ពីខែ សីហា ឆ្នាំ១២៩៦ ដល់ ខែកក្កដា ឆ្នាំ១២៩៧ ដែលធ្វើឡើងដោយលោក ជីវ តាក្វាន់ *(Tcheou Ta-Kouam)* ដែលគាត់បានរៀបរាប់កំណត់ប្រវត្តិរបស់គាត់អំពី ទំនៀមទំលាប់របស់កម្ពុជា ដែលជាសៀវភៅមគ្គុទ្ទេសក៍មួយប្រភេទ សំរាប់ការធ្វើទេសចរណ៍ ទៅកាន់តំបន់ដ៏ល្បីល្បាញបំផុតនៃក្រុងខ្មែរ និងការណែនាំអោយស្គាល់ពីជីវិតនៅក្នុងព្រះបរមរាជវាំង និង ទស្សនិយភាព អំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ។ ក្រោយ មកទៀតនៅដើមសតវត្សទី១៧ យើងទទួលបាននូវភស្តុតាងនៃវត្តមាន របស់អ្នកជំនួញជនជាតិជប៉ុននៅក្នុងប្រទេសកម្ពុជា ហើយពិសេសជាង នេះទៅទៀត យើងមានឯកសាររូបគំនូរប្រាសាទអង្គរជាលើកដំបូង គឺ ជាគំរោងមួយរបស់ប្រាសាទអង្គរវត្តដែលគូរដោយអ្នកធម្មយាត្រាជន ជាតិជប៉ុនម្នាក់ ក្នុងរវាងឆ្នាំ១៦២៣ និងឆ្នាំ១៦៣៦ ជាធម្មនិដ្ឋសាសនា ព្រះពុទ្ធមួយរូបដែលមានជំនឿថា គាត់បានមកដល់ "ម៉ាដា " ដែលជា ទីចាប់កំណើតរបស់ព្រះពុទ្ធសាសនា ហើយគាត់បានទៅទស្សនាវត្ត ជេតាវាណោ ដែលជាទីសក្ការៈនៅក្នុងខ្សែជីវិតរបស់ព្រះពុទ្ធនៅក្នុង ប្រទេសឥណ្ឌា ។

ទោះជាយ៉ាងណាក៏ដោយ គឺដោយសារមានការជួយជ្រោមជ្រែង ភាគច្រើនពីសំណាក់ប្រទេសបារាំង ទើបអង្គរត្រូវគេស្គាល់នៅទូទាំង ពិភពលោក ។ នៅដើមឆ្នាំ១៨៦៣ ទស្សនាវដ្តី *Le Tour du Monde* អ្នកធម្មជាតិវិទ្យា និង "អ្នកស្រាវជ្រាវ" លោក ហេនរី មូហាត់ (*Henri Mouhot*) បានបង្ហាញរូបភាពដែលថតបានថ្មីបំផុត ។ នៅក្នុងការតាំង ពិព័រណ៍សកល នាទីក្រុងប៉ារីសក្នុងឆ្នាំ១៨៧៨ សាធារណជនបានឃើញ ឯកសារសំខាន់ៗជាច្រើនស្តីអំពីសិល្បៈរបស់ខ្មែរជាលើកដំបូងតាមរយៈ រូបចម្លាក់ សូនរូប និងរូបគំនូរ ។ សារមន្ទីរឥណ្ឌូចិនមួយ (បុព្វជនរបស់ Musée Guimet) ត្រូវបានបង្កើតឡើងនៅ *Trocadéro* ។ បន្ទាប់ពីការធ្វើដំណើរនៅខែវិច្ឆិកា ឆ្នាំ១៩០១ អ្នកនិពន្ធម្នាក់ឈ្មោះ លោក ព្យែរ ឡូទី *(Pierre Loti)* បានបញ្ចូលតំបន់នេះទៅក្នុង អក្សរសាស្ត្រនៅក្នុង ស្នាដៃរបស់លោកដែលមានចំណងជើងថា *Un Pèlerin à Angkor* ។ ក្បាច់រាំដ៏ល្អតល្អន់ដឹកនាំដោយក្រុមរបាំ ព្រះរាជទ្រព្យកម្ពុជា ដែលបានទៅសំដែងនៅទីក្រុងប៉ារីស និងទីក្រុង ម៉ាកសី ក្នុង ឆ្នាំ១៩០៦ បានបង្ហាញជូនសាធារណជនយ៉ាងច្រើននូវ និរន្តរភាពដ៏អស្ចារ្យរវាងអាណាចក្រខ្មែរ និងព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងឱកាសចេញទៅសំដែងសិល្បៈនោះ វិចិត្រករចម្លាក់ រូឌីនបាន ជូនរូបគំនូរមួយចំនួនដល់អ្នករបាំ : " នេះជាការមួយដ៏សប្បាយរីករាយ ឥតឧបមា ដែលរូបខ្ញុំបានគូររូបទាំងនេះឡើង " គាត់បានសរសេរ ក្នុងឆ្នាំ១៩២៤ ថា " អ្នករបាំកម្ពុជាដ៏ប្រណីតដែលទើបតែបានមកដល់ ទីក្រុងប៉ារីស មិនយូរប៉ុន្មានជាមួយមហាក្សត្រិយានីរបស់ពួកគេ ។ កាយវិការដ៏ល្អតល្អន់នៃរាងកាយដ៏សមសួន បានបង្កប់នូវការប្រលោម ចិត្តដ៏អស្ចារ្យ និងចម្លែកភ្ញាក់បំផុត " ។

នៅទីបញ្ចប់ជាលទ្ធផលនៃអន្តរាគមន៍ឧបត្ថម្ភគាំទ្រលើកទឹក ចិត្តរបស់ខ្លួន តាមរយៈតុលាការ យុត្តិធម៌ អន្តរជាតិ នៅទីក្រុងឡាអេ ប្រទេសបារាំងបានទទួលជោគជ័យ ក្នុងការជំរុញអោយប្រទេសថៃ ប្រគល់អង្គរមកអោយព្រះរាជាណាចក្រកម្ពុជាវិញនៅឆ្នាំ១៩០៧ ដោយហេតុដូច្នេះហើយ ក៏បានកសាងឡើងវិញនូវដំណែលប្រវត្តិសាស្ត្រ មួយប្រកបដោយកិត្យានុភាព និងវ័យចំណាស់នេះតាមរយៈនិរន្តភាព នៃភូមិសាស្ត្រ ។

វាជាការអាចយល់បានថា នៅក្នុងការពិត និងទិន្នន័យទាំងនេះ ទឹងផ្អែកលើមូលដ្ឋានរបាយការណ៍គួរកត់សំគាល់មួយស្តីអំពីធម្មជាតិ ប្រវត្តិសាស្ត្រវិចិត្រសិល្បៈ និងបុរាណវិទ្យា ដែលរៀបចំដោយសាលា បារាំងចុងបូព៌ា (Ecole française d'Extrême-Orient) តាម ព្រះរាជតំរិះរបស់ព្រះបាទព្រះ នរោត្តម សីហនុ គណៈកម្មាធិការបេតិក ភណ្ឌពិភពលោក ពុំមានការលំបាកក្នុងការទទួលស្គាល់ថា អង្គរ (១) តំណាងអោយស្នាដៃសិល្បៈដ៏វិសេសវិសាលតែមួយគត់ និងស្នាដៃ លេចធ្លោប្រកបដោយគំនិតច្នៃប្រឌិតរបស់មនុស្សជាតិ (២) បង្កប់នូវ អនុភាពដ៏ឧត្តុង្គឧត្តមនៅក្នុងអំឡុងរយៈពេលមួយក្នុងយុគសម័យ វប្បធម៌មួយលើការអភិវឌ្ឍន៍ខាងស្ថាបត្យកម្ម និងសិល្បៈដ៏ធំក្រៃលែង (៣) បន្សល់ទុកជាដំណែលដ៏អស្ចារ្យនៃអរិយធម៌ដែលបានបាត់បង់ ទៅហើយ និង (៤) ជាការប្រមូលផ្តុំដ៏លេចធ្លោនៃប្រភេទអាគារ ឬ ស្ថាបត្យកម្មដែលបង្ហាញអោយឃើញពីយុគសម័យប្រវត្តិសាស្ត្រដ៏ សំខាន់ ។

គេស្ទើរតែនិយាយបានថា តំបន់ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ របស់អង្គរដែលមានប្រាសាទធំស្កឹមស្កៃ និងតំបន់បុរាណវិទ្យាដ៏ធំល្វឹង ល្វើយដែលមានទំហំ ៤០.០០០ ហិកតានោះ អាចបំពេញតាមលក្ខណៈ

វិធានការណ៍ពិសេស៧សំរាប់តំបន់មួយដែលមានតម្លៃដ៏វិសេសវិសាល

ដោយ អាហ្សេឌីន បែសឆាអ៊ូច Azedine Beschaouch

វិនិច្ឆ័យដំបូងទាំង ៤ចំណុច សំរាប់ចុះឈ្មោះចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកឡើយ ។ គេអាចនិយាយបានថា លក្ខខ័ណ្ឌជាមូលដ្ឋានត្រូវបានបំពេញដោយសារ :(ក) យថាភាពនៃប្រាសាទនានា ពុំមាននរណាអាចប្រកួតប្រជែងជាមួយបាន (ខ) ប្រទេសកម្ពុជាបានផ្តល់នូវសច្ចានុម័ត ដល់ "សន្និបាតឆ្នាំ១៩៧២ ស្តីអំពីការការពារបេតិកភណ្ឌវប្បធម៌ " នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩១ ហើយចុងក្រោយនេះ(គ) ក្នុងព្រះនាមជាព្រះប្រធាននៃក្រុមប្រឹក្សាជាន់ខ្ពស់ជាតិនៃកម្ពុជាដែលជាអង្គការសម្របសម្រួលជាតិនៅពេលនោះ ព្រះករុណាព្រះមហាក្សត្របានដាក់សំណើនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩១ សុំបញ្ចូលប្រាសាទអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយព្រះករុណាក៏បានស្នើសុំអោយ យូណេស្កូ ជួយធានាអោយបាននូវកិច្ចសហប្រតិបត្តិការក្នុងការផ្តល់ជំនួយអន្តរជាតិសំរាប់ការថែរក្សាការពារអង្គរ ។

ជាងនេះទៅទៀតនៅក្នុងសម័យប្រជុំទី២៦ នៃសន្និសីទទូទៅ (ខែតុលា-វិច្ឆិកា ឆ្នាំ១៩៩១) តាមរយៈ ខ ទី ២៦គ ដំណោះស្រាយ ៣.១៣ ដែលត្រូវបានអនុម័តជាឯកច្ឆ័ន្ទ យូណេស្កូ បានអញ្ជើញអគ្គនាយកអោយជួយអាជ្ញាធរកម្ពុជាក្នុងការបកស្រាយនីតិបញ្ញត្តិដែលចាំបាច់ និងក្នុងការរៀបចំការតែងតាំងសំរាប់ចុះឈ្មោះចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខខ័ណ្ឌទម្រង់ការមួយចំនួន ដែលតំរូវអោយមានក្នុងនៅក្នុងបរិបទនៃគោលការណ៍ណែនាំដើម្បីគ្រប់គ្រងការអនុវត្តន៍តាមកិច្ចព្រមព្រៀងបេតិកភណ្ឌពិភពលោក ពុំទាន់បំពេញបាននៅឡើយ ។ ICOMOS (ជាអង្គការមួយដែលខ្ញុំមានកិត្តិយស ធ្វើជាសមាជិកចាប់តាំងពីប្រទេសរបស់ខ្ញុំ គឺប្រទេសទុយណេហ្ស៊ី បានចូលរួមក្នុងការបង្កើតធម្មនុញ្ញវ៉ែននីស) បានសំដែងនូវការព្រៀងទុក ដើម្បីអនុម័តយល់ព្រមចំពោះចំណារនេះ ដោយគ្មានល័ក្ខខ័ណ្ឌទម្រង់ការអ្វីទាំងអស់ ។ អ្នកវាយតំលៃរបស់ ICOMOSហាក់ដូចជាចង់ចូលជ្រៅជាងនេះទៅទៀត ហើយអំណាចនៃការជំទាស់របស់ពួកគេ គឺជាឧបសគ្គមួយផងដែរ ។ តាមពិតទៅខ្ញុំគួរតែនិយាយថា តាមការជឿជាក់របស់ខ្ញុំដែលថា អង្គរ គួរតែត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីនោះ ដើម្បីធានាបាននូវការថែរក្សាការពារនិងដើម្បីបញ្ចៀសផុតពីគ្រោះថ្នាក់បន្តទៀត ខ្ញុំបានប្រើប្រាស់អស់លទ្ធភាពនូវឥទ្ធិពលរបស់ខ្ញុំ នៅក្នុងការិយាល័យ និងគណៈកម្មាធិការបេតិកភណ្ឌពិភពលោកក្នុងនាមជាប្រធាន និងជាសមាជិកជាន់ខ្ពស់របស់គណៈកម្មាធិការនេះ (ជាងដប់ពីរឆ្នាំដោយគ្មានការរំខានអ្វីឡើយ និងកិត្តិយសដែលត្រូវបានគេជ្រើសរើសជាប្រធានចំនួនពីរលើក និងជាអ្នកសម្របសម្រួលចំនួនបួនលើកផងដែរ) ។ ដូច្នេះខ្ញុំបានទទួលជោគជ័យ

Jarosavl Poncer

1

១/ ទិដ្ឋភាពខាងក្រៅនៅកាច់ជ្រុងពាយ័ព្យនៃប្រាសាទអង្គរវត្ត (ពាក់កណ្តាលទី១ នៃសតវត្សទី១២) បង្ហាញអោយឃើញទំហំដ៏អស្ចារ្យនៃភាពសាំញ៉ាំនៃស្ថាបត្យកម្មត្រូវបានចុះក្នុង បញ្ជីបេតិភណ្ឌពិភពលោកក្នុងឆ្នាំ ១៩៩២ ។

ប្រវត្តិ និង សង្គម

ក្នុងការសំរេចបាននូវការអនុម័តយល់ព្រម ជាគោលការណ៍នៃការចំណារជាបន្ទាន់មួយ ដែលជាចំណារបង្ការមួយដែលគ្រាន់តែជាចំណារដែលផ្អែកលើ "ការការពារ និងការពន្យល់បកស្រាយ" អំពីបេតិកភណ្ឌដ៏វិសេសវិសាល ។ យ៉ាងណាក៏ដោយក៏ខ្ញុំជឿជាក់ថា ទោះជាសហការីរបស់ខ្ញុំផ្តល់នូវមតិយល់ស្របតាមសំណើរបស់ខ្ញុំក៏ដោយ ក៏សំណើសុំនូវចំណារនេះត្រូវតែភ្ជាប់មកជាមួយនូវវិធានការនានា ដែលញ៉ាំងដោយគោលការណ៍បង្ការជាមុន ។ ដូច្នេះខ្ញុំបានដាក់ជូនទៅការិយាល័យដែលរួមមានតំណាងរបស់ប្រទេសបារាំង ប្រទេសសេណេហ្គាល់ ប្រទេសថៃ ប្រទេសទុយណេហ្ស៊ី និងសហរដ្ឋអាមេរិក ជាមួយនឹងឯកសារដែលត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោក : "ដោយសារតែសភាពការណ៍ពិសេសនៅក្នុងប្រទេសកម្ពុជា ដែលយោងទៅតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានដាក់អោយស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ចាប់តាំងពីខែកក្កដា ឆ្នាំ១៩៩១ មក គណៈកម្មាធិការនេះបានសំរេចបោះបង់ចោលនូវលក្ខខ័ណ្ឌមួយចំនួនដែលតម្រូវអោយមាននៅក្រោមគោលការណ៍ណែនាំនៃប្រតិបត្តិការ និងផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យ (I), (II), (III) និង (IV) បានចុះឈ្មោះ តំបន់អង្គរ ជាមួយនិងប្រាសាទ និងតំបន់បុរាណវិទ្យាដូចដែលបានអធិប្បាយនៅក្នុង "Périmètre de Protection" ដោយភ្ជាប់មកជាមួយនូវ របាយការណ៍របស់ ICO-MOS ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។ គណៈកម្មាធិការបានគូសបញ្ជាក់ថា សកម្មភាពនេះពុំត្រូវបានចាត់ទុកជាគំរូសំរាប់ទម្រង់ការស្នើសុំចំណារឡើយ ប៉ុន្តែគឺគ្រាន់តែជាការឆ្លើយតបទៅនឹងសភាពការណ៍ពិសេសមួយតែប៉ុណ្ណោះ ។ ហេតុដូច្នេះ ដើម្បីធានាបាននូវការការពារតំបន់នេះសំរាប់រយៈពេល ៣ឆ្នាំ (១៩៩៣-១៩៩៥) គណៈកម្មាធិការនេះបានធ្វើការសំរេចចិត្តថា ការសិក្សាស៊ីជំរៅពិសេសមួយ នឹងត្រូវធ្វើឡើងនៅតំបន់អង្គរ ហើយរបាយការណ៍ទាំងឡាយនឹងត្រូវដាក់ជូនការិយាល័យ និងគណៈកម្មាធិការដោយឈរលើស្ថានការណ៍នៃប្រាសាទ និងបរិវេណដែលត្រូវការពារ ។ របាយការណ៍ដំបូងត្រូវដាក់ជូននៅសម័យប្រជុំរបស់ការិយាល័យ នៅខែមិថុនាឆ្នាំ១៩៩៣ និងជាបន្តទៀតគឺរបាយការណ៍ដែលត្រូវដាក់ជូនគណៈកម្មាធិការក្នុងកំឡុងសម័យប្រជុំលើកទី១៧ នៅខែធ្នូ ឆ្នាំ១៩៩៣ " ។

នៅក្នុងស្ថានការណ៍បែបនេះ យើងពុំមានការលំបាកក្នុងការចុះឈ្មោះតំបន់អង្គរចូលក្នុងបញ្ជីនៃបេតិកភណ្ឌពិភពលោក ដែលស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ទាំងឡាយអោយបានឆាប់រហ័ស និងមានប្រសិទ្ធភាពបំផុត ។

ហេតុដូច្នេះហើយ អាជ្ញាធរកម្ពុជាត្រូវបានស្នើសុំអោយចាត់វិធានការណ៍ចាំបាច់នានា ដើម្បីបំពេញនូវលក្ខខ័ណ្ឌដូចតទៅ : (ក) ការប្រកាសអោយអនុវត្តច្បាប់ការពារដែលមានលក្ខណៈគ្រប់គ្រាន់ (ខ) ការបង្កើតភ្នាក់ងារការពាររបស់ជាតិមួយដោយមានបុគ្គលិកគ្រាប់គ្រាន់ (គ) ការបង្កើតព្រំដែនអចិន្ត្រៃយ៍ដោយផ្អែកលើគំរោងចាត់ចែងតំបន់បរិស្ថាន (ZEMP). (ឃ) ការកំណត់តំបន់ទ្រនាប់ចំបងនានា និង (ង) ការបង្កើតការឃ្លាំមើល និងកិច្ចសហប្រតិបត្តិការនៃការខិតខំប្រឹងប្រែងក្នុងការអភិរក្សរបស់អន្តរជាតិ ។

ក្នុងរយៈពេល៣ឆ្នាំ រវាងឆ្នាំ១៩៩៣ និង១៩៩៦ ល័ក្ខខ័ណ្ឌទាំងនេះត្រូវបានបំពេញយ៉ាងជាទីពេញចិត្តបំផុត ទោះបីជាមានផលលំបាកពីសង្គ្រាមក្នុងរយៈពេល៣០ឆ្នាំក៏ដោយ ។ ដូចនេះវាបង្ហាញអោយឃើញយ៉ាងច្បាស់ថាលទ្ធផល គឺហួសពីការស្មានរបស់យើងទៅទៀត ។ លក្ខខ័ណ្ឌពិសេសដែលតំបន់ដ៏អស្ចារ្យមួយត្រូវបានចារិក បានបង្ហាញថាសមហេតុសមផលបំផុត ។ មជ្ឈដ្ឋានដ៏អាក្រក់ត្រូវបានដោះស្រាយអោយបានជ្រះស្រឡះហើយយើងត្រូវសំឡឹងមើលទៅអនាគតកាល ។ ដោយសហគមន៍អន្តរជាតិយល់ពីបញ្ហានេះ ព្រះរាជាណាចក្រកម្ពុជាបានងើបឈរឡើងដើម្បីប្រកួតប្រជែង ហើយអស់រយៈកាលជាងមួយទសវត្សមកហើយដែលការខំប្រឹងខ្នះខ្នែងរបស់យើងត្រូវតែធ្វើបន្តទៅទៀត ។

វិធានការណ៍ពិសេសៗសំរាប់តំបន់មួយដែលមានតម្លៃដ៏វិសេសវិសាល

ដោយ អាហ្សេឌីន បែសឆាអ៊ូច Azedine Beschaouch

កំណត់សំគាល់

---

១) ច្បាប់បេតិកភណ្ឌ (រៀបចំឡើងដោយមានការឧបត្ថម្ភពីអ្នកជំនាញរបស់យូណេស្កូ) ត្រូវបានប្រកាសអោយអនុវត្តនៅ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ។

២) ភ្នាក់ងារការពាររបស់ជាតិដែលមានឈ្មោះថា អាជ្ញាធរអប្សរា (Autorité pour la Protection du Site at l'aménagement de la Région d' Angkor) ត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៥ ហើយត្រូវប្រតិបត្តិជាគ្រឹះស្ថានសាធារណៈមួយដែលមានឋានៈស្រប ច្បាប់ និងមានស្វ័យភាពខាង ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

៣) យោងទៅតាមសំណើររបស់ ZEMP ព្រះរាជក្រឹត្យមួយចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ បានកំណត់ច្បាស់លាស់នូវតំបន់ និងការចាត់ចែងគ្រប់គ្រងរបស់តំបន់សៀមរាបអង្គរ ។

៤) សំរាប់ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដោយសហការជាមួយអាជ្ញាធរកម្ពុជា និងដោយយោងទៅតាមសេចក្តីសំរេចចិត្តរបស់សន្និសីទរវាង រដ្ឋ និងរដ្ឋនៅទីក្រុងតូក្យូ ស្តីអំពីការថែរក្សាការពារ និងអភិវឌ្ឍន៍តំបន់បុរាណវិទ្យារបស់អង្គរ (ថ្ងៃទី១២-១៣ ខែតុលា ឆ្នាំ១៩៩៣) គណៈកម្មាធិការសម្របសម្រួលអន្តរជាតិសំរាប់តំបន់អង្គរ (CIC) ត្រូវបានបង្កើតឡើងក្រោមអធិបតេយ្យភាពរបស់ប្រទេសបារាំង និងជប៉ុន ដែលយូណេស្កូផ្តល់ជូននូវលេខាធិការដ្ឋានផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រជាអចិន្ត្រៃយ៍ ។ ដោយត្រូវបានបង្កើតឡើងនាទីក្រុងភ្នំពេញនៅថ្ងៃទី២១ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៣ គណៈកម្មាធិការនេះបានធ្វើការជួបប្រជុំគ្នាជាទៀងទាត់ចាប់ពីពេលនោះមក គឺចំនួន២ដងក្នុងមួយឆ្នាំ ក្នុងសម័យប្រជុំពេញអង្គ និងសម័យប្រជុំបច្ចេកទេស ។

គ្រប់គ្រងរមណីយដ្ឋានអង្គរដែលជានិមិត្តរូបជាតិ និងតំបន់បេតិកភណ្ឌពិភពលោក

ដោយ ឯកឧត្តម វណ្ណ មូលីវណ្ណ

ឯកឧត្តមវណ្ណ មូលីវណ្ណ ជាទេសរដ្ឋមន្ត្រី និងជាទីប្រឹក្សាផ្ទាល់របស់មហាក្សត្រព្រះបាទនរោត្តមសីហនុ ព្រមទាំងជាទីប្រឹក្សាជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ។ ឯកឧត្តម វណ្ណ មូលីវណ្ណ ដែលជាស្ថាបត្យករដ៏ល្បីល្បាញ បានបំពេញការងារអស់រយៈពេលយ៉ាងយូរនៅតាមភ្នាក់ងារផ្សេងៗនៃអង្គការសហប្រជាជាតិ ជាពិសេសនៅទ្វីបអាហ្វ្រិក អាស៊ីបូព៌ា និងតំបន់មហាសាគរប៉ាស៊ីហ្វិក ។ ឯកឧត្តមវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយពីមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ហើយបានទទួលបន្ទុកការងារនគរូបនីយកម្ម និងការគ្រប់គ្រងដែនដី ។ ឯកឧត្តម ជាស្ថាបនិកសំខាន់មួយរូបក្នុងកម្មវិធីអន្តរជាតិដើម្បីស្រោចស្រង់ និងថែរក្សាតំបន់អង្គរ និងធ្លាប់ជាប្រធានអគ្គនាយកនៃអាជ្ញាធរអប្សរា (អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ) ។

លក្ខខណ្ឌដើម្បីធ្វើចំណាត់ថ្នាក់តំបន់អង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

នៅឆ្នាំ១៩៩២តំបន់អង្គរត្រូវបានបញ្ចូលជាបណ្ដោះអាសន្នទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងបញ្ជីបេតិកភណ្ឌពិភពលោកដែលប្រឈមមុខនឹងគ្រោះថ្នាក់ ។ ចំណាត់ថ្នាក់លើកទី១នេះ តម្រូវអោយរាជរដ្ឋាភិបាលកម្ពុជាបំពេញកាតព្វកិច្ចដូចតទៅក្នុងរយៈពេលបីឆ្នាំដើម្បីការពាររមណីយដ្ឋាន : ១/ អនុម័តច្បាប់ និងបទបញ្ញាផ្សេងៗ ដើម្បីការពារ និងគ្រប់គ្រងកេរមត៌កទាំងនេះ ២/ រៀបចំព្រះរាជក្រឹត្យដើម្បីកំណត់តំបន់ និងរៀបចំផែនការគ្រប់គ្រងតំបន់សៀមរាប-អង្គរ ព្រមទាំង បង្កើតតំបន់ទ្រនាប់ដើម្បីការពាររមណីយដ្ឋាន ។

លក្ខខណ្ឌទាំងនេះត្រូវបានបំពេញកាលពីដើមឆ្នាំ១៩៩៦ ។ ច្បាប់ស្ដីពីការគ្រប់គ្រងដែនដី (ឆ្នាំ១៩៩៤) និងច្បាប់ស្ដីពីការការពារបេតិកភណ្ឌវប្បធម៌ (ឆ្នាំ១៩៩៦) បង្កើតជាក្របខ័ណ្ឌច្បាប់មួយសម្រាប់គ្រប់គ្រងតំបន់ហើយស្ថាប័នពីរទៀតគឺក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ និងអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅកាត់ថា អាជ្ញាធរអប្សរានោះបានទទួលបន្ទុកអនុវត្តសកម្មភាពទាំងនេះចាប់តាំងពីឆ្នាំ១៩៩៥[១] ។

ការកំណត់តំបន់ និងផែនការគ្រប់គ្រងតំបន់សៀមរាប-អង្គរ ត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៩៤ ដោយមានការចូលរួមយ៉ាងសកម្ម

បោះពុម្ពដោយ រោងពុម្ព ស៊ើរអង្គរ ការិយាល័យ ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

ការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ : ជានិមិត្តរូបរបស់ជាតិ និងតំបន់បេតិកភណ្ឌពិភពលោក

ដោយ ឯកឧត្តម វណ្ណ មូលីវណ្ណ

ពីអង្គការយូណេស្កូ (UNESCO) ។ តំបន់ដែលចុះក្នុងចំណាត់ថ្នាក់តម្រូវឱ្យមានការការពារក្នុង ៥កំរិតផ្សេងគ្នា : តំបន់១- រមណីយដ្ឋានមានប្រាសាទ ជាតំបន់ដែលទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។ តំបន់២- ឧទ្យានបុរាណវត្ថុត្រូវការពារ ជាតំបន់ទ្រនាប់សម្រាប់ការពាររមណីយដ្ឋានមានប្រាសាទ ។ តំបន់៣- ទេសភាពវប្បធម៌ត្រូវការពារ ។ តំបន់៤- ចំណុចមានសារៈសំខាន់ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬប្រវត្តិសាស្ត្រ។ តំបន់៥- បរិវេណអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចនៃតំបន់សៀមរាប-អង្គរក្នុងទឹកដីខេត្តសៀមរាប ។

ជាមួយគ្នានោះ ដោយយោងតាមវិធានការខាងលើ ប្រតិបត្តិការចំនួនបីត្រូវបានចាប់អនុវត្តប្រកបដោយលទ្ធផលក្នុងកម្រិតផ្សេងៗគ្នា ។

ជំហានទីមួយគឺការដោះមីននៅតាមឧទ្យានអង្គរ ដើម្បីអោយមហាជនអ្នកស្រាវជ្រាវ ព្រមទាំងភ្ញៀវទេសចរចូលទៅកាន់ទីនោះបាន។ ប្រតិបត្តិការនេះគឺជាជោគជ័យមួយដ៏ត្រចះត្រចង់ ។ ជំហានទីពីរគឺការបង្កើតស្ថងការពិសេសការពារបេតិកភណ្ឌដើម្បីទប់ស្កាត់ការជីកកកាយលួចលាក់ និងការជួញដូរខុសច្បាប់នូវសម្បត្តិវប្បធម៌ខ្មែរ ។ ជាទូទៅនាបច្ចុប្បន្ននេះ ការលួចប្លន់សម្បត្តិវប្បធម៌ទាំងនេះលែងមាននៅតំបន់អង្គរទៀតហើយ ។ លើសពីនេះទៅទៀត នាពេលថ្មីៗនេះ ដោយមានសំណូមពរពីរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលសហរដ្ឋអាមេរិកបានសំរេចដាក់ការបង្អាក់ នូវការនាំចូលវត្ថុបុរាណធ្វើអំពីថ្មដែលមានចំណោសពីសតវត្សទី៦ ដល់សតវត្សទី១៦ ។ វិធានការនេះត្រូវបានដាក់ចូលជាធរមានចាប់ពីខែធ្នូឆ្នាំ១៩៩៩ ។ ជំហានទីបីគឺជាវិធានការណ៍ប្រឆាំងទប់ស្កាត់ការកាប់ឈើខុសច្បាប់ ដែលជាជំនួញអន្តរជាតិដ៏ធំមួយ រួមជាមួយការប្រឹងប្រែងជំរុញអោយមានការដាំដើមឈើឡើងវិញនៅក្នុងឧទ្យានបុរាណ ។ លទ្ធផលនៃជំហានចុងក្រោយពុំបានប្រសើរពេញលេញឡើយ ។

យន្តការស្ថាប័នអន្តរជាតិដើម្បីគ្រប់គ្រងតំបន់អង្គរ

ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩១ ឆ្លៀតឱកាសដែលប្រទេសមានស្ថេរភាពនយោបាយល្អនោះ អគ្គនាយកនៃអង្គការយូណេស្កូគឺលោកហ្វេដឺរិកូ មេយ៉រ (Federico Mayor) បានធ្វើការអំពាវនាវដល់សហគមន៍អន្តរជាតិអោយប្រមូលកម្លាំងគ្នា ដើម្បីជួយការពារថែរក្សា និងលើកតម្លៃតំបន់អង្គរ ។ កាលបរិច្ឆេទនេះ គឺជាចំណុចចាប់ផ្តើមនៃការបង្កើតយន្តការស្ថាប័នអន្តរជាតិសម្រាប់ការគ្រប់គ្រងតំបន់នេះ។ ក្នុងចំណោមប្រទេសជាច្រើនដែលចូលរួមក្នុងយុទ្ធនាការនេះ មានប្រទេសពីរសំខាន់ជាងគេ ដោយសារតួនាទីរបស់ខ្លួននៅក្នុងប្រវត្តិសាស្ត្រ គឺប្រទេសបារាំង និងប្រទេសជប៉ុន ។ គឺដោយមានគំនិតផ្តួចផ្តើមដំបូងរបស់ប្រទេសទាំងពីរព្រមទាំងការគាំទ្រពីសំណាក់អង្គការ យូណេស្កូ (UNESCO) ទើបគណៈកម្មការសហប្រតិបត្តិការអន្តរជាតិដើម្បីការថែរក្សា និងការអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រក្រុងអង្គរ (ICC) ដែលជាយន្តការដើម្បីគ្រប់គ្រង និងត្រួតពិនិត្យយុទ្ធនាការដើម្បីថែរក្សាតំបន់អង្គរ ត្រូវបានបង្កើតឡើងក្នុងខែតុលា ឆ្នាំ១៩៩៣[២] ។ គណៈកម្មការសហប្រតិបត្តិការអន្តរជាតិដើម្បីថែរក្សា និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រក្រុងអង្គរ (ICC) ប្រជុំពេញអង្គជាផ្លូវការមួយឆ្នាំម្តងដោយមានការចូលរួមពីអង្គទូតនៅទីក្រុងភ្នំពេញ ឬនៅក្រុងសៀមរាប ។ ក្នុងចន្លោះពេលនៃការប្រជុំពេញអង្គទាំងនេះ គណៈកម្មការបច្ចេកទេសមួយដែលរួមមានក្រុមប្រឹក្សាការទូតដែលចូលរួមក្នុងការងាររបស់គណៈកម្មការបច្ចេកទេសនេះជួបប្រជុំគ្នាមួយឆ្នាំបីដង ។

ការគ្រប់គ្រងអង្គរកម្រិតជាតិ

ប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជាបានដាក់នូវផែនការបន្ទាន់មួយសម្រាប់គ្រប់គ្រងតំបន់អង្គរ ទៅក្នុងសន្និសីទអន្តររដ្ឋាភិបាលនៅទីក្រុងតូក្យូកាលពីឆ្នាំ១៩៩៣ ។ ដោយគម្រោងនេះមានភាពធំធេង និងត្រូវឱ្យបានពេញលេញ ដោយសម្របសម្រួលកម្មវិធីផ្សេងៗ ដែលនៅពេលនោះមានលក្ខណៈរប៉ាត់រប៉ាយនៅឡើយ បានកំណត់គោលការណ៍អភិវឌ្ឍន៍ចំនួនប្រាំពីរមាន : ១/ បង្កើតក្របខ័ណ្ឌគ្រប់គ្រងរបស់ស្ថាប័នមួយ ២/ កម្មវិធីស្រាវជ្រាវ ៣/ កម្មវិធីដើម្បីជួសជុលស្តារការពារ និង លើកតម្លៃប្រាង្គប្រាសាទនានា ៤/ អភិវឌ្ឍន៍ធនធានមនុស្ស ៥/ អប់រំសហគមន៍នៅតំបន់ ៦/ អភិវឌ្ឍន៍ទេសចរណ៍ ៧/ អភិវឌ្ឍន៍ក្រុង ។ អង្គភាពចំនួនបួនត្រូវបានកំណត់ដើម្បីអនុវត្តគោលការណ៍ទាំងប្រាំពីរនេះ : មានក្រុមសកម្មភាពបួនដែលត្រូវបានគេកំណត់ក្នុងការអនុវត្តន៍ទិសដៅទាំងនេះ ការរៀបចំរចនាសម្ពន្ធអាជ្ញាធរអប្សរាជាថ្មី ១) លើកកំពស់បេតិកភណ្ឌ ២) ៣) ៤) និង ៥) ជំរុញផ្នែកទេសចរណ៍ ៦) និងការអភិវឌ្ឍន៍ក្រុងសៀមរាប ៧) ។

ការរៀបចំបង្កើតស្ថាប័ន

ការអនុវត្ត និងការគ្រប់គ្រងអង្គភាពទាំងនេះ គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរអប្សរា។ ជំហានដំបូងស្ថាប័ននេះយកចិត្តទុកដាក់លើសកម្មភាពស្វែងរកមូលនិធិការកំណត់វិនិយោគទុន និងការរៀបចំការសិក្សាសាកល្បងសម្រាប់គម្រោងអភិវឌ្ឍន៍ដែលមានចែងនៅក្នុងផែនការណ៍បន្ទាន់នោះ ។

ប្រវត្តិ និង សង្គម

បន្ថែមលើជំហានដំបូងដ៏លំបាកនេះ ផែនការណ៍បន្ទាន់នៃអាជ្ញាធរអប្សរាត្រូវបានរាំងស្ទះ ដោយសារវិបត្តិនយោបាយប្រទេសចន្លោះ ខែកក្កដា ឆ្នាំ១៩៩៧ និងខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ ក្នុងកំឡុងពេលនោះ សកម្មភាពសេដ្ឋកិច្ចចុះថយយ៉ាងខ្លាំងនៅទូទាំងប្រទេស ។ ថវិកាជាតិមួយភាគធំត្រូវបានចំណាយទៅលើកងកម្លាំងយោធាសមាហរណកម្មខ្មែរក្រហម និងចំណាយរៀបចំការបោះឆ្នោត ។ វិស័យទេសចរណ៍ និងអចលនវត្ថុត្រូវបានរាំងស្ទះទាំងស្រុង រីឯជំនួយអន្តរជាតិក៏ត្រូវផ្អាកដែរ ។ មានតែមូលនិធិមួយផ្នែកតូចប៉ុណ្ណោះដែលត្រូវបានផ្តល់អោយ ហើយបុគ្គលិកនៃអាជ្ញាធរអប្សរាត្រូវបានកាត់បន្ថយ និងមិនបានទទួលប្រាក់បៀវត្សជាច្រើនខែ ។

ព្រះរាជក្រឹត្យថ្មីមួយដែលត្រូវបានប្រកាសអោយប្រើកាលពីខែមករាឆ្នាំ១៩៩៩ បានកែប្រែស្ថានភាពនេះទាំងស្រុងដោយផ្តល់លទ្ធភាពអោយគេធ្វើការរុះរើកែប្រែទាំងស្រុងទៅលើរដ្ឋបាលមូលដ្ឋានរបស់អាជ្ញាធរអប្សរា ។ អំណើះតទៅប្រធានក្រុមប្រឹក្សាភិបាលដើរតួនាទីជាអ្នកគ្រប់គ្រងផង ជាប្រធានអគ្គនាយកនៃអាជ្ញាធរអប្សរាផង។ សិទ្ធិអំណាចរបស់អាជ្ញាធរអប្សរាលើការអភិវឌ្ឍន៍តំបន់អង្គរត្រូវបានពង្រឹងរួមបញ្ចូលទាំងសិទ្ធិអំណាចរបស់ខ្លួន ទៅលើស្ថាប័នពាក់ព័ន្ធផង។ អំណើះដឹងតទៅរាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចគោរព និងការពារតំបន់អង្គរ និងធានាសុវត្ថិភាព និងនិរន្តរភាពនៃតំបន់នេះ ។ ដូច្នេះរាល់វិធានការណ៍ ឬសេចក្តីអនុញ្ញាតដែលធ្វើឡើងដោយអាជ្ញាធរជាតិ ឬអាជ្ញាធរមូលដ្ឋាននៅកំរិតណាមួយដែលមិនសមស្របទៅតាមកាតព្វកិច្ចអន្តរជាតិ ដែលអាជ្ញាធរអប្សរាកំពុងទទួលខុសត្រូវនោះត្រូវចាត់ទុកជាមោឃៈ ។

សិទ្ធិអំណាចនៃអាជ្ញាធរអប្សរាត្រូវបានពង្រឹងផងដែរក្នុងការអនុវត្តន៍យ៉ាងរឹងប៉ឹងនូវផែនការគ្រប់គ្រងបរិស្ថាន និងការអភិរក្សតំបន់របស់យូណេស្កូនៅតំបន់សៀមរាប-អង្គរ ។ ព្រះរាជក្រឹត្យថ្មីនេះចែងថា : "អាជ្ញាធរអប្សរាទទួលសិទ្ធិផ្តាច់មុខក្នុងការចេញលិខិតអនុញ្ញាតសាងសង់នៅតំបន់អង្គរ ។ រាល់ការចេញសេចក្តីអនុញ្ញាត ឬការចេញលិខិតអនុញ្ញាតទាំងឡាយណាដែលគ្មានការទទួលស្គាល់ពីសមត្ថកិច្ចអភ័យឯកសិទ្ធិរបស់អាជ្ញាធរអប្សរា នឹងត្រូវចាត់ទុកថាគ្មានសុពលភាព ។ សំណង់មានស្រាប់ទាំងឡាយណាដែលគ្មានការអនុញ្ញាត អាចរុះរើចោលក្នុងរយៈពេល៤៥ថ្ងៃ នៃការចេញសេចក្តីដំណើងដោយគ្មានការសងជំងឺចិត្តព្រមទាំងឱ្យសាម៉ីជនរ៉ាប់រងលើថ្លៃនៃការរុះរើនេះ" ។

ដោយសារសិទ្ធិអំណាចទាំងនេះ អាជ្ញាធរអប្សរាបានក្លាយជាគំរូមួយ នៃការគ្រប់គ្រងប្រកបដោយជោគជ័យពីរកំរិតគឺ : រវាងគំរូរការជាតិ និងកាតព្វកិច្ចអន្តរជាតិ ។ ជោគជ័យនៃការគ្រប់គ្រងនេះបានចេញជារូបភាពឡើងក្នុងការរៀបចំហិរញ្ញវត្ថុថ្មី ។

កាលពីមុនរាល់ចំណូលដែលបានមកពីទេសចរណ៍គ្រប់គ្រងឡើងដោយក្រសួងទេសចរណ៍ ។ ក្នុងឆ្នាំដែលនោះដែរ គឺឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានសំរេចថា ប្រាក់ចំណូលមួយផ្នែកដែលបានមកពីការលក់សំបុត្រត្រូវផ្តល់អោយទៅអាជ្ញាធរអប្សរា ។ កិច្ចព្រមព្រៀងស្តីពីការប្រមូលកម្រៃនេះត្រូវបានចុះហត្ថលេខាជាមួយក្រុមហ៊ុនសណ្ឋាគារសុខាដែលត្រូវបង់តំលៃសិទ្ធិដំបូងប្រចាំឆ្នាំនូវទឹកប្រាក់ចំនួន ១.០០០.០០០ ដុល្លាសហរដ្ឋអាមេរិកឱ្យរាជរដ្ឋាភិបាលកម្ពុជាហើយដែលទឹកប្រាក់នេះនឹងកើនឡើងជាស្វ័យប្រវត្តិចំនួន១៥ ភាគរយក្នុងមួយឆ្នាំសំរាប់រយៈពេលប្រាំឆ្នាំ។ រាជរដ្ឋាភិបាលបានសំរេចថាប្រាក់ចំណូលនឹងត្រូវបែងចែកអោយអាជ្ញាធរអប្សរាចំនួន ៨០ភាគរយ ក្រសួងទេសចរណ៍ នឹងទទួលបាន១៥ភាគរយ ហើយក្រសួងវប្បធម៌នឹងទទួលបាន៥ភាគរយ ។

ការកែទម្រង់ដែលបានរៀបរាប់ខាងលើបានផ្តល់ផលល្អក្នុងការពង្រឹងសិទ្ធិអំណាចនៃអាជ្ញាធរអប្សរា។ ក្នុងឆ្នាំ១៩៩៦ អាជ្ញាធរអប្សរាមានបុគ្គលិកតែ១៨នាក់ និងថវិកាចំនួន ១២៣,១៩៨ ដុល្លារសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។ រហូតមកដល់ឆ្នាំ២០០០ បុគ្គលិកបានកើនឡើងដល់ ៨០០នាក់ ហើយមានថវិកាសរុបចំនួន២ ១៨៩,៤៨៣ ដុល្លាសហរដ្ឋអាមេរិក ។ ទៅអនាគតការរីកចំរើននៃអាជ្ញាធរនឹងអាស្រ័យលើកំណើនទេសចរណ៍ ។

កម្មវិធីស្រោចស្រង់ និងអភិវឌ្ឍន៍

តាំងពីមានយុទ្ធនាការដើម្បីស្រោចស្រង់ និងអភិវឌ្ឍន៍តំបន់អង្គរមកក្រុមអ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស និងអ្នកស្រាវជ្រាវដែលមកតំបន់នេះមានចំនួនកើនឡើងជាលំដាប់ ។ កាលពីដំបូងឡើយការងារនៃអ្នកទាំងនោះធ្វើឡើងតែក្នុងក្របខ័ណ្ឌនៃជំនួយអភិវឌ្ឍន៍បរទេស ប៉ុន្តែការចូលរួមនៃអ្នកបច្ចេកទេសខ្មែរក៏កើនឡើងដោយសារធនធានមនុស្សក្នុងស្រុកកើនឡើងដែរ ។

ការងារពាក់ព័ន្ធនឹងប្រាសាទដឹកនាំដោយគណៈកម្មការសហប្រតិបត្តិការអន្តរជាតិ ដើម្បីការពារថែរក្សា និងអភិវឌ្ឍន៍តំបន់អង្គរ (ICC) ដែលបានសម្របសម្រួលកម្មវិធីស្តារផ្ទេរងជាច្រើន ដែលមាន

ការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ : ជានិមិត្តរូបរបស់ជាតិ និងតំបន់បេតិកភណ្ឌពិភពលោក

ដោយ ឯកឧត្តម វណ្ណ មូលិវណ្ណ

បច្ចេកទេស វិធីសាស្ត្រអនុវត្តនិងទ្រឹស្តីការងារផ្សេងៗខ្លួនឱ្យមានការស៊ីសង្វាក់គ្នាជាធ្លុងមួយក្នុងកំរិតខ្ពស់ ។ ដើម្បីធានាអោយបាននូវសហប្រតិបត្តិការបច្ចេកទេស អង្គការយូណេស្កូបានបង្កើតគណៈកម្មការមួយដែលមានអ្នកជំនាញការល្បីៗចំនួនបីរូប ។

កំណាយសំខាន់ៗក្រោម ដីដែលធ្វើឡើងដោយស្ថាប័នអន្តរជាតិនៅអង្គរធំ គឺព្រះលានជល់ដំរី និងប្រាសាទបាពួនគឺបានទទួលមូលនិធិពីប្រទេសបារាំង និងត្រូវបានអនុវត្តន៍ដោយសាលាបារាំងចុងបូព៌ា (EFEO) ។ អង្គរវត្តនៅច្រកផ្លូវចូលខាងលិច និងនៅបណ្ណាល័យខាងជើង ត្រូវបានធ្វើឡើងដោយប្រទេសជប៉ុន ។ ការព្យាបាលថ្ម ព្រមទាំងការថែទាំ និងជួសជុលចម្លាក់ទេពអប្សរាអនុវត្តន៍ដោយក្រុមហ៊ុនអាល្លឺម៉ង់ ។ ប្រទេសជប៉ុនក៏ទទួលបន្ទុកផងដែរក្នុងការដឹកនាំគម្រោងអភិរក្ស ប្រាសាទបាយ័ន ប្រាសាទសួព្រ័ត និងបណ្ណាល័យខាងជើង និងប្រាសាទបន្ទាយក្តី ។ ប្រទេសផ្សេងៗ និងអង្គការនានាក៏ចូលរួមផងដែរក្នុងការងារនេះ ។ ប្រទេសចិន នៅប្រាសាទចៅសាយទេវតា



១/ កម្មវិធីដឹកស្រាវជ្រាវនៅឡបុរាណ នៅភូមិតានៃ ។ ទិដ្ឋភាពភាគខាងលិចនៃតំបន់ជីករណ្តៅ Aŋ ។

The World Monument Foundation នៅប្រាសាទព្រះខ័ន ប្រទេសអ៊ីតាលី នៅប្រាសាទប្រែរូប ប្រទេសអាល្លឺម៉ង់នៅប្រាសាទព្រះគោ និងប្រទេសស្វីសនៅប្រាសាទបន្ទាយស្រី ។

បច្ចុប្បន្ននេះមានកម្មវិធីស្រាវជ្រាវពីរ គឺមួយទាក់ទងនឹងបច្ចេកទេសដុតកុលាលភាជន៍ ។ មួយទៀតទាក់ទងនឹងបច្ចេកទេសសង់ឡបុរាណ ។ ការងារទីមួយធ្វើឡើងនៅភូមិតានិដោយសហការណ៍ជាមួយស្ថាប័នជប៉ុនចំនួនពីរ គឺវិទ្យាស្ថានណារ៉ាស្រាវជ្រាវសម្បត្តិវប្បធម៌ជាតិ (Nara National Cultural Properties Research Institute) និងបេសកម្មអង្គរអន្តរជាតិនៃសកលវិទ្យាល័យសូហ្វីយ៉ា (Sophia University International Angkor Mission) ។ គម្រោងនេះផ្តើមឡើង ពីឆ្នាំ១៩៨៩ ហើយបានផ្តល់លទ្ធភាពអោយអ្នកស្រាវជ្រាវបានទទួលចំណេះដឹងបន្ថែមផ្នែកបច្ចេកទេសដុតកុលាលភាជន៍នៅក្នុងតំបន់អង្គរ ។ ការងារទីពីរ គឺកំពុងតែអនុវត្តនៅតំបន់ឡដុតវត្ថុបុរាណពីរសំខាន់ៗនៅភ្នំគូលែន គឺនៅភូមិថ្នល់ម្រេច និងនៅភូមិសរសៃ ។ តែគួរអោយសោកស្តាយណាស់ដែលតំបន់ទាំងពីនេះមានអំពើលួចប្លន់យ៉ាងខ្លាំងក្លា ។

ទាក់ទិនទៅនឹងបញ្ហាធនធានមនុស្ស អាជ្ញាធរអប្សរាបានបង្កើតវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈពិសេស ហៅថា "វគ្គសិក្សាតានៃ" ។ តានៃទី១ បានចាប់ផ្តើមឡើងក្នុងខែធ្នូ ឆ្នាំ១៩៩៩ ហើយបានបញ្ចប់នៅខែមីនា ឆ្នាំ២០០០ ។ ក្នុងចំណោមអ្នកដែលបញ្ចប់ការសិក្សាចំនួន២០នាក់ ១៦នាក់ ត្រូវបានជ្រើសរើសដោយអាជ្ញាធរអប្សរា ដើម្បីបង្កើតក្រុមបច្ចេកទេសថ្មីៗមួយចំនួនទៀតអោយធ្វើការក្នុងឧទ្យានអង្គរ ។ ក្រុមមួយកំពុងទទួលបន្ទុកលើការអភិរក្សប្រាសាទអង្គរវត្ត និងក្រុមមួយទៀតទទួលបន្ទុកលើការអភិរក្សប្រាសាទអង្គរធំ ។ បន្ថែមលើក្រុមទាំងពីរនេះ មានក្រុមផ្សេងៗទៀតដូចជា : ក្រុមថែទាំប្រាសាទ ក្រុមសិក្សាសង្គមនៅតាមភូមិ និងក្រុមមួយផ្សេងទៀតទទួលបន្ទុកលើការចុះបញ្ជីបេតិកភណ្ឌ ។ វគ្គសិក្សាតានៃទីពីរចាប់ផ្តើមពីខែធ្នូ ឆ្នាំ២០០០ ដល់ខែមេសា ឆ្នាំ២០០១ ។ កម្មសិក្សាការីជាបុរាណវត្ថុវិទូ ស្ថាបត្យករ និងវិស្វករ ព្រមទាំងអ្នកជំនាញខាងវិស័យទេសចរណ៍ និងអ្នកគ្រប់គ្រង ។ បន្ទាប់ពីការប្រលងប្រជែងចូល ក្នុងចំណោមបេក្ខជនជាង៨០នាក់ បេក្ខជនចំនួន២៥នាក់ ត្រូវបានជ្រើសរើសអោយចូលរៀន ។

ដោយយល់ឃើញថាយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌នៅឧទ្យានមានសារសំខាន់ដ៏លើសលុបក្នុងការរៀបចំសេដ្ឋកិច្ចតំបន់

ប្រវត្តិ និង សង្គម

2

២/ បញ្ហាមួយក្នុងចំណោមបញ្ហាចំបងៗក្នុងសកម្មភាពនៃការថែរក្សាការពារ និងការអភិវឌ្ឍន៍តំបន់អង្គរ គឺការបោសសំអាតមីនក្នុងសួនឧទ្យាន ជាលក្ខខ័ណ្ឌចាំបាច់មួយសំរាប់ប្រជាជន និងអ្នកទេសចរក្នុងតំបន់ចូលទៅបាន ។

អាជ្ញាធរអប្សរាផ្តោតយុទ្ធសាស្ត្ររបស់ខ្លួនដោយផ្តល់ការងារក្នុងសហគមន៍ ក៏ដូចជាការប្រាស្រ័យទាក់ទងជាមួយក្រៅសហគមន៍ផងដែរ ។ ការងារនេះធ្វើឡើងក្នុងអាទិភាពពីរ ។

សំរាប់រយៈពេលខ្លីអាជ្ញាធរលើកកំពស់ការងារដែលពលរដ្ឋក្នុងតំបន់ដោយមិនចាំបាច់មាន ការបណ្តុះបណ្តាលរយៈពេលយូរដូចជាការងារសំណង់ និងវិស្វកម្ម ស៊ីវិល ការងារហត្ថកម្មគ្រប់ប្រភេទនៅក្នុងឧទ្យាន និងនៅជុំវិញប្រាង្គប្រាសាទ (លើកលែងតែការងារដែលទាក់ទិនទៅនឹងបុរាណវិទ្យា និងការជួសជុលស្ថារឡើងវិញ) ។ សំរាប់រយៈពេលមធ្យមអាជ្ញាធរកំពុងផ្តល់ការងារដែលមានស្ថេរភាពមួយដែលពាក់ព័ន្ធនឹងការបំពាក់ហេដ្ឋារចនាសម្ព័ន្ធដូចជា អណ្តូងទឹក ប្រព័ន្ធលូទឹក ។ល ។ និងការដាំដើមឈើឡើងវិញនៅតាមឧទ្យានហើយនិងការងារមួយទៀត គឺទាក់ទងទៅនឹងភ្ញៀវទេសចរ និងសកម្មភាពសេវាកម្មផ្សេងៗ (ការថែរក្សាគ្រឿងបរិក្ខារៀបចំទីកន្លែងលក់ដូរនៅតាមបរិវេណប្រាសាទ ។ល ។) ។ អាជ្ញាធរអប្សរាអនុវត្តគោលនយោបាយក្នុងការផ្តល់ការងារដល់ពលរដ្ឋក្នុងតំបន់ដើម្បីថែទាំ និងប្រតិបត្តិសេវាកម្មនៅតាមឧទ្យានថ្មីនានា ។ សកម្មភាពទាំងនេះគឺជាការអនុវត្តយុទ្ធសាស្ត្រតំបន់ដ៏មូលាំទូលាយមួយ ដើម្បីអភិវឌ្ឍន៍សេវាកម្មក្នុងមូលដ្ឋាន ។ ប្រជាជនក្នុងតំបន់ គឺជាអ្នកទទួលអត្ថប្រយោជន៍ទីមួយ ពីផលនៃវិស័យទេសចរណ៍ទាំងតាមរយៈការទទួលឱកាសបណ្តុះបណ្តាលនិងការងារ ទាំងតាមរយៈការទទួលបាននូវផ្លូវអណ្តូងទឹកជនបទ ។ល ។ ព្រមទាំងលទ្ធភាពដើម្បីអោយពួកគេបានលក់ចេញផលិតផលដែលលើសរបស់ពួកគេទៀតផង ។ ដូច្នេះពួកគេនឹងមិនចាកចោលភូមិដ្ឋានរបស់ខ្លួន ហើយរសាត់អណ្តែតមករស់នៅក្នុងទីក្រុងឡើយ ។

ការអភិវឌ្ឍន៍ក្រុងយកមកក្នុងការគ្រប់គ្រងតំបន់កំណត់ដោយកត្តាពីរយ៉ាងគឺកំណើនប្រជាជន និងកំណើននិទស្សន្តនៃការកើនឡើងចំនួនភ្ញៀវទេសចរ ។ ជំរឿនប្រជាជនដែលធ្វើឡើងកាលពីឆ្នាំ១៩៩៨ បង្ហាញអោយឃើញចំនួនមនុស្សដែលរស់នៅ ក្នុងឧទ្យានអង្គរ បន្ទាយស្រី និងរលួស ដូចតទៅ : នៅស្រុកអង្គរជុំមានប្រជាជនចំនួន៤៨ ៤៧៦នាក់ នៅស្រុកអង្គរធំមាន ១៧ ៧៥០នាក់ នៅស្រុកបន្ទាយស្រីមាន ៣២ ២៧១ នាក់ និងនៅស្រុកប្រាសាទបាគងមាន ៥៤១២៩នាក់ ។

ជាង១០ឆ្នាំកន្លងមកនេះ នៅជុំវិញក្រុងសៀមរាប អត្រាកំណើនប្រជាជនកើនឡើងពី៩.១ ភាគរយនៅឆ្នាំ១៩៩២-១៩៩៤ ដល់ ១៣.៧ភាគរយនៅឆ្នាំ១៩៩៤-១៩៩៨ ។ ផ្អែកលើតួលេខទាំងនេះយើងអាចធ្វើការព្យាករណ៍ពីរសំរាប់ឆ្នាំខាងមុខ គឺការព្យាករណ៍កម្រិតទាបថាចំនួនប្រជាជននឹងកើនដល់ ១២០ ០០០នាក់ មុនដំណាច់ឆ្នាំ២០០៥ ឆ្លើយតបនឹងអត្រាកំណើន ៧.៥ ភាគរយ និង១៦០ ០០០នាក់ មុនដំណាច់ឆ្នាំ២០១០ តាមអត្រាកំណើន ៦ភាគរយ ឯការព្យាករណ៍កម្រិតខ្ពស់សន្និដ្ឋានថា មុនដំណាច់ឆ្នាំ២០០៥ ប្រជាជននឹងមានចំនួន១៧៧០០០ តាមអត្រាកំណើន៨.២ភាគរយ និង ២៧១០០០នាក់ មុនដំណាច់ឆ្នាំ២០១០ តាមអត្រាកំណើន ៧ភាគរយ ។ ផែនការមេលើកទីមួយ នៅឆ្នាំ១៩៩៤ សំរាប់តំបន់សៀមរាប-អង្គរ គឺត្រូវផ្តើមកសាងតំបន់សណ្ឋាគារនៅលើផ្ទៃដី៥៦០ហិចតា ។ មុនដំណាច់ឆ្នាំ១៩៩៩ផ្ទៃដីបានកើនឡើងស្ទើរជាពីរគឺ ១០០៧ហិចតា

ការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ : ជានិមិត្តរូបរបស់ជាតិ និងតំបន់បេតិកភណ្ឌពិភពលោក

ដោយ ឯកឧត្តម វណ្ណ មូលីវណ្ណ

នៅខាងកើតផ្លូវឆ្ពោះទៅប្រាង្គប្រាសាទ ។ បច្ចុប្បន្ននេះចំនួនផ្ទះសំណាក់នៅទីរួមខេត្តសៀមរាបកំពុងកើនឡើង ហើយនៅលើផ្លូវឆ្ពោះទៅព្រលានយន្តហោះជាង៨០០បន្ទប់ទៀតនឹងត្រូវសាងសង់ឡើងមុនដំណាច់ឆ្នាំ២០០៥ ។ នៅតាមសង្កាត់នានានៃទីក្រុងនឹងមានផ្ទះសំណាក់ប្រហែលជា ១៨០០បន្ទប់ ដែលត្រៀមបំរុងដាក់អោយប្រើប្រាស់ក្នុងពេលជាមួយគ្នា។ ថ្ងៃក្រោយទៅនឹងគ្មានដីទំនេរនៅលើផ្លូវឆ្ពោះទៅប្រាង្គប្រាសាទទៀតទេ ។ សណ្ឋាគារធំដែលត្រូវការផ្ទៃដីធំសំរាប់កសាង (៦ហិតាឬច្រើនជាង) នឹងត្រូវស្វែងរកកន្លែងផ្សេងទៀតក្នុងតំបន់អភិវឌ្ឍន៍ដែលគ្រោងទុកនៅប៉ែកខាងកើតទីក្រុង ។ នេះជាឱកាសល្អដែលត្រូវផ្តើមយុទ្ធនាការបុរិសណ្ឋាគារដើម្បីសម្របសម្រួលគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលគ្មានសណ្តាប់ធ្នាប់ ។

បច្ចុប្បន្ននេះ យើងមកដល់ដំណាក់កាល១ ដែលតំរូវការការងារក្នុងស្រុកកំពុងកើនឡើងដើម្បីឆ្លើយតបទៅនឹងកំណើនទេសចរណ៍ ។ ការព្យាករណ៍កម្រិតខ្ពស់នៃកំណើនប្រជាជននៅទីក្រុងសៀមរាបគឺផ្អែកទៅលើចំនួនការងារដែលនឹងបង្កើនឡើងដោយបន្ទប់សណ្ឋាគារដែលបានគ្រោងទុក ។ ការព្យាករណ៍ទាំងនេះធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងបទដ្ឋានផ្សេងៗ នៃប្រទេសជាច្រើនដែលមានសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ទេសចរណ៍ប្រហាក់ប្រហែលគ្នានឹងសេដ្ឋកិច្ចនិងទេសចរណ៍នៃប្រទេស កម្ពុជា ។

កំណត់សំគាល់

---

១) ចំពោះព័ត៌មានលំអិតស្តីពីនីតិក្រម សូមអានអត្ថបទរបស់លោក មូលីវណ្ណ វ. អង្គរ អតីត បច្ចុប្បន្ន និង អនាគត។ អប្សរា ខែ មីនា ឆ្នាំ១៩៩៦ (បកប្រែជាភាសាបារាំង ខែ តុលា ឆ្នាំ ១៩៩៧) ភាសាខ្មែរបោះពុម្ពឆ្នាំ១៩៩៨ ។

២) គណៈកម្មការសហប្រតិបត្តិការអន្តរជាតិដើម្បីថែរក្សា និងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រក្រុងអង្គរ (ICC) ត្រូវបានបង្កើតឡើងក្នុងពេលសន្និសីទអន្តររដ្ឋាភិបាលស្តីពីការការពារថែរក្សា និងការអភិវឌ្ឍតំបន់អង្គរកាលពីថ្ងៃទី១២ និងទី១៣ ខែតុលា ឆ្នាំ១៩៩៣ ដោយមានការចូលរួមពីប្រទេសចំនួន ៣១ និងអង្គការក្រៅរដ្ឋាភិបាលចំនួន៧ ។

៣) ក្រុមអ្នកជំនាញបណ្តោះអាសន្នដែលមានសមាជិក : លោក ហ្វ្រង់ស៊ិស្កូ គ្រូស៊ី (មកពីប្រទេសអ៊ីតាលី) លោក ពីយែរ អង់ដ្រេ មកពី (ប្រទេសបារាំង) និង លោក ហ្ស៊ីរ៉ូហ៊ុគី ស៊ុយហ្ស៊ីគី (មកពីប្រទេសជប៉ុន) ។

ទេសចរណ៍វប្បធម៌ និងការអភិវឌ្ឍន៍និរន្តរភាព

ដោយ ហឺវេ បារេ Hervé Barré

លោក Hervé Barré គឺជាសេដ្ឋកិច្ចវិទូមួយរូបដែលបានបំពេញការងារនៅក្នុងផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមានជំនាញខាងផ្នែកវប្បធម៌ និងទេសចរណ៍ ។ គាត់មានឋានៈជាលេខាធិការរបស់ យូណេស្កូ វើល ឌីខេត (UNESCO World Decade) ដើម្បីការអភិវឌ្ឍន៍វប្បធម៌ (១៩៨៨-១៩៩៧) ចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ១៩៩៧ មុនពេលដែលលោកត្រូវបានចាត់តាំងអោយធ្វើជាអ្នកជំនាញការខាងវប្បធម៌ទេសចរណ៍ និងការអភិវឌ្ឍន៍ក្នុងផ្នែកវប្បធម៌របស់យូណេស្កូ ។

ភាពភ្លឺត្រចះត្រចង់សំរាប់វិស័យទេសចរណ៍

បន្ទាប់ពីឆ្លងកាត់សង្គ្រាម និងភាពចលាចលអស់រយៈពេល ៣០ឆ្នាំមកនេះ ប្រទេសកម្ពុជាកំពុងតែចាប់ផ្តើមទាក់ទាញភ្ញៀវទេសចរឡើងវិញ។ នៅក្នុងឆ្នាំ២០០២ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិបានកើនឡើងដល់ចំនួន ៤៦៦.៣៦៥ នាក់ គឺត្រូវនឹងការកើនឡើង ២៧ភាគរយលើសឆ្នាំ១៩៩៩[១] ដែលក្នុងកំឡុងពេលដូចគ្នានោះដែរការចូលមកទស្សនារបស់ភ្ញៀវទេសចរតាមជើងយន្តហោះចំនួនសរុបបានកើនឡើងចំនួន ៣៤ ភាគរយ ។ ដូចគ្នានេះដែរការធ្វើដំណើរតាមជើងយន្តហោះផ្ទាល់ទៅកាន់អាកាសយានដ្ឋានខេត្តសៀមរាបនៅក្បែរប្រាសាទអង្គរវត្តបានកើនឡើង ២៣ ភាគរយ ក្នុងឆ្នាំនោះដែរ ។ ជាមួយនឹងតួលេខទាំងនេះ មន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជារំពឹងថា ចំនួនភ្ញៀវទេសចរនឹងកើនឡើងដល់រាប់លាននាក់នៅក្នុងឆ្នាំ ២០០៣ ខាងមុខនេះ ។

ទោះបីជាយ៉ាងណាក៏ដោយ តួលេខទាំងនេះបង្ហាញអោយឃើញថា ប្រទេសកម្ពុជាបានដើរថយក្រោយក្នុងករិតណានៅក្នុងវិស័យទេសចរណ៍ បើសិនជានិយាយទៅដល់សក្តានុពលរបស់ខ្លួន ជាពិសេសខាងវប្បធម៌នោះ ។ បើធ្វើការប្រៀបធៀបជាមួយនឹងប្រទេសផ្សេងៗនោះ ប្រទេសឡាវបានទទួលភ្ញៀវទេសចរចំនួន ៦១៤.២៧៨ នាក់នៅក្នុងឆ្នាំ១៩៩៩ ប្រទេសវៀតណាមទទួលបាន ១.៧៨១.៧៥៤ នាក់ និងប្រទេសថៃទទួលបាន ៨.៦៥១.២៦០ នាក់ ។ បើគិតតាមតួលេខនេះនៅក្នុងឆ្នាំ១៩៩៩ តំបន់អាស៊ីអាគ្នេយ៍ មានការកើនឡើងខ្លាំងខាងវិស័យទេសចរណ៍ដែលមានអត្រាកើនឡើង ១១ ភាគរយ នៃការមកទស្សនកិច្ចរបស់ភ្ញៀវទេសចរអន្តរជាតិ បើធៀបជាមួយនឹងអត្រានៅទូទាំងពិភពលោកដែលមានចំនួនតែ ៤.៤ ភាគរយប៉ុណ្ណោះ ។

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ប្រវត្តិ និង សង្គម

ដូច្នេះយើងអាចសន្និដ្ឋានបានថា ទស្សនៈវិស័យសំរាប់ការរីកចំរើនខាងវិស័យទេសចរណ៍របស់ប្រទេសកម្ពុជានាពេលអនាគតគឺមានភាពភ្លឺត្រចះត្រចង់ ។

វិស័យទេសចរណ៍នាពេលបច្ចុប្បន្ននេះ ក្លាយជាផ្នែកមួយដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិកម្ពុជា ដែលសព្វថ្ងៃពឹងផ្អែកជាសំខាន់ទៅលើផ្នែករោងចក្រកាត់ដេរ និងកសិកម្ម ។ ប្រទេសកម្ពុជាមានបេតិកភណ្ឌវប្បធម៌ និង ធម្មជាតិដ៏វិសេសវិសាលដែលមានតំបន់វប្បធម៌ជាច្រើន រួមមានជាពិសេស ប្រាសាទអង្គរ (ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកតាំងពីឆ្នាំ១៩៩២មកម្ល៉េះ) ហើយក៏មានតំបន់ធម្មជាតិជាច្រើនទៀតដូចជា បឹងទន្លេសាប ដែលត្រូវបានចុះក្នុងបញ្ជីជាតំបន់អភិរក្សសត្វ ដោយកម្មវិធីមនុស្សធម៌ និងតំបន់ជីវសាស្ត្រ (MAB) របស់អង្គការយូណេស្កូ (UNESCO) ។

កត្តាចាំបាច់ដំបូងសំរាប់ការអភិវឌ្ឍន៍តំបន់

នៅក្រោមការគ្រប់គ្រងរបស់ឯកឧត្តម សុខ អាន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរទេសចរណ៍ជាតិនៃព្រះរាជាណាចក្រកម្ពុជា យុទ្ធសាស្ត្រសំដៅប្រែក្លាយប្រទេសកម្ពុជាអោយទៅជា "ទិសដៅទេសចរណ៍ធម្មជាតិ និងវប្បធម៌ឈានមុខគេ" ដូចដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍នោះបាននឹងកំពុងអភិវឌ្ឍជាបណ្តើរៗអស់រយៈកាលប៉ុន្មានឆ្នាំកន្លងមកហើយស្របគ្នាទៅនឹងកិច្ចការថែរក្សាការពារតំបន់អង្គរ ។

ជាមួយនឹងភាពជឿជាក់ដោយសារការទទួលជោគជ័យនៅក្នុងកម្មវិធីលើកក្រោយទៀត អាជ្ញាធរកម្ពុជាបានសុំអោយ យូណេស្កូ (UNESCO) ជួយសហការនៅក្នុងវិស័យទេសចរណ៍ និងការប្រតិបត្តិគំរោងអភិវឌ្ឍន៍សំរាប់តំបន់អង្គរ ។ ក្រោយពីសន្និសីទអន្តរជាតិស្តីអំពីទេសចរណ៍វប្បធម៌ ដែលបានរៀបចំឡើងដោយអង្គការទេសចរណ៍ពិភពលោក នៅសៀមរាប (ថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២000) យូណេស្កូ បានបើកអង្គសិក្ខាសាលាមួយ ដែលមានពីរវគ្គ នៅក្នុងខេត្តសៀមរាប និងនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី២ និងទី៣ ខែកក្កដា ឆ្នាំ២០០១ ស្តីអំពីការអភិវឌ្ឍន៍តំបន់អង្គរ នៅក្នុងខ្លឹមសារនៃការពិភាក្សាជាលក្ខណៈជាតិ ស្តីអំពីយុទ្ធសាស្ត្រទេសចរណ៍ជាទូទៅមួយសំរាប់ប្រទេសកម្ពុជា ។ យូណេស្កូ បានស្នើអោយក្រុមហ៊ុនពិគ្រោះយោបល់ឯកជនមួយ បើកជាសិក្ខាសាលាមួយឡើងដើម្បីពិនិត្យមើលឡើងវិញនូវការអភិវឌ្ឍន៍តំបន់អង្គរ និងចង្អុលបង្ហាញអំពីទស្សនៈវិស័យសំរាប់ពេលអនាគត ។ សិក្ខាសាលានេះក៏បានធ្វើការបង្ហាញអំពីឧទាហរណ៍នានាស្តីអំពីពិធីអភិវឌ្ឍន៍មធ្យោបាយទេសចរណ៍ ដោយមានការជួយឧបត្ថម្ភពីអន្តរជាតិសំរាប់តំបន់សំខាន់នានា ដែលត្រូវបានចារិកនៅលើបញ្ជីបេតិកភណ្ឌពិភពលោក មានដូចជា Carthage (នៅប្រទេស ទុយណេស៊ី) Pont du Gard (នៅប្រទេសបារាំង) និង Lijiang (នៅប្រទេសចិន) ។

តាមលទ្ធផលរបស់សិក្ខាសាលានេះ គេអាចកំណត់បាននូវគោលការណ៍សំខាន់នានានៃយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍សំរាប់តំបន់អង្គរ ។ រដ្ឋាភិបាលកម្ពុជាគិតថា តំបន់នេះគួរតែធ្វើជាចំណុចគោលសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយផ្តល់នូវការអភិវឌ្ឍន៍មួយប្រកបដោយនិរន្តរភាព ហើយក៏ជួយថែរក្សានិង លើកកំពស់ឥទ្ធិពលវប្បធម៌របស់ប្រទេសមួយ ដែលធ្លាប់បានទទួលនូវអត្ថប្រយោជន៍សំខាន់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈវប្បធម៌ និងអរិយធម៌ដ៏ល្បីល្បាញរបស់ខ្លួន ។ ដូច្នេះ នេះជាការចាំបាច់ណាស់ក្នុងការអភិវឌ្ឍន៍គោលនយោបាយ "បើកចំហមេឃ" និងដើម្បីកំណត់គំរោងអភិវឌ្ឍន៍ទូទៅមួយសំរាប់តំបន់វប្បធម៌នៅក្នុងប្រទេសកម្ពុជា ។

គំរោងនេះត្រូវផ្តោតជាសំខាន់ទៅលើការលើកកំពស់គុណភាពសេវាកម្ម និងមធ្យោបាយសំរបសំរួលតាមរយៈផែនការមេមួយរបស់វិស័យទេសចរណ៍សំរាប់តំបន់អង្គរ ។ គោលបំណង គឺដើម្បីអាចទទួលយកភ្ញៀវទេសចរចំនួនមួយលាននាក់ត្រឹមដំណាច់ឆ្នាំ ២០០៣ ។ គំរោងជាច្រើនត្រូវបានដាក់ស្នើ : ការសាងសង់អាកាសយានដ្ឋានថ្មីមួយ ដែលអាចអោយយន្តហោះធុនធំចុះចតបាន ការសាងសង់បរិវេណសណ្ឋាគារមួយដែលមាន ១០.០០០បន្ទប់ ដោយបង្កើតអោយមានការងារថ្មីសំរាប់ប្រជាជនក្នុងតំបន់ចំនួន ៥០.០០០ ការងារជួសជុលរឺការសាងសង់ផ្លូវចូល ការសាងសង់កន្លែងលំហែកាយ និងកន្លែងលេងកីឡា និងការបង្កើតសកម្មភាពវប្បធម៌ដូចជាពិធីបុណ្យ ដើម្បីលើកទឹកចិត្តដល់ភ្ញៀវទេសចរអោយស្នាក់នៅជាមធ្យមពី ពីរទៅបីថ្ងៃនៅអង្គរវត្ត និងសៀមរាប ។

គោលគំនិតមួយទៀតដែលកំពុងតែមានការរីកចំរើន គឺថាការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅតំបន់អង្គរ គួរតែត្រូវគេមើលឃើញថាជាការអភិវឌ្ឍន៍តំបន់ដ៏ធំមួយដែលលាតសន្ធឹងលើសពី ៤០០ គ.ម^{២} ដើម្បីព័ទ្ធជុំវិញ ភ្នំគូលេន នៅភាគខាងជើង បឹងទន្លេសាបនៅភាគខាង

ទេសចរណ៍វប្បធម៌ និងការអភិវឌ្ឍន៍និរន្តរភាព

ដោយ ហឺវេ បារេ Hervé Barré

ការរៀបចំការផ្លាស់ប្តូរផ្ទៃកសង្គម

ចាប់តាំងពីឆ្នាំ១៩៩៩ មក ការគ្រប់គ្រងសំបុត្រចូលទស្សនាប្រាសាទអង្គរវត្តត្រូវបានផ្ទេរសិទ្ធិពីអាជ្ញាធរអប្សរាទៅអោយក្រុមហ៊ុនឯកជនមួយ ។ ថ្លៃចូលទស្សនាដែលមានតម្លៃ ២០ ដុល្លារអាមេរិក សំរាប់រយៈពេលមួយថ្ងៃ ៤០ដុល្លារអាមេរិក សំរាប់រយៈពេល ពីរ ឬ បីថ្ងៃ និង ៦០ដុល្លារអាមេរិក សំរាប់រយៈពេល បួនទៅប្រាំពីរថ្ងៃ ផ្តល់នូវថវិកាច្រើនគ្រប់គ្រាន់សំរាប់ធ្វើការអភិវឌ្ឍន៍ និង ផ្តល់នូវភាពងាយស្រួលដល់ភ្ញៀវក្នុងខណៈដែលនឹងមានការដាក់អោយប្រើប្រាស់នូវយានជំនិះដើរដោយចរន្តអគ្គិសនី សំរាប់សេវាដឹកជញ្ជូនទៅមកអាចជួយសម្រួលដល់ការដឹកជញ្ជូនទៅទីកន្លែងនេះដោយធ្វើអោយកាន់តែមានភាពស្ងប់ស្ងាត់ជាងមុន និងមានលក្ខណៈ "បៃតង" ដូចធម្មជាតិថែមទៀត ។ គំរោងពិសេសនេះត្រូវបានចោទជាសំណួរឡើងជាបន្ទាន់អំពីថា តើប្រជាជននៅក្នុងតំបន់គួរតែចូលរួមយ៉ាងណាក្នុងការផ្លាស់ប្តូរផ្ទៃកវប្បធម៌ សេដ្ឋកិច្ច និងសង្គមនាពេលអនាគត ដែលបណ្តាលមកពីការហូរចូលមកយ៉ាងច្រើននូវចំនួនភ្ញៀវទេសចរ ។

ការខិតខំប្រឹងប្រែងជាអន្តរជាតិ ដើម្បីអភិរក្សតំបន់នេះត្រូវតែផ្តល់នូវដំណោះស្រាយយូរអង្វែងដល់សេចក្តីត្រូវការក្នុងការអភិវឌ្ឍន៍សហគមន៍ក្នុងតំបន់ដោយរំពឹងថា នឹងមានការផ្លាស់ប្តូរដែលចាំបាច់បំផុត ដោយធ្វើការរៀបចំប្រជាជនសំរាប់អោយពួកគេ និងធានាអោយបានថា ពួកគេមានចំណែកទទួលបានផលប្រយោជន៍យ៉ាងពេញលេញ ។ "ទសវត្សសំរាប់ការអភិវឌ្ឍន៍" អង្គរ ដែលស្នើឡើងដោយយូណេស្កូ ដើម្បីធ្វើអោយ "ទសវត្សអភិរក្ស "អង្គរទទួលបាននូវជោគជ័យ គួរតែធ្វើការអនុម័តនូវវិធីសាស្ត្រតែមួយ ដោយរួមបញ្ចូលនូវការរក្សាការពារបេតិកភណ្ឌ ការត្រួតពិនិត្យលើការហូរចូលនៃភ្ញៀវទេសចរ និងការរៀបចំចាត់ចែងបន្លាស់ផ្ទៃកសង្គម ដែលនឹងមានឥទ្ធិពលលើការរស់នៅរបស់ប្រជាជននៅក្បែរតំបន់ទាំងនោះ ។ ការចូលរួមរបស់ប្រជាជននៅក្នុងតំបន់ ក្នុងការចាត់ចែងទីកន្លែង គឺជាតម្រូវការដ៏ចម្បងសំរាប់ការអភិវឌ្ឍន៍ ដោយសារតែមានការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនប្រជាជននៅក្នុងខេត្តសៀមរាបដែលមានក្រុងមួយចំងាយ៨គីឡូម៉ែត្រ ពីតំបន់នោះ : ពីចំនួនប្រជាជន ៤១.០០០ នាក់ ក្នុងឆ្នាំ១៩៩២ បានឡើងដល់ ៨៣.០០០ នាក់ ក្នុងឆ្នាំ១៩៩៨ ហើយ

ត្បូង និងតំបន់អរិយធម៌ខ្មែរដទៃទៀត ជាពិសេស នៅភាគខាងកើត ។ ដូច្នេះហើយ វាជាការល្អក្នុងការភ្ជាប់ដំណើរទេសចរណ៍ទៅកាន់តំបន់វប្បធម៌ និងតំបន់ធម្មជាតិ របស់ប្រទេសជិតខាងផ្សេងៗ ជាមួយនិងទស្សនៈធ្វើអោយកម្ពុជាក្លាយជាទិសដៅទេសចរណ៍វប្បធម៌មួយ ដោយការខិតខំប្រឹងប្រែងរបស់ខ្លួន ជាជាងការទស្សនាអង្គរតាមបែបការឈោងចូលពីដំណើរកំសាន្តនៅប្រទេសជិតខាង ដទៃទៀត ។

ការយល់ដឹងអំពីលក្ខណៈសម្បត្តិដែលចាំបាច់

ការព្រួយបារម្ភជាចំបងរបស់លោក ប៊ុន ណារិទ្ធិ ប្រធានអាជ្ញាធរអប្សរា ដែលជាអាជ្ញាធរទទួលបន្ទុកក្នុងការចាត់ចែងរៀបចំតំបន់អង្គរ គឺការតាមដានមើលចំពោះការអភិវឌ្ឍន៍វិស័យទេសចរណ៍ដោយអនុលោមទៅតាមគោលដៅដែលបានកំណត់ជាមុនយ៉ាងជាក់លាក់ ។ ដោយហេតុនេះហើយ បានជាអាជ្ញាធរអប្សរាបានបង្កើត "ស្ថានីយ៍ត្រួតពិនិត្យ" មួយ លើវិស័យទេសចរណ៍ ដើម្បីអោយបានដឹងអំពីប្រភេទនៃភ្ញៀវទេសចរ និងសេចក្តីត្រូវការរបស់ពួកគេផងដែរ ។ លទ្ធផលជាដំបូងរបស់ខ្លួនបង្ហាញអោយឃើញថា នៅក្នុងឆ្នាំ២០០០ តំបន់អង្គរបានទទួលភ្ញៀវទេសចរចំនួន ១៧១.៨៣៣ នាក់ (បើប្រៀបធៀបទៅនឹងចំនួន ៤០.៦៧៨ នាក់ ក្នុងឆ្នាំ១៩៩៨) តួលេខនេះ ត្រូវបូកបញ្ចូលទាំងភ្ញៀវទេសចរជាជនជាតិកម្ពុជាប្រមាណជា ១២០.០០០ នាក់ ដែលកោតសសើរអំពីបេតិកភណ្ឌវប្បធម៌របស់ខ្លួន ជាពិសេសក្នុងកំឡុងពេលមានពិធីបុណ្យប្រពៃណីម្តងៗ ។ លទ្ធផលនៃការស្រាវជ្រាវ ក៏បានបង្ហាញអោយឃើញទៀតថា ការនិយាយពីមាត់មួយទៅមាត់មួយ ជាមួយនិងសៀវភៅ និងកូនសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍ គឺជាប្រភពពត៌មានដ៏សំខាន់មួយអំពីតំបន់នេះ និងការលើកទឹកចិត្តអោយភ្ញៀវទេសចរចូលមកទស្សនា ។ ជាការពិតណាស់ដែលថា ភ្ញៀវទេសចរសព្វថ្ងៃនេះ ភាគច្រើនចូលចិត្តដើរទស្សនាតំបន់នេះដោយសេរីជាមួយនិងកូនសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍របស់ខ្លួន គឺជាសញ្ញាបង្ហាញអោយឃើញថា ទេសចរណ៍ជាលក្ខណៈបុគ្គលនៅតែមានចំនួនច្រើនលើសលប់ជាងទេសចរណ៍ជាក្រុម ។ ការស្ទាបស្ទង់មតិទាំងនេះក៏បានបង្ហាញអោយឃើញពីកង្វះខាតខាងការដាក់ផ្លាកសញ្ញាទិសដៅក្រៅ និងក្នុងតំបន់សំភារៈរក្សាអនាម័យ និងពត៌មាននៅនឹងតំបន់ ។

បោះពុម្ពដោយ រោងពុម្ព ស្មើអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

ប្រវត្តិ និង សង្គម

តាមរយៈការព្យាករណ៍សំរាប់ឆ្នាំ២០០៥ ចំនួនប្រជាជនអាចឡើងដល់ ១២០.០០០ ឬ ១៧៧.០០០ នាក់ ដោយយោងតាមកំឡុងពេលមួយផ្សេងទៀត ។

អាជ្ញាធរអប្សរាបានចាត់វិធានការមួយចំនួនរួចមកហើយដើម្បីចាត់ចែងចំពោះរាល់បំលាស់ប្តូរទាំងនេះអោយមានប្រសិទ្ធភាព ។ កាលពីខែតុលា ឆ្នាំ១៩៩៩ អាជ្ញាធរនេះបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដែលមានកាតព្វកិច្ចធ្វើការចរចារជាមួយសហគមន៍ដែលជាប់ពាក់ព័ន្ធ អំពីលក្ខខ័ណ្ឌក្នុងការផ្តល់អោយដីសំរាប់សាងសង់បរិវេណសណ្ឋាគារ និងមធ្យោបាយហេដ្ឋារចនាសម្ព័ន្ធ ។ កិច្ចព្រមព្រៀងក្រៅផ្លូវការ គឺជាវិធីសាស្ត្រដែលបានព្រមព្រៀងគ្នាសំរាប់ដំណើរការនេះដែលអាចនាំទៅដល់ការផ្ទេរកម្មសិទ្ធិទៅអោយអាជ្ញាធរអប្សរា ។ អាជ្ញាធរអប្សរាក៏បានរៀបចំនូវគំរោងមធ្យោបាយដឹកជញ្ជូនសំរាប់រមណីយដ្ឋាននានានៅក្នុងតំបន់ដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើរថយន្តអគ្គីសនី ដូចដែលបានរៀបរាប់រួចមកហើយ ប៉ុន្តែក៏ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនក្នុងស្រុក ដូចជាកង់ រទេះ ដំរី និងស៊ីក្លូ ហើយក៏មិនបំភ្លេចចោលចំពោះការដើរដោយថ្មើជើងផងដែរ ។

ដើម្បីអនុវត្តការសំរេចចិត្តទាំងនេះ ប្រព័ន្ធមួយដែលសំដៅអោយមានការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ការរៀបចំសួនទាំងនេះកំពុងតែត្រូវបានបង្កើតឡើងជាបណ្តើរៗ ។ នាពេលបច្ចុប្បន្ននេះ ប្រជាជនចំនួនប្រមាណជា ៥០ ភាគរយ មានអាយុក្រោម ១៥ ឆ្នាំ ហើយដោយសារតែដីពុំសូវមានជីជាតិល្អនោះ ទិន្នផលកសិកម្មដែលក្រុមគ្រួសារទទួលបាន គឺមានកំរិតតិចតួចបំផុតសំរាប់ការចិញ្ចឹមជីវិត ។ ដូច្នេះការបង្កើតអោយមានការងារថ្មីៗ ដើម្បីរកប្រាក់ចំណូល គឺជាកិច្ចការចាំបាច់សំរាប់ធ្វើអោយមានតុល្យភាពសង្គមនៅឆ្នាំខាងមុខ ។ យុទ្ធសាស្ត្របង្កើតការងារសំរាប់ប្រជាជននៅក្នុងតំបន់គ្របដណ្តប់ទៅលើការងារវិស្វកម្មស៊ីវិលជាបន្ទាន់បំផុត ការងារសាធារណៈ និងការហ្វឹកហ្វឺនខាងសកម្មភាពដែលទាក់ទងទៅនឹងវិស័យទេសចរណ៍ : មានដូចជាការថែទាំសម្ភារៈមធ្យោបាយ ការលក់ដូរវត្ថុអនុស្សាវរីយ៍ និងផលិតផលចម្លាក់ព្រមទាំងការធ្វើមគ្គុទ្ទេសក៏ និងការដឹកជញ្ជូនភ្ញៀវទេសចរ ។ ផ្នែកមួយទៀតនៃយុទ្ធសាស្ត្រទាក់ទងទៅនឹងការងារក្នុងតំបន់លើវិស័យសេវាកម្មក្នុងស្រុកនានា ដូចជាការផ្គត់ផ្គង់ទឹកដែលជាផ្នែកមួយនៃការអភិវឌ្ឍន៍ ក្រុងសៀមរាប រឺការបោសសំអាតបាត

©UNESCO/Anne Lemaistre

១/ ក្រុមអ្នកជំនាញសម្រាប់កិច្ចការពិសេសចុះមើលផ្ទៃដីនៅប្រាសាទប្រែរូប ។

ស្ទឹងដែលហូរកាត់ក្រុង ។ ទោះជាមានល័ក្ខណ៍លំបាកនានាក៏ដោយ ត្រូវលើកំពស់កសិកម្មមូលដ្ឋាន ដើម្បីបំពេញតំរូវការក្នុងស្រុក និងផ្តល់នូវស្បៀងអាហារអោយច្រើនដល់ប្រជាជន ដូចសំរាប់ពួកទេសចរដែរ ។

បន្តធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ

តាមការស្នើសុំរបស់អាជ្ញាធរកម្ពុជា និងអាជ្ញាធរអប្សរា យូណេស្កូ នឹងបន្តបេសកម្មរបស់ខ្លួនក្នុងការផ្តល់ទីប្រឹក្សា និងអ្នកជំនាញការអន្តរជាតិសំដៅធ្វើអោយតំបន់អង្គររួចផុតពីដំណាក់កាលនៃ "តំបន់បេតិកភណ្ឌពិភពលោក ដែលកំពុងប្រឈមមុខនឹងគ្រោះមហន្តរាយ" អោយប្រែក្លាយទៅជា "តំបន់រីកស្គុសស្គាយ និងជាទីដៅបេតិកភណ្ឌឈានមុខគេនៅក្នុងតំបន់អាស៊ី" ។ គំរោងសកម្មភាពរយៈពេលដប់ឆ្នាំ (២០០២-២០១២) ផ្តល់នូវសុពលភាពក្នុងរយៈពេលខ្លីដោយឈរលើមូលដ្ឋាននៃការត្រួតពិនិត្យមើលឡើងវិញយ៉ាងជិតដល់នូវការសិក្សាដែលបានធ្វើរួចមក ហើយនិងការបង្ហាញនូវអាទិភាពជាបន្ទាន់ទាក់ទងទៅនឹងផែនការទេសចរណ៍ និងការអភិវឌ្ឍន៍តំបន់ទីក្រុងនៅក្នុងខេត្តសៀមរាប ។ នេះក៏រួមបញ្ចូលផងដែរនូវចំណុចមួយចំនួនដូចជា ដំណើរទេសចរណ៍ដោយការរៀបចំ និងការដាក់ផ្លាកសញ្ញានៅក្នុងសួន ការរៀបចំការពារប្រាសាទនានា និងការត្រួតពិនិត្យមើលសិទ្ធិក្នុងការប្រើ

ទេសចរណ៍វប្បធម៌ និងការអភិវឌ្ឍន៍និរន្តរភាព

ដោយ ហឺវេ បារេ Hervé Barré

ប្រាស់រូបភាពតំបន់អង្គរនៅក្នុងសារពត៌មាន សំណើដើម្បីដាក់ជូនអាជ្ញាធរអប្សរាសំរាប់ដំណោះស្រាយផ្នែកបច្ចេកទេស ការប៉ាន់ស្មានតំលៃ និងកាលវិភាគការងារ ។ នៅក្នុងរយៈពេលជាមធ្យម ទន្ទឹមពេលគ្នានឹងដំណើរការត្រួតពិនិត្យមើលយ៉ាងជិតដល់នៃការសិក្សាដែលមានកន្លងមក តាមកិច្ចព្រមព្រៀងជាមួយអាជ្ញាធរជាតិ ក្រុមការងារអន្តរជាតិនឹងបង្ហាញពីគំរោងអាទិភាពនានាសំរាប់មធ្យោបាយ សម្របសម្រួលដល់ភ្ញៀវទេសចរនៅនឹងកន្លែង រួមមានសារមន្ទីរអរិយធម៌អង្គរច្រកចេញចូល ទីកន្លែងសំរាកកាយ និងទីកន្លែងសំរាប់ទទួលទាន និងលក់វត្ថុអនុស្សាវរីយ៍ ។ គំរោងនេះក៏រួមបញ្ចូលផងដែរនូវផ្នែកដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍ធនធានមនុស្ស និងការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ ដំណាក់កាលដំបូងរួមមានការរកអោយឃើញនូវសេចក្តីត្រូវការ និងការហ្វឹកហ្វឺនដែលសមស្រប និងជួយក្នុងការជ្រើសរើសបុគ្គលិក ។ ភារកិច្ចទាំងអស់នេះនឹងត្រូវបំពេញដោយមានការសហការណ៍យ៉ាងជិតស្និតជាមួយអាជ្ញាធរអប្សរា និងភ្នាក់ងារនានាដែលផ្តល់កិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ។

នៅក្នុងយុគសម័យភាវូបនីយកម្មនោះ ដើម្បីប្រកួតប្រជែងនៅក្នុងពិភពលោកបើកចំហមួយ ជោគជ័យនៃរមណីយដ្ឋានទេសចរណ៍ត្រូវពឹងផ្អែកម្យ៉ាងទៅលើការរក្សាការពារយថាភាព និងយថាប្រភេទនៃតំបន់ទាំងនេះ ហើយម្យ៉ាងវិញទៀត ក៏ត្រូវពឹងផ្អែកទៅលើការទទួលបាននូវកិរិតស្តង់ដារអន្តរជាតិខាងគុណភាពផ្នែកសេវាកម្ម ការស្នាក់នៅប្រកបដោយសុខមាលភាព បុគ្គលិកមានវិជ្ជាជីវៈត្រឹមត្រូវអនាម័យ និងសន្តិសុខ។ ប្រទេសកម្ពុជានាពេលបច្ចុប្បន្នមានអ្វីៗទាំងអស់ដែលចាំបាច់សំរាប់អភិវឌ្ឍន៍អង្គរ ដូចជាតំបន់របស់ខ្លួន និងដោយសារការពង្រីកប្រទេសទាំងមូល ដើម្បីទទួលនូវកិត្យានុភាពល្បីទូទាំងពិភពលោកតាមរយៈវិស័យទេសចរណ៍ដែលមានគុណភាពខ្ពស់ ។ ដោយគ្មានមន្ទិលសង្ស័យនោះ លក្ខខ័ណ្ឌប្រកបដោយការលើកទឹកចិត្តទាំងនេះ នឹងសម្រួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងវប្បធម៌របស់កម្ពុជានាសម័យបច្ចុប្បន្ននេះ ។

កំណត់សំគាល់

[១] ប្រភព : អង្គការទេសចរណ៍ពិភពលោក សំរាប់តួលេខអន្តរជាតិ និងអាជ្ញាធរអប្សរា សំរាប់តួលេខទាក់ទងទៅនឹងអង្គរវត្ត ។

អំពើលួចប្លន់នៅតំបន់អង្គរ : នៅតែជាសម្ពាធដ៏ធ្ងន់មួយ

ដោយ អេធៀន ក្លេម៉ង់ Etienne Clément

លោក Etienne Clément គឺជាមេធាវីម្នាក់ ដែលមានឯកទេសខាងច្បាប់អន្តរជាតិនិងច្បាប់បេតិកភណ្ឌ ។ លោកបានធ្វើការនៅក្នុងផ្នែកបេតិកភណ្ឌវប្បធម៌របស់យូណេស្កូ អស់រយៈពេល១១ឆ្នាំ ដែលក្នុងរយៈពេលនោះលោកទទួលបន្ទុកការងារអនុវត្តន៍សន្ធិសញ្ញាអន្តរជាតិ ជាពិសេសសន្ធិសញ្ញាឆ្នាំ១៩៧០ ស្តីអំពីការនាំចេញនាំចូលខុសច្បាប់ និងការផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ ។ ចាប់តាំងពីឆ្នាំ១៩៩៨ លោកធ្វើជាតំណាងយូណេស្កូនៅកម្ពុជា និងជាប្រធានការិយាល័យ យូណេស្កូ នៅភ្នំពេញ ។

យើងនឹងចូលក្នុងដំណាក់កាលដាក់ពង្រាយបុគ្គលិកស៊ីវិល និងយោធារបស់អង្គការសហប្រជាជាតិ ដូចដែលបានឃើញស្រាប់ ។ ខែមីនា ឆ្នាំ១៩៩២ : កិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានចុះហត្ថលេខាក្នុងខែតុលា មួយឆ្នាំមុននេះ ហើយអ៊ុនតាក់ (UNTAC) - អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ក៏ត្រូវបានបង្កើតឡើង ។ ការបោះឆ្នោតត្រូវបានគ្រោងធ្វើនៅឆ្នាំ១៩៩៣ ហើយទីបំផុតវាជាការចាប់ផ្តើមសករាជថ្មីនៃសន្តិភាពក្នុងប្រទេសកម្ពុជា ដូចដែលគ្រប់ៗគ្នាសង្ឃឹមទុក ។ ឆ្លើយតបទៅនឹងការអំពាវនាវរបស់ព្រះករុណាព្រះមហាក្សត្រ សហគមន៍អន្តរជាតិបានវិលត្រឡប់មកកាន់អង្គរ ដើម្បីជួយឧបត្ថម្ភគាំទ្រប្រទេសកម្ពុជាក្នុងការថែរក្សាការពារបេតិកភណ្ឌរបស់មនុស្សជាតិនេះ ។

ទិដ្ឋភាពនៃការខូចខាត

ដោយសារហេតុផលនេះហើយទើបបេសកកម្ម យូណេស្កូមួយចំនួនបានត្រូវបញ្ជូនទៅកាន់អង្គរក្នុងឆ្នាំ ១៩៩២ ដើម្បីធ្វើការវាយតម្លៃពីទំហំ នៃការលួចវត្ថុបុរាណ និងផ្តល់នូវយោបល់សំរាប់រកដំណោះស្រាយ ។ ទោះបីជានៅពេលនេះមានភ្ញៀវទេសចរចំនួនតិចតួចបានទៅទស្សនា អង្គរវត្តក៏ដោយក៏មានក្រុមការងារអន្តរជាតិមួយចំនួនបានទៅដល់អង្គររួចទៅហើយ ដើម្បីធ្វើការជួសជុលប្រាង្គប្រាសាទនានា។ ផ្ទុយនឹងពាក្យចចាមអារាម គេបានឃើញច្បាស់ថាប្រាសាទអង្គរវត្តត្រូវបានរងការខូចខាតពីសង្គ្រាមរយៈពេល២០ឆ្នាំ

បោះពុម្ពដោយ រោងពុម្ព ស៊្រីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា ភ្នំពេញ

អំពើលួចប្លន់នៅតំបន់អង្គរ : នៅតែជាសម្ពាធដ៏ធ្ងន់មួយ

ដោយ អេជែន ក្លេម៉ង់ *Etienne Clément*

មុននេះ តិចជាងការដែលគេបានព្រួយបារម្ភទោះបីជាមានស្លាកស្នាម ខ្លះៗនៃការបំផ្លិចបំផ្លាញដែលបន្សល់ទុកជាភស្តុតាង នៃការកាន់កាប់តំបន់នេះរបស់កងយោធាក៏ដោយ ។ ម្យ៉ាងវិញទៀតការលួចប្លន់នាពេលថ្មីៗនេះបានទុកនូវដាន ថ្មីៗ : រូបចម្លាក់អប្សរានិងរូបគ្រុឌត្រូវ

១/ ព្រះភ័ក្ត្រទេវតាទាំងឡាយ គឺជាបំណែកប្រាសាទដែលចោរព្រៃពេញចិត្តជាទីបំផុត ។ បង្ហាញនៅទីនេះ គឺរូបចម្លាក់ទេវតាគ្មានមុខ នៃប្រាសាទព្រះខ័ន (សតវត្សទី១២-១៣) ។ ការទិញវត្ថុបុរាណខ្មែរ ជំរុញអោយមានការលួចប្លន់វត្ថុបុរាណ និងការបំផ្លិចបំផ្លាញមកលើតំបន់ទេសចរណ៍នេះ ។

២/ លទ្ធផលទទួលបានពីការព្យាយាមប្រឹងប្រែងរបស់ជាតិ និងអន្តរជាតិ កងកំលាំងសមត្ថកិច្ចត្រូវបានបង្កើតឡើង ដើម្បីឈ្លបមើល និងបង្ក្រាបការលួចប្លន់វត្ថុបុរាណ ។ វគ្គបណ្តុះបណ្តុះបណ្តាលសមត្ថកិច្ច ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់ត្រូវបានធ្វើឡើងនៅតំបន់អង្គរ ។

បានគាស់ចេញពីកន្លែងក្បាលយក្សត្រូវបានលួចកាត់យកនិងចម្លាក់លឹបត្រូវខូចខាតទ្រង់ទ្រាយជារៀងរហូត ។ ភស្តុតាងទាំងអស់បានបង្ហាញថា ការលួចប្លន់ដ៏ធ្ងន់ធ្ងរនៅតែមានជាបន្ត ។ ពីមួយថ្ងៃទៅមួយថ្ងៃ ឬពីមួយយប់ទៅមួយយប់ ប្រាង្គប្រាសាទនានាត្រូវបានគេដោះយកគ្រឿងលំអដ៏ប្រណីតរបស់ខ្លួនក្នុងកំឡុងពេលដែលខ្វះសន្តិសុខនៅនឹងកន្លែងមានន័យថាពេលកងការពារមិនអាចស្នាក់នៅទីនោះបាន ។ ប្រាសាទខ្លះ គឺជាកន្លែងនៃទុរគតភាពដោយមានបដិមាករខ្លះបែកបាក់ខូចខាតរាយប៉ាយពាសពេញ ដែលជាសក្ខីភាពនៃការប្រញាប់ប្រញាល់របស់ពួកចោរ ។

ព្រមគ្នានឹងលទ្ធភាពដែលគេអាចធ្វើទៅបានជាមួយធនធានដ៏ស្តួចស្តើងបំផុតរបស់គេ បុគ្គលិករបស់ការិយាល័យអភិរក្សអង្គរបានខិតខំប្រឹងប្រែងធ្វើយ៉ាងណាកុំអោយមានការខូចខាតច្រើនដោយ

នៅពេលព្រឹកពួកគេដើរប្រមែប្រមូលរូបបដិមាទាំងឡាយដែលពួកចោរបានទុកចោលដោយសារតែធ្ងន់យកទៅមិនរួច ។ បន្តិចម្តងៗ ចំនួនបដិមាយ៉ាងច្រើនត្រូវបានប្រមូលគរទុកនៅក្នុងឃ្លាំងសម្ភារៈរបស់ការិយាល័យអភិរក្ស ។

ប៉ុន្តែទោះជាមានការការពារសន្តិសុខដោយការិយាល័យអភិរក្សក៏ដោយ ក៏ជញ្ជាំងព្រំដែនការពារត្រូវបានបើកចំហមួយចំហៀងក្នុងចំណោមជញ្ជាំងទាំងបួន ដោយផ្តល់ឱកាសអោយពួកចោរអាចចូលលួចរបស់របរដែលពួកគេកំពុងស្វែងរកនៅក្នុងឃ្លាំងសម្ភារៈនេះបានយ៉ាងងាយស្រួល ។ ក្នុងការការពារដែលពុំមានអាវុធ ឬទទួលការហ្វឹកហ្វឺនសំរាប់ភារកិច្ចរបស់គេឡើយ នៅពេលដែលខ្វះសន្តិសុខបែបនេះ គេពុំហ៊ាននៅក្នុងតំបន់នេះនៅពេលយប់ទេ ដែលទង្វើនេះផ្តល់ឱកាសល្អដល់ពួកចោរ ។

ប្រសិនបើមិនធ្វើសកម្មភាពជាទ្រង់ទ្រាយធំជាបន្ទាន់ទេនោះ កិច្ចខិតខំប្រឹងប្រែងអភិរក្សដែលត្រូវបានគ្រោងឡើងដោយសហគមន៍អន្តរជាតិប្រហែលជានឹងក្លាយជាអសារបង់ឥតអំពើ : អ្វីដែលត្រូវបានការពារនៅពេលថ្ងៃ អាចនឹងត្រូវគេលួចនៅពេលយប់ ។

ប្រវត្តិ និង សង្គម

សកម្មភាពជាបន្ទាន់

ពេលវិលត្រលប់មកភ្នំពេញវិញ គណៈប្រតិភូរបស់យូណេស្កូ ត្រូវបានទទួលចូលជួបព្រះករុណា ព្រះមហាក្សត្រ ដែលជាព្រះប្រធានរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (អង្គការដឹកនាំកម្ពុជា ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស) ។ ស្ថិតក្នុងករណីពិសេសរបស់ព្រះករុណាវិធានការណ៍បន្ទាន់ ដំបូងត្រូវបានចាត់ឡើង : ពង្រឹងសន្តិសុខនៅការិយាល័យអភិរក្សអង្គរ (រួមមានការធ្វើជញ្ជាំងព្រំដែនការពារដែលបាននិយាយខាងលើអោយជិត) ហ្វឹកហ្វឺនដល់បុគ្គលិក បំផុសការយល់ដឹងដល់សាធារណជន និង ប្រកាសឱ្យដឹងជាបន្ទាន់ដល់សហគមន៍អន្តរជាតិតាមរយៈយូណេស្កូ ។ ទីផ្សារអន្តរជាតិមានការពេញចិត្តចំពោះសិល្បៈរបស់អាស៊ីដែលតម្រូវការចំពោះរូបបដិមាខ្មែរកាន់តែកើនឡើង ។ នៅក្នុងសន្និសីទអន្តរជាតិជាច្រើន ដែលបានធ្វើឡើង ក្នុងសហរដ្ឋអាមេរិក អឺរ៉ុប និងថៃ សាធារណជន ដែលជាមិត្តរបស់កម្ពុជាបានរួមគ្នាខិតខំបញ្ឈប់ការជួញដូរខុសច្បាប់នូវវត្ថុបុរាណបេតិកភណ្ឌជាតិ តែទោះជាយ៉ាងណាក៏ដោយនៅរៀងរាល់យប់មានស្រមោលមនុស្សដើរឆ្លងកាត់ប្រាង្គប្រាសាទអង្គរ ។ ដោយត្រូវបានទាក់ទាញដោយរង្វាន់ជូនកាលរហូតស្មើនឹងប្រាក់ខែសំរាប់មួយឆ្នាំ ចោរលួចដែលត្រូវបានគេជួលបានកាត់យករូបបដិមាយ៉ាងស្ទាត់ជំនាញដែលបន្ទាប់មកត្រូវបានគេយកទៅលក់បន្ត ហើយបន្តទៀតជាដំបូងលក់ដោយលួចលាក់ ក្រោយមកលក់ជាចំហ ។ កន្លែងដេញថ្លៃ និង វិចិត្រសាលធំៗមួយចំនួនទទួលទិញវត្ថុបុរាណដែលត្រូវបានគេលួចទាំងនេះ ដោយគ្មានការខ្វាចរអាអ្វីទាំងអស់ហើយគេនៅតែបន្តធ្វើបែបនេះជាច្រើនឆ្នាំទាំងបំពានទៅលើអភិសមាចារខាងវិជ្ជាជីវៈ ។

រហូតដល់ឆ្នាំ១៩៩៣ សូម្បីតែសារមន្ទីរដែលមានកេរ្តិ៍ឈ្មោះបំផុតមួយចំនួនក៏បានទទួលយកទ្រព្យសម្បត្តិ ដែលត្រូវបានគេលួចក្នុងនោះមួយចំនួន គឺជាវត្ថុបុរាណដែលត្រូវបានប្រមូលថែរក្សាទុកដោយការិយាល័យអភិរក្សអង្គរ ។ ធ្វើបែបនេះវាហួសហេតុពេកណាស់ ! ក្រុមប្រឹក្សាសារមន្ទីរអន្តរជាតិ (ICOM) បានក្តាប់បញ្ហាទាំងនេះជាមួយនឹងបូជនីយកិច្ចពិតៗ ដើម្បីអោយសមាជិកទាំងអស់របស់ខ្លួនគោរពច្បាប់វិន័យដែលហាមឃាត់សារមន្ទីរទាំងអស់មិនអោយទទួលយកវត្ថុទាំងឡាយដែលត្រូវបានគេលួចមកពីប្រទេសដទៃទៀត ។

ការិយាល័យអភិរក្សអង្គរ សាលាបារាំងចុងបូព៌ា (Ecole Française d'Extrême-Orient) (EFEO) និង យូណេស្កូ បានចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌយ៉ាងល្អិតល្អន់ និងជាទ្រង់ទ្រាយធំ ដោយធ្វើចំណាត់ថ្នាក់ និង ថតរូបទុកម្តងមួយៗ នូវវត្ថុបុរាណទាំងឡាយដែលកំពុងមាននៅក្នុងឃ្លាំងរបស់ការិយាល័យអភិរក្ស ។ បញ្ជីសារពើភ័ណ្ឌនេះ ត្រូវប្រៀបធៀបជាមួយបណ្ណសារដ្ឋាន ចាប់តាំងពីទសវត្សរ៍១៩៦០ មកដែលអាចផ្តល់លទ្ធភាពបង្កើតបញ្ជីវត្ថុបុរាណដ៏សម្បើមមួយ ដែលបាត់ស្រមោលទៅដោយគ្មានដានអ្វីទាំងអស់ ។ ជាលទ្ធផលនៃប្រតិបត្តិការរយៈពេលយូរនេះ ក្រុមប្រឹក្សាសារមន្ទីរអន្តរ ជាតិ (ICOM) អាចបោះពុម្ពបញ្ជីមួយ ដែលបានកត់ត្រាវត្ថុសំខាន់ៗ ចំនួន១០០ ដែលបានបាត់បង់ទៅរវាងឆ្នាំ១៩៧២ និងឆ្នាំ១៩៩៥ ។ សៀវភៅនេះមានចំណងជើងថា "អំពើលួចប្លន់នៅអង្គរ : វត្ថុចំនួន ១០០ ដែលបានបាត់បង់ " ត្រូវបានចែកចាយទៅអោយសារមន្ទីរ និងវិចិត្រសាលសំខាន់ៗនានានៅជុំវិញពិភពលោក ។

យូណេស្កូ បានអំពាវនាវសុំសេវារបស់ប្រទេសបារាំងដែលជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការផ្នែកប៉ូលីស ដែលមានស្រាប់របស់ខ្លួនជាមួយប្រទេសកម្ពុជា ហើយដែលបានយល់ព្រមទទួលបន្ទុកហ្វឹកហ្វឺនដល់ប៉ូលីសកម្ពុជាចំនួន ៥២០នាក់ ។ បំពាក់ទៅដោយអាវុធ និង ម៉ូតូប៉ូលីសទាំងនេះ ត្រូវបានដាក់ពង្រាយជុំវិញប្រាង្គប្រាសាទ ចំនួន ៨០ នៅលើតំបន់អង្គរដែលនៅទីបំផុតបានផ្តល់នូវសន្តិសុខជាអប្បបរិមា ។ ការិយាល័យអភិរក្សអង្គរ បានចាប់ផ្តើមក្លាយជាជំរុំដែលត្រូវបានគេធ្វើរនាំងការពារហើយមិនយូរប៉ុន្មាន : ក្រុមចោរដោយមើលឃើញថាប្រភពនៃជ័យភ័ណ្ឌរបស់ពួកគេស្ថិតនៅក្នុងគ្រោះរឹងស្ងួតបានបើកប្រតិបត្តិការកងកុម្ម៉ង់ដូទៅលើការិយាល័យអភិរក្សដោយលួចយកវត្ថុបុរាណចំនួន២០ ។ ប៉ុន្តែនោះជាហេតុការណ៍ចុងក្រោយ : ការរួបរួមកំលាំងគ្នារវាងជាតិ និងអន្តរជាតិដើម្បីធានាអោយបាននូវសន្តិសុខដល់ប្រាង្គប្រាសាទនានាបានទទួលជោគជ័យក្នុងការទប់ស្កាត់ចរន្តនេះយ៉ាងហោចណាស់ក៏ធ្វើបាននៅអង្គរដែរ ។

ចំពោះប្រជាជនដែលរស់នៅជុំវិញតំបន់ប្រាង្គប្រាសាទទាំងនេះ គឺជាជំនួយមួយផងដែរ ។ តាមការពិតប្រាង្គប្រាសាទទាំងនេះ គឺជាទីកន្លែងសម្រាប់បូជា ទោះបីជាពុំសូវមានមនុស្សច្រើនកកកុញលុះណាតែមានពិធីបុណ្យផ្សេងៗក៏ដោយ ។ ប្រធានភូមិជាច្រើននាក់បានសំដែងការលំបាក និង ការគ្មានសិទ្ធិអំណាចរបស់ពួកគាត់ទាញយក

អំពើលួចប្លន់នៅតំបន់អង្គរ : នៅតែជាសម្ពាធដ៏ធ្ងន់មួយ

ដោយ អេជែន ក្លេម៉ង់ Etienne Clément

ដើម្បីប្រឈមមុខជាមួយក្រុមចោរ ដែលជួនកាលមានស្បៀកពាក់ជាឯកសណ្ឋានយោធា ។ ដោយសារតែពុំមានប្រព័ន្ធប្រកបដោយប្រសិទ្ធភាពដើម្បីដាក់ទោសពួកចោរ ការការពារដោយប្រដាប់អាវុធរបស់ប៉ូលីស គឺជាដំណោះស្រាយតែមួយគត់ ។ សន្តិសុខរបស់ប្រាង្គប្រាសាទក៏អាចអោយប្រជាជនមានប្រយោជន៍ពីការរីកចំរើនខាងវិស័យ

៣/ ចម្លាក់ ដែលតំណាងអោយសាសនាព្រាហ្មណ៍នេះ ត្រូវបានគេឃើញនៅចក្រភពអង់គ្លេស ក្នុងឆ្នាំ ១៩៩៤ បន្ទាប់ពីត្រូវបានគេបោះពុម្ពផ្សាយក្នុងសារពត៌មាន វត្ថុបុរាណចំនួន១០០ត្រូវបានបាត់ (Cent objets disparus) ។ ការលួចវត្ថុបុរាណនៅអង្គរ (វត្ថុបុរាណចំនួន១០០ត្រូវបានបាត់ ការលួចវត្ថុបុរាណនៅអង្គរ ICOM ១៩៩៣) ។ ក្រោយមកវត្ថុបុរាណនេះត្រូវបានបញ្ជូនមកសារមន្ទីរជាតិភ្នំពេញវិញ នៅឆ្នាំ១៩៩៦ ។

ទេសចរណ៍ផងដែរ ។ ចំនួនអ្នកបោសសំអាតអ្នកលក់ដូរ អ្នកធាក់ស៊ីក្លូបានកើនច្រើនឡើងដោយផ្តល់នូវលទ្ធភាពពិតប្រាកដដល់ប្រជាជននៅក្នុងតំបន់នេះក្នុងការធ្វើអោយកំរិតជីវភាពរស់នៅរបស់គេកាន់តែប្រសើរឡើង ។ តាមរយៈការប្រុងប្រយ័ត្នប្រចាំថ្ងៃរបស់ពួកគេនៅជុំវិញតំបន់ប្រជាជន ដែលរស់នៅក្នុងតំបន់ទាំងនេះក៏អាចជួយការពារតំបន់ទាំងនេះពីអ្នកឈ្លានពានបានផងដែរ ។

ទន្ទឹមគ្នានេះដែរ កន្លែងដេញថ្លៃធំៗ នៅតែបន្តបោះពុម្ពសៀវភៅកាតាឡុកដែលមានស្នាដៃសិល្បៈរបស់ខ្មែរ ចំនួនច្រើនដែលមានខ្លះបានមកពីរបស់ចាស់ៗ ។ តាមអ្នកជំនាញដែលត្រូវបានពិគ្រោះយោបល់លើបញ្ហានេះបានអោយដឹងថា វត្ថុបុរាណមួយចំនួនធំត្រូវបានលួចពីការិយាល័យអភិរក្សអង្គរ និងពីប្រាសាទនានាផងដែរ ។ ទាល់តែនៅពេលដែលស៊ើបអង្កេតការណ៍អ្នកសារពត៌មានផ្អែកដោយបង្ហាញពីទំនាក់ទំនងរវាងការលក់ដូរទាំងនេះជាមួយនឹងការលួចវត្ថុបុរាណពីប្រាង្គប្រាសាទនានា ទើបការដេញថ្លៃត្រូវបានបញ្ឈប់ ប៉ុន្តែជំនួញនៅតែធ្វើជាបន្តតាមរយៈបណ្តាញស្របគ្នា ដែលត្រូវបានគេដឹងក្រោយៗមកទៀតថា បានជោគជ័យក្នុងការដោះយកគ្រឿងលំអពីប្រាសាទទាំងមូលដូច ជាបឹងមាលារហូតដល់ភាគឥសានអង្គរ ។

លទ្ធផលជាក់ស្តែង

ទោះយ៉ាងណាក៏ដោយយុទ្ធនាការរបស់ ICOM បានចាប់ផ្តើមចេញផ្លែផ្កាជាបណ្តើរៗហើយ ។ សារមន្ទីរនានា បានចាប់ផ្តើមរាយការណ៍ថា គេបានទទួលវត្ថុបុរាណដែលសង្ស័យថា ត្រូវបានលួចយកមកលក់ ។ តែបន្ទាប់ពីសំណើជាបន្តបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា និងបន្ទាប់ពីយុទ្ធនាការរបស់ ICOM និងអត្ថបទដែលនិយាយចំៗ ខ្លាំងៗនៅក្នុងសារពត៌មានអាមេរិក ទីបំផុតសារមន្ទីរក្រុងញូវយ៉កបានប្រគល់មកអោយប្រទេសកម្ពុជាវិញនូវវត្ថុបុរាណដែលត្រូវបានលួចពីការិយាល័យអភិរក្សអង្គរហើយថែមទាំងជំរុញអោយមានការប្រគល់ជូនវិញនូវវត្ថុបុរាណផ្សេងៗ ទៀតដែលត្រូវបានអ្នកក្រុងញូវយ៉កប្រមូលទិញទុក ។ វិចិត្រសាលនានានៅសហរដ្ឋអាមេរិក បារាំង និង អង់គ្លេស ទោះចង់មិនចង់ត្រូវតែប្រគល់វត្ថុបុរាណអស់ទាំងនោះមកវិញ ដែលនៅពេលនេះត្រូវបានបង្ហាញថា នៅមានការទើសទាល់ ។ ការរឹបអូសដ៏គំហុកបានកើតឡើងក្នុងប្រទេសថៃឡង់ដ៏នៅព្រំដែនតាមផ្លូវទៅកាន់ទីក្រុងបាងកក និងនៅក្នុងបន្ទប់តាំងនាទីក្រុងបាងកក ។ តាមសំណើរបស់អាជ្ញាធរគយនៃប្រទេសហូឡង់ នាវាភ័ណ្ឌត្រូវរឹបអូសបាននៅកំពង់ផែ រ៉ុតធើដាម (Rotterdam) និងវត្ថុទាំងអស់ត្រូវបញ្ជូនទៅអោយស្ថានទូតកម្ពុជាប្រចាំនៅទីនោះ ។

នៅក្នុងជោគជ័យទាំងនេះ វត្ថុបុរាណសំខាន់ៗ ចំនួន១៩ ដែលបានប្រគល់មកវិញដោយសារមន្ទីរ និងវិចិត្រសាលនានា ពុំបានទប់ស្កាត់នូវអ្វីដែលនឹងត្រូវកត់ត្រាទុកក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាជាការគួរខ្មាស់អៀនបំផុតចំពោះការលួចប្លន់បែបនេះ : វាយបំបែកជាបំនែកៗ នូវជញ្ជាំងទាំងមូលរបស់ប្រាសាទបន្ទាយឆ្មារនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ សរុបមកមានវត្ថុបុរាណចំនួន១២២ បានឆ្លងកាត់

ប្រវត្តិ និង សង្គម

ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ។ ជាភ័ព្វសំណាងល្អបំផុត ដែលវត្ថុបុរាណមួយចំនួនត្រូវអាជ្ញាធរថៃរឹបអូសបានប្រគល់មកអោយប្រទេសកម្ពុជាវិញបន្ទាប់ពីមានការចរចាគ្នាមក ។ ចាប់តាំងពីតំបន់អង្គរត្រូវបានការពារសន្តិសុខយ៉ាងល្អមក ពួកចោរបានបង្វែរទិសដៅទៅកាន់ប្រាសាទដទៃ ដែលនៅតំបន់ដាច់ស្រយាល ។ រហូតមកដល់ពេលនេះ កន្លែងទាំងនោះ បានទទួលការអភិរក្សតិចតួចបំផុតដោយសារតែតំបន់ទាំងនោះមានគ្រាប់មីនហើយក្រុមការងាររបស់ក្រសួងវប្បធម៌ពុំអាចចូលទៅដល់ ។ នៅពេលដែលចូលទៅកាន់តំបន់ទាំងនោះត្រូវបានដោះមីនរួចរាល់អស់មកគេ ក៏បានដឹងច្បាស់ពីទំហំនៃការខូតខាត ។ តាមផ្លូវទៅកាន់ភ្នំគូលេន ជាឧទាហរណ៍តំបន់ក្បាលស្ពានដែលមានក្រុមចម្លាក់ដ៏ល្អប្រណីតនៅក្នុងបាតស្ទឹងត្រូវទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ដោយជាក់ស្តែងជាលទ្ធផលនៃការអារយ៉ាងស្អាត និងគ្មានមេត្តាដែលមិនមែនគ្រាន់តែជាសកម្មភាពលួចប៉ុណ្ណោះ ។

សំឡឹងឆ្ពោះទៅមុខ

ជាលទ្ធផល អាជ្ញាធរកម្ពុជាឥឡូវនេះកំពុងតែបង្វែរការយកចិត្តទុកដាក់របស់ខ្លួនទៅលើប្រាសាទតូចៗ នៅឆ្ងាយដាច់ស្រយាលដែលពុំទាន់ទទួលបាននូវការត្រួតពិនិត្យមើលយ៉ាងជិតដល់នៅឡើយ ។ គ្រឹះស្ថានអន្តរជាតិមួយចំនួនកំពុងតែផ្តល់នូវការឧបត្ថម្ភគាំទ្ររបស់គេ ដែលរួមមាន យូណេស្កូ និងមូលនិធិប្រាសាទពិភពលោក (N.MF) នៅបន្ទាយឆ្មារ កោះកែ (ជាអតីតរាជធានី) និងសំបូរព្រៃគុក ។

វិធានការប្រឆាំងតាមផ្លូវច្បាប់នានាកំពុងតែមានភាពប្រសើរឡើង ។ ប្រទេសកម្ពុជាដែលជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាយូណេស្កូ ឆ្នាំ១៩៧០ស្តីអំពីចរាចរណ៍ខុសច្បាប់នូវសម្បត្តិវប្បធម៌នាពេលថ្មីៗ នេះ បានប្រកាសនូវសច្ចានុមតិសន្ធិសញ្ញា UNIDROIT ឆ្នាំ១៩៩៥ ស្តីអំពីសម្បត្តិវប្បធម៌ដែលត្រូវបានគេលួច ឬនាំចេញដោយខុសច្បាប់ ។ ដោយសារតែប្រទេសថៃ ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសកម្ពុជានៅក្បែរនឹងប្រាសាទទាំងនេះ មិនមែនជាភាគីមួយនៃសន្ធិសញ្ញាណាមួយ ក្នុងចំណោមសន្ធិសញ្ញាទាំងនេះនោះ ទើបបានជាកិច្ចព្រមព្រៀងទ្វេភាគី ត្រូវបានធ្វើឡើងរវាងប្រទេសទាំងពីរក្នុងឆ្នាំ១៩៩៩ ស្តីអំពីការប្រគល់ជាបដិការសម្បត្តិវប្បធម៌ដែលបានលួចយកទៅ ។ នាពេលបច្ចុប្បន្ននេះការចរចានានាកំពុងតែដំណើរការដោយឈរលើសន្ធិសញ្ញានេះ ។ ដោយមានជំនួយពីយូណេស្កូ ក្នុងឆ្នាំ២០០១ ប្រទេសកម្ពុជាបានបង្កើតច្បាប់ជាតិដ៏តឹងរឹងមួយនៅឆ្នាំ១៩៩៦ នឹងចាប់ផ្តើមរៀបចំវិធានការណ៍ចុះអនុវត្តច្បាប់ដែលនឹងឱ្យកម្ពុជាមានដល់ខ្លួននូវសិទ្ធិស្របច្បាប់ពេញលេញដែលត្រូវការសំរាប់អនុវត្តសន្ធិសញ្ញាអន្តរជាតិ ។ វិធានការអនុវត្ត ច្បាប់ទាំងនេះទាក់ទងជាពិសេសទៅនឹងរណ្តៅបុរាណវិទ្យាដែលគួរតែត្រូវបានអនុញ្ញាតដោយយោងទៅតាមបទបញ្ជាសមស្រប ។ វិធានការណ៍មួយទៀតនឹងដាក់កម្រិតល័ក្ខខ័ណ្ឌដល់ការជួញដូរវត្ថុសិល្បៈនៅក្នុងប្រទេសកម្ពុជា គឺជាលើកទីមួយនៅក្នុងអនុតំបន់ ។ ទីបញ្ចប់ការនាំចេញនូវសម្បត្តិវប្បធម៌របស់កម្ពុជានឹងតម្រូវអោយមានលិខិតស្នាមពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមកាលៈទេសៈពិសេសដូចជាពិព័រណ៍ សិល្បៈ និង កម្មវិធីប្តូរគ្នាទៅវិញទៅមក ។ សម្បត្តិវប្បធម៌ទាំងឡាយណាដែលនាំចេញពីប្រទេសកម្ពុជាដោយគ្មានលិខិតស្នាមនេះនឹងត្រូវចាត់ទុកថាជាការនាំចេញខុសច្បាប់ ។ សិក្ខាសាលាមួយដើម្បីប្រមូលផ្តុំក្រសួង និង ស្ថាប័នជាតិទាំងអស់ដែលជាប់ពាក់ព័ន្ធត្រូវបានគ្រោងធ្វើនៅឆ្នាំ២០០២ ខណៈពេលដែលការរៀបចំផ្នែកច្បាប់ត្រូវបានរៀបរយ ។

ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគៀបសង្កត់ និងបំបាត់អំពើទុច្ចរិតនេះ នៅពេលដែលបន្តទទួលបានការឧបត្ថម្ភគាំទ្រ និងសមានចិត្តពីសហគមន៍អន្តរជាតិនៅក្នុងវិស័យនេះ នៅខែមីនា ឆ្នាំ២០០១ ប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំរបស់គណៈកម្មាធិការទំនាក់ទំនងរដ្ឋាភិបាលរបស់យូណេស្កូ ដើម្បីជំរុញអោយមានការប្រគល់សម្បត្តិវប្បធម៌ទៅអោយប្រទេសដើមវិញ ឬសំណងក្នុងករណីយកធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ។ ថ្វីបើប្រទេសកម្ពុជាមិនមែនជាសមាជិករបស់គណៈកម្មាធិការនេះក៏ដោយ ការពិតដែលថាព្រឹត្តិការណ៍បែបនេះត្រូវបានធ្វើឡើង ដោយផ្តល់ឱកាសអោយមានការពិភាក្សាតទល់គ្នាតាមកញ្ចក់ទូរទស្សន៍ជាតិដ៏សំខាន់មួយស្តីអំពីការជួញដូរសម្បត្តិវប្បធម៌ ។

១/ ដើមគដែលដុះនៅជ្រុងម្ខាងនៃប្រាសាទតាព្រហ្ម ចុងសតវត្សទី១២ ដើមសតវត្សទី១៣៖ គឺជានិមិត្តសញ្ញានៃការងារដែលត្រូវធ្វើចំពោះមុខ និងការជ្រើសរើសដ៏លំបាក ដែលនឹងត្រូវធ្វើនៅតំបន់មួយ ដែលជាទីកន្លែង ដែលទំនាក់ទំនងកក្តាចំរុះរវាងធម្មជាតិ និងវប្បធម៌ ជាអ្វីដែលធ្វើអោយមានសោភ័ណភាពស្រស់បំព្រងក្រៃលែង...........។

ឯកសារយោងសំរាប់អានបន្ថែម
អង្គរ លេខ ២១៣/២១៤

ប្រវត្តិសាស្ត្រអង្គរ និងបុរាណវត្ថុវិទ្យា

- G. Groslier, សិល្បៈ និងបូរាណវិទ្យាខ្មែរ (ពីរភាគ) ក្រុងប៉ារីស ការបោះពុម្ពផ្សាយពីភូមិសាស្ត្រដែនសមុទ្រ និងអាណានិគម ឆ្នាំ១៩២១-១៩២៣
- D. Chandler ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ចេញផ្សាយលើកទី២ West-view Press ឆ្នាំ ១៩៩២
- C. Jacques and M. Freeman ទីក្រុងខ្មែរ ហ្សឺណែវ. បោះពុម្ព Olizone, ២០០០
- James C. Harles, សិល្បៈ និងស្ថាបត្យកម្មនៃឧបទ្វីបឥណ្ឌា Harmondsworth, The Pelican History of Art, ឆ្នាំ ១៩៨៦
- E. Moore,"ការគ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសកម្ពុជាកាលពីសម័យបុរាណ : ភស្តុតាងពីរូបថតពីលំហអាកាស" ទិន្នានុប្បវត្តិភូមិសាស្ត្រ ភាគទី ១៥៥ លេខ ២ ក្រុងឡុង ឆ្នាំ ១៩៨៩
- អង្គរ : សៀវភៅសរសេរដៃសំរាប់អតីតកាល បច្ចុប្បន្ន និងអនាគតអប្សរា ខែមីនា ឆ្នាំ ១៩៩៦ ការបោះពុម្ពផ្សាយជាភាសាបារាំង (ខែឧសភា ឆ្នាំ១៩៩៧)
- V. Roveda ទេវកថាវិទ្យាខ្មែរ : អាថិកំបាំងនៃអង្គរ ក្រុងបាងកក Riverbooks, Nirisa,
- Chakrabonse ឆ្នាំ ១៩៩៧

Michael Vickery, , សង្គមសេដ្ឋកិច្ច និងនយោបាយនៅក្នុងប្រទេសកម្ពុជាមុនសម័យអង្គរ សតវត្សទី៧ និងទី៨ ក្រុង Tokyo មជ្ឈមណ្ឌលសំរាប់ការសិក្សាពីអាស៊ីខាងកើតសំរាប់អង្គការយូណេស្កូ ឆ្នាំ ១៩៩៨

- B. Brugier ជីវប្រវត្តិរបស់ប្រទេសកម្ពុជាសម័យបុរាណ (ពីរភាគ) សាលាបារាំងចុងបូព៌ា ឆ្នាំ១៩៩៨

ឯកសារចងក្រងផ្សេងទៀត

- H. Marchal សារមន្ទីរ លូីស៍ ហ្វីណូត (Louis Finot), La collection khmere ក្រុងហាណូយ EFEO ឆ្នាំ១៩៣៩
- S. O' Connor, ព្រះនៃសាសនាព្រាហ្មណ៍នៃឧបទ្វីបប្រទេសថៃ Ascona, Artibus Asiae publishers, ឆ្នាំ១៩៧២
- H. Jessup and T. Zephir, (eds) អង្គរ និងសតវត្សទី១០ (កាតាឡុកនៃការតាំងពិព័រណ៍) ការប្រមូលផ្តុំឯកសារនៃសារមន្ទីរជាតិ ក្រុងប៉ារីស ឆ្នាំ១៩៩៧
- N. Dalsheimer, ការប្រមូលផ្តុំឯកសារនៃសារមន្ទីរជាតិក្រុងភ្នំពេញ coll ។ សិល្បៈរបស់ប្រទេសកម្ពុជានៅសម័យបុរាណ សាលាបារាំងចុងបូព៌ា ក្រុងប៉ារីស Magellan et Cie ឆ្នាំ២០០១

បោះពុម្ពដោយ រោងពុម្ព រស្មីអង្គរ. ការិយាល័យ. ៤០ ផ្លូវ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧មករា ភ្នំពេញ

ឯកសារយោងសំរាប់អានបន្ថែម
អង្គរ លេខ ២១៣/២១៤

ឯកសារយោងផ្នែកអភិរក្ស

G. Croci. លក្ខណៈរចនាសម្ព័ន្ធរបស់ប្រាសាទខ្មែរ ក្រុងប៉ារីស អង្គការយូណេស្កូ ឆ្នាំ១៩៩៧

- C. Cres. P. Garner. G & J. Nafilyan. សិល្បៈខ្មែរដែលស្ថិតនៅក្នុងថែរក្សា Editions EMP. ឆ្នាំ១៩៩៧ (បោះពុម្ពជាភាសាអង់គ្លេស និងបារាំង) វត្ថុ១០០បានបាត់បង់ ការលួចប្លន់នៅអង្គរ ក្រុងប៉ារីស ការបោះពុម្ពផ្សាយរបស់ក្រុមប្រឹក្សាសារមន្ទីរអន្តរជាតិ (ICOM) EFEO. យូណេស្កូ ឆ្នាំ១៩៩៣

- P. Askerud and E. Clement (eds). មគ្គុទ្ទេសក៍សំរាប់ការអនុវត្តអនុសញ្ញារបស់អង្គការយូណេស្កូ ឆ្នាំ១៩៩៧ ស្តីពីការប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធទំនិញវប្បធម៌ខុសច្បាប់ក្រុងប៉ារីស អង្គការយូណេស្កូ ឯកសារភាសាអង់គ្លេស ឆ្នាំ១៩៩៧ ឯកសារភាសាបារាំង ឆ្នាំ២០០០ (ព្រមទាំងមានឯកសារជាភាសាអេស្ប៉ាញ និងភាសាចិន)

- P.J. O' Keefe. ជំនួញវត្ថុបូរាណ ការប្រយុទ្ធនឹងការបំផ្លិចបំផ្លាញ និងការបំបាត់ចោលនូវការចងចាំរបស់ប្រជាជនក្រុងប៉ារីសអង្គការយូណេស្កូ ឆ្នាំ១៩៩៩ ឯកសារភាសាអង់គ្លេស (ឆ្នាំ១៩៩៧) ក្រុមអ្នកវិទ្យាសាស្ត្រដែលធ្វើកិច្ចសហប្រតិបត្តិការនៅក្នុងកម្មវិធីថែរក្សាការពារជាអន្តរជាតិចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំនៃការងារស្រាវជ្រាវ និងអភិរក្ស ។ របាយការណ៍ទាំងនេះក៏មានផងដែរ នៅឯមជ្ឈមណ្ឌលឯកសារអន្តរជាតិនៅខេត្តសៀមរាប ពត៌មានបន្ថែមទៀតអាចទទួលបានពីប្រភព

Internet

- http://autoriteapsara.org/

ឯកសារស្របច្បាប់របស់ជាតិទាក់ទងនឹងសកម្មភាពថែរក្សាការពារ និងអភិវឌ្ឍន៍ប្រាសាទអង្គរគឺមានផ្សាយនៅតាម
http://www. bigpond.com.kh/Coucil_of Jurist/Culture/somculf.htm

សារមន្ទីរអន្តរជាតិ

ការទំនាក់ទំនង

សំណួរពាក់ព័ន្ធនឹងបញ្ហាវិចារណកថា :
និពន្ធនាយក : សារមន្ទីរអន្តរជាតិអង្គការយូណេស្កូ
UNESCO. 7 place de Fontenoy
75352 Paris 07 SP (France)
ទូរស័ព្ទ : (៣៣-១) ៤៥ ៦៨ ៤៣ ៣៩
ទូរសារ : (៣៣-១) ៤៥ ៦៨ ៥៥ ៩១
សារមន្ទីរអន្តរជាតិ (ការបោះពុម្ពផ្សាយជាភាសាអង់គ្លេស) ចេញផ្សាយបួនដង (៤ ដង) ក្នុងមួយឆ្នាំគឺនៅក្នុងខែមករា មីនា មិថុនា និងខែកញ្ញា ឬបីដងក្នុងមួយឆ្នាំ ដោយការចេញពីរលេខជាប់គ្នាមួយលេខ និងការចេញមួយលេខ ផ្សេងៗគ្នាពីរលេខ ដែលត្រូវបោះពុម្ពផ្សាយនៅរាល់ខែឧសភា ខែកញ្ញា និងខែធ្នូ ។
អ៊ីនធឺណិត : http/www.blackwellpublishers.co.uk
លេខចេញផ្សាយមុនៗ : លេខចេញផ្សាយមួយដាច់ពីគ្នាពីរភាគនាពេលបច្ចុប្បន្ន និងពេលមុននោះអាចទទួលបានពី Blackwell Publisher Journals.
លេខចេញផ្សាយមុនៗប្រហែលជាអាចទទួលបាន ពីក្រុមហ៊ុនសេវាសាមាយិកប័ត្រនៅផ្ទះលេខ 11 Main Street, Germantown, NY 12526 USA. Tel:001 518 537 4700. Fax: 001 518 537 5899.
E-mail: psc@backsets.com ។

សណ្ឋានមីក្រូ : ទស្សនាវដ្ដីអាចទទួលបានតាមការបញ្ចាំងភាពយន្តខ្នាតតូច (១៦ ឬ៣៥មីលីម៉ែត្រ) ឬ១០៥មីលីម៉ែត្រពីផ្នែកវត្ថុដែលមាន នៃទស្សនាវដ្ដី University Microfilms Inc., 300 North Zeeb Road, Ann Arbor MI (48106 USA) ។

ការផ្ញើតាមប្រៃសណីយ : តែមសាមាយិកប័ត្រត្រូវបង់នៅ Rahway, New Jersey ។ បដិគ្គាហកប្រៃសណីយស្ថាន : ផ្ញើទៅអាស័យដ្ឋានត្រឹមត្រូវ Museum International, c/o Mercury Airfreight International Ltd Inc., 305 Blair Road, Avenel, NJ 07001 (USA) (ភ្នាក់ងារប្រៃសណីយសហរដ្ឋអាមេរិក) ។

ការផ្សាយពាណិជ្ជកម្ម : សម្រាប់ពត៌មានលំអិត សូមទាក់ទង Pamela Courtney, Albert House, Monnington on Wye, Hereford, HR4 7NL (UK), Tel: 44(0) 1981 500344 ។

ការរក្សាសិទ្ធិ : រក្សាសិទ្ធិគ្រប់បែបយ៉ាង ។ ប្រសិនបើគ្មានការទាក់ទងសមរម្យ ដើម្បីគោលបំណងស្រាវជ្រាវ ឬសិក្សាឯកជន ឬវិវេចនា ឬការពិនិត្យផ្ទៀងផ្ទាត់ ដូចបានអនុញ្ញាតិនៅក្នុងច្បាប់រក្សាសិទ្ធិ រចនារូបភាព និងច្បាប់ប៉ាតង់ឆ្នាំ១៩៨៨ ទេនោះ ហាមមិនអោយថតចម្លង រក្សាទុក ឬបញ្ជូនផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះ ដោយគ្មានការអនុញ្ញាតលាយល័ក្ខអក្សរជាមុនពីអ្នកបោះពុម្ពផ្សាយ ឬការអនុញ្ញាតសមស្របទៅតាមល័ក្ខខ័ណ្ឌនៃប័ណ្ណអនុញ្ញាតរក្សាសិទ្ធិ ដែលចេញដោយអង្គការទាំងឡាយដែលបានទទួលការអនុញ្ញាតពីអ្នកបោះពុម្ពដើម្បីអភិបាលសិទ្ធិនៃការចម្លងរូបភាពក្នុងសៀវភៅឡើយ ។ អ្នកបោះពុម្ពផ្សាយអនុញ្ញាតអោយថតចម្លង សម្រាប់ការប្រើប្រាស់សម្រាប់ការអប់រំក្នុងថ្នាក់រៀនបាន អោយតែមានការបង់ថ្លៃ សមរម្យដោយផ្ទាល់ចំពោះមជ្ឈមណ្ឌលជម្រះបញ្ជីរក្សាសិទ្ធិ ដែលមានអាស័យដ្ឋាន នៅ : 222 Rosewood Drive, Danvers, MA 01923, USA (Tel: 508-750-8400) ជាកន្លែងដែលគេគួរទទួលបាននូវលិខិតបញ្ជាក់ការជម្រះបញ្ជីជាមុន ។ សម្រាប់ពត៌មានបន្ថែម សូមមើល ជជជ នៅតាមអ៊ីនធឺណិត : http//www.copyright.com/ ។
ឯកសារចម្លងនៃអត្ថបទទាំងឡាយដែលមាននៅក្នុងទស្សនាវដ្ដីនេះអាចទទួលបាន ពីវិទ្យាស្ថានពត៌មានវិទ្យាសាស្ត្រ ផ្ញើជូន : (រចនាការបោះពុម្ពផ្សាយ) 3501 Market Street, Philadelphia, PA 19104 (USA).

បានបោះពុម្ព និងចងជាសៀវភៅនៅក្នុងរាជាណាចក្ររួមអង់គ្លេសដោយក្រុមហ៊ុន Headley Brothers Ltd, Kent ។ បានបោះពុម្ពលើក្រដាសដែលគ្មានជាតិអាស៊ីដ ។

យូណេស្កូ ២០០២